ព័ត៌មានសំខាន់នៅខាងក្នុង

ទំព័រនេះត្រូវបានទុកអោយនៅទំនេរដោយចេតនា

KAISER PERMANENTE®

L.A. Care Health Plan

សៀវភៅណែនាំសមាជិក

អ្វីដែលអ្នកត្រូវដឹងអំពីអត្ថប្រយោជន៍របស់អ្នក

សំណុំបែបបទកស្តុតាងរួមនៃការធានារ៉ាប់រងនិងការបង្ហាញព័ត៌មាន (EOC/DF) ឆ្នាំ 2022

មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី 1 ខែមករាឆ្នាំ 2022
Kaiser Foundation Health Plan, Inc.
តំបន់កាលីហ្វ័រញ៉ាភាគខាងត្បូង

តារាងមាតិកា

តារាងមាតិកា ..... **i**

ភាសានិងទម្រង់ ផ្សេងៗទៀត ..... **vii**

ភាសាផ្សេងៗទៀត vii

ទម្រង់ផ្សេងៗទៀត vii

សេវាអ្នកបកប្រែ viii

សូមស្វាគមន៍មកកាន់ Kaiser Permanente! **1**

សៀវភៅណែនាំសមាជិក 1

ទំនាក់ទំនងមកយើងខ្ញុំ 2

1. ការចាប់ផ្តើមក្នុងនាមជាសមាជិក **3**

របៀបទទួលបានជំនួយ 3

ផ្នែកសេវាសមាជិក Kaiser Permanente 3

ការទទួលបានជំនួយពី L.A. Care Health Plan 4

Medi-Cal ក្នុងអំឡុងពេលផ្លាស់ប្តូរ 4

អ្នកណាខ្លះអាចត្រូវបានចាត់តាំងមកពួកយើង 4

ប័ណ្ណ ("ID") អត្តសញ្ញាណ 4

2. អំពីផែនការសុខភាពរបស់អ្នក **6**

ទិដ្ឋភាពទូទៅនៃផែនការសុខភាព 6

ពេលដែលធានារ៉ាប់រងរបស់អ្នកចាប់ផ្តើម និងបញ្ចប់ 7

ការពិចារណាពិសេសសម្រាប់ជនជាតិដើមអាមេរិកស្បែកក្រហមក្នុងការថែទាំគ្រប់គ្រង 8

របៀបដែលផែនការរបស់អ្នកដំណើរការ 8

ការផ្លាស់ប្តូរបណ្តាញអ្នកផ្តល់សេវា 9

ការផ្លាស់ប្តូរផែនការសុខភាព 10

និស្សិតមហាវិទ្យាល័យដែលផ្លាស់ទីលំនៅទៅខោនធីថ្មី ឬក្រៅពីកាលីហ្វ័រញ៉ា 10

ការទៅរៀននៅមហាវិទ្យាល័យក្រៅតំបន់គេហដ្ឋានរបស់អ្នកក្នុងកាលីហ្វ័រនីញ៉ា 11

ការទៅរៀនមហាវិទ្យាល័យនៅក្រៅរដ្ឋកាលីហ្វ័រញ៉ា 11

ការបន្តការថែទាំ 12

ការបំពេញសេវាពីអ្នកផ្តល់សេវាដែលមិននៅក្នុងផែនការ 12

សមាជិកថ្មី 12

ថ្លៃចំណាយ 15
ថ្លៃចំណាយសម្រាប់សមាជិក 15
សម្រាប់សមាជិកដែលមានការថែទាំរយៈពេលវែង
និងការចែករំលែកតម្លៃចំណាយ 16
របៀបដែលអ្នកផ្តល់សេវាត្រូវបានទូទាត់ប្រាក់ 16
ការស្នើសុំយើងអោយបង់ថ្លៃវិភ័យប័ត្រ 16

3. របៀបទទួលបានការថែទាំ 19
ការទទួលបានសេវាថែទាំសុខភាព 19
អ្នកផ្តល់សេវាថែទាំបឋម ("PCP") 21
ជម្រើសនៃវេជ្ជបណ្ឌិត និងអ្នកផ្តល់សេវាថែទាំផ្សេងៗទៀត 22
ការវាយតម្លៃសុខភាពដើម ("IHA") 23
ការថែទាំជាប្រចាំ 23
បណ្តាញអ្នកផ្តល់សេវា Medi-Cal 24
អ្នកផ្តល់សេវានៅក្នុងបណ្តាញ 25
អ្នកផ្តល់សេវាក្រៅបណ្តាញនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក 26
អ្នកផ្តល់សេវានៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក 27
វេជ្ជបណ្ឌិត 28
មន្ទីរពេទ្យ 29
អ្នកឯកទេសសុខភាពរបស់ស្ត្រី 29
សៀវភៅបញ្ជីអ្នកផ្តល់សេវា 29
ការទទួលបានតំហែទាំទាន់ពេលវេលា 30
ពេលវេលាធ្វើដំណើរ ឬចម្ងាយទៅកាន់ការថែទាំ 32
ការណាត់ជួប 32
ការធ្វើដំណើរទៅកាន់ការណាត់ជួប 33
ការលុបចោលនិងការដាក់ថ្លៃណាត់ជួបឡើងវិញ 33
ការបង់ប្រាក់ 34
ការបញ្ជូន 35
ការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) 37
មតិទីពីរ 39
ការថែទាំសម្ងាត់ 40
សេវាត្រូវបានយល់ព្រមសម្រាប់អនីតិជន 40
ការថែទាំសម្ងាត់សម្រាប់មនុស្សពេញវ័យ 41
ការជំទាស់ផ្នែកសីលធម៌ 42
ការថែទាំបន្ទាន់ 43
ការថែទាំសង្គ្រោះបន្ទាន់ 44
ការថែទាំក្រោយមានស្ថិរភាព 45
បណ្តាញទូរស័ព្ទសម្រាប់ការណាត់ជួបនិងផ្តល់ដំបូន្មាន 47

សេចក្តីណែនាំជាមុន 47
ការបរិច្ចាគសរីរាង្គនិងជាលិកា 48

4. អត្ថប្រយោជន៍និងសេវាកម្ម 49
អ្វីដែលផែនការសុខភាពរបស់អ្នករ៉ាប់រង 49
អត្ថប្រយោជន៍ Medi-Cal ដែលរ៉ាប់រងដោយ Kaiser Permanente 52
សេវាអ្នកជំងឺមិនសម្រាកពេទ្យ (ដែលអាចដើរបាន) 52
ការចាក់ថ្នាំបង្ការសម្រាប់មនុស្សពេញវ័យ 52
ការថែទាំសម្ភពនិងទារកកើតថ្មី 56
ការអប់រំពីការបំបៅដោះ 56
The Provisional Postpartum Care Extension Program
(មានប្រសិទ្ធិភាពរហូតដល់ថ្ងៃទី 1 ខែមេសា ឆ្នាំ 2022) 57
The Postpartum Care Extension Program
(មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2022) 57
សេវា តេឡេសុខភាព 58
សេវាសុខភាពផ្លូវចិត្ត 58
ការវាយតម្លៃសុខភាពផ្លូវចិត្ត 58
សេវាសង្គ្រោះបន្ទាន់ 59
សេវាជំងឺសម្រាកមន្ទីរពេទ្យនិងមិនសម្រាកមន្ទីរពេទ្យដែលចាំបាច់
ដើម្បីព្យាបាលភាពបន្ទាន់ ផ្នែកវេជ្ជសាស្ត្រ 59
ការអប់រំផ្នែកសុខភាព 60
ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់ 61
ការថែទាំជំងឺមុខនឹងស្លាប់ 61
ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ 63
សេវាអ្នកជំនាញខាងថ្នាំស្ពឹក 63
សេវាអង្គេត 64
ឱសថ បរិក្ខារផ្តត់ផ្គង់
និងថ្នាំបំប៉នមានវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេ
ទ្យដែលរ៉ាប់រងដោយ Kaiser Permanente 65
សេវានិងឧបករណ៍ ("ការព្យាបាល") ពង្រឹងនិងស្តារនីតិសម្បទា 69
សេវាការប្តូរភេទ 77
ការព្យាបាលសាកល្បង 77
សេវាមន្ទីរពិសោធន៍និងវិទ្យុសកម្ម 78
សេវាបង្ការនិងសុខុមាលភាព និងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ 79
សេវាបង្ការ 79
ការរះកាត់កែលម្អ 80
សេវាពិនិត្យមើលរិបត្តិការប្រើប្រាស់គ្រឿងញៀន 80
សេវាផ្នែកចក្ខុ 81

ការពិនិត្យភ្នែកជាប្រចាំ 81
សេវាការដឹកជញ្ជូនសម្រាប់ស្ថានភាពដែលមិនមែនសង្គ្រោះបន្ទាន់.....82
អត្ថប្រយោជន៍និងកម្មវិធីដទៃទៀតដែលរ៉ាប់រងដោយ Kaiser Permanente.....85
សេវានិងជំនួយរយៈពេលវែងមានការគ្រប់គ្រង ("MLTSS").....85
ការសម្របសម្រួលការថែទាំ 85
ការផ្តួចផ្តើមការថែទាំដែលត្រូវបានសម្របសម្រួល ("CCI").....86
ការគ្រប់គ្រងការថែទាំបានពង្រីក 86
Community Supports (“CS”) 87
ការវះកាត់ប្តូរសរីរាង្គធំៗ.....88
ការវះកាត់ប្តូរសរីរាង្គសម្រាប់កុមារក្រោមអាយុ 21 ឆ្នាំ.....88
កម្មវិធីនិងសេវា Medi-Cal ដទៃទៀតដែលមិនធានារ៉ាប់រង ដោយ
Kaiser Permanente.....88
ការថែទាំគ្រប់គ្រងផ្នែកទន្តសាស្ត្រ 89
Medi-Cal Rx.....89
សេវាសុខភាពផ្លូវចិត្តឯកទេស 90
California Children’s Services (“CCS”) 91
សេវាព្យាបាលវិបត្តិការប្រើប្រាស់គ្រឿងញៀន.....92
ការព្យាបាលដោយការឧទ្ទិស ឬសាសនា 93
សេវាវាយតម្លៃនៃទីភ្នាក់ងារការអប់រំតាមមូលដ្ឋាន ("LEA").....93
សេវា LEA ដូចបានបញ្ជាក់ក្នុងចំណងជើង 22 CCR ផ្នែក 51360.....93
សេវាមន្ទីពិសោធន៍ដែលបានផ្តល់នៅក្រោមកម្មវិធីធ្វើតេស្តអាល់ហ្វា -
ហ្វីតូប្រូតេទីនរបស់រដ្ឋ.....93
ការថែទាំសុខភាពពេលថ្ងៃសម្រាប់កុមារ.....93
សេវាគ្រប់គ្រងករណីតាមគោលដៅដូចដែលបានបញ្ជាក់ក្នុងចំណងជើង
22 CCR ផ្នែក 51185 និង 51351 93
សេវាដែលអ្នកមិនអាចទទួលបានតាមរយៈ Kaiser Permanente ឬ Medi-Cal.....94
ការពិនិត្យជំងឺ និងសេវាជាក់លាក់មួយចំនួន.....94
ទំនិញសម្រាប់ផាសុកភាព ឬភាពងាយស្រួល.....94
សេវាសំអិតសំអាងខ្លួន.....94
សម្ភារៈដែលប្រើហើយបោះចោល 95
សេវាពិសោធន៍.....95
សេវាការបន្តពូជ 95
ការព្យាបាលការជ្រុះ ឬបណ្ពុះសក់.....95
ទំនិញនិងសេវាដែលពុំមែនជាទំនិញនិងសេវាថែទាំសុខភាព 95
ការព្យាបាលដោយការគក់ច្របាច់ 96
សេវាថែទាំផ្ទាល់ខ្លួន 97
ការស្រាយចំណងស្បូន.....97
ទំនិញនិងសេវាថែទាំប្រអប់ជើងជាប្រចាំ.....97

សេវាកម្មដែលមិនត្រូវបានអនុម័តដោយរដ្ឋបាលចំណីអាហារ និងឱសថ
របស់សហព័ន្ធ។ 97
សេវាបានអនុវត្តដោយអ្នកដែលគ្មានអាជ្ញាប័ណ្ណ....98
សេវាទាក់ទងនឹងសេវាមិនមានជានារ៉ាប់រង....98
ការគ្រប់គ្រងករណីពុលជាតិសំណក្នុងកុមារភាពផ្តល់ដោយមន្ទីរសុខាភិបាល
ខោនធី....98
ការវាយតម្លៃនៃបច្ចេកវិទ្យាថ្មីនិងដែលមានស្រាប់....98

5. ការថែទាំសុខភាពកុមារនិងយុវជន 99
សេវាជំងឺកុមារ (កុមារក្រោមអាយុ 21)....99
ការពិនិត្យសុខភាព និងការថែទាំបង្ការសុខភាពកុមារ....100
ការតេស្តជាតិពុលសំណក្នុងឈាម....101
ជំនួយដើម្បីទទួលបានសេវាថែទាំសុខភាពកុមារ និងយុវជន....101
សេវាដែលអ្នកអាចទទួលបានតាមរយៈថ្លៃឈួល-សម្រាប់-សេវា ("FFS")
Medi-Cal ឬកម្មវិធីផ្សេងៗទៀត....102
ការពិនិត្យធ្មេញ....102
សេវាបញ្ជូនការអប់រំបង្ការបន្ថែម....104

6. ការរាយការណ៍និងការដោះស្រាយបញ្ហា 105
ពាក្យបណ្តឹងភ្លាមៗ....106
បណ្តឹងឧទ្ធរណ៍....108
អ្វីដែលត្រូវធ្វើប្រសិនបើអ្នកមិនយល់ស្របជាមួយសេចក្តីសម្រេចលើបណ្តឹងឧ
ទ្ធរណ៍....111
ពាក្យបណ្តឹងភ្លាមៗនិងការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យ ("IMR")
ជាមួយនាយកដ្ឋានថែទាំសុខភាពមានការគ្រប់គ្រង....112
សវនាការរដ្ឋ....113
ការក្លែងបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពាន....115
មជ្ឈត្តវិនិច្ឆ័យចងក្រាប់....116
វិសាលភាពនៃមជ្ឈត្តវិនិច្ឆ័យ....116
វិធាននៃនីតិវិធី....117
របៀបស្នើសុំមជ្ឈត្តវិនិច្ឆ័យ....117
ការបំពេញតាមការទាមទារសម្រាប់មជ្ឈត្តវិនិច្ឆ័យ....118
ថ្លៃឈួលសម្រាប់ការរៀបចំពាក្យបណ្តឹង....118
ចំនួននៃមជ្ឈត្តវិនិច្ឆ័យ....119
ថ្លៃឈួលនិងការចំណាយរបស់មជ្ឈត្តករ....119
ថ្លៃចំណាយ....119
ការផ្តល់ជូនទូទៅ....120

7. សិទ្ធិ និងទំនួលខុសត្រូវ 121
សិទ្ធិរបស់អ្នក....121

ទំនួលខុសត្រូវរបស់អ្នក 123
សេចក្តីជូនដំណឹងពីការមិនរើសអើង 123
របៀបដាក់ពាក្យបណ្តឹងសារទុក្ខជាមួយ Kaiser Permanente 124
របៀបដាក់ពាក្យបណ្តឹងសារទុក្ខទៅការិយាល័យសិទ្ធិពលរដ្ឋនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ូ *(សម្រាប់តែអ្នកទទួលផលពី Medi-Cal ប៉ុណ្ណោះ)* 125
របៀបដាក់បណ្តឹងសារទុក្ខទៅកាន់ការិយាល័យសិទ្ធិពលរដ្ឋនាយកដ្ឋានសេវាសុខភាព និងមនុស្សជាតិអាមេរិក 125
វិធីនានាដើម្បីចូលរួមក្នុងនាមជាសមាជិក 126
គណៈកម្មាធិការប្រឹក្សាសាធារណៈ L.A. Care 126
គណៈកម្មាធិការប្រឹក្សាសហគមន៍ក្នុងតំបន់ L.A. Care ("RCAC") 126
កិច្ចប្រជុំគណៈអភិបាល 127
សេចក្តីជូនដំណឹងការអនុវត្តន៍ឯកជនភាព 127
សេចក្តីជូនដំណឹងអំពីច្បាប់ 128
សេចក្តីជូនដំណឹងអំពី Medi-Cal ក្នុងនាមជាអ្នកបង់ប្រាក់ជម្រើសចុងក្រោយ ការធានារ៉ាប់រងសុខភាពដទៃទៀត និងការទទួលខុសត្រូវចំពោះការខូចខាត 128
សេចក្តីជូនដំណឹងការស្រោចស្រង់ទ្រព្យសម្បត្តិ 129
សេចក្តីជូនដំណឹងអំពីសកម្មភាព 130
សេចក្តីជូនដំណឹងអំពីកាលៈទេសៈខុសពីធម្មតា 130
សេចក្តីជូនដំណឹងអំពីការគ្រប់គ្រងនៃអត្ថប្រយោជន៍របស់អ្នក 130
សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរទៅលើសៀវភៅណែនាំសមាជិកនេះ 130
សេចក្តីជូនដំណឹងស្តីពីថ្លៃឈ្នួលនិងការចំណាយលើមេធាវីនិងអ្នកគាំពារ 131
សេចក្តីជូនដំណឹងថាសៀវភៅណែនាំសមាជិកនេះនឹងចងភ្ជាប់កាតព្វកិច្ចលើសមាជិក 131
សេចក្តីជូនដំណឹងថា L.A. Care Health Plan មិនមែនជាភ្នាក់ងាររបស់យើងទេ 131
សេចក្តីជូនដំណឹងអំពីធានារ៉ាប់រងរបស់អ្នក 131

8. លេខនិងពាក្យសំខាន់ៗដែលត្រូវដឹង 132
លេខទូរស័ព្ទសំខាន់ៗ 132
ពាក្យដែលត្រូវដឹង 132

ភាសានិងទម្រង់ផ្សេងៗទៀត

ភាសាផ្សេងៗទៀត

អ្នកអាចទទួលបានសៀវភៅសមាជិកនិងឯកសារផែនការផ្សេងទៀតដោយឥតគិតថ្លៃជាភាសាដទៃ។ យើងផ្តល់ទម្រង់បែបបទជាលាយលក្ខណ៍អក្សរ ពីអ្នកបកប្រែមានលក្ខណៈសម្បត្តិពេញលេញ។ សូមទូរស័ព្ទលេខ **1-800-464-4000** (TTY **711**)។ ការទូរស័ព្ទនេះគឺមិនគិតថ្លៃ។ អានសៀវភៅណែនាំសមាជិកនេះដើម្បីស្វែងយល់បន្ថែមអំពីសេវាជំនួយភាសា ផ្នែកថែទាំសុខភាពដូចជាសេវាបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់។

ទម្រង់ផ្សេងៗទៀត

អ្នកអាចទទួលបានព័ត៌មាននេះដោយឥតគិតថ្លៃនៅក្នុងទម្រង់ផ្សេងៗទៀតដូចជាអក្សរសម្រាប់អ្នកពិការភ្នែក ការបោះពុម្ពជាអក្សរធំទំហំ 20 ជាសម្លេង និងជាទម្រង់អេឡិចត្រូនិចដែលអាចចូលមើលបាន។ ទូរស័ព្ទមកលេខ **1-800-464-4000** (TTY **711**)។ ការទូរស័ព្ទនេះគឺមិនគិតថ្លៃ។

សេវាអ្នកបកប្រែ

យើងផ្តល់សេវាបកប្រែផ្តាល់មាត់ ពីអ្នកបកប្រែមានលក្ខណៈសម្បត្តិពេញលេញ។ អ្នកមិនចាំបាច់ប្រើសមាជិកគ្រួសារ ឬមិត្តភក្តិធ្វើជាអ្នកបកប្រែទេ។ យើងមិនចង់ប្រើប្រាស់អនីតិជនជាអ្នកបកប្រែ លើកលែងតែវាជាភាពអាសន្ន។ សេវាខាងអ្នកបកប្រែភាសា និងវប្បធម៌គឺមានជូនដោយមិនគិតថ្លៃពីអ្នក។ ជំនួយគឺមានជូន 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍។ សម្រាប់ជំនួយខាងភាសា ឬដើម្បីទទួលបានសៀវភៅណែនាំសមាជិកនេះជាភាសាផ្សេង សូមទូរស័ព្ទទៅលេខ **1-800-464-4000** (TTY **711**)។ ការហៅទូរស័ព្ទគឺឥតគិតថ្លៃ។

Language Assistance Services

English: Language assistance is available at no cost to you, 24 hours a day, 7 days a week. You can request interpreter services, materials translated into your language, or in alternative formats. You can also request auxiliary aids and devices at our facilities. Just call us at **1-800-464-4000**, 24 hours a day, 7 days a week (closed holidays). TTY users call **711**.

Arabic: خدمات الترجمة الفورية متوفرة لك مجانًا على مدار الساعة كافة أيام الأسبوع. بإمكانك طلب خدمة الترجمة الفورية أو ترجمة وثائق للغتك أو لصيغ أخرى. يمكنك أيضاً طلب مساعدات إضافية وأجهزة في مرافقنا. ما عليك سوى الاتصال بنا على الرقم **1-800-464-4000** على مدار الساعة كافة أيام الأسبوع (مغلق أيام العطلات). لمستخدمي خدمة الهاتف النصي يرجي الاتصال على الرقم (**711**).

Armenian: Ձեզ կարող է անվճար օգնություն տրամադրվել լեզվի հարցում՝ օրը 24 ժամ, շաբաթը 7 օր: Դուք կարող եք պահանջել բանավոր թարգմանչի ծառայություններ, Ձեր լեզվով թարգմանված կամ այլընտրանքային ձևաչափով պատրաստված նյութեր: Դուք նաև կարող եք խնդրել օժանդակ օգնություններ և սարքեր մեր հաստատություններում: Պարզապես զանգահարեք մեզ **1-800-464-4000** հեռախոսահամարով՝ օրը 24 ժամ, շաբաթը 7 օր (տոն օրերին փակ է): TTY-ից օգտվողները պետք է զանգահարեն **711**:

Chinese: 您每週 7 天，每天 24 小時均可獲得免費語言協助。您可以申請口譯服務、要求將資料翻譯成您所用語言或轉換為其他格式。您還可以在我們的場所內申請使用輔助工具和設備。我們每週 7 天，每天 24 小時均歡迎您打電話 **1-800-757-7585** 前來聯絡（節假日休息）。聽障及語障專線 (TTY) 使用者請撥 **711**。

Farsi: خدمات زبانی در 24 ساعت شبانروز و 7 روز هفته بدون اخذ هزینه در اختیار شما است. شما می‌توانید برای خدمات ترجمه شفاهی، ترجمه مدارک به زبان شما و یا به صورت‌های دیگر درخواست کنید. شما همچنین می توانید کمکهای جانبی و وسایل کمکی برای محل اقامت خود درخواست کنید. کلیه‌ای است در 24 ساعت شبانروز و 7 روز هفته (به استثنای روزهای تعطیل) با ما به شماره **1-800-464-4000** تماس بگیرید. کاربران شنوا (TTY) با شماره **711** تماس بگیرند.

Hindi: बिना किसी लागत के दुभाषिया सेवाएँ, दिन के 24 घंटे, सप्ताह के सातों दिन उपलब्ध हैं। आप एक दुभाषिये की सेवाओं के लिए, बिना किसी लागत के सामग्रियों को अपनी भाषा में अनुवाद करवाने के लिए, या वैकल्पिक प्रारूपों के लिए अनुरोध कर सकते हैं। आप हमारे सुविधा-स्थलों में सहायक साधनों और उपकरणों के लिए भी अनुरोध कर सकते हैं। बस केवल हमें **1-800-464-4000** पर, दिन के 24 घंटे, सप्ताह के सातों दिन (छुट्टियों वाले दिन बंद रहता है) कॉल करें। TTY उपयोगकर्ता **711** पर कॉल करें।

Hmong: Muaj kec pab txhais lus pub dawb rau koj, 24 teev ib hnub twg, 7 hnub ib lim tiam twg. Koj thov tau cov kev pab txhais lus, muab cov ntaub ntawv txhais ua koj hom lus, los yog ua lwm hom. Koj kuj thov tau lwm yam kev pab thiab khoom siv hauv peb tej tsev hauj lwm. Tsuas hu rau **1-800-464-4000**, 24 teev ib hnub twg, 7 hnub ib lim tiam twg (cov hnub caiv kaw). Cov neeg siv TTY hu **711**.

Japanese: 当院では、言語支援を無料で、年中無休、終日ご利用いただけます。通訳サービス、日本語に翻訳された資料、あるいは資料を別の書式でも依頼できます。補助サービスや当施設の機器についてもご相談いただけます。お気軽に **1-800-464-4000** までお電話ください（祭日を除き年中無休）。TTY ユーザーは **711** にお電話ください。

Khmer: ជំនួយភាសា គឺឥតគិតថ្លៃថ្លៃដល់អ្នកឡើយ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកអាចស្នើសុំសេវាអ្នកបកប្រែឯកសារដែលបានបកប្រែទៅជាភាសាខ្មែរ ឬជាទំរង់ជំនួសផ្សេងៗទៀត។ អ្នកក៏អាចស្នើសុំឧបករណ៍និងបរិក្ខារជំនួយទំនាក់ទំនងសម្រាប់អ្នកពិការនៅទីតាំងរបស់យើងផងដែរ។ គ្រាន់តែទូរស័ព្ទមកយើង តាមលេខ **1-800-464-4000** បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (បិទថ្ងៃបុណ្យ)។ អ្នកប្រើ TTY សូមហៅលេខ 711។

Korean: 요일 및 시간에 관계없이 언어지원 서비스를 무료로 이용하실 수 있습니다. 귀하는 통역 서비스,귀하의 언어로 번역된 자료 또는 대체 형식의 자료를 요청할 수 있습니다. 또한 저희 시설에서 보조기구 및 기기를 요청하실 수 있습니다. 요일 및 시간에 관계없이 **1-800-464-4000** 번으로 전화하십시오 (공휴일휴무). TTY 사용자번호 **711**.

Laotian: ການຊ່ວຍເຫຼືອດ້ານພາສາມີໃຫ້ໂດຍບໍ່ເສັງຄ່າ ແກ່ທ່ານ, ຕະຫຼອດ 24 ຊົ່ວໂມງ, 7 ວັນຕໍ່ອາທິດ. ທ່ານ ສາມາດຮ້ອງຂໍຮັບບໍລິການນາຍພາສາ, ໃຫ້ແປເອກະ ສານເປັນພາສາຂອງທ່ານ, ຫຼື ໃນຮູບແບບອື່ນ. ທ່ານສາມາດຂໍອຸປະກອນຊ່ວຍເສີມ ແລະ ອຸປະກອນ ຕ່າງໆໃນສະຖານບໍລິການຂອງພວກເຮົາໄດ້.ພຽງແຕ່ໂທ ຫາພວກເຮົາທີ່ **1-800-464-4000**, ຕະຫຼອດ 24 ຊົ່ວໂມງ, 7 ວັນຕໍ່ອາທິດ (ບິດວັນພັກຕ່າງໆ). ຜູ້ໃຊ້ສາຍ TTY ໂທ **711**.

Mien: Mbenc nzoih liouh wang-henh tengx nzie faan waac bun muangx maiv zuqc cuotv zinh nyaanh meih, yietc hnoi mbenc maaih 24 norm ziangh hoc, yietc norm liv baaiz mbenc maaih 7 hnoi. Meih se haih tov heuc tengx lorx faan waac mienh tengx faan waac bun muangx, dorh nyungc horngh jaa-sic mingh faan benx meih nyei waac, a'fai liouh ginv longc benx haaix hoc sou-guv daan yaac duqv. Meih corc haih tov longc benx wuotc ginc jaa-dorngx tengx aengx caux jaa-sic nzie bun yiem njiec zorc goux baengc zingh gorn zangc. Kungx douc waac mingh lorx taux yie mbuo yiem njiec naaiv **1-800-464-4000**, yietc hnoi mbenc maaih 24 norm ziangh hoc, yietc norm liv baaiz mbenc maaih 7 hnoi. (hnoi-gec se guon gorn zangc oc). TTY nyei mienh nor douc waac lorx **711**.

Navajo: Doo bik'é asíníłáágóó saad bee ata' hane' bee áká e'elyeed nich'į' ąą'át'é, t'áá áłahjį' jį̨į̨go dóó tł'ée'go áádóó tsosts'ijí ąą'át'é. Ata' hane' yídíikił, naaltsoos t'áá Diné bizaad bee bik'i' ashchíigo, éí doodago hane' bee didíits'íiłígíí yídíikił. Hane' bee bik'i' di'díítíiłígíí dóó bee hane' didíits'íiłígíí bína'ídíłkidgo yídíikił. Kojį́ hodiilnih **1-800-464-4000**, t'áá áłahjį', jį̨į̨go dóó tł'ée'go áádóó tsosts'ijí ąą'át'é. (Dahodílzingóne' doo nida'anish dago éí da'deelkaal). TTY chodayooł'ínígíí kojį́ dahalne' **711**.

Punjabi: ਬਿਨਾਂ ਕਿਸੀ ਲਾਗਤ ਦੇ, ਦਿਨ ਦੇ 24 ਘੰਟੇ, ਹਫਤੇ ਦੇ 7 ਦਿਨ, ਦੁਭਾਸ਼ੀਆ ਸੇਵਾਵਾਂ ਤੁਹਾਡੇ ਲਈ ਉਪਲਬਧ ਹੈ। ਤੁਸੀਂ ਇੱਕ ਦੁਭਾਸ਼ੀਏ ਦੀ ਮਦਦ ਲਈ, ਸਮੱਗਰੀਆਂ ਨੂੰ ਆਪਣੀ ਭਾਸ਼ਾ ਵਿੱਚ ਅਨੁਵਾਦ ਕਰਵਾਉਣ ਲਈ, ਜਾਂ ਕਿਸੇ ਵੱਖ ਫਾਰਮੈਟ ਵਿੱਚ ਪ੍ਰਾਪਤ ਕਰਨ ਲਈ ਬੇਨਤੀ ਕਰ ਸਕਦੇ ਹੋ। ਤੁਸੀਂ ਸਾਡੀਆਂ ਸੁਵਿਧਾਵਾਂ ਵਿੱਚ ਵੀ ਸਹਾਇਕ ਸਾਧਨਾਂ ਅਤੇ ਉਪਕਰਣਾਂ ਲਈ ਬੇਨਤੀ ਕਰ ਸਕਦੇ ਹਾਂ। ਬਸ ਸਿਰਫ਼ ਸਾਨੂੰ **1-800-464-4000** ਤੇ, ਦਿਨ ਦੇ 24 ਘੰਟੇ, ਹਫਤੇ ਦੇ 7 ਦਿਨ (ਛੁੱਟੀਆਂ ਵਾਲੇ ਦਿਨ ਬੰਦ ਰਹਿੰਦਾ ਹੈ) ਫ਼ੋਨ ਕਰੋ। TTY ਦਾ ਉਪਯੋਗ ਕਰਨ ਵਾਲੇ **711** 'ਤੇ ਫ਼ੋਨ ਕਰਨ।

Russian: Мы бесплатно обеспечиваем Вас услугами перевода 24 часа в сутки, 7 дней в неделю. Вы можете воспользоваться помощью устного переводчика, запросить перевод материалов на свой язык или запросить их в одном из альтернативных форматов. Мы также можем помочь вам с вспомогательными средствами и альтернативными форматами. Просто позвоните нам по телефону **1-800-464-4000**, который доступен 24 часа в сутки, 7 дней в неделю (кроме праздничных дней). Пользователи линии TTY могут звонить по номеру **711**.

Spanish: Tenemos disponible asistencia en su idioma sin ningún costo para usted 24 horas al día, 7 días a la semana. Puede solicitar los servicios de un intérprete, que los materiales se traduzcan a su idioma o en formatos alternativos. También puede solicitar recursos para discapacidades en nuestros centros de atención. Solo llame al **1-800-788-0616**, 24 horas al día, 7 días a la semana (excepto los días festivos). Los usuarios de TTY, deben llamar al **711**.

Tagalog: May magagamit na tulong sa wika nang wala kang babayaran, 24 na oras bawat araw, 7 araw bawat linggo. Maaari kang humingi ng mga serbisyo ng tagasalin sa wika, mga babasahin na isinalin sa iyong wika o sa mga alternatibong format. Maaari ka ring humiling ng mga karagdagang tulong at device sa aming mga pasilidad. Tawagan lamang kami sa **1-800-464-4000**, 24 na oras bawat araw, 7 araw bawat linggo (sarado sa mga pista opisyal). Ang mga gumagamit ng TTY ay maaaring tumawag sa **711**.

Thai: มีบริการช่วยเหลือด้านภาษาฟรีตลอด 24 ชั่วโมง 7 วันต่อสัปดาห์ คุณสามารถ ขอใช้บริการล่าม แปลเอกสารเป็นภาษาของคุณ หรือในรูปแบบอื่นได้ คุณสามารถขออุปกรณ์และเครื่องมือช่วยเหลือได้ที่ศูนย์บริการให้ความช่วยเหลือของเรา โดยโทรหา เราที่ **1-800-464-4000** ตลอด 24 ชั่วโมง 7 วันต่อสัปดาห์ (ยกเว้นวันหยุดราชการ) ผู้ใช้ TTY ให้โทร **711**

Ukrainian: Послуги перекладача надаються безкоштовно, цілодобово, 7 днів на тиждень. Ви можете зробити запит на послуги усного перекладача, отримання матеріалів у перекладі мовою, якою володієте, або в альтернативних форматах. Також ви можете зробити запит на отримання допоміжних засобів і пристроїв у закладах нашої мережі компаній. Просто зателефонуйте нам за номером **1-800-464-4000**. Ми працюємо цілодобово, 7 днів на тиждень (крім святкових днів). Номер для користувачів телетайпа: **711**.

Vietnamese: Dịch vụ thông dịch được cung cấp miễn phí cho quý vị 24 giờ mỗi ngày, 7 ngày trong tuần. Quý vị có thể yêu cầu dịch vụ thông dịch, tài liệu phiên dịch ra ngôn ngữ của quý vị hoặc tài liệu bằng nhiều hình thức khác. Quý vị cũng có thể yêu cầu các phương tiện trợ giúp và thiết bị bổ trợ tại các cơ sở của chúng tôi. Quý vị chỉ cần gọi cho chúng tôi tại số **1-800-464-4000**, 24 giờ mỗi ngày, 7 ngày trong tuần (trừ các ngày lễ). Người dùng TTY xin gọi **711**.

សូមស្វាគមន៍មកកាន់ Kaiser Permanente!

អរគុណអ្នកសម្រាប់ការជ្រើសរើស Kaiser Permanente ជាអ្នកផ្តល់សេវាក្នុងបណ្តាញថែទាំសុខភាពរបស់អ្នកតាមរយៈ L.A. Care Health Plan។ L.A. Care Health Plan គឺជាផែនការសុខភាពសម្រាប់អ្នកដែលមាន Medi-Cal។ L.A. Care Health Plan ធ្វើការជាមួយរដ្ឋកាលីហ្វ័រញ៉ាដើម្បីជួយអ្នកឲ្យទទួលបានការថែទាំសុខភាពដែលអ្នកត្រូវការ។ Kaiser Permanente គឺជាបណ្តាញអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកតាមរយៈ L.A. Care Health Plan។

សៀវភៅណែនាំសមាជិក

សៀវភៅណែនាំសមាជិក ប្រាប់អ្នកអំពីធានារ៉ាប់រងរបស់អ្នកនៅក្រោមផែនការសុខភាព។ សូមអានវាដោយប្រុងប្រយ័ត្ននិងពេញលេញ។ វានឹងជួយអ្នកឲ្យយល់ និងប្រើប្រាស់អត្ថប្រយោជន៍និងសេវារបស់អ្នក។ វាក៏ពន្យល់អំពីសិទ្ធិនិងទំនួលខុសត្រូវរបស់អ្នក ក្នុងនាមជាសមាជិកនៃផែនការសុខភាពផងដែរ។ ប្រសិនបើអ្នកមានតម្រូវការផ្នែកសុខភាពពិសេស សូមប្រាកដថាអ្នកអានផ្នែកទាំងអស់ដែលអនុវត្តចំពោះអ្នក។

នៅក្នុងសៀវភៅណែនាំសមាជិកនេះ Kaiser Foundation Health Plan, Inc. ជួនកាលត្រូវបានសំដៅទៅលើ ""ពួកយើង" ឬ "យើង"។" សមាជិកជួនកាលត្រូវបានសំដៅទៅលើ "អ្នក"។" លក្ខខ័ណ្ឌដែលត្រូវបានសរសេរជាអក្សរធំខ្លះមានអត្ថន័យពិសេសនៅក្នុងសៀវភៅណែនាំសមាជិកនេះ។ សូមមើលជំពូក 8 (" លេខនិងពាក្យសំខាន់ៗដែលត្រូវដឹង") សម្រាប់ពាក្យដែលអ្នកគួរដឹង។

សៀវភៅណែនាំសមាជិកនេះក៏ត្រូវបានហៅផងដែរថាជាសំណុំបែបបទភស្តុតាងរួមនៃការធានារ៉ាប់រង និងការបង្ហាញព័ត៌មាន (Combined Evidence of Coverage and Disclosure Form, "EOC/DF")។ វាគឺជាសេចក្តីសង្ខេបនៃច្បាប់និងគោលការណ៍និងផ្នែកទៅលើកិច្ចសន្យារវាង Kaiser Permanente Foundation Health Plan, Inc. និង L.A. Care Health Plan។ ការធានារ៉ាប់រងសុខភាពរបស់អ្នកត្រូវបានកំណត់ដោយកិច្ចសន្យារបស់យើងជាមួយនឹង L.A. Care Health Plan។ ប្រសិនបើអ្នកបានទទួល ឬបានទាញយកសៀវភៅសមាជិកមួយច្បាប់ដោយផ្ទាល់ពី L.A. Care Health Plan សូមបោះវាចោលហើយប្រើមួយនេះវិញ។ សៀវភៅណែនាំសមាជិកនេះនឹងផ្តល់ជូនអ្នកនូវព័ត៌មានត្រឹមត្រូវបំផុតអំពីសេវាដែលអ្នកអាចទទួលបានពីយើង។ ប្រសិនបើមានភាពខុសគ្នារវាងសៀវភៅណែនាំសមាជិកដែលអ្នកបានទទួលពី L.A. Care Health Plan ហើយនិងសៀវភៅមួយនេះ ឯកសារនេះនឹងជាអ្វីដែលយើងនឹងប្រើដើម្បីជួយអ្នក។ ទូរស័ព្ទទៅ **1-888-839-9909** (TTY **711**) ដើម្បីស្នើសុំមួយច្បាប់នៃកិច្ចសន្យារវាង L.A. Care

សូមស្វាគមន៍មកកាន់ Kaiser Permanente!

Health Plan និង នាយកដ្ឋានសេវាកម្មថែទាំសុខភាព (Department of Health Care Services, DHCS)។

អ្នកអាចស្នើសុំសៀវភៅណែនាំសមាជិកនេះមួយច្បាប់ទៀតដោយឥតគិតថ្លៃដោយការទូរស័ព្ទទៅ **1-800-464-4000** (TTY **711**) ឬ ចូលទៅគេហទំព័ររបស់យើងនៅ kp.org/medi-cal/documents (ជាភាសាអង់គ្លេស) ដើម្បីមើលសៀវភៅណែនាំសមាជិក។ អ្នកក៏អាចស្នើសុំផងដែរ ដោយមិនគិតថ្លៃ នូវសំណៅដំណើរការនិងគោលការណ៍ផ្នែករដ្ឋបាលនិងពិនិត្យព្យាបាលដែលមិនមែនកម្មសិទ្ធរបស់យើង ឬរបៀបចូលមើលព័ត៌មាននេះនៅលើគេហទំព័ររបស់យើង។ ដើម្បីស្វែងយល់បន្ថែមទៀតអំពីដំណើរការការព្យាបាលនិងរដ្ឋបាលរបស់យើង សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

ទំនាក់ទំនងមកយើងខ្ញុំ

យើងនៅទីនេះរង់ចាំផ្តល់ជំនួយ។ ប្រសិនបើអ្នកមានសំណួរ ទូរស័ព្ទមក **1-800-464-4000** (TTY **711**)។ ពួកយើងនៅទីនេះ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងថ្ងៃឈប់សម្រាកដែលបិទ)។ ការទូរស័ព្ទនេះគឺមិនគិតថ្លៃ។

អ្នកក៏អាចចូលទៅអនឡាញនៅពេលណាក៏បានតាម **kp.org** (ជាភាសាអង់គ្លេស) ឬទៅកាន់នាយកដ្ឋានសេវាសមាជិកនៅឯទីតាំងផែនការមួយ (យោងលើបញ្ជីរាយឈ្មោះនិងព័ត៌មានស្តាប់ននៅលើគេហទំព័ររបស់យើងនៅt kp.org/facilities [ជាភាសាអង់គ្លេស] សម្រាប់អាសយដ្ឋាន)។ សម្រាប់ព័ត៌មានបន្ថែមស្តីពីអ្នកផ្តល់សេវានិងទីតាំងរបស់យើង សូមទូរស័ព្ទមកមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង kp.org/facilities (ជាភាសាអង់គ្លេស)។

សូមអរគុណ
Kaiser Foundation Health Plan, Inc.

1. ការចាប់ផ្តើមក្នុងនាមជាសមាជិក

របៀបទទួលបានជំនួយ

We want you to be happy with your health care. If you have any questions or concerns about your care, we want to hear from you!

ផ្នែកសេវាសមាជិក Kaiser Permanente

សេវាសមាជិក Kaiser Permanente នៅទីនេះដើម្បីជួយអ្នក។ យើងអាច៖

- ឆ្លើយសំណួរអំពីសេវាដែលត្រូវបានធានារ៉ាប់រងដោយយើង
- ជួយអ្នកជ្រើសរើស ឬផ្លាស់ប្តូរអ្នកផ្តល់សេវាថែទាំសុខភាពបឋម (Primary Care Provider, "PCP")
- ប្រាប់អ្នកពីទីកន្លែងដើម្បីទទួលការថែទាំដែលអ្នកត្រូវការ
- ជួយអ្នកអោយទទួលបានសេវាអ្នកបកប្រែប្រសិនបើអ្នកមិនចេះនិយាយភាសាអង់គ្លេស
- ជួយអ្នកអោយទទួលបានព័ត៌មានជាភាសានិងទម្រង់ផ្សេងៗទៀត

ប្រសិនបើអ្នកត្រូវការជំនួយ សូមទូរស័ព្ទមកមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងដូចខាងក្រោម៖

- ភាសាអង់គ្លេស **1-800-464-4000**
  (និងច្រើនជាង 150 ភាសាដែលប្រើសេវាអ្នកបកប្រែ)
- ភាសាអេស្ប៉ាញ **1-800-788-0616**
- ក្រាមភាសាចិន **1-800-757-7585**
- TTY **711**

ពួកយើងនៅទីនេះ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងថ្ងៃឈប់សម្រាកដែលបិទ)។ ការហៅទូរស័ព្ទគឺឥតគិតថ្លៃ។ យើងត្រូវប្រាកដថាអ្នករង់ចាំតិចជាង 10 នាទីនៅពេលទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង។ អ្នកក៏អាចចូលទៅអនឡាញបានគ្រប់ពេលផងដែរនៅ **kp.org** (ជាភាសាអង់គ្លេស)។

ការទទួលបានជំនួយពី L.A. Care Health Plan

ប្រសិនបើអ្នកមានសំណួរអំពី L.A. Care Health Plan សូមទូរស័ព្ទទៅពួកគេលេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

Medi-Cal ក្នុងអំឡុងពេលផ្លាស់ប្តូរ

Medi-Cal ក្នុងអំឡុងពេលផ្លាស់ប្តូរ ក៏ត្រូវបានហៅផងដែរថា "Medi-Cal សម្រាប់អ្នកធ្វើការ។" អ្នកប្រហែលជាអាចទទួលបាន Medi-Cal ក្នុងអំឡុងពេលផ្លាស់ប្តូរ ប្រសិនបើអ្នកឈប់ទទួលបាន Medi-Cal ដោយសារ៖

- អ្នកចាប់ផ្តើមរកប្រាក់បានច្រើនជាងមុន
- គ្រួសាររបស់អ្នកចាប់ផ្តើមទទួលបានប្រាក់ឧបត្ថម្ភដល់កូន ឬប្តីប្រពន្ធច្រើនជាងមុន

អ្នកអាចសួរសំណួរអំពីលក្ខណៈសម្បត្តិក្នុងការទទួលបាន Medi-Cal ក្នុងអំឡុងពេលផ្លាស់ប្តូរនៅការិយាល័យសេវាសុខភាពនិងមនុស្សជាតិក្នុងខោនធីរបស់អ្នកនៅ **http://www.dhcs.ca.gov/services/medi-cal/Pages/CountyOffices.aspx** (ជាភាសាអង់គ្លេស) អ្នកក៏អាចទូរស័ព្ទមក Health Care Options លេខ **1-800-430-4263** (TTY **1-800-430-7077** ឬ **711**)។

អ្នកណាខ្លះអាចត្រូវបានចាត់តាំងមកពួកយើង

យើងមិនចុះឈ្មោះសមាជិកដោយផ្ទាល់ទេ។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបស្នើសុំការចាត់តាំងជាមួយយើង សូមទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**)។

ប័ណ្ណ ("ID") អត្តសញ្ញាណ

ក្នុងនាមជាសមាជិករបស់ Health Plan អ្នកនឹងទទួលបានប័ណ្ណអត្តសញ្ញាណ Kaiser Permanente មួយ។ អ្នកក៏ត្រូវតែមានប័ណ្ណអត្តសញ្ញាណអត្ថប្រយោជន៍ (Benefits Identification Card, "BIC") Medi-Cal ដែលរដ្ឋកាលីហ្វ័រញ៉ាបានផ្តើរឲ្យអ្នកផងដែរ។ អ្នកត្រូវតែបង្ហាញប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នក ប័ណ្ណអត្តសញ្ញាណ L.A. Care Health Plan របស់អ្នក Medi-Cal BIC របស់អ្នក និងអត្តសញ្ញាណប័ណ្ណមានរូបថតរបស់អ្នកនៅពេលអ្នកទទួលយកសេវាថែទាំសុខភាព ឬវេជ្ជបញ្ជា។ អ្នកគួរតែយកប័ណ្ណសុខភាពទាំងអស់

មកជាមួយអ្នកគ្រប់ពេលវេលា។ នេះជាគំរូប័ណ្ណអត្តសញ្ញាណ BIC និង Kaiser Permanente ដើម្បីបង្ហាញអ្នកថាតើរបស់អ្នកនឹងមើលទៅដូចម្តេច៖





ប្រសិនបើអ្នកមិនទទួលបានប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នកក្នុងរយៈពេលពីរបីសប្តាហ៍នៃការចាត់តាំងរបស់អ្នកទៅពួកយើងទេ ឬប្រសិនបើប័ណ្ណរបស់អ្នកខូច បាត់ ឬត្រូវចោរលួច សូមទូរស័ព្ទទៅសេវាសមាជិកភ្លាមៗ។ យើងនឹងផ្ញើរប័ណ្ណថ្មីមួយជូនអ្នកដោយឥតគិតថ្លៃ។ សូមទូរស័ព្ទលេខ **1-800-464-4000** (TTY **711**)។

2. អំពីផែនការសុខភាពរបស់អ្នក

ទិដ្ឋភាពទូទៅនៃផែនការសុខភាព

L.A. Care Health Plan គឺជាផែនការសុខភាពសម្រាប់អ្នកដែលមាន Medi-Cal នៅក្នុងខោនធី Los Angeles ។ L.A. Care Health Plan ធ្វើការជាមួយរដ្ឋកាលីហ្វញ៉ាដើម្បីជួយអ្នកឲ្យទទួលបានការថែទាំសុខភាពដែលអ្នកត្រូវការ។

L.A. Care Health Plan គឺជាផែនការថែទាំគ្រប់គ្រងដោយ Medi-Cal របស់អ្នក ហើយ Kaiser Permanente គឺជាអ្នកផ្តល់សេវាក្នុងបណ្តាញថែទាំសុខភាពរបស់អ្នកតាមរយៈ L.A. Care Health Plan។ នៅពេលអ្នកជ្រើសរើសយក Kaiser Permanente អ្នកកំពុងជ្រើសរើសទទួលការថែទាំរបស់អ្នកតាមរយៈកម្មវិធីថែទាំវេជ្ជសាស្ត្ររបស់យើង។ អ្នកត្រូវតែទទួលយកសេវាភាគច្រើនពីអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente។

អ្នកអាចនិយាយជាមួយអ្នកតំណាងផ្នែកសេវាសមាជិករបស់ Kaiser Permanente ដើម្បីស្វែងយល់បន្ថែមអំពី Kaiser Permanente និងរបៀបធ្វើឲ្យវាដំណើរការសម្រាប់អ្នក។ សូមទូរស័ព្ទលេខ **1-800-464-4000** (TTY **711**)។

Kaiser Permanente ផ្តល់នូវសេវាថែទាំសុខភាពដោយផ្ទាល់ដល់សមាជិកតាមរយៈកម្មវិធីថែទាំសុខភាពចម្រុះ។ ផែនការសុខភាព មន្ទីរពេទ្យរបស់ផែនការ និង Southern California Permanente Medical Group ("ក្រុមវេជ្ជសាស្ត្រ") ធ្វើការរួមគ្នាដើម្បីផ្តល់ជូនសមាជិករបស់យើងនូវការថែទាំប្រកបដោយគុណភាព។ កម្មវិធីថែទាំវេជ្ជសាស្ត្ររបស់យើងផ្តល់ឲ្យអ្នកនូវការទទួលបានសេវាមានធានារ៉ាប់រងដែលអ្នកប្រហែលជាត្រូវការ ដូចជាការថែទាំជាប្រចាំ ការថែទាំនៅមន្ទីរពេទ្យ សេវាមន្ទីរពិសោធន៍ ការថែទាំសង្ត្រោះបន្ទាន់ ការថែទាំបន្ទាន់ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលបានពិពណ៍នានៅក្នុងសៀវភៅណែនាំសមាជិកនេះ។ លើសពីនេះទៅទៀតកម្មវិធីអប់រំសុខភាពរបស់យើងផ្តល់ជូនអ្នកនូវវិធីល្អៗដើម្បីការពារ និងលើកកម្ពស់សុខភាពរបស់អ្នក។

ប្រសិនបើអ្នកមានសំណួរអំពី L.A. Care Health Plan អ្នកអាចទូរស័ព្ទទៅពួកគេលេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ពេលដែលជានាវ៉ាប់រងរបស់អ្នកចាប់ផ្តើម និងបញ្ចប់

នៅពេលដែលអ្នកត្រូវបានចាត់តាំងឲ្យយើងតាមរយៈ L.A. Care Health Plan យើងនឹងផ្ញើរអត្តសញ្ញាណប័ណ្ណសមាជិក Kaiser Permanente ក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីកាលបរិច្ឆេទការចាត់តាំង ។ សូមបង្ហាញប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នក ប័ណ្ណសម្គាល់អត្ថប្រយោជន៍ ប័ណ្ណសម្គាល់អត្ថប្រយោជន៍ (Benefits Identification Card, BIC) របស់អ្នក និងប័ណ្ណអត្តសញ្ញាណ L.A. Care Health Plan របស់អ្នកនៅពេលអ្នកទទួលយកសេវាថែទាំសុខភាព ឬវេជ្ជបញ្ជា។

ការជានាវ៉ាប់រង Medi-Cal របស់អ្នកនឹងត្រូវធ្វើជាថ្មីរៀងរាល់ឆ្នាំ។ ប្រសិនបើការិយាល័យខោនធីក្នុងតំបន់របស់អ្នកមិនអាចបន្តការវ៉ាប់រង Medi-Cal របស់អ្នកដោយប្រើប្រភពអេឡិចត្រូនិចបានទេ ខោនធីនឹងផ្ញើទម្រង់បែបបទបន្ត Medi-Cal ទៅអ្នក។ បំពេញទម្រង់បែបបទនេះហើយប្រគល់វាទៅទីភ្នាក់ងារសេវាមនុស្សជាតិក្នុងខោនធីរបស់អ្នក។ អ្នកអាចប្រគល់ព័ត៌មានរបស់អ្នកតាមអ៊ីនធឺណិត ដោយផ្ទាល់ ឬតាមទូរស័ព្ទ ឬមធ្យោបាយអេឡិចត្រូនិចផ្សេងទៀត ប្រសិនបើមាននៅក្នុងខោនធីរបស់អ្នក។

អ្នកអាចស្នើសុំនៅពេលណាក៏បានដើម្បីបញ្ចប់ការចាត់តាំងរបស់អ្នកទៅ Kaiser Permanente ហើយជ្រើសរើសអ្នកផ្តល់សេវាផ្សេងទៀតដែលធ្វើការជាមួយ L.A. Care Health Plan។ សំរាប់ជំនួយជ្រើសរើសអ្នកផ្តល់សេវាថ្មី សូមទូរស័ព្ទទៅ L.A. Care Health Plan តាមលេខ **1-888-839-9909** (TTY **711**) ឬចូលទៅកាន់ **www.lacare.org** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចស្នើសុំបញ្ចប់ Medi-Cal របស់អ្នកបានដែរ។

យើងអាចស្នើសុំ L.A. Care Health Plan ដើម្បីចាត់តាំងអ្នកទៅអ្នកផ្តល់សេវាផ្សេងនៅក្នុងបណ្តាញ ប្រសិនបើករណីណាមួយដូចខាងក្រោមកើតឡើង៖

- អាកប្បកិរិយារបស់អ្នកគម្រាមកំហែងដល់សុវត្ថិភាពរបស់បុគ្គលិក Kaiser Permanente ឬជនណាម្នាក់ ឬទ្រព្យសម្បត្តិនៅទីកន្លែងរបស់ផែនការ
- អ្នកប្រព្រឹត្តសកម្មភាពលួចពីអ្នកផ្តល់សេវាក្នុងបណ្តាញ ឬទីកន្លែងរបស់ផែនការ
- អ្នកប្រព្រឹត្តការកេងបន្លំដោយចេតនា ដូចជាការបង្ហាញវេជ្ជបញ្ជាដែលមិនមានសុពលភាព ឬការអនុញ្ញាតឲ្យនរណាម្នាក់ប្រើប្រាស់ប័ណ្ណសម្គាល់ខ្លួន Medi-Cal ឬ Kaiser Permanente របស់អ្នក

ប្រសិនបើ L.A. Care Health Plan ចាត់តាំងអ្នកជាថ្មីអោយទៅបណ្តាញអ្នកផ្តល់សេវាផ្សេងទៀត ពួកគេនឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ។

សិទ្ធិទទួល Medi-Cal របស់អ្នកជាមួយ L.A. Care Health Plan អាចបញ្ចប់ប្រសិនបើកត្តាណាមួយដូចខាងក្រោម គឺពិតៈ

- អ្នកផ្លាស់ទីលំនៅទៅក្រៅតំបន់សេវា L.A. Care Health Plan
- អ្នកជាប់នៅក្នុងមន្ទីរឃុំឃាំង ឬពន្ធនាគារ

- អ្នកលែងមាន Medi-Cal ទៀត
- អ្នកក្លាយជាមានសិទ្ធិទទួលបានកម្មវិធីលើកលែង ដែលតម្រូវឲ្យអ្នកចុះឈ្មោះក្នុងបង់ថ្លៃឈ្នួលពេលប្រើសេវា (Fee-For-Service, FFS) Medi-Cal

ប្រសិនបើសិទ្ធិរបស់អ្នកជាមួយ L.A. Care Health Plan និងការចាត់តាំងរបស់អ្នកទៅ Kaiser Permanente បញ្ចប់ អ្នកនៅតែអាចមានសិទ្ធិទទួលបានការធានារ៉ាប់រង Medi-Cal បង់ថ្លៃឈ្នួល-នៅពេល-ប្រើសេវា ("FFS")។ ប្រសិនបើអ្នកមិនជាក់ច្បាស់ថាអ្នកនៅតែត្រូវបានធានារ៉ាប់រងដោយយើងសម្រាប់ Medi-Cal របស់អ្នក សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

ការពិចារណាពិសេសសម្រាប់ជនជាតិដើមអាមេរិកស្បែកក្រហមក្នុងការថែទាំគ្រប់គ្រង

ជនជាតិដើមអាមេរិកស្បែកក្រហមមានសិទ្ធិមិនចុះឈ្មោះក្នុងផែនការថែទាំគ្រប់គ្រង Medi-Cal ឬពួកគេអាចចាកចេញពីផែនការថែទាំគ្រប់គ្រង Medi-Cal ហើយត្រឡប់ទៅ Medi-Cal FFS វិញបានគ្រប់ពេលនិងដោយមូលហេតុណាក៏ដោយ។

ប្រសិនបើអ្នកជាជនជាតិដើមអាមេរិក អ្នកមានសិទ្ធិទទួលសេវាអ្នកផ្តល់ថែទាំសុខភាពនៅតាមទីតាំងសេវាសុខភាពឥណ្ឌាស្បែកក្រហម (Indian Health Care Provider, "IHCP")។ អ្នកក៏អាចនៅជាមួយ ឬដកឈ្មោះចេញពី L.A. Care Health Plan ខណៈពេលកំពុងទទួលបានសេវាថែទាំសុខភាពពីទីតាំងទាំងនេះផងដែរ។ សម្រាប់ព័ត៌មានបន្ថែមចំពោះការចុះឈ្មោះនិងការដកឈ្មោះចេញ សូមទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**)។

របៀបដែលផែនការរបស់អ្នកដំណើរការ

L.A. Care Health Plan គឺជាផែនការថែទាំសុខភាពមានការគ្រប់គ្រងដែលចុះកិច្ចសន្យាជាមួយនាយកដ្ឋានសេវាសុខភាពរដ្ឋកាលីហ្វ័រញ៉ា (Department of Health Care Services, "DHCS") សម្រាប់ Medi-Cal។ Kaiser Permanente គឺជាអ្នកផ្តល់សេវាក្នុងបណ្តាញថែទាំសុខភាពរបស់អ្នកតាមរយៈ L.A. Care Health Plan។

Kaiser Permanente ផ្តល់នូវសេវាថែទាំសុខភាពដោយផ្ទាល់ដល់សមាជិកតាមរយៈកម្មវិធីថែទាំសុខភាពចម្រុះ។ កម្មវិធីថែទាំវេជ្ជសាស្ត្ររបស់យើងផ្តល់ឲ្យអ្នកនូវការទទួលបានសេវាមានធានារ៉ាប់រងភាគច្រើន ដែលអ្នកប្រហែលជាត្រូវការ ដូចជាការថែទាំជាប្រចាំ ការថែទាំនៅមន្ទីរពេទ្យ សេវាមន្ទីរពិសោធន៍ និងការថែទាំសង្គ្រោះបន្ទាន់ ការថែទាំបន្ទាន់ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំសមាជិកនេះ។ លើសពីនេះទៅទៀត កម្មវិធីអប់រំសុខភាពរបស់យើងផ្តល់ជូនអ្នកនូវវិធីល្អៗដើម្បីការពារ និងលើកកម្ពស់សុខភាពរបស់អ្នក។

គោលការណ៍អត្ថប្រយោជន៍និងដំណើរការសម្រាប់វិធីទទួលបានសេវាមានជានាវ៉ាប់រងអាចមានភាពខុសគ្នា ក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរបណ្តាញអ្នកផ្តល់សេវា សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ខណៈដែលអ្នកជាសមាជិក Medi-Cal នៃ Kaiser Permanente អ្នកអាចមានសិទ្ធិដើម្បីទទួលសេវាបន្ថែមដែលត្រូវបានផ្តល់ឲ្យតាមរយៈ FFS Medi-Cal។ ទាំងនេះរួមមានឱសថតាមវេជ្ជបញ្ជាសម្រាប់អ្នកជំងឺមិនស្នាក់ក្នុងមន្ទីរពេទ្យ ឱសថគ្មានវេជ្ជបញ្ជា ការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រមួយចំនួន និងឱសថបំប៉នដែលមានតាមរយៈកម្មវិធី Medi-Cal Rx។ សេវានានាដែលអ្នកអាចទទួលបានពី Medi-Cal FFS ត្រូវបានពិពណ៌នានៅក្នុងជំពូកទី 4 ("អត្ថប្រយោជន៍និងសេវា")។

ដើម្បីស្វែងយល់បន្ថែមទៀត សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ អ្នកក៏អាចស្វែងរកព័ត៌មានអំពីសេវាសមាជិកតាមអនឡាញផងដែរនៅ kp.org (ជាភាសាអង់គ្លេស)។

ដើម្បីស្វែងយល់អំពី L.A. Care Health Plan សូមហៅទូរស័ព្ទទៅពួកគេលេខ **1-888-839-9909** (TTY **711**)។ អ្នកក៏អាចស្វែងរកព័ត៌មានអំពីសេវាសមាជិកតាមអនឡាញផងដែរនៅ **www.lacare.org** (ជាភាសាអង់គ្លេស)។

ការផ្លាស់ប្តូរបណ្តាញអ្នកផ្តល់សេវា

អ្នកអាចចាកចេញពី Kaiser Permanente ហើយផ្លាស់ប្តូរទៅបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan ផ្សេងទៀតនៅពេលណាក៏បាន។ សូមទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃបុណ្យ។ ប្រាប់ពួកគេថាអ្នកចង់ផ្លាស់ប្តូរបណ្តាញអ្នកផ្តល់សេវា។ ការផ្លាស់ប្តូរនេះនឹងមិនកើតឡើងភ្លាមៗនោះទេ។ L.A. Care Health Plan នឹងឲ្យអ្នកដឹងនៅពេលដែលការចាត់តាំងអ្នកផ្តល់សេវាថ្មីរបស់អ្នកចាប់ផ្តើម។ ទំរាំដល់ពេលនោះ អ្នកត្រូវតែទទួលយកសេវាពី Kaiser Permanente។

គោលការណ៍អត្ថប្រយោជន៍និងដំណើរការសម្រាប់វិធីទទួលបានសេវាមានជានាវ៉ាប់រងអាចមានភាពខុសគ្នា ក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរបណ្តាញអ្នកផ្តល់សេវា សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ប្រសិនបើអ្នកចង់ចាកចេញពី Kaiser Permanente បានឆាប់ជាងនេះ អ្នកអាចស្នើសុំ L.A. Care Health Plan រកការចាត់តាំងឡើងវិញបន្ទាន់ (លឿន)។ ប្រសិនបើហេតុផលសម្រាប់ការស្នើសុំរបស់អ្នកបានបំពេញតាមច្បាប់សម្រាប់ការចាត់តាំងឡើងវិញបន្ទាន់ អ្នកនឹងទទួលបានលិខិតមួយដើម្បីប្រាប់អ្នកថាអ្នកត្រូវបានចាត់តាំងឡើងវិញហើយ។

ការផ្លាស់ប្តូរផែនការសុខភាព

អ្នកអាចចាកចេញពី L.A. Care Health Plan ហើយចូលរួមក្នុងផែនការថែទាំសុខភាពគ្រប់គ្រងផ្សេងទៀត នៅក្នុងខោនធីដែលអ្នករស់នៅនៅពេលណាក៏បាន។ ទូរស័ព្ទមក Health Care Options លេខ **1-800-430-4263** (TTY **1-800-430-7077**) ដើម្បីជ្រើសរើសផែនការថ្មី។ អ្នកអាចទូរស័ព្ទពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រម៉ោង 8 ព្រឹករហូតដល់ម៉ោង 6 ល្ងាច ឬចូលទៅ **https://www.healthcareoptions.dhcs.ca.gov/** (ជាភាសាអង់គ្លេស)។

វាត្រូវការពេលរហូតដល់ 30 ថ្ងៃដើម្បីដំណើរការសំណើសុំរបស់អ្នកក្នុងការចាកចេញពី L.A. Care Health Plan ហើយចុះឈ្មោះនៅក្នុងផែនការថែទាំគ្រប់គ្រងផ្សេងទៀតនៅក្នុងខោនធីរបស់អ្នក ប្រសិនបើមិនមានបញ្ហាអ្វីជាមួយសំណើនោះទេ។ ទំរាំដល់ពេលនោះ អ្នកត្រូវតែទទួលយកសេវាពីពួកយើង។ ដើម្បីដឹងពីស្ថានភាពនៃសំណើរបស់អ្នក សូមទូរស័ព្ទទៅ Health Care Options លេខ **1-800-430-4263** (TTY **1-800-430-7077**)។

ប្រសិនបើអ្នកចង់ចេញពី L.A. Care Health Plan ឱ្យបានឆាប់ អ្នកអាចស្នើសុំ Health Care Options រកការដកឈ្មោះចេញបន្ទាន់ (លឿន) ។ ប្រសិនបើហេតុផលសម្រាប់ការស្នើសុំរបស់អ្នកបំពេញតាមច្បាប់សម្រាប់ការដកឈ្មោះចេញបន្ទាន់ អ្នកនឹងទទួលបានលិខិតមួយដើម្បីប្រាប់អ្នកថាអ្នកត្រូវបានដកឈ្មោះចេញហើយ។

សមាជិកដែលអាចស្នើសុំការដកឈ្មោះចេញបន្ទាន់រួមមាន ប៉ុន្តែមិនត្រូវបានកំណត់តែចំពោះ៖

- កុមារដែលទទួលបានសេវាក្រោម Foster Care ឬក៏ Adoption Assistance Programs។
- សមាជិកដែលមានតម្រូវការការថែទាំសុខភាពពិសេស
- សមាជិកដែលបានចុះឈ្មោះរួចនៅក្នុង Medicare, Medi-Cal មួយទៀត ឬផែនការថែទាំគ្រប់គ្រងលក្ខណៈពាណិជ្ជកម្ម

អ្នកអាចស្នើសុំចាកចេញពី L.A. Care Health Plan ដោយផ្ទាល់នៅឯការិយាល័យសេវាមនុស្សជាតិនិងសុខភាពប្រចាំខោនធីរបស់អ្នក។ ស្វែងរកការិយាល័យក្នុងមូលដ្ឋានរបស់អ្នកនៅ **https://www.dhcs.ca.gov/services/medi-cal/Pages/CountyOffices.aspx** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចទូរស័ព្ទមក Health Care Options លេខ **1-800-430-4263** (TTY **1-800-430-7077**)។

និស្សិតមហាវិទ្យាល័យដែលផ្លាស់ទីលំនៅទៅខោនធីថ្មី ឬក្រៅពីកាលីហ្វ័រញ៉ា

ប្រសិនបើអ្នកផ្លាស់ទៅខោនធីថ្មីនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាដែលនៅក្រៅពីតំបន់លំនៅដ្ឋានរបស់អ្នក ដើម្បីចូលរៀនមហាវិទ្យាល័យ យើងនឹងរ៉ាប់រងតែលើការថែទាំសង្គ្រោះបន្ទាន់និងការថែទាំបន្ទាន់

នៅក្នុងខោនធីថ្មីរបស់អ្នកប៉ុណ្ណោះ។ ការថែទាំសង្គ្រោះបន្ទាន់និងការថែទាំបន្ទាន់អាចរកបានសម្រាប់អ្នកចុះឈ្មោះ Medi-Cal ទាំងអស់នៅទូទាំងរដ្ឋដោយមិនគិតពីខោនធីនៃលំនៅដ្ឋាន។ ការថែទាំជាប្រចាំនិងការថែទាំបង្ការត្រូវបានរ៉ាប់រងតែនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នកប៉ុណ្ណោះ។

ការទៅរៀននៅមហាវិទ្យាល័យក្រៅតំបន់គេហដ្ឋានរបស់អ្នកក្នុងកាលីហ្វូនីញ៉ា

ប្រសិនបើអ្នកបានចុះឈ្មោះក្នុងកម្មវិធី Medi-Cal ហើយនឹងចូលរៀនមហាវិទ្យាល័យនៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នកក្នុងរដ្ឋកាលីហ្វូនីយ៉ា អ្នកមិនចាំបាច់ដាក់ពាក្យសុំ Medi-Cal នៅក្នុងខោនធីនោះទេ។ នៅពេលអ្នកផ្លាស់ទីលំនៅជាបណ្តោះអាសន្នឆ្ងាយពីផ្ទះដើម្បីទៅរៀនមហាវិទ្យាល័យនៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក មានជំរើសពីរដែលអាចរកបានសម្រាប់អ្នក។

អ្នកអាចធ្វើវិធីណាមួយដូចខាងក្រោម៖

- ជូនដំណឹងដល់ការិយាល័យប្រចាំខោនធីនៃលំនៅដ្ឋានរបស់អ្នក ថាអ្នកកំពុងផ្លាស់ទីលំនៅជាបណ្តោះអាសន្ន ដើម្បីចូលរៀនមហាវិទ្យាល័យហើយផ្តល់អាស័យដ្ឋានរបស់អ្នកដែលនៅក្នុងខោនធីថ្មី។ ខោនធីនឹងធ្វើបច្ចុប្បន្នភាពកំណត់ហេតុករណីនេះដោយប្រើអាសយដ្ឋាន និងលេខកូដខោនធីថ្មីរបស់អ្នក នៅក្នុងទិន្នន័យរបស់រដ្ឋ។ ប្រើជំរើសនេះប្រសិនបើអ្នកចង់ទទួលបានការថែទាំជាប្រចាំ រួមមានការថែទាំបង្ការនៅក្នុងខោនធីថ្មីរបស់អ្នក។ អ្នកអាចត្រូវផ្លាស់ប្តូរផែនការថែទាំគ្រប់គ្រង Medi-Cal របស់អ្នក។ សំរាប់សំណួរបន្ថែមនិងដើម្បីទប់ស្កាត់ការពន្យារពេល ក្នុងការចុះឈ្មោះចូលក្នុងផែនការសុខភាពថ្មី អ្នកគួរតែទំនាក់ទំនងទៅ Health Care Options លេខ **1-800-430-4263** (TTY **1-800-430-7077**) សម្រាប់ជំនួយក្នុងការចុះឈ្មោះ។

ឬក៏

- ជ្រើសរើសមិនផ្លាស់ប្តូរផែនការថែទាំគ្រប់គ្រងរបស់អ្នកនៅពេលដែលអ្នកផ្លាស់ទៅបណ្តោះអាសន្នដើម្បីចូលរៀនមហាវិទ្យាល័យនៅក្នុងខោនធីផ្សេង។ អ្នកអាចប្រើប្រាស់ការថែទាំសង្គ្រោះបន្ទាន់ ឬការថែទាំបន្ទាន់នៅក្នុងខោនធីថ្មីតែប៉ុណ្ណោះ។ សម្រាប់ការថែទាំសុខភាពជាប្រចាំ រួមទាំងការថែទាំបង្ការ អ្នកនឹងត្រូវប្រើអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente នៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក។ ដើម្បីស្វែងយល់បន្ថែមទៀត ចូលទៅជំពូកទី 3 ("របៀបទទួលបានការថែទាំ") សម្រាប់ព័ត៌មានអំពីការថែទាំសង្គ្រោះបន្ទាន់និងការថែទាំបន្ទាន់។

ការទៅរៀនមហាវិទ្យាល័យនៅក្រៅរដ្ឋកាលីហ្វ័រញ៉ា

ប្រសិនបើអ្នកចាកចេញពីរដ្ឋកាលីហ្វ័រញ៉ាជាបណ្តោះអាសន្នដើម្បីចូលរៀនមហាវិទ្យាល័យ ក្នុងរដ្ឋមួយផ្សេងទៀតហើយអ្នកចង់រក្សាការជានាវ៉ាប់រង Medi-Cal របស់អ្នកសូមទំនាក់ទំនង បុគ្គលិកផ្នែកសិទ្ធិទទួលបាននៅឯការិយាល័យខោនធីនៃលំនៅដ្ឋានរបស់អ្នក។ ដរាបណាអ្នកមានសិទ្ធិទទួលបាន, Medi-Cal នឹងរ៉ាប់រងលើការថែទាំសង្គ្រោះបន្ទាន់និងការថែទាំបន្ទាន់នៅក្នុងរដ្ឋមួយផ្សេងទៀត។ Medi-Cal ក៏នឹងរ៉ាប់រងលើការថែទាំអាសន្នដែលតម្រូវឱ្យមានការចូលសម្រាកមន្ទីរពេទ្យនៅកាណាដា និងម៉ិកស៊ិកូផងដែរ ប្រសិនបើសេវានេះត្រូវបានយល់ព្រមហើយវេជ្ជបណ្ឌិតនិងមន្ទីរពេទ្យបំពេញតាមលក្ខខណ្ឌច្បាប់ Medi-Cal ។ ប្រសិនបើអ្នកចង់ទទួលបានការថែទាំជា

ប្រចាំ រួមជាមួយការថែទាំបង្ការនៅរដ្ឋមួយផ្សេងទៀត អ្នកនឹងត្រូវដាក់ពាក្យសុំកម្មវិធី Medicaid នៅក្នុងរដ្ឋនោះ។ ប្រសិនបើអ្នកចុះឈ្មោះប្រើ Medicaid នៅរដ្ឋមួយផ្សេងទៀតអ្នកនឹងលែងមានសិទ្ធិទទួល Medi-Cal នៅរដ្ឋកាលីហ្វ័រញ៉ា ហើយយើងនឹងមិនបង់ថ្លៃថែទាំសុខភាពរបស់អ្នកទេ។ Medi-Cal Rx មិនរ៉ាប់រងឱសថវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យដែលនៅក្រៅរដ្ឋកាលីហ្វ័រញ៉ាឡើយ លើកលែងតែវេជ្ជបញ្ជាដែលត្រូវបានផ្តល់ឱ្យអ្នកជាផ្នែកនៃការថែទាំសង្គ្រោះបន្ទាន់ ឬការថែទាំបន្ទាន់ដែលត្រូវបានរ៉ាប់រង។

ការបន្តការថែទាំ

ការបំពេញសេវាពីអ្នកផ្តល់សេវាដែលមិននៅក្នុងផែនការ

សមាជិកថ្មី

ប្រសិនបើអ្នកជាសមាជិកថ្មីហើយបាននិងកំពុងទទួលការថែទាំពីអ្នកផ្តល់សេវា ដែលមិននៅក្នុងបណ្តាញ Kaiser Permanente អ្នកប្រហែលជាអាចបន្តជួបនឹងពួកគេរហូតដល់ 12 ខែ ឬលើសពីនេះតាមស្ថានភាពជាក់ស្តែង។ ប្រសិនបើស្ថានភាពសុខភាពរបស់អ្នកស្ថិតក្រោមករណីមួយ ដែលបានរាយខាងក្រោមក្រោមចំណងជើងថា "សិទ្ធិទទួលបាន" អ្នកអាចស្នើសុំបន្តការថែទាំជាមួយអ្នកផ្តល់សេវានោះ។

សមាជិករួចជាស្រេច

ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកឈប់ធ្វើការជាមួយ Kaiser Permanente អ្នកប្រហែលជាអាចនៅបន្តទទួលបានសេវាពីអ្នកផ្តល់សេវានោះ។ នេះគឺជាទម្រង់មួយទៀតនៃការបន្តការថែទាំ។

ប្រសិនបើអ្នកត្រូវបានចាត់តាំងទៅក្នុងក្រុមអ្នកផ្តល់សេវា ដែលកិច្ចសន្យារបស់ពួកគេជាមួយយើងបញ្ចប់ យើងនឹងផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកយ៉ាងហោចណាស់ 60 ថ្ងៃមុនការបញ្ចប់ (ឬឲ្យបានឆាប់តាមលទ្ធភាពសមរម្យ)។ យើងក៏នឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរផងដែរយ៉ាងហោចណាស់ 60 ថ្ងៃមុនពេល ដែលយើងបញ្ចប់កិច្ចសន្យាជាមួយមន្ទីរពេទ្យដែលមានចម្ងាយ 15 ម៉ៃល៍ពីកន្លែងដែលអ្នករស់នៅ។ អ្នកប្រហែលជាអាចបន្តទៅជួបអ្នកផ្តល់សេវានៅក្នុងក្រុមអ្នកផ្តល់សេវានោះ ឬនៅមន្ទីរពេទ្យនោះរហូតដល់ 12 ខែ ឬយូរជាងនេះក្នុងស្ថានភាពជាក់លាក់។ ប្រសិនបើស្ថានភាពសុខភាពរបស់អ្នកធ្លាក់ក្រោមករណីមួយក្នុងចំណោមករណីខាងក្រោមក្រោមចំណងជើង "សិទ្ធិទទួលបាន" អ្នកអាចស្នើសុំឲ្យបន្តការថែទាំជាមួយក្រុមអ្នកផ្តល់សេវា ឬមន្ទីរពេទ្យនោះ។

សិទ្ធិទទួលបាន

ផ្នែកនេះពិពណ៌នាស្ថានភាពវេជ្ជសាស្ត្រ ដែលអ្នកអាចស្នើសុំការបន្តនៃការថែទាំ។ មានលក្ខណៈវិនិច្ឆ័យបន្ថែមដែលត្រូវតែបំពេញ ដើម្បីឲ្យពួកយើងយល់ព្រមលើសំណើរបស់អ្នក។ លក្ខណៈវិនិច្ឆ័យបន្ថែមទាំងនោះត្រូវបានរាយបញ្ជីនៅពេលក្រោយនៅក្នុងផ្នែកនេះ។ ប្រសិនបើយើងយល់ព្រមលើសំណើរបស់អ្នកសម្រាប់ការបំពេញសេវាកម្មដែលមានការរ៉ាប់រង យើងនឹងគ្របដណ្តប់លើសេវាកម្មដែលមានរាយខាងក្រោម។ សម្រាប់សមាជិកថ្មី សេវាដែលបានយល់ព្រមត្រូវបានរ៉ាប់រង

ហូតដល់ 12 ខែចាប់ពីថ្ងៃចុះឈ្មោះរបស់អ្នក លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះខាងក្រោម។

- **ស្ថានភាពធ្ងន់ធ្ងរ។** សេវាកម្មត្រូវបានរ៉ាប់រងរហូតដល់ស្ថានភាពធ្ងន់ធ្ងរបញ្ចប់
- **ស្ថានភាពរ៉ាំរ៉ៃធ្ងន់ធ្ងរ។** សេវាកម្មត្រូវបានគ្របដណ្តប់រហូតដល់មុន (1) 12 ខែចាប់ពីថ្ងៃដែលកិច្ចសន្យារបស់អ្នកផ្តល់សេវាបានចប់; ឬ (2) នៅថ្ងៃទីមួយបន្ទាប់ពីដំណើរការព្យាបាលបានបញ្ចប់ នៅពេលដែលវាមានសុវត្ថិភាពក្នុងការផ្ទេរការថែទាំរបស់អ្នកទៅឲ្យអ្នកផ្តល់សេវាក្នុងបណ្តាញដែលបានកំណត់ដោយ Kaiser Permanente បន្ទាប់ពីបានពិគ្រោះជាមួយសមាជិកនិងអ្នកផ្តល់សេវាក្រៅបណ្តាញ និងស្របទៅតាមការអនុវត្តវិជ្ជាជីវៈល្អ។ ស្ថានភាពរ៉ាំរ៉ៃធ្ងន់ធ្ងរគឺជាជម្ងឺឬស្ថានភាពសុខភាពដទៃទៀតដែលធ្ងន់ធ្ងរ ប្រសិនបើមួយក្នុងចំនោមចំណុចខាងក្រោមនេះជាការពិតអំពីស្ថានភាពនោះ៖
  - វានៅតែបន្តដោយគ្មានវិធីព្យាបាលពេញលេញ
  - វាកាន់តែដុនដាបខ្លាំងក្នុងចេរវេលាយូរអង្វែង
  - វាតម្រូវឲ្យមានការព្យាបាលបន្តដើម្បីថែទាំស្ថានភាពជម្ងឺ ឬទប់ស្កាត់ស្ថានភាពមិនឲ្យយ៉ាប់យឺនទៅ
- **ការថែទាំមាតា។** សេវាកម្មត្រូវបានរ៉ាប់រង ខណៈពេលអ្នកមានផ្ទៃពោះ និងភ្លាមៗក្រោយពីអ្នកសម្រាលកូន។
- **សេវាកម្មសម្រាប់ស្ត្រីដែលមានស្ថានភាពសុខភាពផ្លូវចិត្ត** ខណៈពេលមានផ្ទៃពោះ ឬភ្លាមៗក្រោយពេលសម្រាល។ សេវាកម្មដែលមានការរ៉ាប់រងរហូតដល់ 12 ខែចាប់ពីពេលការធ្វើរោគវិនិច្ឆ័យសុខភាពផ្លូវចិត្ត ឬពីចុងបញ្ចប់នៃការមានផ្ទៃពោះមួយណាក៏ដោយដែលក្រោយគេ
- **ជម្ងឺមុខនឹងស្លាប់** សេវាកម្មត្រូវបានរ៉ាប់រងសេវាទាំងនេះសម្រាប់កំឡុងរយៈពេលនៃជំងឺ។ ជម្ងឺមុខនឹងស្លាប់ គឺជាជម្ងឺដែលមិនអាចព្យាបាល ឬត្រឡប់ថយក្រោយបាន និងប្រហែលជាបណ្តាលឲ្យស្លាប់នៅក្នុងរយៈពេលមួយឆ្នាំ ឬតិចជាងនេះ
- **ការថែទាំសម្រាប់កុមារអាយុក្រោម 3 ឆ្នាំ។** អាចរ៉ាប់រងសេវាទាំងនេះរហូតដល់មុន (1) 12 ខែចាប់ពីកាលបរិច្ឆេទដែលកិច្ចសន្យារបស់អ្នកផ្តល់សេវាបានបញ្ចប់ ឬ (2) ខួបកំណើតលើកទីបីរបស់កុមារ
- **ការរះកាត់ ឬដំណើរការព្យាបាលផ្សេងទៀតដែលជាផ្នែកនៃការព្យាបាល។**
  - ប្រសិនបើអ្នកជាសមាជិកថ្មី ការរះកាត់ឬដំណើរការព្យាបាលត្រូវតែបានផ្តល់អនុសាសន៍ និងចងក្រងដោយអ្នកផ្តល់សេវាឲ្យកើតមានឡើងក្នុងរយៈពេល 180 ថ្ងៃ គិតពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃធានារ៉ាប់រងរបស់អ្នក
  - ប្រសិនបើកិច្ចសន្យារបស់អ្នកផ្តល់សេវារបស់អ្នកជាមួយ Kaiser Permanente បញ្ចប់ ការរះកាត់ឬដំណើរការព្យាបាលត្រូវតែណែនាំនិងចងក្រងឯកសារដោយអ្នកផ្តល់សេវា ឲ្យកើតឡើងក្នុងរយៈពេល 180 ថ្ងៃនៃថ្ងៃបញ្ចប់នៃកិច្ចសន្យារវាង Kaiser Permanente និងអ្នកផ្តល់សេវា

- **អ្នកកំពុងទទួលការថែទាំរយៈពេលវែង** ក្រោមសេវានិងជំនួយរយៈពេលវែងមានការគ្រប់គ្រង (Managed Long-term Services and Supports, "MLTSS")

ដើម្បីមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការបំពេញការជានាវ៉ាប់រងសេវាកម្ម សេចក្តីតម្រូវទាំងអស់ខាងក្រោមត្រូវតែបំពេញបាន៖

- ការជានាវ៉ាប់រង Medi-Cal របស់អ្នកមានប្រសិទ្ធិភាពនៅកាលបរិច្ឆេទដែលអ្នកទទួលសេវា
- សម្រាប់សមាជិកថ្មី ការជានាវ៉ាប់រងរបស់ផែនការមុនរបស់អ្នកទៅលើសេវាកម្មរបស់អ្នកផ្តល់សេវា បានបញ្ចប់ ឬនឹងបញ្ចប់នៅពេលដែលការជានាវ៉ាប់រងរបស់អ្នកជាមួយយើងក្លាយជាមានប្រសិទ្ធិភាព
- អ្នកកំពុងទទួលសេវានៅក្នុងករណីមួយដែលបានរាយដូចខាងលើពីអ្នកផ្តល់សេវាមិននៅក្នុងផែនការ នៅកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការជានាវ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកជាសមាជិកថ្មី ឬពីអ្នកផ្តល់សេវាផែនការដែលបានបញ្ឈប់នៅកាលបរិច្ឆេទបញ្ចប់របស់អ្នកផ្តល់សេវានោះ
- សំរាប់សមាជិកថ្មី នៅពេលដែលអ្នកចុះឈ្មោះក្នុងផែនការសុខភាព អ្នកមិនបានមានជំរើសក្នុងការបន្តផែនការ សុខភាពពីមុនរបស់អ្នករឺជ្រើសរើសយកគំរោងមួយផ្សេងទៀត (រួមទាំងជំរើសក្រៅបណ្តាញ) ដែលនឹងជានាវ៉ាប់រងលើសេវារបស់អ្នកផ្តល់សេវាដែលមិននៅក្នុងផែនការបច្ចុប្បន្នរបស់អ្នក
- សម្រាប់សមាជិកថ្មី អ្នកត្រូវតែមានទំនាក់ទំនងរួចហើយ ជាមួយអ្នកផ្តល់សេវាដែលអ្នកកំពុងស្នើសុំ បន្តទៅជួបទៀត។
  - ♦ សម្រាប់សេវាព្យាបាលសុខភាពអាកប្បកិរិយាសម្រាប់ក្មេងអាយុក្រោម 21 ឆ្នាំ ទំនាក់ទំនងដែលមានស្រាប់មានន័យថាអ្នកត្រូវបានជួបពិនិត្យដោយអ្នកផ្តល់សេវា ក្នុងរយៈពេលប្រាំមួយខែមុនការចុះឈ្មោះរបស់អ្នកនៅក្នុងផែនការថែទាំគ្រប់គ្រងដោយ Medi-Cal
- សម្រាប់សេវាផ្សេងទៀតទាំងអស់ ទំនាក់ទំនងដែលមានស្រាប់មានន័យថាអ្នកត្រូវបានជួបពិនិត្យដោយអ្នកផ្តល់សេវាក្នុងរយៈពេល 12 ខែចុងក្រោយសម្រាប់ការជួបមិនមែនសង្គ្រោះបន្ទាន់។
- អ្នកផ្តល់សេវានេះព្រមព្រៀងទៅនឹងលក្ខខ័ណ្ឌកិច្ចសន្យាស្តង់ដារបស់យើង
- សេវាទាំងនោះមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងជាសេវាដែលត្រូវបានរ៉ាប់រងក្រោម សៀវភៅណែនាំសមាជិកនេះប្រសិនបើអ្នកបានទទួលពួកវាពីអ្នកផ្តល់សេវាក្នុងបណ្តាញ
- អ្នកស្នើសុំការបំពេញសេវាកម្មក្នុងរយៈពេល 30 ថ្ងៃ (ឬតាប់បំផុតតាមលទ្ធភាពសមរម្យ) ពីកាលបរិច្ឆេទនៃការជានាវ៉ាប់រងរបស់អ្នកប្រសិនបើអ្នកជាសមាជិកថ្មី ឬពីកាលបរិច្ឆេទបញ្ចប់នៃ អ្នកផ្តល់សេវារបស់ផែនការ
- Kaiser Permanente មិនមានកង្វល់ទាក់ទងនឹងគុណភាពនៃការថែទាំដែលបានទុកជាឯកសារ ជាមួយអ្នកផ្តល់សេវាដែលមិននៅក្នុងផែនការ

Kaiser Permanente **មិន** គ្របដណ្តប់ការបំពេញសេវាកម្មត្រូវបានរ៉ាប់រងពីអ្នកផ្តល់សេវាដែលមិននៅក្នុងផែនការឡើយប្រសិនបើកត្តាខាងក្រោមគឺពិត៖

- សេវាទាំងនោះមិនត្រូវបានរ៉ាប់រងដោយការថែទាំគ្រប់គ្រង Medi-cal
- អ្នកផ្តល់សេវារបស់អ្នកនឹងមិនធ្វើការជាមួយ Kaiser Permanente។ អ្នកនឹងចាំបាច់ត្រូវស្វែងរកអ្នកផ្តល់សេវាថ្មី
- យើងមិនត្រូវបានតម្រូវឲ្យផ្តល់នូវការបន្តនៃការថែទាំសម្រាប់សេវាកម្មដែលមិនត្រូវបានរ៉ាប់រង ដោយ Medi-Cal, ឧបករណ៍វេជ្ជសាស្ត្រប្រើប្រាស់បានយូរ ការដឹកជញ្ជូនសេវាជំនួយបន្ថែមផ្សេងទៀត និងអ្នកផ្តល់សេវាលើសេវាកម្មដកចេញឡើយ។

ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពីបទប្បញ្ញត្តិនេះ ឬដើម្បីស្នើសុំសេវា ឬសំណៅចម្លងនៃគោលការណ៍ "ការបំពេញសេវាកម្មដែលត្រូវបានរ៉ាប់រង" របស់យើង សូមទូរស័ព្ទមកមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។ មជ្ឈមណ្ឌលទំនាក់ទំនងសមាជិករបស់យើង ក៏អាចប្រាប់អ្នកថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានសេវាពីអ្នកផ្តល់សេវាក្រៅបណ្តាញដែរឬទេ។

ថ្លៃចំណាយ

ថ្លៃចំណាយសម្រាប់សមាជិក

L.A. Care Health Plan បម្រើជូនអ្នកដែលមានលក្ខណៈសម្បត្តិទទួលបាន Medi-Cal។ សមាជិក L.A. Care Health Plan **មិន**ចាំបាច់បង់ថ្លៃសម្រាប់សេវាត្រូវបានរ៉ាប់រងដែលទទួលបានពីអ្នកផ្តល់សេវាក្នុងបណ្តាញឡើយ។ សម្រាប់បញ្ជីសេវាដែលត្រូវបានរ៉ាប់រង សូមមើលជំពូកទី 4 ("អត្ថប្រយោជន៍និងសេវាកម្ម")។

ប្រសិនបើអ្នកទទួលយកសេវាពីអ្នកផ្តល់សេវាក្រៅបណ្តាញ សេវាទាំងនោះប្រហែលនឹង មិនត្រូវបានរ៉ាប់រងទេប្រសិនបើអ្នកមិនបានទទួលការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ។ ក្នុងករណីដែលសេវាមិនត្រូវបានរ៉ាប់រង អ្នកអាចចេញលុយពីហោប៉ៅសម្រាប់សេវានោះ។

អ្នកអាចទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញសម្រាបការថែទាំសម្ងាត់ ដោយមិនចាំបាច់មានការអនុញ្ញាតជាមុន។ សម្រាប់ព័ត៌មានថាតើអ្វីដែលជាការថែទាំសម្ងាត់ សូមចូលទៅកាន់ចំណងជើង "ការថែទាំសម្ងាត់" ក្នុងជំពូកទី 3 ("របៀបទទួលបានការថែទាំ")។

អ្នកមិនត្រូវការការអនុញ្ញាតជាមុនសម្រាប់ការថែទាំសង្គ្រោះបន្ទាន់ទេ សូម្បីនៅពេលអ្នកទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញក៏ដោយ។ ប្រសិនបើអ្នកកំពុងនៅក្រៅសហរដ្ឋអាមេរិក ក្រៅពីប្រទេសកាណាដា ឬម៉ិកស៊ិកូ ហើយត្រូវការការថែទាំសង្គ្រោះបន្ទាន់នោះ Kaiser Permanente នឹង **មិន** រ៉ាប់រងលើការថែទាំរបស់អ្នកឡើយ។

នៅពេលអ្នកស្ថិតនៅក្នុងសហរដ្ឋអាមេរិក យើងរ៉ាប់រងសេវាថែទាំសង្គ្រោះបន្ទាន់។ ប្រសិនបើនៅក្នុងតំបន់លំនៅដ្ឋាន អ្នកត្រូវតែទទួលការអនុញ្ញាតជាមុនដើម្បីទទួលបានការថែទាំបន្ទាន់ពីអ្នកផ្តល់សេវាក្រៅបណ្តាញ ដែលនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក។ អ្នកមិនត្រូវការការយល់ព្រមជាមុន សម្រាប់ការថែទាំបន្ទាន់ទេ ប្រសិនបើអ្នករស់នៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក។ ប្រសិនបើអ្នកកំពុងនៅក្រៅសហរដ្ឋអាមេរិក សេវាថែទាំបន្ទាន់ **មិន** ត្រូវបានរ៉ាប់រងទេ ហើយអ្នកនឹងត្រូវចំណាយសម្រាប់ការថែទាំរបស់អ្នក។ តំបន់លំនៅដ្ឋានរបស់អ្នកគឺជាតំបន់រដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូងរបស់ Kaiser Permanente។

សម្រាប់សមាជិកដែលមានការថែទាំរយៈពេលវែង និងការចែករំលែកតម្លៃចំណាយ

អ្នកប្រហែលជាត្រូវបង់មួយចំណែកនៃការចំណាយរៀងរាល់ខែ សម្រាប់សេវាថែទាំរយៈពេលវែងរបស់អ្នក។ ចំនួនទឹកប្រាក់នៃចំណែកចំណាយរបស់អ្នកអាស្រ័យលើប្រាក់ចំណូលនិងធនធានរបស់អ្នក។ រៀងរាល់ខែអ្នកនឹងបង់វិក័យប័ត្រវេជ្ជសាស្ត្រផ្ទាល់ខ្លួន រួមជាមួយតែមិនកំណត់តែចំពោះវិក័យប័ត្រសេវាកម្មជំនួយរយៈពេលវែងមានការគ្រប់គ្រង ("MLTSS") រហូតដល់ចំនួនទឹកប្រាក់ដែលអ្នកបានបង់នោះស្មើនឹងចំណែកចំណាយរបស់អ្នក។ ក្រោយពីនោះ ការថែទាំរយៈពេលវែងរបស់អ្នកនឹងត្រូវបានរ៉ាប់រងដោយ L.A. Care Health Plan សម្រាប់ខែនោះ។ សម្រាប់ព័ត៌មានបន្ថែមអំពីចំណែកនៃចំណាយ សូមទូរស័ព្ទទៅ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

របៀបដែលអ្នកផ្តល់សេវាត្រូវបានទូទាត់ប្រាក់

Kaiser Permanente ទូទាត់ប្រាក់ឲ្យអ្នកផ្តល់សេវាតាមវិធីទាំងនេះ៖

- ការបង់ថ្លៃឈ្នួលជាប្រចាំ
  - ♦ យើងបង់ថ្លៃឈ្នួលដល់អ្នកផ្តល់សេវាមួយចំនួនក្នុងចំនួនទឹកប្រាក់កំណត់មួយជារៀងរាល់ខែ សម្រាប់សមាជិកម្នាក់ៗ។ នេះត្រូវបានគេហៅថាការបង់ថ្លៃឈ្នួលជាប្រចាំ។ យើងធ្វើការជាមួយអ្នកផ្តល់សេវាដើម្បីសំរេចលើចំនួនទឹកប្រាក់ដែលត្រូវបង់
- ការទូទាត់ FFS
  - ♦ អ្នកផ្តល់សេវាខ្លះផ្តល់ការថែទាំដល់សមាជិក Medi-Cal ហើយបន្ទាប់មកផ្ញើវិក័យប័ត្រអោយយើងសំរាប់សេវាដែលពួកគេបានផ្តល់។ នេះត្រូវបានគេហៅថាការទូទាត់ FFS។ យើងធ្វើការជាមួយអ្នកផ្តល់សេវាដើម្បីសំរេចថាត្រូវបង់ថ្លៃប៉ុន្មានសម្រាប់សេវានីមួយៗ

ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែលយើងទូទាត់ប្រាក់អោយអ្នកផ្តល់សេវា សូមចូលទៅគេហទំព័ររបស់យើងនៅ **kp.org** (ជាភាសាអង់គ្លេស) ឬទូរស័ព្ទលេខ **1-800-464-4000** (TTY **711**)។

ការស្នើសុំយើងអោយបង់ថ្លៃវិក័យប័ត្រ

សេវាកម្មត្រូវបានរ៉ាប់រង គឺជាសេវាកម្មដែលយើងទទួលខុសត្រូវចេញថ្លៃឲ្យ។ ប្រសិនបើអ្នកទទួលបានវិក័យប័ត្រសំរាប់សេវាដែលត្រូវបានរ៉ាប់រង សូមកុំបង់វិក័យប័ត្រនោះ។ ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងភ្លាមៗតាមលេខ **1-800-464-4000** (TTY **711**)។

ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក KP លេខ **1-800-464-4000** (TTY **711**)។ ការទូរស័ព្ទនេះគឺមិនគិតថ្លៃ។ ពួកយើងនៅទីនេះ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងថ្ងៃឈប់សម្រាកដែលបិទ)។ ចូលទៅអនឡាញនៅ **kp.org** (ជាភាសាអង់គ្លេស)

ប្រសិនបើអ្នកទទួលបានវិក័យបត្រពីឱសថស្ថានសម្រាប់ឱសថវេជ្ជបញ្ជា ក្រៀងផ្គត់ផ្គង់ ឬថ្នាំបំប៉ន សូមទូរស័ព្ទទៅផ្នែកសេវាអតិថិជន Medi-Cal Rx តាមលេខ **1-800-977-2273** 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **711** ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច។ អ្នកក៏អាចចូលទៅកាន់គេហទំព័រ Medi-Cal Rx សម្រាប់ព័ត៌មាននៅ **https://medi-calrx.dhcs.ca.gov/home/** (ជាភាសាអង់គ្លេស)។

ប្រសិនបើអ្នកបង់ថ្លៃសេវាដែលអ្នកគិតថាយើងគួរតែរាប់រង អ្នកអាចដាក់ពាក្យទាមទារសំណង។ ប្រើទម្រង់បែបបទទាមទារសំណងហើយប្រាប់យើងជាលាយលក្ខណ៍អក្សរថា ហេតុអ្វីបានជាអ្នកត្រូវបង់។ ទូរស័ព្ទទៅលេខ **1-800-464-4000** (TTY **711**) ដើម្បីស្នើសុំបែបបទទាមទារសំណង។ យើងនឹងត្រួតពិនិត្យការតវ៉ារបស់អ្នកដើម្បីមើលថាតើអ្នកអាចទទួលបានប្រាក់មកវិញឬទេ។

ដើម្បីដាក់ពាក្យទាមទារការទូទាត់ប្រាក់ឬដើម្បីទទួលបានប្រាក់មកវិញ នេះគឺជាអ្វីដែលអ្នកត្រូវធ្វើ៖

- យ៉ាងឆាប់រហ័សតាមដែលអ្នកអាចធ្វើបាន សូមផ្ញើរទម្រង់បែបបទទាមទារសំណងដែលត្រូវបានបំពេញរួចមកយើង។ អ្នកអាចទទួលបានទម្រង់បែបបទទាមទារសំណងតាមអនឡាញក្នុងវិធីដូចខាងក្រោម៖
  - នៅលើគេហទំព័ររបស់យើងតាម **kp.org** (ជាភាសាអង់គ្លេស)
  - ដោយផ្ទាល់ពីការិយាល័យសេវាសមាជិកនៅទីតាំងផែនការណាមួយ និងពីអ្នកផ្តល់សេវារបស់ផែនការ។ អ្នកអាចស្វែងរកទីតាំងនានារបស់ស្ថាប័ននៅលើគេហទំព័ររបស់យើងនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)
  - ដោយការទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** ឬ (TTY **711**)

យើងនឹងរីករាយក្នុងការជួយអ្នក ប្រសិនបើអ្នកត្រូវការជំនួយបំពេញសំណុំបែបបទទាមទារសំណងរបស់យើង។

ប្រសិនបើអ្នកបានបង់ប្រាក់សម្រាប់សេវា អ្នកត្រូវរួមបញ្ចូលវិក័យប័ត្រ និងបង្កាន់ដៃទាំងអស់ពីអ្នកផ្តល់សេវាក្រៅបណ្តាញជាមួយនឹងបែបបទទាមទារសំណងរបស់អ្នក។ ប្រសិនបើអ្នកចង់ឲ្យយើងបង់ប្រាក់ទៅអ្នកផ្តល់សេវាក្រៅបណ្តាញសម្រាប់សេវា អ្នកត្រូវរួមបញ្ចូលវិក័យប័ត្រ និងបង្កាន់ដៃទាំងអស់ពីអ្នកផ្តល់សេវាក្រៅបណ្តាញជាមួយនឹងបែបបទទាមទារសំណងរបស់អ្នក។ ប្រសិនបើនៅពេលក្រោយអ្នកទទួលបានវិក័យប័ត្រ ពីអ្នកផ្តល់សេវាក្រៅបណ្តាញ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-400** (TTY **711**) សម្រាប់ជំនួយ។

អ្នកត្រូវតែផ្ញើទម្រង់បែបបទទាមទារសំណងដែលបានបំពេញរួចមកពួកយើង ឲ្យបានឆាប់តាមដែលអ្នកអាច បន្ទាប់ពីទទួលបានការថែទាំ។

ទម្រង់បែបបទទាមទារសំណងដែលបានបំពេញរួច ព្រមទាំងវិក័យប័ត្រ ឬបង្កាន់ដៃ ត្រូវតែផ្ញើតាមប្រៃសណីយ៍ទៅកាន់៖

Kaiser Permanente
Claims Administration - SCAL
P.O. Box 7004
Downey, CA 90242-7004

3. របៀបទទួលបានការថែទាំ

ការទទួលបានសេវាថែទាំសុខភាព

សូមអានពត៌មានខាងក្រោមនេះ ដូច្នេះអ្នកនឹងដឹងថាពីអ្នកណា ឬក្រុមអ្វីនៃអ្នកផ្តល់សេវាដែលការថែទាំសុខភាពអាចត្រូវបានទទួល។

ព័ត៌មានអំពីការជានាវ៉ាប់រងនៅក្នុងសៀវភៅណែនាំសមាជិកនេះអនុវត្តនៅពេលដែល អ្នកទទួលបានសេវាថែទាំសុខភាពនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក។ តំបន់លំនៅដ្ឋានរបស់អ្នកគឺជាតំបន់ Kaiser Permanente នៅកន្លែងដែលអ្នករស់នៅ។ តំបន់លំនៅដ្ឋានរបស់អ្នកគឺជារដ្ឋកាលីហ្វ័រនីញ៉ាភាគខាងត្បូង ហើយត្រូវបានកំណត់ទុក នៅលើក្របនៃសៀវភៅណែនាំសមាជិកនេះ ហើយនិងនៅប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នក។ ប្រសិនបើអ្នកទៅតំបន់ Kaiser Permanente មួយផ្សេងទៀត អ្នកត្រូវបានវ៉ាប់រងតែសម្រាប់ការថែទាំជាបន្ទាន់ ឬការថែទាំសង្គ្រោះប៉ុណ្ណោះ លើកលែងតែយើងបានអនុញ្ញាតជាមុនលើសេវាកម្មនោះសម្រាប់អ្នកជាមុន។ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបស្វែងរកអ្នកផ្តល់សេវាថែទាំក្នុងបណ្តាញ ក្នុងតំបន់គេហដ្ឋាន សូមចូលទៅបញ្ជីឈ្មោះអ្នកផ្តល់សេវាថែទាំ **kp.org/facilities** (ជាភាសាអង់គ្លេស) ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

អ្នកអាចចាប់ផ្តើមទទួលសេវាថែទាំសុខភាពនៅកាលបរិច្ឆេទ ដែលមានប្រសិទ្ធិភាពនៃការចាត់តាំងរបស់អ្នកមកកាន់យើង។ នេះគឺជាសេចក្តីសង្ខេបនៃច្បាប់និងគោលការណ៍និងផ្អែកទៅលើកិច្ចសន្យារវាង Kaiser Permanente Foundation Health Plan, Inc. និង L.A. Care Health Plan។

សូមដាក់ប័ណ្ណអត្តសញ្ញាណ Kaiser Permanente ប័ណ្ណអត្តសញ្ញាណ L.A. Care Health Plan និងប័ណ្ណ Medi-Cal ប័ណ្ណសម្គាល់អត្ថប្រយោជន៍ (Benefits Identification Card, BIC) និងប័ណ្ណធានាវ៉ាប់រងសុខភាពឯទៀតតាមខ្លួនរបស់អ្នកជានិច្ច។ មិនត្រូវអនុញ្ញាតឲ្យអ្នកណាម្នាក់ប្រើប័ណ្ណអត្តសញ្ញាណ ឬ BIC របស់អ្នកឡើយ។

យើងផ្តល់សេវាដល់សមាជិកតាមរយៈអ្នកផ្តល់សេវាក្នុងបណ្តាញរបស់យើង។ ពួកគេធ្វើការជាមួយគ្នាដើម្បីផ្តល់ដល់អ្នកនូវការថែទាំប្រកបដោយគុណភាព។ នៅពេលអ្នកជ្រើសយក Kaiser Permanente ទុកជាអ្នកផ្តល់សេវាក្នុងបណ្តាញរបស់អ្នក អ្នកកំពុងតែជ្រើសយកការថែទាំរបស់អ្នកតាមរយៈកម្មវិធីថែទាំខាងវេជ្ជសាស្ត្ររបស់យើង។ ដើម្បីស្វែងរកទីតាំងអ្នកផ្តល់សេវា

បណ្ដាញរបស់យើង សូមចូលទៅគេហទំព័ររបស់យើងនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងភ្លាមៗ តាមលេខ **1-800-464-4000** (TTY **711**)។

សមាជិកថ្មីត្រូវតែជ្រើសរើសអ្នកផ្តល់សេវាថែទាំចម្បង (primary care provider, "PCP") ដែលស្ថិតនៅក្នុងអ្នកផ្តល់សេវាក្នុងបណ្ដាញរបស់យើង និងនៅក្នុងតំបន់សេវា L.A. Care Health Plan។ អ្នកត្រូវតែជ្រើសរើសរក PCP ក្នុងអំឡុង 30 ថ្ងៃចាប់ពីពេលដែលអ្នកត្រូវបានចាត់តាំងមកកាន់យើង។ ប្រសិនបើអ្នកមិនជ្រើសរើស PCP យើងនឹងជ្រើសរើសមួយសម្រាប់អ្នក។ អ្នកអាចជ្រើសរើស PCP ដូចគ្នាឬ PCP ខុសៗគ្នាសម្រាប់សមាជិកគ្រួសារទាំងអស់ ដែលត្រូវបានចាត់តាំងទៅ Kaiser Permanente។

ប្រសិនបើអ្នកមានវេជ្ជបណ្ឌិតដែលអ្នកចង់រក្សា ឬអ្នកចង់រក PCP ថ្មី អ្នកអាចមើលនៅក្នុងសៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា (Provider Directory)។ វាមានបញ្ជី PCPs ទាំងអស់នៅក្នុងបណ្ដាញ Kaiser Permanente។ សៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវាមានព័ត៌មានផ្សេងទៀតដើម្បីជួយអ្នកក្នុងការជ្រើសរើស។ ប្រសិនបើអ្នកត្រូវការសៀវភៅបញ្ជីឈ្មោះអ្នកផ្តល់សេវា សូមទូរស័ព្ទទៅលេខ **1-800-464-4000** (TTY **711**)។ អ្នកអាចរកឃើញបញ្ជីឈ្មោះអ្នកផ្តល់សេវាតាមអនឡាញនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចទាញយកបញ្ជីឈ្មោះអ្នកផ្តល់សេវាពីគេហទំព័ររបស់យើង នៅ **kp.org/Medi-Cal/documents** (ជាភាសាអង់គ្លេស)។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងភ្លាមៗតាមលេខ **1-800-464-4000** (TTY **711**)។

ប្រសិនបើអ្នកមិនអាចទទួលបានការថែទាំដែលអ្នកត្រូវការពីអ្នកផ្តល់សេវាបណ្ដាញ Kaiser Permanente, PCP របស់អ្នកត្រូវតែស្នើ Southern California Permanente Medical Group សុំការយល់ព្រម ដើម្បីបញ្ជូនអ្នកទៅអ្នកផ្តល់សេវាក្រៅបណ្ដាញ។ នេះត្រូវបានហៅថាការបញ្ជូនក្រៅបណ្ដាញ។ អ្នកមិនត្រូវការការយល់ព្រមដើម្បីទៅរកអ្នកផ្តល់សេវាក្រៅបណ្ដាញ ដើម្បីទទួលបានការថែទាំសម្ងាត់ទេ ដែលនេះត្រូវបានពិពណ៌នានៅក្រោមចំណងជើង "ការថែទាំសម្ងាត់" នៅពេលក្រោយក្នុងជំពូកនេះ។

សូមអានជំពូកដែលនៅសល់ដើម្បីស្វែងយល់បន្ថែមអំពី PCP សៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា និងបណ្ដាញអ្នកផ្តល់សេវា។

ឥឡូវនេះអត្ថប្រយោជន៍ឱសថស្ថានត្រូវបានគ្រប់គ្រងតាមរយៈកម្មវិធីបង់ថ្លៃពេលប្រើសេវា (Fee-For-Service, "FFS") Medi-Cal Rx។ ដើម្បីស្វែងយល់ថែមទៀត សូមអានផ្នែក "អត្ថប្រយោជន៍និងកម្មវិធីផ្សេងទៀតដែលរ៉ាប់រងដោយ Kaiser Permanente" ជំពូកទី 4។

អ្នកផ្តល់សេវាថែទាំបឋម ("PCP")

អ្នកត្រូវជ្រើសរើស PCP ក្នុងរយៈពេល 30 ថ្ងៃចាប់ពីពេលដែលអ្នកត្រូវបានចាត់តាំងអោយទៅ Kaiser Permanente។

ដើម្បីជួយអ្នកឲ្យស្វែងរកវេជ្ជបណ្ឌិតដែលសមស្របសម្រាប់អ្នក អ្នកអាចស្វែងរកព័ត៌មានផ្ទាល់ខ្លួន របស់វេជ្ជបណ្ឌិតរបស់យើងតាមអនឡាញនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ អ្នកអាចដឹងថាតើវេជ្ជបណ្ឌិតកំពុងតែទទួលអ្នកជម្ងឺថ្មីឬទេ ហើយជ្រើសយកម្នាក់ដែលសមស្របនឹងតម្រូវការរបស់អ្នក។

មនុស្សពេញវ័យអាចជ្រើសរើស PCP ចេញពី៖

- ផ្នែកព្យាបាលមនុស្សពេញវ័យ/ជំងឺសរីរាង្គ
- ផ្នែកព្យាបាលសម្រាប់គ្រួសារ
- វេជ្ជបណ្ឌិតឯកទេសសម្ភពនិងរោគស្ត្រីដែល Southern California Permanente Medical Group ("ក្រុមវេជ្ជសាស្ត្រ") ចាត់ទុកជា PCP

សម្រាប់ក្មេងមានអាយុរហូតដល់ 18 ឆ្នាំ អ្នកអាចជ្រើសយកវេជ្ជបណ្ឌិតម្នាក់ពីផ្នែកជំងឺកុមារ/យុវជន ឬពេទ្យប្រចាំគ្រួសារដើម្បីធ្វើជា PCP របស់កូនពួកគេ។ សមាជិកគ្រួសារដែលត្រូវបានរ៉ាប់រងនីមួយៗ អាចនឹងជ្រើសរើសយកវេជ្ជបណ្ឌិតផ្ទាល់ខ្លួនរបស់ពួកគេ។ អាស្រ័យលើប្រភេទអ្នកផ្តល់សេវា អ្នកអាចជ្រើសរើស PCP មួយសម្រាប់គ្រួសារទាំងមូលរបស់អ្នក ដែលជាសមាជិករបស់ Kaiser Permanente។ ប្រសិនបើអ្នកនៅក្នុងកម្មវិធី Medicare និង Medi-Cal ឬប្រសិនបើអ្នកមានការធានារ៉ាប់រងការថែទាំសុខភាពដទៃទៀត អ្នកមិនចាំបាច់ជ្រើសរើស PCP ទេ។

អ្នកក៏អាចជ្រើសរើសទទួលបានការថែទាំសុខភាពបឋមនៅមជ្ឈមណ្ឌលសុខភាពស្របតាមលក្ខខ័ណ្ឌសហព័ន្ធ (Federally Qualified Health Center, "FQHC") អ្នកផ្តល់សេវាថែទាំសុខភាពជនជាតិដើមអាមេរិក (Indian Health Care Provider, "IHCP") ឬគ្លីនិកសុខភាពជនបទ (Rural Health Clinic, "RHC") ក្នុងបណ្តាញរបស់យើងបានផងដែរ។ អាស្រ័យលើប្រភេទអ្នកផ្តល់សេវា អ្នកអាចជ្រើសរើស PCP មួយសម្រាប់គ្រួសារទាំងមូលរបស់អ្នក ដរាបណាម PCP មានជូនសម្រាប់អ្នក។

កំណត់ចំណាំ៖ ជនជាតិដើមអាមេរិកស្បែកក្រហមអាចជ្រើសយក IHC ធ្វើជា PCP របស់ពួកគេ បើទោះបីជា IHC នោះមិនមែននៅក្នុងបណ្តាញរបស់យើងក្តី។

ប្រសិនបើអ្នកមិនជ្រើសរើស PCP ក្នុងរយៈពេល 30 ថ្ងៃគិតពីថ្ងៃចាត់តាំងទៅនោះទេ យើងនឹងចាត់អ្នកទៅ PCP មួយ។

អ្នកអាចផ្លាស់ប្តូរទៅកាន់វេជ្ជបណ្ឌិត Kaiser Permanente ផ្សេងទៀតដែលមានផ្តល់ជូនផងដែរ បានគ្រប់ពេលដោយសារហេតុផលណាមួយ ។ អ្នកអាចផ្លាស់ប្តូរវេជ្ជបណ្ឌិតរបស់អ្នកតាមអនឡាញ

នៅពេលណាក៏បាននៅ **kp.org** (ជាភាសាអង់គ្លេស) ឬអ្នកអាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងខ្ញុំ តាមរយៈលេខ **1-800-464-4000** (TTY **711**)។

PCP របស់អ្នកនឹង៖

- ស្វែងយល់អំពីប្រវត្តិនិងតម្រូវការផ្នែកសុខភាពរបស់អ្នក
- រក្សាទុកកំណត់ត្រាសុខភាពរបស់អ្នក
- ផ្តល់ឲ្យអ្នកនូវការថែទាំសុខភាពជាប្រចាំនិងបង្ការដែលអ្នកត្រូវការ
- បញ្ជូន (ផ្ញើ) អ្នកទៅអ្នកឯកទេស ប្រសិនបើអ្នកត្រូវការ

អ្នកអាចមើលក្នុងសៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា Medi-Cal ដើម្បីស្វែងរក PCP មួយក្នុងបណ្តាញ Kaiser Permanente។ បញ្ជីឈ្មោះអ្នកផ្តល់សេវា Medi-Cal មានបញ្ជីឈ្មោះអ្នកផ្តល់សេវាដែលធ្វើការជាមួយ Kaiser Permanente ដើម្បីផ្តល់សេវារ៉ាប់រងដោយ Medi-Cal ។

អ្នកអាចរកសៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា Kaiser Permanente តាមអនឡាញនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ យើងក៏អាចស្នើសុំបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា ឲ្យផ្ញើរទៅអ្នក ដោយទូរស័ព្ទទៅលេខ **1-800-464-4000** (TTY **711**)។

ជម្រើសនៃវេជ្ជបណ្ឌិត និងអ្នកផ្តល់សេវាថែទាំផ្សេងៗទៀត

អ្នកដឹងពីតម្រូវការការថែទាំសុខភាពរបស់អ្នកបានល្អបំផុត ដូច្នេះវាប្រសើរបំផុតប្រសិនបើអ្នកជ្រើសរើស PCP របស់អ្នក។

វាល្អបំផុតក្នុងការមាន PCP ម្នាក់ ដូច្នេះពួកគាត់អាចយល់ដឹងអំពីតម្រូវការសុខភាពរបស់អ្នក។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើអ្នកចង់ផ្លាស់ប្តូរទៅ PCP ថ្មី អ្នកអាចប្តូរបានគ្រប់ពេល។ អ្នកត្រូវតែជ្រើសរើស PCP ដែលមាននៅក្នុងបណ្តាញអ្នកផ្តល់សេវា Kaiser Permanente ហើយនិងកំពុងទទួលអ្នកជំងឺថ្មី។

ដើម្បីស្វែងយល់អំពីរបៀបជ្រើសរើសឬផ្លាស់ប្តូរ PCP របស់អ្នក សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

យើងអាចស្នើសុំអ្នកឲ្យផ្លាស់ប្តូរ PCP របស់អ្នកប្រសិនបើ PCP មិនទទួលយកអ្នកជំងឺថ្មី, បានចាកចេញពីបណ្តាញរបស់យើង ឬមិនផ្តល់ការថែទាំអ្នកជំងឺដែលមានអាយុអ្នក។ យើងអាចស្នើសុំ L.A. Care Health Plan ចាត់តាំងអ្នកអោយទៅអ្នកផ្តល់សេវាផ្សេងទៀត នៅក្នុងបណ្តាញ ប្រសិនបើអ្នកមិនចុះសម្រុង ឬយល់ព្រមជាមួយ PCP របស់អ្នក ឬប្រសិនបើអ្នកខកខាន ឬយឺតយ៉ាវក្នុងការណាត់ជួប។ ប្រសិនបើ L.A. Care Health Plan ចាត់តាំងអ្នកជាថ្មីទៅបណ្តាញអ្នកផ្តល់សេវាផ្សេងទៀត ពួកគេនឹងប្រាប់អ្នកជាលាយលក្ខណ៍អក្សរ។

កត្តាមួយចំនួនដើម្បីយកមកគិតនៅពេលជ្រើសយក PCP ម្នាក់៖

- តើ PCP នោះថែទាំកុមារឬទេ?

- តើ PCP នោះធ្វើការជាមួយទីកន្លែងផែនការដែលខ្ញុំចូលចិត្តប្រើឬទេ?
- តើការិយាល័យរបស់ PCP នោះនៅជិតផ្ទះខ្ញុំ កន្លែងធ្វើការខ្ញុំ ឬសាលារៀនរបស់កូនឬទេ?
- តើវេជ្ជបណ្ឌិតនិយាយភាសាខ្ញុំឬទេ?
- តើម៉ោងធ្វើការនៃការិយាល័យ PCP នោះសមស្របនឹងកាលវិភាគខ្ញុំឬទេ?

ការវាយតម្លៃសុខភាពដើម ("IHA")

យើងផ្តល់អនុសាសន៍ថាក្នុងនាមជាសមាជិកថ្មី អ្នកនឹងទៅជួប PCP ថ្មីរបស់អ្នកក្នុងរយៈពេល 120 ថ្ងៃបន្ទាប់សម្រាប់ការវាយតម្លៃសុខភាពដំបូង (Initial Health Assessment, "IHA")។ គោលបំណងរបស់ IHA គឺដើម្បីជួយឲ្យ PCP របស់អ្នករៀនអំពីប្រវត្តិថែទាំសុខភាពនិងតម្រូវការរបស់អ្នក។ PCP របស់អ្នកអាចសួរអ្នកនូវសំណួរមួយចំនួនអំពីប្រវត្តិសុខភាពរបស់អ្នក ឬអាចស្នើសុំឲ្យអ្នកបំពេញកម្រងសំណួរ។ PCP របស់អ្នកក៏នឹងប្រាប់អ្នកផងដែរអំពីការប្រឹក្សាយោបល់និងថ្នាក់អប់រំសុខភាពដែលអាចជួយអ្នកបាន។

យកប័ណ្ណ BIC របស់អ្នកអត្តសញ្ញាណប័ណ្ណ L.A. Care Health Plan របស់អ្នក អត្តសញ្ញាណប័ណ្ណ Kaiser Permanente របស់អ្នក និងអត្តសញ្ញាណមានរូបថតរបស់អ្នក ទៅកាន់ការណាត់ជួបរបស់អ្នក។ វាជាគំនិតល្អក្នុងការយកបញ្ជីឱសថនិងសំនួររបស់អ្នកទៅជាមួយក្នុងការជួបរបស់អ្នក។ ត្រៀមខ្លួនឲ្យរួចរាល់ដើម្បីពិគ្រោះជាមួយ PCP របស់អ្នកអំពីតម្រូវការនិងកង្វល់នៃការថែទាំសុខភាពរបស់អ្នក។

ត្រូវប្រាកដថាទូរស័ព្ទទៅការិយាល័យ PCP របស់អ្នក ប្រសិនបើអ្នកនឹងយឺតយ៉ាវឬមិនអាចទៅការណាត់ជួបរបស់អ្នក។

ប្រសិនបើអ្នកមានសំណួរ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

ការថែទាំជាប្រចាំ

ការថែទាំជាប្រចាំគឺជាការថែទាំសុខភាពដែលទៀងទាត់។ វារួមបញ្ចូលការថែទាំបង្ការដែលត្រូវបានហៅផងដែរថា ការថែទាំសុខុមាលភាពឬការថែទាំសុខភាព។ វាជួយអ្នកឲ្យមានសុខភាពល្អនិងជួយរក្សាអ្នកពីការឈឺ។ ការថែទាំបង្ការរួមមានការពិនិត្យសុខភាពជាទៀងទាត់ ការអប់រំសុខភាព និងការប្រឹក្សាយោបល់។ កុមារអាចទទួលបានសេវាបង្ការជាមុនដែលចាំបាច់ដូចជាការពិនិត្យមើលការស្តាប់ឮនិងការមើលឃើញ ការវាយតម្លៃដំណើរការកំលូតលាស់ រួមទាំងសេវាជាច្រើនទៀតដែលត្រូវបានផ្តល់អនុសាសន៍ ដោយគោលការណ៍ណែនាំរបស់ Bright Futures នៃវេជ្ជបណ្ឌិតខាងជម្ងឺកុមារ។ បន្ថែមពីលើការថែទាំបង្ការ ការថែទាំជាប្រចាំក៏រួមបញ្ចូលការថែទាំនៅពេលអ្នកឈឺផងដែរ។ Kaiser Permanente រ៉ាប់រងការថែទាំជាប្រចាំពីបណ្តាញអ្នកផ្តល់សេវារបស់អ្នក។

PCP របស់អ្នកនឹង៖

- ផ្តល់ជូនអ្នកនូវការថែទាំជាប្រចាំទាំងអស់របស់អ្នក រួមមានការត្រួតពិនិត្យជាទៀងទាត់ ការចាក់ថ្នាំ ការព្យាបាល វេជ្ជបញ្ជា និងការណែនាំវេជ្ជសាស្ត្រ
- រក្សាទុកកំណត់ត្រាសុខភាពរបស់អ្នក
- បញ្ជូន (ផ្ញើ) អ្នកទៅអ្នកឯកទេស ប្រសិនបើចាំបាច់
- ដាក់បញ្ជាការពិនិត្យកាំរស្មី X ការពិនិត្យសុដន់ ឬការជួសឈាមនៅទីពិសោធន៍ប្រសិនបើអ្នកត្រូវការវា

នៅពេលអ្នកត្រូវការការថែទាំជាប្រចាំ អ្នកអាចទូរស័ព្ទទៅលេខ **1-833-574-2273** (TTY **711**) ដើម្បីដាក់ពេលណាត់ជួប ឬអ្នកអាចដាក់ការណាត់តាមអនឡាញ។ ដើម្បីស្នើសុំការណាត់តាមអនឡាញ សូមចូលមើលគេហទំព័ររបស់យើងនៅ **kp.org** (ជាភាសាអង់គ្លេស)។

សម្រាប់ការថែទាំគ្រាអាសន្ន សូមទូរស័ព្ទទៅ **911** ឬទៅបន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត។

ដើម្បីស្វែងយល់បន្ថែមអំពីការថែទាំសុខភាពនិងសេវាកម្មដែលយើងរាប់រាប់រង និងអ្វីដែលយើងមិនរាប់រង សូមអានជំពូកទី 4 ("អត្ថប្រយោជន៍និងសេវាកម្ម") និងជំពូកទី 5 ("ការថែទាំសុខភាពទូទៅកុមារនិងយុវជន") នៅក្នុងសៀវភៅណែនាំសមាជិកនេះ។

អ្នកផ្តល់សេវាក្នុងបណ្តាញទាំងអស់អាចប្រើប្រាស់ជំនួយ និងសេវាកម្មដើម្បីទំនាក់ទំនងជាមួយសមាជិក និងអ្នកថែទាំដែលមានពិការភាព។ ពួកគេក៏អាចទំនាក់ទំនងជាមួយអ្នក ក្នុងភាសាឬទម្រង់មួយផ្សេងទៀត។ ប្រាប់អ្នកផ្តល់សេវារបស់អ្នក ឬទូរស័ព្ទមកប្រាប់យើងអំពីអ្វីដែលអ្នកត្រូវការ។

បណ្តាញអ្នកផ្តល់សេវា Medi-Cal

បណ្តាញអ្នកផ្តល់សេវា Medi-Cal គឺជាក្រុមវេជ្ជបណ្ឌិត មន្ទីរពេទ្យ និងអ្នកផ្តល់សេវាផ្សេងទៀតដែលធ្វើការជាមួយ Kaiser Permanente ដើម្បីផ្តល់សេវារ៉ាប់រងដោយ Medi-Cal ដល់សមាជិករបស់យើង។

Kaiser Permanente គឺជាបណ្តាញអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកតាមរយៈ L.A. Care Health Plan។ នៅពេលអ្នកជ្រើសរើសយក Kaiser Permanente អ្នកកំពុងជ្រើសរើសទទួលការថែទាំរបស់អ្នក តាមរយៈកម្មវិធីថែទាំវេជ្ជសាស្ត្ររបស់យើង។ អ្នកត្រូវតែទទួលយកសេវាភាគច្រើនពីអ្នកផ្តល់សេវាក្នុងបណ្តាញរបស់យើង។

អ្នកអាចទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញ ដោយគ្មានលិខិតបញ្ជូន ឬការអនុញ្ញាតជាមុនសម្រាប់សេវាសង្គ្រោះបន្ទាន់ ឬ សេវាដែនការត្រួសារ។ អ្នកក៏អាចទៅជួបអ្នកផ្តល់សេវាក្រៅបណ្តា

ញសម្រាប់ការថែទាំសុខភាពបន្ទាន់ក្រៅមូលដ្ឋាន នៅពេលអ្នកកំពុងស្ថិតនៅក្នុងតំបន់ដែលយើងមិនមានប្រតិបត្តិការ។ អ្នកត្រូវតែមានលិខិតបញ្ជូន ឬការអនុញ្ញាតជាមុនសម្រាប់សេវាក្រៅបណ្តាញដទៃទៀតទាំងអស់ បើមិនដូច្នោះវានឹងមិនត្រូវបានរ៉ាប់រងឡើយ។

កំណត់ចំណាំ៖ ជនជាតិដើមអាមេរិកស្បែកក្រហមអាចជ្រើសយក អ្នកផ្តល់សេវាថែទាំសុខភាពសម្រាប់ជនជាតិអាមេរិចស្បែកក្រហម ("IHCP") ធ្វើជា PCP របស់ពួកគេ បើទោះបីជា IHCP នោះមិនមែននៅក្នុងបណ្តាញក្តី។

ប្រសិនបើ PCP មន្ទីរពេទ្យ ឬអ្នកផ្តល់សេវាផ្សេងទៀតមានការជំទាស់ផ្នែកសីលធម៌ក្នុងការផ្តល់ឲ្យអ្នកនូវសេវាដែលត្រូវបានរ៉ាប់រងដូចជាការធ្វើផែនការគ្រួសារ ឬការរំលូតកូន ពួកគេអាចជួយអ្នកស្វែងរកបណ្តាញអ្នកផ្តល់សេវា ដែលនឹងផ្តល់ដល់អ្នកនូវសេវាដែលអ្នកត្រូវការ។ លោកអ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង តាមរយៈលេខ **1-800-464-4000** (TTY **711**) ដើម្បីស្នើសុំជំនួយស្វែងរកបណ្តាញអ្នកផ្តល់សេវាមួយទៀត។ សម្រាប់ព័ត៌មានបន្ថែមអំពីការប្រឆាំងផ្នែកសីលធម៌ សូមមើល "ការប្រឆាំងផ្នែកសីលធម៌" នៅផ្នែកក្រោយក្នុងជំពូកនេះ។

អ្នកផ្តល់សេវានៅក្នុងបណ្តាញ

អ្នកនឹងប្រើប្រាស់អ្នកផ្តល់សេវានៅក្នុងបណ្តាញ Kaiser Permanente សម្រាប់តម្រូវការ ថែទាំសុខភាពស្ទើរតែទាំងអស់របស់អ្នក។ អ្នកនឹងទទួលការថែទាំជាប្រចាំ រួមជាមួយការថែទាំបង្ការពី PCP របស់អ្នក។ អ្នកក៏នឹងប្រើប្រាស់អ្នកឯកទេស មន្ទីរពេទ្យ និងអ្នកផ្តល់សេវាផ្សេងៗទៀតនៅក្នុងបណ្តាញ Kaiser Permanente ផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីអ្នកផ្តល់សេវាក្នុងបណ្តាញរបស់យើង សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ អ្នកក៏អាចស្វែងរកអ្នកផ្តល់សេវាក្នុងបណ្តាញនិងទីតាំងរបស់ Kaiser Permanente តាមអនឡាញនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចទាញយកមួយច្បាប់នៃបញ្ជីឈ្មោះអ្នកផ្តល់សេវាពីគេហទំព័រនៅ **kp.org/Medi-Cal/documents** (ជាភាសាអង់គ្លេស)។

ដើម្បីទទួលបានច្បាប់ចម្លងនៃបញ្ជីឱសថកិច្ចសន្យា Medi-Cal Rx សូមទូរស័ព្ទទៅផ្នែកសេវាអតិថិជន Medi-Cal Rx តាមរយៈលេខ **1-800-977-2273** 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **1-800-977-2273** ហើយចុចលេខ 5 ឬហៅទៅលេខ **711** ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច។ អ្នកក៏អាចចូលមើលគេហទំព័រ **https://medi-calrx.dhcs.ca.gov/home/** (ជាភាសាអង់គ្លេស)។

សម្រាប់ការថែទាំគ្រាអាសន្ន សូមទូរស័ព្ទទៅ **911** ឬទៅបន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត។

លើកលែងតែសម្រាប់ការថែទាំគ្រាអាសន្ន ការថែទាំបន្ទាន់ ឬការថែទាំសម្ងាត់ អ្នកត្រូវតែទទួលបានការអនុញ្ញាតជាមុនពី Kaiser Permanente មុននឹងអ្នកជួបជាមួយអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente។ ប្រសិនបើអ្នកមិនទទួលបានការអនុញ្ញាតជាមុន ហើយអ្នកទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញ សម្រាប់ការថែទាំដែលមិនមែនជាការថែទាំសង្គ្រោះ ការថែទាំប

ន្ទាន់ នៅក្រៅតំបន់របស់អ្នក ឬការថែទាំសម្ងាត់ អ្នកប្រហែលជាត្រូវបង់ប្រាក់សម្រាប់សេវាដែលអ្នកទទួលបានពីអ្នកផ្តល់សេវាក្រៅបណ្តាញនោះ។ អ្នកផ្តល់សេវា Kaiser Permanente ដែលនៅក្រៅតំបន់គេហដ្ឋានរបស់អ្នកគឺជាអ្នកផ្តល់ សេវាថែទាំក្រៅបណ្តាញ។

អ្នកផ្តល់សេវាក្រៅបណ្តាញនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក

អ្នកផ្តល់សេវាក្រៅបណ្តាញគឺជាអ្នកដែលមិនមានកិច្ចព្រមព្រៀងក្នុងការធ្វើការជាមួយ Kaiser Permanente។

យើងត្រូវតែទទួលបានការយល់ព្រមជាមុន មុនពេលអ្នកទៅរកអ្នកផ្តល់សេវា ក្រៅបណ្តាញនៅក្នុងតំបន់លំនៅដ្ឋាន លើកលែងតែសម្រាប់៖

- ការថែទាំសង្គ្រោះបន្ទាន់។
- ការថែទាំសម្ងាត់

សម្រាប់ការថែទាំជាបន្ទាន់ក្នុងតំបន់លំនៅដ្ឋាន អ្នកត្រូវតែជូបអ្នកផ្តល់សេវាបណ្តាញរបស់ Kaiser Permanente។ អ្នកមិនត្រូវការអនុញ្ញាតជាមុនដើម្បីទទួលការថែទាំបន្ទាន់ពីអ្នកផ្តល់សេវាក្នុងបណ្តាញទេ។

អ្នកត្រូវតែទទួលការអនុញ្ញាតពីយើងដើម្បីទទួលបានការថែទាំបន្ទាន់ពីអ្នកផ្តល់សេវាក្រៅបណ្តាញដែលនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក។ ប្រសិនបើអ្នកមិនទទួលបានការអនុញ្ញាតជាមុន អ្នកអាចត្រូវបង់ប្រាក់សម្រាប់ការថែទាំបន្ទាន់ ដែលអ្នកទទួលពីអ្នកផ្តល់សេវាក្រៅបណ្តាញនៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការថែទាំគ្រាអាសន្ន ការថែទាំបន្ទាន់ និងការថែទាំសម្ងាត់ សូមចូលទៅចំណងជើងទាំងនោះក្នុងជំពូកនេះ។

កំណត់ចំណាំ៖ ប្រសិនបើអ្នកជាជនជាតិអាមេរិកស្បែកក្រហម អ្នកអាចទទួលបានការថែទាំនៅ IHCP នៅក្រៅបណ្តាញអ្នកផ្តល់សេវារបស់យើង ដោយមិនចាំបាច់មានលិខិតបញ្ជូន។

ប្រសិនបើអ្នកត្រូវការសេវាកម្មត្រូវបានរ៉ាប់រងចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលមិនមាននៅក្នុងបណ្តាញ Kaiser Permanente យើងនឹងយល់ព្រមហើយបញ្ជូនអ្នកទៅអ្នកផ្តល់សេវាក្រៅបណ្តាញដើម្បីទទួលបានសេវាទាំងនោះ។ ប្រសិនបើយើងផ្តល់លិខិតបញ្ជូនដល់អ្នកទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញ យើងនឹងបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នក។

អ្នកផ្តល់សេវាថែទាំបន្ទាន់របស់អ្នកអាចផ្តល់ឲ្យអ្នកនូវឱសថដែលជាផ្នែកនៃការជួបថែទាំបន្ទាន់របស់អ្នក។ ប្រសិនបើអ្នកទទួលបានថ្នាំដែលជាផ្នែកនៃការជួបពិនិត្យរបស់អ្នក យើងនឹងរ៉ាប់រងលើថ្នាំដែលជាផ្នែកនៃការថែទាំបន្ទាន់មានធានារ៉ាប់រងរបស់អ្នក។ ប្រសិនបើអ្នកផ្តល់សេវាថែទាំបន្ទាន់របស់អ្នកផ្តល់ឲ្យអ្នកនូវវេជ្ជបញ្ជាដើម្បីយកទៅឱសថស្ថាននោះ ថ្នាំដែលត្រូវបានចេញវេជ្ជបញ្ជាសម្រាប់អ្នកនឹងត្រូវរ៉ាប់រងដោយកម្មវិធី Medi-Cal Rx។ សម្រាប់ព័ត៌មានបន្ថែមអំពី Medi-Cal Rx សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្នុងផ្នែក "កម្មវិធីនិងសេវាកម្ម Medi-Cal ផ្សេងទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" នៅក្នុងជំពូកទី 4។

ប្រសិនបើអ្នកត្រូវការជំនួយជាមួយសេវាក្រៅបណ្តាញ សូមនិយាយជាមួយ PCP របស់អ្នក ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង **1-800-464-4000** (TTY **711**)។

អ្នកផ្តល់សេវានៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក

ការថែទាំជាប្រចាំដែលរួមមានការថែទាំបង្ការមិនត្រូវបានរ៉ាប់រងនៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នកទេ។

ប្រសិនបើអ្នកស្ថិតនៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក ហើយត្រូវការការថែទាំដែល **មិនមែន** ជាការថែទាំគ្រាអាសន្នឬបន្ទាន់ សូមទូរស័ព្ទទៅលេខ **1-833-574-2273** (TTY **711**) ហើយនិយាយជាមួយអ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

អ្នកផ្តល់សេវាថែទាំបន្ទាន់របស់អ្នកអាចផ្តល់ឲ្យអ្នកនូវឱសថ ដែលជាផ្នែកនៃការជួបថែទាំបន្ទាន់របស់អ្នក។ ប្រសិនបើអ្នកទទួលបានថ្នាំដែលជាផ្នែកនៃការជួបពិនិត្យរបស់អ្នក យើងនឹងរ៉ាប់រងលើថ្នាំដែលជាផ្នែកនៃការថែទាំបន្ទាន់មានជានារ៉ាប់រងរបស់អ្នក។ ប្រសិនបើអ្នកផ្តល់សេវាថែទាំបន្ទាន់របស់អ្នកផ្តល់ឲ្យអ្នកនូវវេជ្ជបញ្ជាដើម្បីយកទៅឱសថស្ថាននោះ ថ្នាំដែលត្រូវបានចេញវេជ្ជបញ្ជាសម្រាប់អ្នកនឹងត្រូវរ៉ាប់រងដោយកម្មវិធី Medi-Cal Rx។ សម្រាប់ព័ត៌មានបន្ថែមអំពី Medi-Cal Rx សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្នុងផ្នែក "កម្មវិធីនិងសេវាកម្ម Medi-Cal ផ្សេងទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" នៅក្នុងជំពូកទី 4 ។

សម្រាប់ការថែទាំគ្រាអាសន្ន សូមទូរស័ព្ទទៅ **911** ឬទៅបន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត។ Kaiser Permanente រ៉ាប់រងលើការថែទាំសង្គ្រោះបន្ទាន់ក្រៅបណ្តាញ។ ប្រសិនបើអ្នកធ្វើដំណើរទៅប្រទេសកាណាដា ឬម៉ិកស៊ិកូហើយត្រូវការការថែទាំសង្គ្រោះបន្ទាន់ ដែលតម្រូវឲ្យចូលមន្ទីរពេទ្យ Kaiser Permanente នឹងរ៉ាប់រងការថែទាំរបស់អ្នក។ ប្រសិនបើអ្នកកំពុងធ្វើដំណើរជាអន្តរជាតិនៅក្រៅប្រទេសកាណាដា ឬម៉ិកស៊ិកូហើយត្រូវការ ការថែទាំសង្គ្រោះបន្ទាន់ យើងនឹងមិនរ៉ាប់រងការថែទាំរបស់អ្នកទេ។

ប្រសិនបើអ្នកចេញថ្លៃសម្រាប់ការថែទាំសង្គ្រោះបន្ទាន់ ដែលតម្រូវនូវការសម្រាកនៅមន្ទីរពេទ្យក្នុងប្រទេសកាណាដា ឬម៉ិកស៊ិកូ អ្នកអាចស្នើសុំឲ្យយើងទូទាត់សងអ្នកវិញ។ ដាក់ទម្រង់ទាមទារសំណង ហើយយើងនឹងត្រួតពិនិត្យមើលសំណើរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមអំពីការដាក់ពាក្យទាមទារ សូមមើលផ្នែក "សុំឲ្យយើងបង់វិក្កយបត្រ" នៅក្នុងជំពូកទី 2 ។

ប្រសិនបើអ្នកស្ថិតនៅក្នុងរដ្ឋមួយផ្សេងទៀត រួមទាំងទឹកដីសហរដ្ឋអាមេរិក (អាមេរិចកាំងសាម៉ូអា ហ្គាំ កោះម៉ារីអាណាខាងជើង ប៉ុរតូរីកូ និង កោះវឺជីនអាមេរិច) អ្នកនឹងត្រូវបានធានារ៉ាប់រងសម្រាប់ការថែទាំសង្គ្រោះបន្ទាន់។ មិនមែនគ្រប់មន្ទីរពេទ្យ និងវេជ្ជបណ្ឌិតទាំងអស់ទទួលយក Medicaid ទេ (Medicaid គឺជាអ្វីដែល Medi-Cal ត្រូវបានគេហៅនៅក្នុងរដ្ឋផ្សេងទៀត)។ ប្រសិនបើអ្នកត្រូវការការថែទាំសង្គ្រោះបន្ទាន់នៅខាងក្រៅរដ្ឋកាលីហ្វ័រញ៉ា ប្រាប់មន្ទីរពេទ្យ ឬក្រុមពេទ្យបន្ទប់សង្គ្រោះបន្ទាន់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបានថាអ្នកមាន Medi-Cal និងជាសមាជិក Kaiser Permanente។ ស្នើសុំឲ្យមន្ទីរពេទ្យធ្វើការចម្លងប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នក។ ប្រាប់មន្ទីរពេទ្យនិងវេជ្ជបណ្ឌិតឲ្យធ្វើរឹកយប័ត្រមកយើង។ ប្រសិនបើអ្នកទទួលបានរឹកយប័ត្រសម្រាប់សេវាដែលអ្នកបានទទួលនៅក្នុងរដ្ឋមួយផ្សេងទៀត

សូមទូរស័ព្ទមកយើងភ្លាមៗ។ យើងនឹងធ្វើការជាមួយមន្ទីរពេទ្យ និង/ឬវេជ្ជបណ្ឌិតដើម្បីរៀបចំបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នក។

Medi-Cal មិនរាប់រងលើសេវាថែទាំបន្ទាន់នៅក្រៅសហរដ្ឋអាមេរិកទេ។ ប្រសិនបើអ្នកកំពុងធ្វើដំណើរនៅក្រៅសហរដ្ឋអាមេរិកហើយត្រូវការការថែទាំបន្ទាន់ Medi-Cal នឹងមិនចេញថ្លៃសម្រាប់ការថែទាំរបស់អ្នកទេ។

ប្រសិនបើអ្នកនៅក្រៅរដ្ឋកាលីហ្វ័រញ៉ា ហើយមានតម្រូវការបន្ទាន់ដើម្បីបំពេញថ្នាំវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យ នោះសូមឲ្យឱសថស្ថានទូរស័ព្ទទៅផ្នែកបម្រើអតិថិជន Medi-Cal Rx តាមរយៈលេខ **1-800-977-2273** 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

កំណត់ចំណាំ៖ ជនជាតិអាមេរិកស្បែកក្រហម អាចទទួលបានសេវាក្រៅបណ្តាញ IHCP។

ប្រសិនបើអ្នកមានសំណួរអំពីសេវាដែលអាចរកបានពីអ្នកផ្តល់សេវាក្រៅបណ្តាញ ឬក្រៅតំបន់លំនៅដ្ឋានរបស់អ្នក សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង លេខ **1-800-464-4000** (TTY **711**)។

វេជ្ជបណ្ឌិត

អ្នកនឹងជ្រើសយកអ្នកផ្តល់សេវាថែទាំចម្បង ("PCP") របស់អ្នកពីបណ្តាញ អ្នកផ្តល់សេវារបស់យើង។ ដើម្បីស្វែងរក PCP ម្នាក់នៅក្បែរអ្នក អ្នកអាចរកមើលក្នុងគេហទំព័ររបស់យើងនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ អ្នកអាចទាញយកច្បាប់នៃបញ្ជីឈ្មោះអ្នកផ្តល់សេវារបស់យើងនៅ **kp.org/Medi-Cal/documents** (ជាភាសាអង់គ្លេស) អ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

អ្នកក៏គួរតែទូរស័ព្ទមក ប្រសិនបើអ្នកចង់ពិនិត្យដើម្បីប្រាកដថា PCP ដែលអ្នកចង់បានកំពុងទទួលអ្នកជំងឺថ្មី។

ប្រសិនបើអ្នកមានគ្រូពេទ្យណាមួយមុនពេលដែលអ្នកជាសមាជិករបស់ Kaiser Permanente ហើយថាវេជ្ជបណ្ឌិតនោះមិននៅក្នុងផ្នែកនៃបណ្តាញអ្នកផ្តល់សេវារបស់យើង អ្នកប្រហែលជាអាចបន្តជួបគ្រូពេទ្យនោះក្នុងរយៈពេលកំណត់មួយ។ នេះត្រូវបានគេហៅថាការបន្តការថែទាំ។ អ្នកអាចអានបន្ថែមអំពីការបន្តការថែទាំនៅក្នុងជំពូកទី 2 នៃសៀវភៅណែនាំសមាជិកនេះ។ ដើម្បីស្វែងយល់បន្ថែមទៀត សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

ប្រសិនបើអ្នកត្រូវការអ្នកឯកទេស PCP របស់អ្នកនឹងបញ្ជូនអ្នកទៅកាន់អ្នកឯកទេសក្នុងបណ្តាញ Kaiser Permanente។ វិស័យឯកទេសខ្លះមិនតម្រូវឲ្យមានការបញ្ជូនទេ។ សម្រាប់ព័ត៌មានបន្ថែមអំពីការបញ្ជូន សូមចូលទៅចំណងជើង "ការបញ្ជូន" ក្រោយទៀតនៅក្នុងជំពូកទី 3 នេះ។

សូមចាំថា ប្រសិនបើអ្នកមិនជ្រើសរើស PCP យើងនឹងជ្រើសរើសយកមួយសម្រាប់អ្នក។ អ្នកដឹងពីតម្រូវការការថែទាំសុខភាពរបស់អ្នកល្អបំផុត ដូច្នេះវាល្អបំផុតប្រសិនបើអ្នកជ្រើសរើស។

ប្រសិនបើអ្នកនៅក្នុងកម្មវិធី Medicare និង Medi-Cal ឬប្រសិនបើអ្នកមានការធានារ៉ាប់រងការថែទាំសុខភាពដទៃទៀត អ្នកមិនចាំបាច់ជ្រើសរើស PCP ទេ។

ប្រសិនបើអ្នកចង់ផ្លាស់ប្តូរ PCP របស់អ្នកអ្នកត្រូវតែជ្រើសរើស PCP ចេញពីបណ្តាញ Kaiser Permanente។ ត្រូវប្រាកដថា PCP កំពុងទទួលអ្នកជំងឺថ្មី។ ដើម្បីស្វែងយល់អំពីរបៀបជ្រើសរើសឬផ្លាស់ប្តូរទៅ PCP ផ្សេងសូមចូលទៅកាន់គេហទំព័ររបស់យើងនៅ **kp.org** (ជាភាសាអង់គ្លេស) ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

មន្ទីរពេទ្យ

សម្រាប់ការថែទាំគ្រាអាសន្ន សូមទូរស័ព្ទទៅ **911** ឬទៅបន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត។

ប្រសិនបើវាមិនមែនជាការសង្គ្រោះបន្ទាន់ ហើយអ្នកត្រូវការការថែទាំពីមន្ទីរពេទ្យ PCP របស់អ្នកនឹងសំរេចថាអ្នកទៅមន្ទីរពេទ្យណា។ អ្នកនឹងត្រូវទៅមន្ទីរពេទ្យក្នុងបណ្តាញរបស់យើង។ ដើម្បីស្វែងរកមន្ទីរពេទ្យក្នុងបណ្តាញរបស់យើង អ្នកអាចរកមើលក្នុងគេហទំព័ររបស់យើងនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ លោកអ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងតាមរយៈលេខ **1-800-464-4000** (TTY **711**)។

អ្នកឯកទេសសុខភាពរបស់ស្ត្រី

អ្នកអាចទៅជួបគ្រូពេទ្យឯកទេសខាងសុខភាពរបស់ស្ត្រី នៅក្នុងបណ្តាញ Kaiser Permanente សម្រាប់ការថែទាំដែលចាំបាច់ ដើម្បីផ្តល់នូវសេវាថែទាំសុខភាពជាប្រចាំ និងបង្ការរបស់ស្ត្រី។ អ្នកមិនចាំបាច់ត្រូវការការបញ្ជូន ដើម្បីទទួលបានសេវាទាំងនេះទេ។ សំរាប់ជំនួយរកអ្នកឯកទេសសុខភាពស្ត្រី អ្នកអាចទូរស័ព្ទទៅ **1-800-464-4000** (TTY **711**)។ អ្នកក៏អាចទូរស័ព្ទទៅ **1-833-574-2273** (TTY **711**) និងពិគ្រោះជាមួយ អ្នកជំនាញថែទាំសុខភាពមានអាជ្ញាប័ណ្ណ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

សៀវភៅបញ្ជីអ្នកផ្តល់សេវា

សៀវភៅបញ្ជីអ្នកផ្តល់សេវា Kaiser Permanente "បញ្ជីអ្នកផ្តល់សេវា" រាយឈ្មោះអ្នកផ្តល់សេវានានាដែលចូលរួមក្នុងបណ្តាញ Kaiser Permanente Medi-Cal។ បណ្តាញគឺជាក្រុមអ្នកផ្តល់សេវាដែលធ្វើការជាមួយ Kaiser Permanente។

បញ្ជីឈ្មោះអ្នកផ្តល់សេវា Medi-Cal Kaiser Permanente រាយបញ្ជីប្រភេទអ្នកផ្តល់សេវាដូចខាងក្រោមដែលមាននៅក្នុងបណ្តាញរបស់យើង៖

- អ្នកផ្តល់សេវារៀបចំផែនការគ្រួសារ
- កម្មវិធីមជ្ឈមណ្ឌលសុខភាពតាមលក្ខខ័ណ្ឌសហព័ន្ធ ("FQHC") នៅកន្លែងដែលមានជូន
- អ្នកផ្តល់សេវាសុខភាពផ្លូវចិត្តសម្រាប់ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ
- សេវានិងជំនួយរយៈពេលវែងមានការគ្រប់គ្រង (Managed long-term services and supports, "MLTSS")

- មជ្ឈមណ្ឌលផ្តល់កំណើតតាមធម្មជាតិ (Freestanding Birth Center, "FBC") នៅកន្លែងដែលមានជូន
- មន្ទីរពេទ្យ
- អ្នកផ្តល់សេវាថែទាំសុខភាពអាមេរិកស្បែកក្រហម ("IHCP")
- គិលានុបដ្ឋាយិកា និងឆ្មបគិលានុបដ្ឋាយិកា
- PCP
- ឱសថស្ថាន
- ជំនួយការវេជ្ជបណ្ឌិត
- គ្លីនិកសុខភាពជនបទ ("RHC") នៅកន្លែងដែលមានជូន
- អ្នកឯកទេស

បញ្ជីរាយនាមអ្នកផ្តល់សេវាមានឈ្មោះអ្នកផ្តល់េសវាក្នុងបណ្តាញ Kaiser Permanente ឯកទេស អាសយដ្ឋាន លេខទូរស័ព្ទ ម៉ោងធ្វើការ និងភាសាដែលនិយាយ។ វាក្រាប់អ្នកប្រសិនបើអ្នកផ្តល់សេវាកំពុងតែទទួលអ្នកជម្ងឺថ្មី។ វាក៏ផ្តល់នូវកម្រិតនៃភាពងាយស្រួលក្នុងការចូលអគារផងដែរ ដូចជាចំណត ផ្លូវជម្រាល ជណ្តើរដែលមានបង្កាន់ដៃ និងបន្ទប់ទឹកដែលមានទ្វារធំទូលាយ និងរនុកគោង។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីការអប់រំ ការបណ្តុះបណ្តាល និងការបញ្ជាក់ពីក្រុមប្រឹក្សាភិបាល សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**).

អ្នកអាចស្វែងរកបញ្ជីឈ្មោះអ្នកផ្តល់សេវាដែលអាចស្រាវជ្រាវឃើញតាមអនឡាញនៅ **kp.org/facilities** (ជាភាសាអង់គ្លេស)។ អ្នកអាចទាញយកមួយច្បាប់នៅ **kp.org/Medi-Cal/documents** (ជាភាសាអង់គ្លេស)។ ប្រសិនបើអ្នកត្រូវការសៀវភៅបញ្ជីឈ្មោះអ្នកផ្តល់សេវាមួយក្បាល សូមទូរស័ព្ទទៅលេខ **1-800-464-4000** (TTY **711**).

អ្នកអាចស្វែងរកបញ្ជីឱសថស្ថានដែលធ្វើការជាមួយ Medi-Cal Rx នៅក្នុងសៀវភៅបញ្ជីឱសថ Medi-Cal Rx នៅ **https://medi-calrx.dhcs.ca.gov/home/** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចស្វែងរកឱសថស្ថានដែលចូលរួមនៅជិតអ្នកដោយហៅទូរសព្ទទៅផ្នែកសេវាអតិថិជន Medi-Cal Rx តាមរយៈលេខ **1-800-977-2273** ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **1-800-977-2273** សូមចុចលេខ 5 ឬទូរស័ព្ទទៅលេខ **711** ពីថ្ងៃច័ន្ទ ដល់ សុក្រពីម៉ោង 8 ព្រឹកដល់ 5 ល្ងាច។

ការទទួលបានតំហែទាំទាន់ពេលវេលា

អ្នកផ្តល់សេវារបស់អ្នកត្រូវតែផ្តល់ការណាត់ជួបដល់អ្នក ក្នុងអំឡុងពេលដែលរាយប្រាប់នៅខាងក្រោម។

ប្រភេទនៃការណាត់ជួប	ត្រូវតែផ្តល់ការណាត់ជួបក្នុង
ការណាត់ជួបថែទាំបន្ទាន់ដែលមិនតម្រូវឲ្យមានការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)	48 ម៉ោង
ការណាត់ជួបថែទាំបន្ទាន់ដែលតម្រូវការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)	96 ម៉ោង
ការណាត់ជួបថែទាំ (ជាប្រចាំ) បឋមមិនមែនបន្ទាន់	រយៈពេល 10 ថ្ងៃធ្វើការ
ការណាត់ជួបថែទាំ (ជាប្រចាំ) បឋមមិនមែនបន្ទាន់	រយៈពេល 15 ថ្ងៃធ្វើការ
ការណាត់ជួបថែទាំ(មិនមែនគ្រូពេទ្យ)ជាមួយអ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត(ជាប្រចាំ) មិនមែនបន្ទាន់	រយៈពេល 10 ថ្ងៃធ្វើការ
ការណាត់ជួបមិនមែនបន្ទាន់ (ជាប្រចាំ) សម្រាប់សេវាជំនួយ (គាំទ្រ) ដល់ការធ្វើរោគវិនិច្ឆ័យ ឬការព្យាបាលរបួស ជំងឺ ឬស្ថានភាពសុខភាពផ្សេងទៀត	រយៈពេល 15 ថ្ងៃធ្វើការ
ពេលវេលារង់ចាំទូរស័ព្ទសម្រាប់សេវាសមាជិកកំឡុងម៉ោងធ្វើការធម្មតា	10 នាទី

ប្រសិនបើអ្នកចង់រង់ចាំការណាត់ជួបនៅពេលក្រោយដែលត្រូវនឹងកាលវិភាគរបស់អ្នកជាង ឬចង់ជួបអ្នកផ្តល់សេវា Kaiser Permanente ដែលអ្នកជ្រើសរើស យើងនឹងគោរពតាមការពេញចិត្តរបស់អ្នក។ ជួនកាល ការរង់ចាំយូរសម្រាប់ការថែទាំ គឺមិនមែនជាបញ្ហាទេ។ អ្នកផ្តល់សេវារបស់អ្នកអាចផ្តល់ឲ្យអ្នកនូវពេលវេលារង់ចាំយូរជាងនេះ ប្រសិនបើវាមិនបង្កគ្រោះថ្នាក់ដល់សុខភាពរបស់អ្នក។ ប្រសិនបើត្រូវតែត្រូវបានកត់សម្គាល់នៅក្នុងកំណត់ត្រារបស់អ្នកថា ពេលវេលារង់ចាំយូរជាងនេះនឹងមិនមានគ្រោះថ្នាក់ដល់សុខភាពរបស់អ្នកទេ។

ស្តង់ដារសម្រាប់អត្ថិភាពនៃការណាត់ជួប មិនអនុវត្តចំពោះការថែទាំបង្ការនោះទេ។ វេជ្ជបណ្ឌិតរបស់អ្នកអាចណែនាំកាលវិភាគជាក់លាក់មួយសម្រាប់សេវាកម្មបង្ការទាំងនេះ អាស្រ័យលើតម្រូវការរបស់អ្នក។ បទដ្ឋានទាំងនេះក៏មិនអនុវត្តចំពោះការថែទាំតាមដានបន្តមួងម្កាលសម្រាប់ជំងឺដែលកំពុងកើតមាន ឬការបញ្ជូនបន្តជាអចិន្ត្រៃយ៍ទៅកាន់អ្នកឯកទេសផងដែរ។

សេវាអ្នកបកប្រែ

ប្រសិនបើអ្នកត្រូវការសេវាអ្នកបកប្រែភាសាផ្តាល់មាត់ នៅពេលអ្នកទូរស័ព្ទមកយើងខ្ញុំ ឬនៅពេលអ្នកទទួលបានសេវាដែលមានការរ៉ាប់រង សូមឲ្យយើងដឹង។ សេវាអ្នកបកប្រែផ្តាល់មាត់ដែលរួមមានភាសាសញ្ញាផងដែរ គឺមាននៅគ្រប់ម៉ោងធ្វើការទាំងអស់ ដោយមិនគិតថ្លៃសម្រាប់លោកអ្នក។ យើងខ្ញុំសូមមិនលើកទឹកចិត្តឲ្យប្រើអនីតិជន ឬសមាជិកគ្រួសារធ្វើជាអ្នកបកប្រែផ្តាល់មា

ត់ឡើយ។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាអ្នកបកប្រែ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវា សមាជិករបស់យើង លេខ **1-800-464-4000** (TTY **711**)។

ប្រសិនបើអ្នកត្រូវការសេវាបកប្រែ រួមទាំងភាសាសញ្ញា នៅឱសថស្ថាន Medi-Cal Rx ដែលនៅក្រៅបណ្តាញ Kaiser Permanente សូមទូរស័ព្ទទៅសេវាអតិថិជន Medi-Cal Rx តាមរយៈលេខ **1-800-977-2273** 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **711** ចន្លះដល់សុក្រពីម៉ោង 8 ព្រឹកដល់ 5 ល្ងាច។

ពេលវេលាធ្វើដំណើរ ឬចម្ងាយទៅកាន់ការថែទាំ

Kaiser Permanente ត្រូវតែអនុវត្តតាមបទដ្ឋានពេលវេលាធ្វើដំណើរ ឬចម្ងាយសម្រាប់ ការថែទាំរបស់អ្នក។ បទដ្ឋានទាំងនោះជួយធ្វើឲ្យប្រាកដថាអ្នកអាចទទួលបានការថែទាំ ដោយមិនចាំបាច់ធ្វើដំណើរយូរពេក ឬឆ្ងាយពេកពីកន្លែងដែលអ្នករស់នៅ។ បទដ្ឋានពេលវេលាធ្វើដំណើរឬចម្ងាយអាស្រ័យទៅតាមខោនធីដែលអ្នករស់នៅ។

ប្រសិនបើអ្នកត្រូវការការថែទាំពីអ្នកឯកទេស ហើយអ្នកផ្តល់សេវានោះមានទីតាំងនៅឆ្ងាយ ពីកន្លែងដែលអ្នករស់នៅ ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ ពួកគេអាចជួយអ្នកស្វែងរកអ្នកផ្តល់សេវាដែលនៅក្បែរអ្នកជាងគេ។ ប្រសិនបើយើងមិនអាចរកឃើញអ្នកផ្តល់សេវានៅក្បែរទេ អ្នកអាចស្នើសុំឲ្យយើងរៀបចំការដឹកជញ្ជូន សម្រាប់អ្នកដើម្បីទៅជួបអ្នកផ្តល់សេវា បើទោះបីជាអ្នកផ្តល់សេវានៅស្ថិតនៅឆ្ងាយ ពីលំនៅដ្ឋានរបស់អ្នកក៏ដោយ។

វាត្រូវបានចាត់ទុកថាឆ្ងាយ ប្រសិនបើអ្នកមិនអាចទៅដល់អ្នកឯកទេសនោះ ក្នុងបទដ្ឋានពេលវេលាធ្វើដំណើរនិងចម្ងាយសម្រាប់ខោនធីរបស់អ្នក ដោយមិនគិតពីបទដ្ឋានចូលប្រើប្រាស់ជំនួសណាមួយដែលអាចមានសម្រាប់លេខកូដតំបន់របស់អ្នក។

ប្រសិនបើអ្នកត្រូវការជំនួយជាមួយអ្នកផ្តល់សេវាឱសថស្ថាន សូមទូរស័ព្ទទៅ Medi-Cal Rx លេខ **1-800-977-2273** (TTY **1-800-977-2273** ហើយចុចលេខ 5 ឬ **711**)។

ការណាត់ជួប

នៅពេលអ្នកត្រូវការការថែទាំសុខភាព៖

- សូមទូរស័ព្ទទៅ PCP របស់អ្នក
- សូមត្រៀមលេខកំណត់ត្រាវេជ្ជសាស្ត្រ Kaiser Permanente របស់អ្នក (ដែលនៅលើប័ណ្ណសម្គាល់ Kaiser Permanente របស់អ្នក) ឲ្យរួចរាល់នៅពេលអ្នកទូរស័ព្ទទៅ
- ផ្ទៀងទុកសារជាសំលេងដោយមានឈ្មោះនិងលេខទូរស័ព្ទរបស់អ្នកប្រសិនបើការិយាល័យបានបិទ

- យកប័ណ្ណ BIC អត្តសញ្ញាណប័ណ្ណ L.A. Care Health Plan អត្តសញ្ញាណប័ណ្ណ Kaiser Permanente និងអត្តសញ្ញាណប័ណ្ណមានរូបថតរបស់អ្នកទៅកាន់ការណាត់ជួបរបស់អ្នក
- ស្នើសុំការដឹកជញ្ជូនទៅកាន់ការណាត់ជួប ប្រសិនបើត្រូវការ
- ស្នើសុំជំនួយខាងភាសា ឬសេវាអ្នកបកប្រែ ប្រសិនបើត្រូវការ
- អញ្ជើញទៅឲ្យទាន់ពេលសម្រាប់ការណាត់ជួបរបស់អ្នក មកដល់ពីរបីនាទីមុនដើម្បីចូល បំពេញទម្រង់បែបបទ និងឆ្លើយសំណួរណាមួយដែលអ្នកផ្តល់សេវារបស់អ្នកអាចមាន
- ហៅទូរស័ព្ទភ្លាមប្រសិនបើអ្នកមិនអាចរក្សាការណាត់ជួបរបស់អ្នក ឬនឹងទៅយឺត
- ត្រៀមសំណួរនិងព័ត៌មានឱសថរបស់អ្នកឲ្យរួចរាល់ ក្នុងករណីដែលអ្នកត្រូវការវា

ប្រសិនបើអ្នកមានករណីសង្គ្រោះបន្ទាន់ សូមទូរស័ព្ទទៅ **911** ឬទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

ការធ្វើដំណើរទៅកាន់ការណាត់ជួប

ប្រសិនបើអ្នកមិនមានមធ្យោបាយទៅនិងមកពីសេវាថែទាំសុខភាព និងការណាត់ជួបរបស់អ្នកទេ យើងអាចជួយរៀបចំការដឹកជញ្ជូនសម្រាប់អ្នក។ ជំនួយផ្នែកដឹកជញ្ជូនមានសម្រាប់សេវានិងការណាត់ជួបដែលមិនទាក់ទងនឹងការថែទាំសង្គ្រោះបន្ទាន់ ហើយអ្នកអាចជិះដោយមិនគិតថ្លៃសម្រាប់អ្នក។ សេវានេះ មានឈ្មោះថាការដឹកជញ្ជូនខាងវេជ្ជសាស្ត្រគឺ **មិន** សម្រាប់ភាពបន្ទាន់ឡើយ។ ប្រសិនបើអ្នកកំពុងមានការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ សូមទូរស័ព្ទ **911**។

សូមចូលទៅកាន់ផ្នែក "សេវាដឹកជញ្ជូនសម្រាប់ស្ថានភាពដែលមិនមានភាពអាសន្ន" នៅក្នុងជំពូកទី 4 ("អត្ថប្រយោជន៍ និងសេវាកម្ម") សម្រាប់ព័ត៌មានបន្ថែម។

ការលុបចោលនិងការដាក់ថ្លៃណាត់ជួបឡើងវិញ

ប្រសិនបើអ្នកមិនអាចធ្វើការណាត់ជួបរបស់អ្នក ទូរស័ព្ទទៅការិយាល័យអ្នកផ្តល់សេវាភ្លាមៗ។ ក្រុមេទ្យភាគច្រើនសុំឲ្យអ្នកទូរស័ព្ទទៅ 24 ម៉ោង (1 ថ្ងៃធ្វើការ) មុនពេលការណាត់ជួបរបស់អ្នក ប្រសិនបើអ្នកត្រូវលុបចោល។ ប្រសិនបើអ្នកខកខានការណាត់ជួបម្តងហើយម្តងទៀត ក្រុមេទ្យរបស់អ្នកប្រហែលជាមិនចង់ពិនិត្យអ្នកជាអ្នកជំងឺទៀតទេ។

ការបង់ប្រាក់

អ្នក**មិន**ចាំបាច់ត្រូវបង់ថ្លៃសេវាដែលត្រូវបានរ៉ាប់រងទេ។ ក្នុងករណីភាគច្រើន អ្នកនឹងមិនទទួលវិក័យប័ត្រពីអ្នកផ្តល់សេវាទេ។ អ្នកត្រូវតែបង្ហាញប័ណ្ណអត្តសញ្ញាណ Kaiser Permanente ប័ណ្ណអត្តសញ្ញាណ L.A. Care Health Plan របស់អ្នក Medi-Cal BIC របស់អ្នក នៅពេលអ្នកទទួលយកសេវាថែទាំសុខភាព ឬវេជ្ជបញ្ជា។ ប័ណ្ណអែឌីរបស់អ្នកនឹងប្រាប់វេជ្ជបណ្ឌិតរបស់អ្នកអំពីកន្លែងដើម្បីនឹងផ្ញើរវិក័យប័ត្រ។ អ្នកអាចនឹងទទួលបានការពន្យល់ពីអត្ថប្រយោជន៍ (Explanation of Benefits, "EOB") ពីយើង ឬសេចក្តីថ្លែងការណ៍ពី ឬអ្នកផ្តល់សេវា។ EOB និងសេចក្តីថ្លែងការណ៍មិនមែនជាវិក័យប័ត្រទេ។

ប្រសិនបើអ្នកទទួលបានមួយច្បាប់ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ ប្រាប់យើងពីចំនួនទឹកប្រាក់ដែលត្រូវបានគិតថ្លៃ កាលបរិច្ឆេទនៃសេវា និងមូលហេតុនៃវិក័យប័ត្រ។ អ្នក **មិន** មានទំនួលខុសត្រូវក្នុងការបង់ថ្លៃដល់អ្នកផ្តល់សេវា ក្នុងចំនួនទឹកប្រាក់ណាមួយ ដែលត្រូវបានជំពាក់ដោយ Kaiser Permanente សម្រាប់សេវាដែលត្រូវបានរ៉ាប់រងទេ។

ប្រសិនបើអ្នកទទួលបានវិក្កយបត្រពីឱសថស្ថានសម្រាប់ឱសថតាមវេជ្ជបញ្ជា ការផ្គត់ផ្គង់ឬថ្នាំគ្រាប់ សូមទូរស័ព្ទទៅផ្នែកសេវាអតិថិជន Medi-Cal Rx តាមលេខ **1-800-977-2273** 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **711** ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច។ អ្នកក៏អាចចូលទៅកាន់គេហទំព័រ Medi-Cal Rx សម្រាប់ព័ត៌មាននៅ **https://medi-calrx.dhcs.ca.gov/home/** (ជាភាសាអង់គ្លេស) អ្នកត្រូវតែទទួលបានការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) មុនពេលអ្នកទៅកាន់អ្នកផ្តល់សេវាក្រៅបណ្តាញ លើកលែងតែពេលដែលអ្នកត្រូវការ៖

- ការថែទាំសង្គ្រោះបន្ទាន់។
- ការថែទាំនៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក
  - នៅក្នុងតំបន់លំនៅដ្ឋាន អ្នកត្រូវតែទទួលការអនុញ្ញាតជាមុនដើម្បីទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញ សម្រាប់ការថែទាំជាបន្ទាន់។
- ការថែទាំសម្ងាត់

ប្រសិនបើអ្នកមិនទទួលបានការយល់ព្រមជាមុនទេ អ្នកប្រហែលជាត្រូវបង់ប្រាក់សម្រាប់ការថែទាំ ពីអ្នកផ្តល់សេវាដែលនៅក្រៅបណ្តាញ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីសេវាថែទាំគ្រោះអាសន្ន ការថែទាំបន្ទាន់ និងការថែទាំសម្ងាត់ សូមចូល ទៅចំណងជើងទាំងនោះក្នុងជំពូកនេះ។

ប្រសិនបើអ្នកត្រូវការសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលត្រូវបានរ៉ាប់រងដោយ Medi-Cal ដែលមិនមាននៅក្នុងបណ្តាញ Kaiser Permanente យើងនឹងយល់ព្រមហើយបញ្ជូនអ្នកទៅអ្នកផ្តល់សេវាក្រៅបណ្តាញដើម្បីទទួលបានសេវាទាំងនោះ។

ប្រសិនបើអ្នកទទួលបានវិក័យប័ត្រ ឬត្រូវបានស្នើសុំឲ្យបង់ប្រាក់សហការ ដែលអ្នកជឿថាអ្នកមិនគួរត្រូវធ្វើទេ អ្នកអាចដាក់ពាក្យទាមទារសំណង។ អ្នកនឹងត្រូវប្រាប់យើងជាលាយលក្ខណ៍អក្សរថា ហេតុអ្វីបានជាអ្នកត្រូវបង់ប្រាក់សម្រាប់ទំនិញឬសេវានោះ។ យើងនឹងអានពាក្យទាមទារសំណងរបស់អ្នក ហើយសម្រេចចិត្តថាតើអ្នកអាចទទួលបានប្រាក់វិញឬទេ។ អ្នកអាចទទួលបានទម្រង់បែបបទទាមទារសំណងតាមអនឡាញនៅ **kp.org** (ជាភាសាអង់គ្លេស)។ លោកអ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងតាមរយៈលេខ **1-800-464-4000** (TTY **711**)។ យើងនឹងរីករាយក្នុងការជួយអ្នក ប្រសិនបើអ្នកត្រូវការជំនួយបំពេញសំណុំបែបបទទាមទារសំណងរបស់យើង។

ប្រសិនបើអ្នកទទួលបានសេវាកម្មនៅក្នុងប្រព័ន្ធកិច្ចការអតីតយុទ្ធជន ឬសេវាកម្មដែលមិនមានការរ៉ាប់រង ឬគ្មានការអនុញ្ញាតដែលទទួលបាននៅខាងក្រៅរដ្ឋកាលីហ្វ័រញ៉ា អ្នកអាចនឹងទទួលខុសត្រូវចំពោះការបង់ប្រាក់។

ការបញ្ជូន

វេជ្ជបណ្ឌិតរបស់អ្នកនឹងផ្តល់ឲ្យអ្នកនូវការបញ្ជូនបន្ត ដើម្បីបញ្ជូនអ្នកទៅអ្នកឯកទេសប្រសិនបើអ្នកត្រូវការ។ អ្នកឯកទេសគឺជាវេជ្ជបណ្ឌិតដែលមានការអប់រំបន្ថែមនៅក្នុងផ្នែកមួយនៃវេជ្ជសាស្ត្រ។ វេជ្ជបណ្ឌិតរបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បីជ្រើសរើសអ្នកឯកទេស។ ការិយាល័យវេជ្ជបណ្ឌិត របស់អ្នកអាចជួយអ្នកក្នុងការរៀបចំពេលវេលាដើម្បីជួបអ្នកឯកទេស។

ឧទាហរណ៍នៃសេវាដែលត្រូវការការបញ្ជូនរួមមាន៖

- ការសម្រាកនៅមន្ទីរពេទ្យដែលមិនមែនជាផ្នែកការថែទាំជាបន្ទាន់
- ការវះកាត់
- ផ្នែកគ្រោងឆ្អឹង
- ផ្នែកបេះដូង
- ផ្នែកជំងឺមហារីក
- ផ្នែកជំងឺស្បែក
- ការព្យាបាលដោយចលនា វិជ្ជាជីវៈ និងការនិយាយ
- ការសម្រាកនៅប្រភេទនៃទីកន្លែងដូចតទៅ៖
  - ការថែទាំនៅមន្ទីរថែទាំដោយគិលានុប្បដ្ឋាកជំនាញ
  - មន្ទីរសម្រាប់ជម្ងឺធ្ងន់ធ្ងរ
  - មន្ទីរសម្រាប់ជម្ងឺធ្ងន់ធ្ងររបស់កុមារ
  - មន្ទីរថែទាំជម្ងឺមធ្យម
- ការព្យាបាលឯកទេស

ម៉្យាងទៀត PCP របស់អ្នកត្រូវតែធ្វើការបញ្ជូនអ្នកមុនពេលអ្នកអាចទទួលបានការថែទាំ ពីអ្នកផ្តល់សេវាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្នែកជំងឺអូធីសឹម។

ប្រសិនបើអ្នកមានបញ្ហាសុខភាពដែលត្រូវការការថែទាំវេជ្ជសាស្ត្រពិសេសរយៈពេលយូរ អ្នកប្រហែលជាត្រូវការការបញ្ជូនជាអចិន្ត្រៃយ៍។ នេះមានន័យថាអ្នកអាចទៅជួបគ្រូពេទ្យឯកទេសដដែលនោះច្រើនជាងមួយដង ដោយមិនត្រូវការការបញ្ជូនរៀងរាល់ពេល។

ប្រសិនបើអ្នកមានបញ្ហាក្នុងការទទួលបានការបញ្ជូន ឬចង់បានគោលការណ៍ការបញ្ជូនមួយច្បាប់របស់ Kaiser Permanente សូមទូរស័ព្ទទៅ **1-800-464-4000** (TTY **711**)។

អ្នកមិនត្រូវការការបញ្ជូនទេសម្រាប់៖

- ការជួបជាមួយ PCP
- អ្នកឯកទេសទូទៅផ្នែកព្យាបាលមនុស្សពេញវ័យ វេជ្ជបណ្ឌិតប្រចាំគ្រួសារ និងវេជ្ជបណ្ឌិតជំងឺកុមារ
- វេជ្ជបណ្ឌិតឯកទេសភ្នែក
- សេវាសុខភាពផ្លូវចិត្តសម្រាប់ស្ថានភាពវេជ្ជសាស្ត្រស្រាលរហូតដល់មធ្យម រួមទាំងការវាយតម្លៃ សុខភាពផ្លូវចិត្ត
- ការទៅជួបពេទ្យផ្នែកសម្ភព-រោគស្ត្រី (Obstetrics/Gynecology, "OB/GYN")
- ការថែទាំបន្ទាន់
- សេវាកម្មសម្ងាត់សម្រាប់មនុស្សពេញវ័យ ដូចជាការថែទាំការរំលោភផ្លូវភេទ
- ការថែទាំសង្គ្រោះបន្ទាន់។
- សេវាកម្មការធ្វើផែនការគ្រួសារ (ដើម្បីស្វែងយល់បន្ថែម ហៅទូរស័ព្ទទៅសេវាពត៌មាន និងការបញ្ជូននៃការិយាល័យផែនការគ្រួសារលេខ **1-800-942-1054**)
- ការធ្វើតេស្តនិងការប្រឹក្សាយោបល់មេរោគ HIV (អាយុ 12 ឆ្នាំឡើងទៅ)
- សេវាសម្រាប់ជំងឺឆ្លងតាមការរួមភេទ (អាយុ 12 ឆ្នាំឡើងទៅ)
- សេវាចាប់សរសៃនិងសន្លាក់ (ការបញ្ជូននឹងត្រូវអាចបានតម្រូវដោយ FQHC និង RHC និង IHCP ដែលនៅក្រៅបណ្តាញ)

អនីតិជនក៏អាចទទួលបានសេវាសុខភាពផ្លូវចិត្តសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យជាក់លាក់ សេវាថែទាំសម្ងាត់ និងសេវាព្យាបាលរបិត្តិការប្រើប្រាស់សារធាតុញៀន ដោយមិនត្រូវការការយល់ព្រមពីឪពុកម្តាយរបស់ពួកគេ។ សេវាការព្យាបាលរបិត្តប្រើប្រាស់គ្រឿងញៀនមិនត្រូវបានរ៉ាប់រងនៅក្រោមសៀវភៅ ណែនាំសមាជិកនេះទេ។ វាត្រូវបានរ៉ាប់រងដោយផែនការសុខភាពផ្លូវចិត្តខោនធី។

មិនមែនសេវាសុខភាពផ្លូវចិត្តមិនសម្រាកមន្ទីរពេទ្យទាំងអស់ត្រូវបានរាប់រងនៅក្រោមសៀវភៅណែនាំសមាជិកនេះទេ។ សូមមើលចំណងជើង "សេវាសុខភាពផ្លូវចិត្ត" ក្នុងជំពូកទី 4 សម្រាប់ព័ត៌មានបន្ថែមទៅលើអ្វី ដែលត្រូវបានរាប់រង។

ទោះបីជាការបញ្ជូន ឬការយល់ព្រមជាមុនមិនត្រូវបានតម្រូវដើម្បីទទួលបានការថែទាំភាគច្រើនពីអ្នកផ្តល់សេវាទាំងនេះក៏ដោយ អ្នកអាចត្រូវការការបញ្ជូនមួយក្នុងស្ថានភាពខាងក្រោម៖

- អ្នកផ្តល់សេវាអាចត្រូវតែមានការយល់ព្រមជាមុនសម្រាប់សេវាមួយចំនួន
- អ្នកផ្តល់សេវាអាចត្រូវតែបញ្ជូនអ្នកទៅគ្រូពេទ្យឯកទេសដែលមានប្រវត្តិពិនិត្យព្យាបាល ពាក់ព័ន្ធនឹងជម្ងឺ ឬស្ថានភាពរបស់អ្នក

ចង់ឈប់ជក់បារីឬ? សូមទូរស័ព្ទទៅលេខ 800-NO-BUTTS (800-662-8887) ដើម្បីស្វែងរកពីរបៀប។ ឬចូលទៅ www.nobutts.org (ជាភាសាអង់គ្លេស)។

ការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)

សំរាប់ការថែទាំប្រភេទមួយចំនួន PCP ឬគ្រូពេទ្យឯកទេសរបស់អ្នកនឹងត្រូវស្នើសុំឲ្យ Southern California Permanente Medical Group ឲ្យមានការអនុញ្ញាតិមុននឹងអ្នកទទួលបានការថែទាំ។ នេះត្រូវបានគេហៅថាការស្នើសុំការអនុញ្ញាតមុន ការយល់ព្រមមុន ឬការយល់ព្រមជាមុន។ វាមានន័យថា Southern California Permanente Medical Group ត្រូវប្រាកដថាការថែទាំគឺជាភាពចាំបាច់ខាងវេជ្ជសាស្ត្រឬត្រូវការចាំបាច់។

ការថែទាំគឺចាំបាច់ខាងវេជ្ជសាស្ត្រ
ប្រសិនបើវាសមហេតុផលនិងចាំបាច់ក្នុងការការពារជីវិតរបស់អ្នក ជួយអ្នកកុំឲ្យធ្លាក់ខ្លួនឈឺឬពិការធ្ងន់ធ្ងរ ឬបន្ថយការឈឺចាប់ខ្លាំងពីរោគា ជំងឺឬ របួសដែលត្រូវបានធ្វើរោគវិនិច្ឆ័យ។ សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្ររួមមានការថែទាំដែលត្រូវការដើម្បីជួសជុល ឬជួយសម្រាលជំងឺ ឬស្ថានភាពផ្លូវចិត្ត។

ខាងក្រោមនេះគឺជាឧទាហរណ៍នៃសេវាដែលតែងតែត្រូវការការយល់ព្រមជាមុន៖

- សេវាចាក់ម្ជុលវិទ្យាសាស្ត្រនៅពេលអ្នកត្រូវការ នៅពេលអ្នកត្រូវទៅជួបលើសពីពីរដងក្នុងមួយខែ
- សេវាមនុស្សពេញវ័យតាមសហគមន៍ (Community-Based Adult Services, "CBAS")
- ថ្នាំស្លឹកសម្រាប់ធ្មេញ
- បរិក្ខារវេជ្ជសាស្ត្រប្រើជាប់បានយូរ
- ការថែទាំសុខភាពនៅផ្ទះ
- សម្ភារៈផ្គត់ផ្គង់ការរះរន្ធលាមក និងតម្រងនោម

- ឧបករណ៍សិប្បនិម្មិត និងសម្រាប់តម្រង់ឆ្អឹងជើង
- សេវាកម្មដែលមិនអាចរកបានពីអ្នកផ្តល់សេវាក្នុងបណ្តាញ
- ការរះកាត់ប្តូរសរីរាង្គឬជាលិកា
- សេវាក្រៅបណ្តាញ រួមបញ្ចូលទាំងការសំរាកព្យាបាលក្នុងមន្ទីរពេទ្យ ក្រោយពីស្ថានភាពរបស់អ្នកមានភាពនឹងនរ

សម្រាប់សេវាមួយចំនួន អ្នកត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)។ នៅក្រោមក្រមសុខភាពនិងសុវត្ថិភាព (Health and Safety Code) 1367.01(h)(1) Southern California Permanente Medical Group នឹងសំរេចការអនុញ្ញាតជាមុន (ការអនុញ្ញាតជាមុន) ជាប្រចាំក្នុងរយៈពេល 5 ថ្ងៃនៃថ្ងៃធ្វើការ នៅពេលដែល Southern California Permanente Medical Group ទទួលបានព័ត៌មានចាំបាច់ដែលសមហេតុផលដើម្បីសម្រេចចិត្ត។

ចំពោះសំណើសុំដែលអ្នកផ្តល់សេវាចង្អុលបង្ហាញ ឬអ្នកត្រូវបានចាត់តាំងដែលជាក្រុមវេជ្ជសាស្ត្រ កំណត់ថាការអនុលោមតាមពេលវេលាស្តង់ដារអាចបង្កអន្តរាយធ្ងន់ធ្ងរដល់អាយុជីវិត ឬសុខភាព ឬសមត្ថភាពក្នុងការទទួលបាន ថែរក្សា ឬទទួលបានឡើងវិញនូវមុខងារអតិបរិមា Southern California Permanente Medical Group នឹងធ្វើការសំរេចចិត្តការអនុញ្ញាតបន្ទាន់ (លឿន)។ យើងនឹងផ្តល់សេចក្តីជូនដំណឹងឲ្យបានឆាប់រហ័សតាមតម្រូវការសុខភាពរបស់អ្នក ហើយមិនឲ្យលើសពី 72 ម៉ោង បន្ទាប់ពីទទួលបានសំណើសេវា។ សំណើសុំការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ត្រូវបានពិនិត្យដោយបុគ្គលិកគ្លីនិក ឬពេទ្យ ដូចជាវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាជាដើម។

Kaiser Permanente **មិន** បង់ថ្លៃអ្នកត្រួតពិនិត្យដើម្បីបដិសេធការជានាវ៉ាប់រងឬសេវាទេ។ យើងនឹងផ្ញើជូនអ្នកនូវលិខិតជូនដំណឹងអំពីសកម្មភាព (Notice of Action, "NOA") របស់ Southern California Permanente Medical Group មិនយល់ព្រមលើសំណើរបស់អ្នកទេ។ លិខិត NOA នឹងប្រាប់អ្នកពីរបៀបដាក់បណ្តឹងឧទ្ធរណ៍ ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសំរេចនោះ។

យើងនឹងទំនាក់ទំនងអ្នកប្រសិនបើ Southern California Permanente Medical Group ត្រូវការព័ត៌មានបន្ថែម ឬពេលវេលាបន្ថែមទៀតដើម្បីពិនិត្យមើលសំណើរបស់អ្នក។

អ្នកមិនត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) សម្រាប់ការថែទាំសង្គ្រោះបន្ទាន់ ទោះបីជាវានៅក្រៅបណ្តាញ ឬនៅខាងក្រៅតំបន់ផ្ទះរបស់អ្នកក៏ដោយ។ អ្នកមិនត្រូវការការយល់ព្រមជាមុនទេ សម្រាប់ការថែទាំបន្ទាន់នៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នក។ នេះរួមបញ្ចូលទាំងការឈឺពោះនិងសម្រាលកូន ប្រសិនបើអ្នកមានផ្ទៃពោះ។ អ្នកមិនត្រូវការការយល់ព្រមជាមុននោះទេ (ការអនុញ្ញាតជាមុន) សម្រាប់ការថែទាំសម្ងាត់បំផុត។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាសម្ងាត់ សូមចូលទៅផ្នែក "ការថែទាំសម្ងាត់" ក្នុងជំពូកនេះ។

សម្រាប់បញ្ជីពេញលេញនៃសេវាដែលតម្រូវឲ្យមានការយល់ព្រមជាមុន និងលក្ខណៈវិនិច្ឆ័យ ដែលត្រូវបានប្រើដើម្បីធ្វើការសម្រេចចិត្តអនុញ្ញាត សូមចូលទៅគេហទំព័ររបស់យើងនៅ **kp.org/UM**

(ជាភាសាអង់គ្លេស) ឬហៅទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

មតិទីពីរ

អ្នកប្រហែលជាចង់បានមតិទីពីរអំពីការថែទាំដែលអ្នកផ្តល់សេវារបស់អ្នកនិយាយថាអ្នកត្រូវការ ឬអំពីការធ្វើរោគវិនិច្ឆ័យ ឬផែនការព្យាបាលរបស់អ្នក។ ឧទាហរណ៍អ្នកអាចត្រូវការមតិទីពីរ ប្រសិនបើអ្នកមិនប្រាកដថា អ្នកត្រូវការការព្យាបាលតាមវេជ្ជបញ្ជា ឬការវះកាត់ ឬអ្នកបានព្យាយាមធ្វើតាមផែនការព្យាបាលហើយវាមិនដំណើរការ។

ដើម្បីទទួលបានមតិទីពីរ សូមទូរស័ព្ទទៅ PCP របស់អ្នក។ PCP របស់អ្នកអាចបញ្ជូនអ្នកទៅកាន់អ្នកផ្តល់សេវាក្នុងបណ្តាញដែលជាអ្នកជំនាញវេជ្ជសាស្ត្រដែលមានសិទ្ធសមស្របសម្រាប់ស្ថានភាពវេជ្ជសាស្ត្ររបស់អ្នកសម្រាប់មតិទីពីរ។ អ្នកក៏អាចទូរស័ព្ទមកមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក លេខ **1-800-464-4000** (TTY **711**) ដើម្បីជួយអ្នករៀបចំការបញ្ជូនមួយជាមួយអ្នកផ្តល់សេវាក្នុងបណ្តាញ។

យើងនឹងបង់ថ្លៃសម្រាប់មតិទីពីរ ប្រសិនបើអ្នកឬអ្នកផ្តល់សេវាក្នុងបណ្តាញអ្នកស្នើសុំវា ហើយអ្នកទទួលបានមតិទីពីរនោះពីអ្នកផ្តល់សេវាក្នុងបណ្តាញ។ អ្នកមិនត្រូវការការអនុញ្ញាតពីយើងដើម្បីទទួលបានមតិទីពីរពីអ្នកផ្តល់សេវាក្នុងបណ្តាញទេ។

ប្រសិនបើមិនមានអ្នកផ្តល់សេវាក្នុងបណ្តាញដែលជាអ្នកឯកទេសវេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិ សមរម្យសម្រាប់លក្ខខណ្ឌរបស់អ្នកទេ នោះផ្នែកសេវាសមាជិកនឹងជួយអ្នករៀបចំ ការពិគ្រោះយោបល់ជាមួយអ្នកផ្តល់សេវាក្រៅបណ្តាញសម្រាប់មតិទីពីរ។ ប្រសិនបើយើងបញ្ជូនអ្នកទៅកាន់អ្នកផ្តល់សេវាក្រៅបណ្តាញ សម្រាប់មតិទីពីរ យើងនឹងបង់ប្រាក់សម្រាប់មតិទីពីរ។ យើងនឹងប្រាប់អ្នកក្នុងរយៈពេល 5 ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើអ្នកផ្តល់សេវាដែលអ្នកជ្រើសរើសសម្រាប់មតិទីពីរត្រូវបានយល់ព្រម។ ប្រសិនបើអ្នកមានជម្ងឺរ៉ាំរ៉ៃ ឬធ្ងន់ធ្ងរ ឬប្រឈមមុខនឹងការគម្រាមកំហែងភ្លាមៗនិងធ្ងន់ធ្ងរចំពោះ សុខភាពរបស់អ្នក រួមទាំង តែមិនកំណត់តែចំពោះការបាត់បង់ជីវិត អាវៈយវៈ ឬផ្នែកនៃរាងកាយ ឬមុខងាររាងកាយដែលសំខាន់ យើងនឹងសម្រេចចិត្តក្នុងអំឡុងពេល 72 ម៉ោង។

ប្រសិនបើយើងបដិសេធការស្នើសុំរបស់អ្នកសម្រាប់មតិទីពីរ អ្នកអាចដាក់ពាក្យបណ្តឹងសារទុក្ខមួយ។ ដើម្បីស្វែងយល់បន្ថែមអំពីបណ្តឹងសារទុក្ខ សូមចូលទៅកាន់ផ្នែក "ពាក្យបណ្តឹង" នៅក្នុងជំពូកទី 6 ("ការរាយការណ៍ និងការដោះស្រាយបញ្ហា") នៅក្នុងសៀវភៅណែនាំសមាជិកនេះ។

ការថែទាំសម្ងាត់

សេវាត្រូវបានយល់ព្រមសម្រាប់អនីតិជន

អ្នកអាចទទួលបានតែសេវាដូចខាងក្រោមដោយគ្មានការអនុញ្ញាតរបស់ឪពុកម្តាយ ឬ អាណាព្យាបាលរបស់អ្នក ប្រសិនបើអ្នកមានអាយុ 12 ឆ្នាំឡើងទៅ៖

- សុខភាពផ្លូវចិត្តសម្រាប់ជំងឺមិនសម្រាកនៅពេទ្យ៖
  - ការរំលោភបំពានផ្លូវភេទ (គ្មានកម្រិតសម្រាប់អាយុទាប)
  - ទំនាក់ទំនងផ្លូវភេទជាមួយសាច់ញាតិបង្កើត
  - ការវាយបំពានរូបរាងកាយ
  - ការរំលោភបំពានកុមារ
  - នៅពេលអ្នកបានគិតអំពីការធ្វើបាបខ្លួនឯង ឬអ្នកដទៃទៀត
- ការការពារ/ការធ្វើតេស្ត/ការព្យាបាល HIV/AIDS
- ការការពារ/ការធ្វើតេស្ត/ការព្យាបាលរោគចម្លងពីការរួមភេទ
- សេវាព្យាបាលរបិតិនៃការប្រើប្រាស់គ្រឿងញៀន
  - ការព្យាបាលរបិតប្រើប្រាស់គ្រឿងញៀនគឺមិនត្រូវបានរ៉ាប់រងនៅក្រោមសៀវភៅណែនាំសមាជិកទេ។ អ្នកត្រូវតែទទួលសេវាពីផែនការសុខភាពផ្លូវចិត្តខោនធីក្នុងខោនធីដែលអ្នករស់នៅ។ សូមចូលទៅកាន់ចំណងជើង "សេវាព្យាបាលរបិតិការប្រើប្រាស់គ្រឿងញៀន" នៅក្រោមផ្នែក "កម្មវិធី និងសេវា Medi-Cal ផ្សេងទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" សម្រាប់ព័ត៌មានបន្ថែម។

ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ អ្នកអាចទៅជួបវេជ្ជបណ្ឌិតដោយគ្មានការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល សម្រាប់ប្រភេទទាំងនេះនៃការថែទាំសុខភាព៖

- ការធ្វើតេស្តនិងការប្រឹក្សាអំពីការមានផ្ទៃពោះ
- ការធ្វើផែនការគ្រួសារ/ការពន្យាកំណើត (រួមទាំងការក្រៀវ)
- សេវាពន្លូតកូន
- ការថែទាំការបំពានផ្លូវភេទ

សម្រាប់សេវាធ្វើតេស្តការមានផ្ទៃពោះ ផែនការគ្រួសារឬពន្យារកំណើត ឬសេវាការពារមិនឲ្យមានកូន ឬ សេវាសម្រាប់ជម្ងឺចម្លងពីការរួមភាម វេជ្ជបណ្ឌិតឬគ្លីនិក មិនចាំបាច់ជាផ្នែកនៃបណ្តាញ Kaiser Permanente ទេ។ អ្នកអាចជ្រើសយកអ្នកផ្តល់សេវា Medi-Cal ណាមួយ ដោយមិនចាំបាច់មានលិខិតបញ្ជូន ឬការអនុញ្ញាតជាមុនឡើយ។ អ្នកក៏អាចទទួលបានសេវាទំនាក់ទំនងនឹងរោគចម្លងមកពីការរួមភេទ ពីអ្នកផ្តល់សេវាផែនការពន្យាគ្រួសាររបស់ Medi-Cal។

សម្រាប់សេវាដែលបានយល់ព្រមសម្រាប់អនិតិជនដែលមិនមែនជាសេវាសុខភាពផ្លូវចិត្តឯកទេស អ្នកអាចជួបអ្នកផ្តល់សេវាថែទាំក្នុងបណ្តាញ ដោយគ្មានលិខិតបញ្ជូននិងដោយគ្មានការអនុញ្ញាតជាមុន។ PCP របស់អ្នកមិនចាំបាច់បញ្ជូនអ្នក ហើយអ្នកមិនត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ពីយើងដើម្បីទទួលបានសេវាដែលបានយល់ព្រមសម្រាប់អនិតិជនដែលត្រូវបានរ៉ាប់រង នៅក្រោមសៀវភៅណែនាំសមាជិកនេះឡើយ។ អនីតិជនអាចពិគ្រោះជាមួយអ្នកតំណាងដោយសម្ងាត់ អំពីកង្វល់សុខភាពរបស់ខ្លួនដោយទូរស័ព្ទទៅលេខ **1-833-574-2273** (TTY **711**)។

សេវាត្រូវបានយល់ព្រមសម្រាប់អនិតិជនដែលជាសេវាសុខភាពផ្លូវចិត្តឯកទេស គឺមិនត្រូវបានរ៉ាប់រងក្រោមសៀវភៅណែនាំសមាជិកនេះឡើយ។ សេវាសុខភាពផ្លូវចិត្តឯកទេសត្រូវបានរ៉ាប់រងដោយផែនការសុខភាពផ្លូវចិត្តខោនធី សម្រាប់ខោនធីដែលអ្នករស់នៅ។

សេវាពីអ្នកផ្តល់សេវាក្រៅបណ្តាញដែលមិនទាក់ទងនឹងការថែទាំសម្ងាត់ អាចនឹងមិនត្រូវបានរ៉ាប់រងឡើយ។ សម្រាប់ជំនួយស្វែងរកអ្នកផ្តល់សេវា Medi-Cal ដែលស្ថិតនៅក្រៅបណ្តាញ Kaiser Permanente ឬដើម្បីស្នើសុំជំនួយការដឹកជញ្ជូនដើម្បីទៅជួបអ្នកផ្តល់សេវា សូមទូរស័ព្ទទៅ មជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

អនីតិជនអាចពិគ្រោះជាមួយអ្នកតំណាងដោយសម្ងាត់ អំពីកង្វល់សុខភាពរបស់ខ្លួនដោយទូរស័ព្ទទៅលេខ **1-833-574-2273** (TTY **711**) និងពិគ្រោះជាមួយអ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

ការថែទាំសម្ងាត់សម្រាប់មនុស្សពេញវ័យ

ជាមនុស្សពេញវ័យ (អាយុ 18 ឆ្នាំឡើងទៅ) អ្នកប្រហែលជាមិនចង់ទៅជួប PCP របស់អ្នកសម្រាប់ការថែទាំសម្ងាត់ជាក់លាក់ ឬមានលក្ខណៈឯកជននោះទេ។ បើដូច្នេះ អ្នកអាចជ្រើសរើសវេជ្ជបណ្ឌិត ឬគ្លីនិកសម្រាប់ការថែទាំប្រភេទខាងក្រោម៖

- ការធ្វើផែនការគ្រួសារ/ពន្យារកំណើត (រួមទាំងសេវាការក្រៀវ)
- ការធ្វើតេស្ត និងការប្រឹក្សាអំពីការមានផ្ទៃពោះ
- ការការពារ/ការធ្វើតេស្ត/ការព្យាបាល HIV/AIDS
- ការការពារ/ការធ្វើតេស្ត/ការព្យាបាលរោគចម្លងពីការរួមភេទ
- ការថែទាំការបំពានផ្លូវភេទ
- សេវារំលូតកូនសម្រាប់អ្នកជំងឺមិនសម្រាកនៅពេទ្យ

សម្រាប់សេវាធ្វើតេស្តការមានផ្ទៃពោះ ផែនការគ្រួសារឬពន្យារកំណើត ឬសេវាការពារមិនឲ្យមានកូន ឬ សេវាសម្រាប់ជម្ងឺចម្លងពីការរួមភាម វេជ្ជបណ្ឌិតឬគ្លីនិក មិនចាំបាច់ជាផ្នែកនៃបណ្តាញ Kaiser Permanente ទេ។ អ្នកអាចជ្រើសយកអ្នកផ្តល់សេវា Medi-Cal ណាមួយដោយមិនចាំបាច់មានលិខិតបញ្ជូន ឬការអនុញ្ញាតជាមុនឡើយ។ សម្រាប់ជំនួយស្វែងរកអ្នកផ្តល់សេវា Medi-Cal ដែលស្ថិតនៅក្រៅបណ្តាញ Kaiser Permanente សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង លេខ **1-800-464-4000** (TTY **711**)។

ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក KP លេខ **1-800-464-4000** (TTY **711**)។
ការទូរស័ព្ទនេះគឺមិនគិតថ្លៃ។ ពួកយើងនៅទីនេះ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងថ្ងៃឈប់សម្រាកដែលបិទ)។ ចូលទៅអនឡាញនៅ **kp.org** (ជាភាសាអង់គ្លេស)

សម្រាប់សេវាសម្ងាត់មនុស្សពេញវ័យដទៃទៀតទាំងអស់ អ្នកអាចជួបជាមួយអ្នកផ្តល់សេវាបណ្តាញ ដោយគ្មានលិខិតបញ្ជូនឬ ការអនុញ្ញាតជាមុន។ PCP របស់អ្នកមិនចាំបាច់បញ្ជូនអ្នក ហើយអ្នកមិនចាំបាច់ទទួលបានការយល់ព្រមមុន (ការអនុញ្ញាតជាមុន) ពីយើងដើម្បីទទួលការថែទាំសម្ងាត់សម្រាប់មនុស្សពេញវ័យ ដែលត្រូវបានរ៉ាប់រងដោយយើងឡើយ។

សេវាកម្មពីអ្នកផ្តល់សេវាក្រៅបណ្តាញដែលមិនទាក់ទងនឹងការថែទាំសម្ងាត់ អាចនឹងមិនត្រូវបានរ៉ាប់រងឡើយ។ សម្រាប់ជំនួយស្វែងរកវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាដែលផ្តល់សេវាទាំងនេះ ឬសម្រាប់ការដឹកញ្ជូនទៅទទួលបានសេវាទាំងនេះ អ្នកអាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក លេខ **1-800-464-4000** (TTY **711**)។ អ្នកក៏អាចទូរស័ព្ទទៅ **1-833-574-2273** និងពិគ្រោះជាមួយអ្នកជំនាញថែទាំសុខភាពមានអាជ្ញាប័ណ្ណ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ ។

ការជំទាស់ផ្នែកសីលធម៌

អ្នកផ្តល់សេវាខ្លះមានការជំទាស់ផ្នែកសីលធម៌ចំពោះសេវាដែលបានរ៉ាប់រងមួយចំនួន។ នេះមានន័យថាពួកគេមានសិទ្ធិ មិនផ្តល់សេវាដែលត្រូវបានរ៉ាប់រងមួយចំនួន ប្រសិនបើពួកគេមិនយល់ស្របទៅនឹងសីលធម៌ជាមួយសេវាទាំងនោះ។ ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកមានការជំទាស់ខាងសីលធម៌ ពួកគេនឹងជួយអ្នករកអ្នកផ្តល់សេវា ផ្សេងទៀតដែលនឹងផ្តល់នូវសេវាដែលអ្នកត្រូវការ។ Kaiser Permanente ក៏អាចធ្វើការជាមួយអ្នកដើម្បីស្វែងរកអ្នកផ្តល់សេវាបានដែរ។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបញ្ជូនទៅកាន់អ្នកផ្តល់សេវាផ្សេង សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក **1-800-464-4000** (TTY **711**)។

មន្ទីរពេទ្យមួយចំនួននិងអ្នកផ្តល់សេវាផ្សេងទៀតមិនផ្តល់ជូននូវសេវាមួយឬច្រើនក្នុងចំណោមសេវាដូចខាងក្រោម ដែលអាចត្រូវបានរ៉ាប់រងក្រោមកិច្ចសន្យាផែនការរបស់អ្នក ហើយអ្នកឬសមាជិកគ្រួសាររបស់អ្នកអាចត្រូវការ៖

- **ការធ្វើផែនការគ្រួសារ**
- **សេវាថ្នាំពន្យារកំណើត រួមទាំងការពន្យាកំណើតបន្ទាន់**
- **ការក្រៀវ រួមទាំងការចងដៃស្ត្រីនៅពេលឈឺពោះនិងសម្រាលកូន**
- **ការព្យាបាលភាពគ្មានកូន**
- **ការរំលូតកូន**

អ្នកគួរតែទទួលបានព័ត៌មានបន្ថែមមុនពេលអ្នកចុះឈ្មោះ។ ហៅទូរស័ព្ទទៅវេជ្ជបណ្ឌិត ក្រុមវេជ្ជសាស្ត្រ សមាគមអនុវត្តន៍ឯករាជ្យ ឬគ្លីនិករបស់អ្នក ឬទូរស័ព្ទមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក លេខ 1-800-464-4000 (TTY 711) ដើម្បីធានាថាអ្នកអាចទទួលបានសេវាថែទាំសុខភាពដែលអ្នកត្រូវការ។

សេវាទាំងនេះមានសម្រាប់អ្នក ហើយយើងត្រូវតែធានាថាអ្នក ឬសមាជិកគ្រួសាររបស់អ្នកជួបអ្នកផ្តល់សេវា ឬត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដែលនឹងអនុវត្តសេវាដែលមានការរ៉ាប់រងនោះ។

សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**) ប្រសិនបើអ្នកមានសំណួរ ឬត្រូវការស្វែងរកអ្នកផ្តល់សេវា។

ការថែទាំបន្ទាន់

ការថែទាំបន្ទាន់គឺ **មិនមែន** សម្រាប់ស្ថានភាពប៉ះពាល់ដល់ជីវិត ឬអាសន្នឡើយ។ វាគឺសម្រាប់សេវាដែលអ្នកត្រូវការដើម្បីការពារការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នក មកពីជំងឺភ្លាមៗ ការរងរបួស ឬភាពស្មុគស្មាញនៃជម្ងឺដែលអ្នកមានរួចហើយ។ ការណាត់ជួបសម្រាប់ការថែទាំបន្ទាន់ភាគច្រើនមិនត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) នោះទេ និងអាចរកបានក្នុងរយៈពេល 48 ម៉ោងបន្ទាប់ពីការស្នើសុំរបស់អ្នក។ ប្រសិនបើសេវាថែទាំបន្ទាន់ដែលអ្នកត្រូវការតម្រូវអោយមានការយល់ព្រមជាមុន
អ្នកនឹងត្រូវបានផ្តល់ជូនការណាត់ជួបក្នុងរយៈពេល 96 ម៉ោងបន្ទាប់ពីការស្នើសុំរបស់អ្នក។

តំរូវការសំរាប់ការព្យាបាលបន្ទាន់អាចជាជំងឺផ្តាសាយ ឈឺបំពង់ក ក្តៅខ្លួន ឈឺត្រចៀក ក្រែចសាច់ដុំ រឺសេវាសម្ភព។ សម្រាប់ការថែទាំបន្ទាន់ ទូរស័ព្ទទៅ **1-833-574-2273** (TTY **711**) ហើយនិយាយជាមួយអ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

អ្នកត្រូវតែទទួលសេវាថែទាំបន្ទាន់ពីអ្នកផ្តល់សេវាក្នុងបណ្តាញនៅពេលអ្នកស្ថិតនៅក្នុងតំបន់គេហដ្ឋានរបស់អ្នក។ អ្នកមិនត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) សម្រាប់ការថែទាំបន្ទាន់ពីអ្នកផ្តល់សេវា ក្នុងបណ្តាញនៅក្នុងតំបន់គេហដ្ឋានរបស់អ្នកទេ។

ប្រសិនបើអ្នកនៅក្រៅតំបន់លំនៅដ្ឋានរបស់អ្នកប៉ុន្តែនៅក្នុងសហរដ្ឋអាមេរិក អ្នកមិនត្រូវការការ យល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ដើម្បីទទួលបានការថែទាំបន្ទាន់ទេ។ ទៅកាន់កន្លែងថែទាំបន្ទាន់ដែលនៅជិតបំផុត។ Medi-Cal មិនរាប់រួមលើសេវាថែទាំបន្ទាន់នៅក្រៅសហរដ្ឋអាមេរិកទេ។ ប្រសិនបើអ្នកកំពុងធ្វើដំណើរនៅក្រៅសហរដ្ឋអាមេរិកហើយត្រូវការការថែទាំបន្ទាន់ យើងនឹង មិន រាប់រួមការថែទាំរបស់អ្នកទេ។

អ្នកផ្តល់សេវាថែទាំបន្ទាន់របស់អ្នកអាចផ្តល់ឱ្យអ្នកនូវឱសថដែលជាផ្នែកនៃការជួបថែទាំបន្ទាន់របស់អ្នក។ ប្រសិនបើអ្នកទទួលបានថ្នាំដែលជាផ្នែកនៃការជួបពិនិត្យរបស់អ្នក យើងនឹងរាប់រួមលើថ្នាំដែលជាផ្នែកនៃការថែទាំបន្ទាន់មានជានារាប់រួមរបស់អ្នក។ ប្រសិនបើអ្នកផ្តល់សេវាថែទាំបន្ទាន់របស់អ្នកផ្តល់ឱ្យអ្នកនូវវេជ្ជបញ្ជាដើម្បីយកទៅឱសថស្ថាននោះ ថ្នាំដែលត្រូវបានចេញវេជ្ជបញ្ជាសម្រាប់អ្នកនឹងត្រូវរាប់រួមដោយកម្មវិធី Medi-Cal Rx។ សម្រាប់ព័ត៌មានបន្ថែមអំពី Medi-Cal Rx សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្នុងផ្នែក "កម្មវិធី និងសេវា Medi-Cal ផ្សេងទៀតដែលមិនត្រូវបានរាប់រួមដោយ Kaiser Permanente" នៅក្នុងជំពូកទី 4 ។

ប្រសិនបើការថែទាំរបស់អ្នកគឺជាកង្វល់ការថែទាំបន្ទាន់ផ្នែកសុខភាពផ្លូវចិត្ត សូមទំនាក់ទំនងមក លេខទូរស័ព្ទឥតគិតថ្លៃរបស់ផែនការសុខភាពផ្លូវចិត្តក្នុងខោនធីដែលអាចរកបាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ ដើម្បីស្វែងរកលេខទូរស័ព្ទរបស់ខោនធីទាំងអស់ដោ

យតតគិតថ្លៃតាមអនឡាញ សូមចូលទៅកាន់
http://www.dhcs.ca.gov/individuals/Pages/MHPContactList.aspx (ជាភាសាអង់គ្លេស)។

យើងមិនរ៉ាប់រងការថែទាំតាមដានបន្តពីអ្នកផ្តល់សេវាក្រៅបណ្តាញទេ បន្ទាប់ពីអ្នកលែងត្រូវការការថែទាំបន្ទាន់ហើយនោះ លើកលែងតែឧបករណ៍វេជ្ជសាស្ត្រជាប់បានយូរដែលត្រូវបានរ៉ាប់រងប៉ុណ្ណោះ។ បន្ទាប់ពីបញ្ហាការថែទាំបន្ទាន់របស់អ្នកត្រូវបានដោះស្រាយរួចរាល់ អ្នកត្រូវតែទៅជួបអ្នកផ្តល់សេវាបណ្តាញសម្រាប់ការថែទាំតាមដានបន្តដែលត្រូវការ។ ប្រសិនបើអ្នកត្រូវការឧបករណ៍វេជ្ជសាស្ត្រជាប់បានយូរដែលទំនាក់ទំនងនឹងការថែទាំបន្ទាន់របស់អ្នក អ្នកផ្តល់សេវាក្រៅបណ្តាញរបស់អ្នកត្រូវតែទទួលការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ពីយើង។

ការថែទាំសង្គ្រោះបន្ទាន់

សម្រាប់ការថែទាំគ្រាអាសន្ន សូមទូរស័ព្ទទៅ **911** ឬទៅបន្ទប់សង្គ្រោះបន្ទាន់ដែលនៅជិតបំផុត។ សម្រាប់ការថែទាំសង្គ្រោះបន្ទាន់ អ្នក **មិន** ត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ពីពួកយើងទេ។ អ្នកមានសិទ្ធិប្រើប្រាស់មន្ទីរពេទ្យឬកន្លែងផ្សេងទៀតក៏បានសម្រាប់ការថែទាំសង្គ្រោះបន្ទាន់ ក្នុងប្រទេសកាណាដា និងមីកស៊ិក។ ការថែទាំបន្ទាន់និងការថែទាំផ្សេងទៀតក្នុងប្រទេសដទៃមិនត្រូវបានរ៉ាប់រងទេ។

ការថែទាំសង្គ្រោះបន្ទាន់គឺសម្រាប់ស្ថានភាពវេជ្ជសាស្ត្រដែលមានភាពអាសន្ន។ វាគឺសម្រាប់ជំងឺឬរបួសដែលសាមញ្ញជនដែលមានវិចារណញ្ញាណ (មិនមែនអ្នកជំនាញថែទាំសុខភាព) ដែលមានចំនេះដឹងកំរិតមធ្យមអំពីសុខភាពនិងឱសថអាចរំពឹងថា ប្រសិនបើអ្នកមិនទទួលការថែទាំភ្លាមៗ អ្នកអាចធ្វើឲ្យសុខភាពរបស់អ្នក (ឬសុខភាពទារកដែលមិនទាន់កើតរបស់អ្នក) ស្ថិតក្នុងគ្រោះថ្នាក់ ឬបង្កើតហានិភ័យគ្រោះថ្នាក់ធ្ងន់ធ្ងរដល់មុខងាររាងកាយ សរីរាង្គរាងកាយ ឬផ្នែកនៃរាងកាយ។ ឧទាហរណ៍នៃស្ថានភាពវេជ្ជសាស្ត្របន្ទាន់រួមមាន ប៉ុន្តែមិនត្រូវបានកំណត់តែចំពោះ៖

- ការឈឺពោះសម្រាលកូន
- ឆ្អឹងបាក់
- ការឈឺក្នុងទ្រូង
- ការប្រើថ្នាំជ្រើនហួសកំណត់
- ស្ថានភាពបន្ទាន់ផ្នែកចិត្តសាស្ត្រដូចជាជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរ ឬគំនិតធ្វើអត្តឃាត (រ៉ាប់រងដោយផែនការសុខភាពផ្លូវចិត្តក្នុងខោនធី)
- ការហូរឈាមច្រើន
- ការរលាកខ្លាំង
- ការឈឺចាប់ខ្លាំង

- បញ្ហាការដកដង្ហើម
- ការសន្លប់

កុំទៅផ្នែកថែទាំសង្គ្រោះបន្ទាន់ (Emergency Room, ER) សម្រាប់ការថែទាំជាប្រចាំ ឬការថែទាំដែលមិនត្រូវការភ្លាមៗ។ អ្នកគួរទទួលការថែទាំជាប្រចាំពី PCP របស់អ្នកដែលដឹងពីអ្នកច្រើនជាងគេ។ ប្រសិនបើអ្នកមិនច្បាស់ថាវាជាការបន្ទាន់ឬអត់ សូមទូរស័ព្ទទៅ PCP របស់អ្នក។ អ្នកក៏អាចទូរស័ព្ទទៅ **1-833-574-2273** (TTY **711**) និងពិគ្រោះជាមួយអ្នកជំនាញថែទាំសុខភាពមានអាជ្ញាប័ណ្ណ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើអ្នកត្រូវការការថែទាំសង្គ្រោះបន្ទាន់ពេលនៅឆ្ងាយពីផ្ទះ សូមទៅបន្ទប់សង្គ្រោះបន្ទាន់ ("ER") ដែលនៅជិតបំផុត បើទោះបីវាមិនមែននៅក្នុងបណ្តាញ Kaiser Permanente ក៏ដោយ។ ប្រសិនបើអ្នកទៅរក ER សូមស្នើពួកគេឲ្យទូរស័ព្ទមកយើង។ អ្នកឬមន្ទីរពេទ្យដែលអ្នកត្រូវបានទទួលឲ្យសំរាកព្យាបាល គួរទូរស័ព្ទទៅ Kaiser Permanente ក្នុងរយៈពេល 24 ម៉ោងបន្ទាប់ពីអ្នកទទួលការថែទាំសង្គ្រោះបន្ទាន់។ ប្រសិនបើអ្នកកំពុងនៅក្រៅសហរដ្ឋអាមេរិក ក្រៅពីប្រទេសកាណាដា ឬម៉ិកស៊ិកូ ហើយត្រូវការការថែទាំសង្គ្រោះបន្ទាន់នោះ Kaiser Permanente នឹង**មិន**រាប់រងលើការថែទាំរបស់អ្នកឡើយ។

ប្រសិនបើអ្នកត្រូវការការដឹកជញ្ជូនសង្គ្រោះបន្ទាន់ សូមទូរស័ព្ទទៅ **911**។ អ្នកមិនចាំបាច់សួរ PCP របស់អ្នកឬ Kaiser Permanente ជាមុននោះទេ មុនពេលអ្នកទៅ ER។

ប្រសិនបើអ្នកត្រូវការការថែទាំនៅក្នុងមន្ទីរពេទ្យក្រៅបណ្តាញក្រោយពីការសង្គ្រោះបន្ទាន់របស់អ្នក (ការថែទាំក្រោយមានស្ថេរភាព) មន្ទីរពេទ្យនឹងទូរស័ព្ទទៅ Kaiser Permanente។

សូមចាំថា៖ កុំទូរស័ព្ទទៅ **911** លើកលែងតែវាជាភាពអាសន្ន។ ទទួលការថែទាំសង្គ្រោះបន្ទាន់សម្រាប់តែគ្រាអាសន្នប៉ុណ្ណោះ មិនមែនសម្រាប់ការថែទាំជាប្រចាំ ឬជំងឺតិចតួចដូចជាជំងឺផ្តាសាយ ឬឈឺបំពង់កទេ។ ប្រសិនបើវាជាករណីសង្គ្រោះបន្ទាន់ សូមទូរស័ព្ទទៅ **911** ឬទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

ការថែទាំក្រោយមានស្ថិរភាព

ការថែទាំសុខភាពក្រោយពេលមានស្ថិរភាពគឺជាសេវាដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ នៅក្នុងមន្ទីរពេទ្យ (រួមបញ្ចូល ER) ដែលអ្នកទទួលបានបន្ទាប់ពីវេជ្ជបណ្ឌិតដែលកំពុងព្យាបាលអ្នករកឃើញថា ស្ថានភាពវេជ្ជសាស្ត្របន្ទាន់របស់អ្នកមានស្ថេរភាពហើយ។ ការថែទាំក្រោយស្ថិរភាពក៏រួមបញ្ចូលនូវគ្រឿងបរិក្ខារវេជ្ជសាស្ត្រជាប់បានយូរផងដែរ (Durable Medical Equipment, "DME") តែនៅពេលដែលលក្ខខណ្ឌដូចខាងក្រោមត្រូវបានបំពេញប៉ុណ្ណោះ៖

- ឧបករណ៍ DME ត្រូវបានរាប់រងនៅក្នុងសៀវភៅណែនាំសមាជិកនេះ។

- វាគឺជាចាំបាច់ខាងវេជ្ជសាស្ត្រក្នុងការដែលអ្នកមានឧបករណ៍ DME បន្ទាប់ពីអ្នកចេញពីមន្ទីរពេទ្យ
- ឧបករណ៍ DME ទំនាក់ទំនងនឹងការថែទាំបន្ទាន់ដែលអ្នកបានទទួលនៅក្នុងមន្ទីរពេទ្យ។

សម្រាប់ព័ត៌មានបន្ថែមអំពីគ្រឿងបរិក្ខារវេជ្ជសាស្ត្រជាប់បានយូរដែលត្រូវបានធានារ៉ាប់រងក្រោមសៀវភៅណែនាំសមាជិកនេះសូមចូលទៅកាន់ "គ្រឿងបរិក្ខារវេជ្ជសាស្ត្រប្រើជាប់បានយូរ" ដែលមានចំណងជើងថាជំពូកទី 4 ("អត្ថប្រយោជន៍និងសេវាកម្ម") នៃសៀវភៅណែនាំសមាជិកនេះ។

យើងរ៉ាប់រងការថែទាំក្រោយមានស្ថិរភាពពីអ្នកផ្តល់សេវាក្រៅបណ្តាញតែក្នុងករណីដែល យើងយល់ព្រមជាមុន ឬបើមិនដូច្នោះទេត្រូវបានតម្រូវដោយច្បាប់ដែលអនុវត្តប៉ុណ្ណោះ។ អ្នកផ្តល់សេវាដែលព្យាបាលអ្នកត្រូវតែទទួលការអនុញ្ញាតិពីយើងមុនពេលយើងនឹងបង់ថ្លៃ សម្រាប់ការថែទាំក្រោយមានស្ថេរភាព។

ដើម្បីស្នើសុំការយល់ព្រមជាមុនសម្រាប់អ្នកក្នុងការទទួលបានការថែទាំក្រោយពេលមានស្ថេរភាពពីអ្នកផ្តល់សេវាក្រៅបណ្តាញ អ្នកផ្តល់សេវាត្រូវតែទូរស័ព្ទមកយើងលេខ **1-800-225-8883** (TTY **711**)។ ពួកគេក៏អាចទូរស័ព្ទតាមលេខនៅខាងក្រោយប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នកបានដែរ។ អ្នកផ្តល់សេវាត្រូវតែទូរស័ព្ទមកយើងមុនពេលអ្នកទទួលបានសេវា។

នៅពេលដែលអ្នកផ្តល់សេវាទូរស័ព្ទមក យើងនឹងនិយាយទៅកាន់វេជ្ជបណ្ឌិតដែលកំពុង ព្យាបាលអ្នកអំពីបញ្ហាសុខភាពរបស់អ្នក។ ប្រសិនបើយើងកំណត់ថាអ្នកត្រូវការការថែទាំក្រោយមានស្ថេរភាព យើងនឹងផ្តល់សិទ្ធិលើសេវាដែលត្រូវបានរ៉ាប់រង។ ក្នុងករណីខ្លះ យើងអាចរៀបចំឲ្យមានអ្នកផ្តល់សេវាក្នុងបណ្តាញផ្តល់ការថែទាំនោះ។

ប្រសិនបើយើងសម្រេចចិត្តឲ្យមានមន្ទីរពេទ្យក្នុងបណ្តាញ ទីតាំងមើលថែជំងឺដែលមានជំនាញ ឬអ្នកផ្តល់សេវាផ្សេងទៀតផ្តល់ការថែទាំ យើងអាចអនុញ្ញាតលើសេវាដឹកជញ្ជូនដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រដើម្បីនាំអ្នកទៅអ្នកផ្តល់សេវា។ នេះអាចរួមបញ្ចូលសេវាដឹកជញ្ជូនពិសេសដែលយើងជាធម្មតានឹងមិនរ៉ាប់រង។

អ្នកគួរសួរអ្នកផ្តល់សេវាថាតើការថែទាំអ្វី (រួមបញ្ចូលការដឹកជញ្ជូនណាមួយ) ដែលយើងបានអនុញ្ញាត។ យើងរ៉ាប់រងតែសេវា ឬការដឹកជញ្ជូនដែលពាក់ព័ន្ធដែលយើងបានអនុញ្ញាតប៉ុណ្ណោះ។ ប្រសិនបើអ្នកស្នើសុំនិងទទួលយកសេវាដែលមិនត្រូវបានធានារ៉ាប់រង យើងអាចមិនបង់ថ្លៃទៅអ្នកផ្តល់សេវាសម្រាប់សេវាទាំងនោះទេ។

> បណ្តាញណាត់ជួប និងប្រឹក្សាផ្តល់ជូនអ្នកនូវព័ត៌មាន និងដំបូន្មានវេជ្ជសាស្ត្រដោយឥតគិតថ្លៃ 24 ម៉ោងក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃនៃឆ្នាំ។ ទូរស័ព្ទទៅលេខ **1-833-574-2273** (TTY **711**)។

បណ្តាញទូរស័ព្ទសម្រាប់ការណាត់ជួបនិងផ្តល់ដំបូន្មាន

ជួនកាល វាពិបាកដឹងច្បាស់ថាតើការថែទាំប្រភេទណាដែលអ្នកត្រូវការ។ យើងខ្ញុំមានអ្នកជំនាញថែទាំមានអាជ្ញាប័ណ្ណ ដែលអាចទទួលបានដើម្បីជួយលោកអ្នកតាមទូរស័ព្ទ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ អ្នកអាចៈ

- ពិភាក្សាជាមួយអ្នកជំនាញផ្នែកថែទាំសុខភាពដែលនឹងឆ្លើយសំណួរវេជ្ជសាស្ត្រ ផ្តល់ការណែនាំអំពីការថែទាំ និងជួយអ្នកក្នុងការសម្រេចចិត្តថាតើអ្នកគួរតែទៅជួបអ្នកផ្តល់សេវាភ្លាមៗឬអត់
- ទទួលបានជំនួយជាមួយស្ថានភាពវេជ្ជសាស្ត្រ ដូចជាជំងឺទឹកនោមផ្អែម ឬជំងឺហឺត រួមទាំងការណែនាំអំពីអ្នកផ្តល់សេវាប្រភេទណាដែលត្រឹមត្រូវសម្រាប់ស្ថានភាពរបស់អ្នក។
- ទទួលបានជំនួយអំពីអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកត្រូវការការថែទាំ ហើយទីកន្លែងដែនការត្រូវបានបិទ ឬអ្នកនៅខាងក្រៅតំបន់ផ្ទះរបស់អ្នក។

អ្នកអាចនិយាយជាមួយអ្នកជំនាញថែទាំសុខភាពមានអាជ្ញាប័ណ្ណដោយទូរស័ព្ទទៅលេខ **1-833-574-2273** (TTY **711**)។ នៅពេលអ្នកហៅទូរស័ព្ទទៅ អ្នកជំនួយការដែលបានទទួលការបណ្តុះបណ្តាលអាចសួរអ្នកនូវសំណួរ ដើម្បីជួយកំណត់ពីការបញ្ជូនការហៅទូរស័ព្ទរបស់អ្នក។

សេចក្តីណែនាំជាមុន

លិខិតណែនាំសុខភាពជាមុនគឺជាទម្រង់បែបបទផ្លូវច្បាប់។ នៅលើវា អ្នកអាចកត់បញ្ជីការថែទាំសុខភាពដែលអ្នកចង់បានក្នុងករណីដែលអ្នកមិនអាចនិយាយ ឬធ្វើការសំរេចចិត្តនៅពេលក្រោយ។ អ្នកអាចកត់បញ្ជីការថែទាំដែលអ្នកមិនចង់បាន។ អ្នកអាចដាក់ឈ្មោះនរណាម្នាក់ដូចជាស្វាមីឬភរិយា ដើម្បីធ្វើការសំរេចចិត្តអំពីការថែទាំសុខភាពអ្នក ប្រសិនបើអ្នកមិនអាច។

អ្នកអាចទទួលទម្រង់បែបបទណែនាំជាមុន ពីស្តាប័ន Kaiser Permanente ផែនការដោយមិនអស់ប្រាក់ពីអ្នក។ អ្នកក៏អាចទទួលបានទម្រង់បែបបទនេះនៅក្នុងឱសថស្ថាន មន្ទីរពេទ្យ ការិយាល័យច្បាប់ និងការិយាល័យរបស់វេជ្ជបណ្ឌិតផងដែរ។ អ្នកប្រហែលជាត្រូវបង់ប្រាក់សម្រាប់ទម្រង់បែបបទនេះ ប្រសិនបើអ្នកមិនទទួលបានទម្រង់នេះពីយើង។ អ្នកក៏អាចទាញយកទម្រង់បែបបទនេះដោយមិនអស់ប្រាក់ពីគេហទំព័ររបស់យើង **kp.org** (ជាភាសាអង់គ្លេស)។ អ្នកអាចស្នើសុំក្រុសាររបស់អ្នក, PCP ឬនរណាម្នាក់ដែលអ្នកទុកចិត្ត ដើម្បីជួយអ្នកបំពេញសំណុំបែបបទនេះ។

អ្នកមានសិទ្ធិឲ្យគេដាក់លិខិតណែនាំជាមុនរបស់អ្នកនៅក្នុងកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក។ អ្នកមានសិទ្ធិផ្លាស់ប្តូរ ឬបោះបង់ចោលសេចក្តីណែនាំជាមុនរបស់អ្នកនៅពេលណាក៏បាន។

អ្នកមានសិទ្ធិដឹងអំពីការផ្លាស់ប្តូរទៅលើច្បាប់នៃសេចក្តីណែនាំជាមុន។ Kaiser Permanente នឹងប្រាប់អ្នកអំពីការផ្លាស់ប្តូរលើច្បាប់រដ្ឋ មិនឲ្យយូរជាង 90 ថ្ងៃបន្ទាប់ពីការផ្លាស់ប្តូរទេ។

សម្រាប់ព័ត៌មានបន្ថែម អ្នកអាចទូរស័ព្ទមកមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង តាមរយៈលេខ **1-800-464-4000** (TTY **711**)។

ការបរិច្ចាគសរីរាង្គនិងជាលិកា

អ្នកអាចជួយសង្គ្រោះជីវិតបានជាច្រើនដោយក្លាយជាអ្នកបរិច្ចាគសរីរាង្គឬជាលិកា។ ប្រសិនបើអ្នកមានអាយុពី 15 ទៅ 18 ឆ្នាំ អ្នកអាចក្លាយជាអ្នកបរិច្ចាគដោយការយល់ព្រមជាលាយលក្ខណ៍អក្សរពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អ្នក។ អ្នកអាចផ្លាស់ប្តូរចិត្តអ្នកអំពីការក្លាយជាអ្នកបរិច្ចាគសរីរាង្គបានគ្រប់ពេល។ ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែមអំពីការបរិច្ចាគសរីរាង្គឬជាលិកា សូមពិគ្រោះជាមួយ PCP របស់អ្នក។ អ្នកក៏អាចចូលមើលគេហទំព័ររបស់នាយកដ្ឋានសេវាសុខភាព និងមនុស្សជាតិអាមេរិកនៅ **organdonor.gov** (ជាភាសាអង់គ្លេស) ផងដែរ។

4. អត្ថប្រយោជន៍និងសេវាកម្ម

អ្វីដែលផែនការសុខភាពរបស់អ្នករ៉ាប់រង

ផ្នែកនេះពន្យល់ប្រាប់អំពីសេវាដែលត្រូវបានរ៉ាប់រងរបស់អ្នក ក្នុងនាមជាសមាជិករបស់ Kaiser Foundation Health Plan, Inc. សេវាមានជានារ៉ាប់រងរបស់អ្នកគឺមិនយកប្រាក់ពីអ្នក ដរាបណាវាចាំបាច់ខាងវេជ្ជសាស្ត្រ ហើយត្រូវបានផ្តល់ស្របតាមបទបញ្ជាដែលបានចែង ក្នុងសៀវភៅណែនាំសមាជិកនេះ។ សេវាភាគច្រើនត្រូវបានផ្តល់ដោយអ្នកផ្តល់សេវាក្នុងបណ្តាញ។ យើងអាចរ៉ាប់រងសេវាចាំបាច់ខាងវេជ្ជសាស្ត្រពីអ្នកផ្តល់សេវាក្រៅបណ្តាញ ក្នុងករណីខ្លះ។ អ្នកត្រូវតែស្នើសុំការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ប្រសិនបើការថែទាំស្ថិតនៅក្រៅបណ្តាញ លើកលែងតែសម្រាប់សេវាសម្ងាត់ គ្រាអាសន្ន ឬបន្ទាន់ប៉ុណ្ណោះ។

ការថែទាំគឺចាំបាច់ខាងវេជ្ជសាស្ត្រ ប្រសិនបើវាសមហេតុផលនិងចាំបាច់ក្នុងការការពារជីវិតរបស់អ្នក ជួយអ្នកកុំឲ្យធ្លាក់ខ្លួនឈឺឬពិការធ្ងន់ធ្ងរ ឬបន្ថយការឈឺចាប់ខ្លាំងពីរោគា ជំងឺឬរបួសដែលត្រូវបានធ្វើរោគវិនិច្ឆ័យ។ សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្ររួមមានការថែទាំដែលត្រូវការដើម្បីជួសជុល ឬជួយសម្រាលជំងឺ ឬស្ថានភាពផ្លូវចិត្ត។ សមាជិកមានអាយុក្រោម 21 ឆ្នាំដែលអាចទទួលអត្ថប្រយោជន៍ និងសេវាបន្ថែមទៀត។ សូមអានជំពូកទី 5 ("ការថែទាំសុខភាពទូទៅកុមារនិងយុវជន") សម្រាប់ព័ត៌មានបន្ថែម។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាមានជានារ៉ាប់រងរបស់អ្នក សូមទូរស័ព្ទទៅមជ្ឈមណ្ឌល ទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

អ្នកត្រូវតែទទួលយកសេវាភាគច្រើនពីអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente។ សេវាដែលអ្នកអាចទទួលយកពីអ្នកផ្តល់សេវាក្រៅបណ្តាញគឺមានដូចនៅខាងក្រោមប៉ុណ្ណោះ៖

- ការថែទាំនៅមន្ទីរសេវាសុខភាពអាមេរិចស្បែកក្រហម
- សេវាថយន្តសង្គ្រោះបន្ទាន់
- សេវាសង្គ្រោះបន្ទាន់ និងការថែទាំក្រោយមានស្ថិរភាព
- សេវាការរៀបចំផែនការគ្រួសារ
- ការថែទាំបន្ទាន់ក្រៅតំបន់

- ការបញ្ជូនទៅអ្នកផ្តល់សេវាក្រៅបណ្តាញ
- ការថែទាំសម្ងាត់មួយចំនួន

ខាងក្រោមនេះមានជាឧទាហរណ៍នៃសេវាដែលយើងរ៉ាប់រង៖

- សេវាកម្ម (ជំងឺមិនសម្រាកនៅពេទ្យ) ដែលអាចដើរបាន
- ចំនួនមានកំណត់នៃឱសថវេជ្ជបញ្ជា បរិក្ខារផ្តត់ផ្គង់ និងថ្នាំបំប៉នសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យ។ ឱសថវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកពេទ្យភាគច្រើន សម្ភារៈផ្គត់ផ្គង់ និងថ្នាំបំប៉នត្រូវបានរ៉ាប់រងក្រោមកម្មវិធី Medi-Cal Rx ក្រោមកម្មវិធី បង់ថ្លៃ-ពេលប្រើ-សេវា របស់ Medi-Cal
- សេវាសង្គ្រោះបន្ទាន់ រួមជាមួយសេវាកម្មឡានសង្គ្រោះអាសន្ន
- ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់
- ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ
- សេវាលក្ខណៈស៊ើបអង្កេត
- សេវាមន្ទីរពិសោធន៍និងវិទ្យុសកម្ម ដូចជាការស្កេនអ៊ិច
- សេវានិងជំនួយរយៈពេលវែងមានការគ្រប់គ្រង (Managed long-term services and supports, "MLTSS")
- ការថែទាំសម្ភពនិងទារកកើតថ្មី
- សេវាសុខភាពផ្លូវចិត្តសម្រាប់ស្ថានភាពវេជ្ជសាស្ត្រស្រាលរហូតដល់មធ្យម រួមទាំងការវាយតម្លៃ សុខភាពផ្លូវចិត្ត
- ការដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនសង្គ្រោះបន្ទាន់ (Non-emergency medical transportation, "NEMT")
- ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ (Non-medical transportation, "NMT")
- សេវាជំងឺកុមារ
- សេវាបង្ការនិងសុខុមាលភាព និងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ
- សេវានិងឧបករណ៍ (ការព្យាបាល) ពង្រឹងនិងស្តារនីតិសម្បទា
- ការរះកាត់កែលម្អ
- សេវាពិនិត្យមើលរបិតិការប្រើប្រាស់គ្រឿងញៀន
- សេវា Telehealth ពីអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente
- សេវាភ្នែក

សូមអានផ្នែកនីមួយៗខាងក្រោមដើម្បីស្វែងយល់បន្ថែមអំពីសេវាដែលអ្នកអាចទទួលបាន។

សេវាថែទាំសុខភាពដែលផ្តល់ជូនដល់សមាជិក Kaiser Permanente ត្រូវអនុលោមតាមលក្ខខ័ណ្ឌ ស្តានភាព ការដាក់កម្រិត និងការដកចេញនានាក្នុងកិច្ចសន្យារវាង Kaiser Permanente និង L.A. Care Health Plan និងដូចដែលបានចុះបញ្ជីនៅក្នុងសៀវភៅណែនាំសមាជិកនិងវិសោធនកម្មផ្សេងៗ។

គោលការណ៍អត្ថប្រយោជន៍និងដំណើរការសម្រាប់វិធីទទួលបានសេវាមានជានាវ៉ាប់រងអាចមានភាពខុសគ្នា ក្នុងចំណោមអ្នកផ្តល់សេវាក្នុងបណ្តាញរបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរអ្នកផ្តល់សេវាក្នុងបណ្តាញ សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909**, (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ភាពចាំបាច់ខាងវេជ្ជសាស្ត្រគឺជាសេវាដែលនឹង (ឬត្រូវបានរំពឹងទុកដោយសមហេតុផលដើម្បី) ការពារ ធ្វើរោគវិនិច្ឆ័យ ព្យាបាល កែតម្រូវ ឬធ្វើអោយប្រសើរឡើងនូវចំណុចខាងក្រោម ហើយដែលត្រូវបានផ្តល់ជូនក្នុងលក្ខណៈដែលស្របតាមស្តង់ដារដែលទទួលយកបាននៃការអនុវត្តផ្នែកវេជ្ជសាស្ត្រ៖

- ការឈឺចាប់និងការរងលំបាក
- ផលប៉ះពាល់ខាងរាងកាយ ផ្លូវចិត្ត ការយល់ដឹង ឬការអភិវឌ្ឍន៍នៃជំងឺ របួស ឬពិការភាព

សម្រាប់ការពិនិត្យ រោគវិនិច្ឆ័យ និងការព្យាបាលជាមុន និងតាមកាលកំណត់ (Early and Periodic Screening, Diagnostic and Treatment, EPSDT) សេវាទាំងនេះក៏អាចរាប់បញ្ចូលទាំងការព្យាបាលដែលជាការសង្កេតតែប៉ុណ្ណោះ និងសេវាដែលនឹងកែតម្រូវ ឬកែលម្អពិការភាព និងជំងឺផ្លូវកាយ និងផ្លូវចិត្តដែលបានរកឃើញដោយសេវាពិនិត្យ។

សេវាចាំបាច់ខាងវេជ្ជសាស្ត្រមិនរួមបញ្ចូលៈ

- ការព្យាបាលដែលមិនទាន់បានតេស្ត ឬកំពុងត្រូវបានធ្វើតេស្ត
- សេវា ឬមុខទំនិញដែលមិនត្រូវបានទទួលយកជាទូទៅថាមានប្រសិទ្ធភាព
- សេវានៅខាងក្រៅវគ្គនិងរយៈពេលធម្មតានៃសេវាកម្ម ឬការព្យាបាលដែលមិនមានការណែនាំអំពីគ្លីនិក
- សេវាសម្រាប់ភាពងាយស្រួលដល់អ្នកថែទាំ ឬអ្នកផ្តល់សេវា

យើងនឹងសម្របសម្រួលជាមួយកម្មវិធីផ្សេងទៀត ដើម្បីជានាថាអ្នកទទួលបានសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រទាំងអស់ ទោះបីជាសេវាទាំងនោះត្រូវបានគ្រប់គ្រងដោយកម្មវិធីផ្សេងទៀត និងមិនមែនដោយ យើងក៏ដោយ។

សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ រួមមានសេវារ៉ាប់រង ដែលសមហេតុផល និងចាំបាច់ដើម្បីៈ

- ការពារជីវិត
- ការពារជម្ងឺធ្ងន់ធ្ងរ ឬពិការភាពកម្រិតធ្ងន់
- សម្រាលការឈឺចាប់ខ្លាំង
- សម្រេចនូវការលូតលាស់និងការអភិវឌ្ឍស្របតាមអាយុ
- ទទួលបាន រក្សាទុក និងកើនសមត្ថភាពក្នុងការប្រើចលនា

សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្ររួមមានសេវាកម្មដែលត្រូវបានធានារ៉ាប់រងទាំងអស់ ដែលបានកំណត់ខាងលើ និងការថែទាំសុខភាពចាំបាច់ផ្សេងទៀត សេវាវិនិច្ឆ័យ ការព្យាបាល និងវិធានការផ្សេងទៀតដើម្បីកែតម្រូវ ឬបន្ធូរបន្ថយពិការភាព និងជំងឺផ្លូវកាយ និងផ្លូវចិត្ត និងលក្ខខណ្ឌនានា ដូចដែលបានតម្រូវដោយផ្នែកអត្ថប្រយោជន៍ ការពិនិត្យជាមុន និងតាមកាលកំណត់ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល ("EPSDT") របស់សហព័ន្ធ។

EPSDT ផ្តល់សេវាបង្ការ រោគវិនិច្ឆ័យ និងការព្យាបាលយ៉ាងទូលំទូលាយសម្រាប់ទារក កុមារ និងក្មេងជំទង់ក្រោមអាយុ 21 ឆ្នាំដែលមានប្រាក់ចំណូលទាប។ អត្ថប្រយោជន៍ EPSDT គឺរឹងមាំជាងអត្ថប្រយោជន៍សម្រាប់មនុស្សពេញវ័យ ហើយត្រូវបានបង្កើតឡើងដើម្បីធានាថាកុមារទទួលបានការរកឃើញ និងការថែទាំទាន់ពេលវេលា ដូច្នេះបញ្ហាសុខភាពត្រូវបានបញ្ឈប់ ឬធ្វើរោគវិនិច្ឆ័យ និងព្យាបាលឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ គោលដៅនៃ EPSDT គឺដើម្បីធានាថាកុមារម្នាក់ៗទទួលបានការថែទាំសុខភាពដែលពួកគេត្រូវការនៅពេលពួកគេត្រូវការ - ការថែទាំត្រឹមត្រូវចំពោះកុមារត្រឹមត្រូវនៅពេលត្រឹមត្រូវក្នុងទីតាំងដែលត្រឹមត្រូវ។

យើងនឹងសម្របសម្រួលជាមួយកម្មវិធីផ្សេងទៀត ដើម្បីធានាថាអ្នកទទួលបានសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រទាំងអស់ ទោះបីជាសេវាទាំងនោះត្រូវបានគ្រប់ដណ្តប់ដោយកម្មវិធីផ្សេងទៀត និងមិនមែនដោយ Kaiser Permanente ក៏ដោយ។

អត្ថប្រយោជន៍ Medi-Cal ដែលរ៉ាប់រងដោយ Kaiser Permanente

សេវាអ្នកជំងឺមិនសម្រាកពេទ្យ (ដែលអាចដើរបាន)

ការចាក់ថ្នាំបង្ការសម្រាប់មនុស្សពេញវ័យ

អ្នកអាចទទួលបានវ៉ាក់សាំងការពារសម្រាប់មនុស្សពេញវ័យ (ការចាក់ថ្នាំ) ពីអ្នកផ្តល់សេវាក្នុងបណ្តាញ ដោយមិនចាំបាច់មានការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)។ យើងរ៉ាប់រងការចាក់ថ្នាំទាំងនោះដែលត្រូវបានផ្តល់អនុសាសន៍ដោយគណៈកម្មាធិការប្រឹក្សា លើការអនុវត្តការចាក់ថ្នាំបង្ការ (Advisory Committee on Immunization Practices, "ACIP") នៃមជ្ឈមណ្ឌលសម្រាប់ការ

គ្រប់គ្រងនិងបង្ការជំងឺ (Centers for Disease Control and Prevention, "CDC") រួមទាំងការចាក់ថ្នាំដែលអ្នកត្រូវការនៅពេលធ្វើដំណើរ។ សម្រាប់ព័ត៌មានស្តីពីការចាក់ថ្នាំបង្ការសម្រាប់កុមារ សូមចូលទៅកាន់ជំពូកទី 5 ("ការថែទាំសុខភាពទូទៅកុមារនិងយុវជន")។

អ្នកក៏អាចទទួលបានសេវាចាក់ថ្នាំបង្ការមនុស្សពេញវ័យមួយចំនួននៅក្នុងឱសថស្ថានតាមរយៈ Medi-Cal Rx ផងដែរ។ ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធី Medi-Cal Rx សូមចូលទៅកាន់ចំណងជើងនោះនៅក្រោមផ្នែក "កម្មវិធី និងសេវាកម្មផ្សេងទៀតដែលមិនត្រូវបានជានាវ៉ាប់រងដោយ Kaiser Permanente" នៅពេលក្រោយ នៅក្នុងជំពូកទី 4 នេះ។

ការថែទាំជំងឺអាឡែកហ្ស៊ី

យើងវ៉ាប់រងលើការធ្វើតេស្តនិងការព្យាបាលប្រតិកម្មអាឡែកហ្ស៊ីដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ រួមមានការបំបាត់អាឡែកហ្ស៊ី ការកាត់បន្ថយអាឡែកហ្ស៊ី ឬការព្យាបាលដោយចាក់ថ្នាំពន្រឹងប្រព័ន្ធភាពស៊ាំ។

សេវាអ្នកជំនាញខាងថ្នាំស្ពឹក

យើងវ៉ាប់រងសេវាថ្នាំស្ពឹកដែលចាំបាច់ខាងវេជ្ជសាស្ត្រនៅពេលអ្នកទទួលការថែទាំមិនសម្រាកក្នុងមន្ទីរពេទ្យ។ សេវាទាំងនេះអាចរាប់បញ្ចូលទាំងការប្រើថ្នាំសន្លប់សម្រាប់ដំណើការព្យាបាលផ្សេងៗ នៅពេលដែលផ្តល់ដោយគ្រូពេទ្យឯកទេសខាងថ្នាំស្ពឹក។

សម្រាប់ដំណើការទន្តសាស្ត្រ យើងវ៉ាប់រងសេវាដូចខាងក្រោមនៅពេលដែលត្រូវបានអនុញ្ញាតដោយ Southern California Permanente Medical Group៖

- ការចាក់ថ្នាំស្ងប់អារម្មណ៍តាមសេរ៉ូម ឬ សេវាចាក់ថ្នាំស្ពឹកទូទៅដែលត្រូវបានចាត់ចែងដោយអ្នកវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាទីកន្លែងដែលទាក់ទងទៅនឹងការចាក់ថ្នាំស្ងប់អារម្មណ៍ ឬ ការចាក់ថ្នាំស្ពឹកនៅក្នុងការវះកាត់ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ មជ្ឈមណ្ឌលសុខភាពស្របតាមលក្ខខ័ណ្ឌសហព័ន្ធ (Federally Qualified Health Center, "FQHC") ការិយាល័យទន្តសាស្ត្រ ឬ ទីតាំងមន្ទីរពេទ្យ

យើងមិនវ៉ាប់រងសេវាណាផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងការថែទាំធ្មេញ ដូចជាសេវារបស់ទន្តពេទ្យជាដើមទេ។

សេវាព្យាបាលចាប់សរសៃនិងសន្លាក់

យើងវ៉ាប់រងសេវាព្យាបាលចាប់សរសៃនិងសន្លាក់ ដែលត្រូវបានកំណត់តែចំពោះការព្យាបាលនៃឆ្អឹងខ្នង ដោយការសម្រួលដោយដៃ។ អ្នកអាចទៅរហូតដល់ពីរដងក្នុងមួយខែ ដោយគ្មានការអនុញ្ញាតជាមុន។ ការទៅជួបពិនិត្យបន្ថែមអាចត្រូវបានយល់ព្រមនៅពេលដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

- ***សេវាចាប់សសៃរនិងសន្លាក់ពីអ្នកផ្តល់សេវាក្នុងបណ្តាញ American Specialty Health***
  យើងធ្វើការជាមួយ American Specialty Health ដើម្បីរៀបចំសេវាព្យាបាលចាប់សសៃរនិងសន្លាក់។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាព្យាបាលចាប់សសៃរនិងសន្លាក់ សូមទំនាក់ទំនង American Specialty Health លេខ **1-800-678-9133** (TTY **711**)។ សមាជិកដូចខាងក្រោមមានសិទ្ធិដើម្បីទទួលសេវាព្យាបាលចាប់សសៃនិងសន្លាក់ពីអ្នកផ្តល់សេវាក្នុងបណ្តាញ American Specialty Health៖
  - កុមារអាយុក្រោម 21 ឆ្នាំ
  - ស្ត្រីមានផ្ទៃពោះរហូតដល់កំឡុងពេលក្រោយសម្រាលកូន
  - អ្នកមានទីលំនៅក្នុងទីកន្លែងថែទាំដែលមានជំនាញ កន្លែងថែទាំកម្រិតមធ្យម ឬកន្លែងថែទាំជិតដល់

- ***សេវាព្យាបាលចាប់សរសៃនិងសន្លាក់ ពីទីកន្លែងរបស់ខោនធី FQHC និង RHC***
  Medi-Cal អាចរ៉ាប់រងសេវាព្យាបាលចាប់សសៃរនិងសន្លាក់សម្រាប់សមាជិកគ្រប់អាយុទាំងអស់ នៅពេលបានទទួលនៅបណ្តាញរបស់នាយកដ្ឋានជំងឺមិនសម្រាកមន្ទីរពេទ្យខោនធី គ្លីនិកជំងឺមិនសម្រាកមន្ទីរពេទ្យខោនធី FQHC ឬ គ្លីនិកសុខភាពជនបទ (Rural Health Clinic, RHC) ដែលមាននៅក្នុង L.A. Care Health Plan។ FQHC និង RHC អាចតម្រូវឲ្យមានការបញ្ជូនដើម្បីទទួលបានសេវា ។ មិនមែនគ្រប់មន្ទីររបស់ខោនធី FQHC ឬ RHC ទាំងអស់ទេ ដែលផ្តល់សេវាព្យាបាលចាប់សរសៃនិងសន្លាក់មិនសម្រាកនៅមន្ទីរពេទ្យ។ ដើម្បីទទួលបានព័ត៌មានបន្ថែម សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងភ្លាមៗតាមលេខ **1-800-464-4000** (TTY **711**)។

សេវាលាងឈាម/លាងតម្រងនោម

យើងរ៉ាប់រងការព្យាបាលដោយការលាងឈាមដែលចាំបាច់ខាងវេជ្ជសាស្ត្រ។ យើងក៏រ៉ាប់រងលើសេវាលាងឈាមតាមក្រលៀន (ការលាងឈាមរ៉ាំរ៉ៃ) និងការលាងឈាមតាមពោះវៀនផងដែរ។ អ្នកត្រូវតែបំពេញបានរាល់លក្ខណៈវិនិច្ឆ័យវេជ្ជសាស្ត្រដែលបានបង្កើតដោយ Southern California Permanente Medical Group និងដោយទីកន្លែងដែលផ្តល់ការលាងឈាម។

យើងមិនរ៉ាប់រងលើ

- គ្រឿងបរិក្ខា សម្ភារៈផ្គត់ផ្គង់ និងលក្ខណៈពិសេសដែលផ្តល់ជាសុកភាព ភាពងាយស្រួល ឬភាពប្រណិត
- ទំនិញមិនមែនវេជ្ជសាស្ត្រ ដូចជាម៉ាស៊ីនភ្លើង ឬសម្ភារៈបន្ទាប់បន្សំដើម្បីធ្វើឲ្យបរិក្ខារលាងឈាមតាមផ្ទះ អាចយកតាមខ្លួនបានសម្រាប់ការធ្វើដំណើរ

ការវះកាត់ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ និងដំណើរការព្យាបាលជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យផ្សេងទៀត

យើងរ៉ាប់រងការវះកាត់ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងដំណើរការព្យាបាលមិនសម្រាកមន្ទីរពេទ្យផ្សេងៗទៀត។

សេវាវេជ្ជបណ្ឌិត

យើងរ៉ាប់រងសេវាវេជ្ជបណ្ឌិតដែលចាំបាច់ខាងវេជ្ជសាស្ត្រ។ សេវាខ្លះអាចត្រូវបានផ្តល់ជាការណាត់ជួបជាក្រុម។

សេវាកម្មដែយ៉ាឌិក

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2022 តទៅ យើងនឹងរ៉ាប់រងលើសេវាសុខភាពអាកប្បកិរិយាដែលផ្តល់ដោយ អ្នកផ្តល់សេវាថែទាំបឋម (Primary Care Provider, PCP) របស់អ្នក ឬ PCP របស់កូនអ្នក។ សេវាដែយ៉ាឌិកគឺជាសេវាពិនិត្យ និងប្រឹក្សាដែលផ្តោតលើគ្រួសារ។ ពួកគេកំណត់អត្តសញ្ញាណសុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត និងកត្តាកំណត់សង្គមនៃការព្រួយបារម្ភអំពីសុខភាពជាមុន ហើយផ្តល់ការបញ្ជូនទៅកាន់ធនធានសហគមន៍តាមតម្រូវការ។

សេវាព្យាបាលការគ្រេចជើង (ប្រអប់ជើង)

យើងរ៉ាប់រងលើសេវាព្យាបាលគ្រេចជើងដែលចាំបាច់ខាងវេជ្ជសាស្ត្រសម្រាប់ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលនៃជើងមនុស្សដោយវេជ្ជសាស្ត្រ វះកាត់ មេកានិច ពត់សម្រួល និងដោយអគ្គិសនី។ នេះរួមទាំងកែងជើងនិងសសៃពួរដែលដាក់បញ្ចូលក្នុងប្រអប់ជើង និងការព្យាបាលមិនមែនវះកាត់ នៃសាច់ដុំនិងសសៃពួរនៃជើងដែលគ្រប់គ្រងមុខងារប្រអប់ជើង។

វិធីព្យាបាល

យើងរ៉ាប់រងវិធីព្យាបាលដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ រួមមាន៖

- ការព្យាបាលដោយឱសថ
- ការព្យាបាលដោយវិទ្យុសកម្ម
- ឱសថនិងផលិតផលដែលមានការត្រួតពិនិត្យ ទាំងនេះគឺជាឱសថ និងផលិតផលដែលតម្រូវនូវការត្រួតពិនិត្យនិងការអង្កេតមើលដោយ អ្នកផ្តល់សេវាថែទាំសុខភាព។ យើងរ៉ាប់រងទំនិញទាំងនេះ នៅពេលអ្នកផ្តល់សេវាក្នុងបណ្តាញចេញវេជ្ជបញ្ជាឲ្យអ្នកក្នុងការអនុលោមតាមគោលការណ៍ណែនាំរូបមន្តឱសថរបស់យើង។ ទំនិញត្រូវតែចាត់ចែងដោយស្ថាប័នរបស់ផែនការ ឬ ក្នុងអំឡុងពេលទៅជួបព្យាបាលតាមផ្ទះ ដើម្បីអោយវាត្រូវបានធានារ៉ាប់រង។ ឧទាហរណ៍នៃឱសថមានការត្រួតពិនិត្យដែលយើងរ៉ាប់រង រួមមានប៉ុន្តែពុំមែនកំណត់តែចំពោះ៖
  - ឈាមទាំងមូល កោសិកាឈាមក្រហម ប្លាស្មា និងផ្លាកែត
  - ឱសថព្យាបាលជម្ងឺមហារីក

- សារធាតុបង្កើតប្រព័ន្ធភាពស៊ាំប្រឆាំងអាឡែកហ្ស៊ី
- ឱសថនិងផលិតផលដែលត្រូវបានផ្តល់តាមរយៈការព្យាបាលចាក់បញ្ចូលតាមសរ៉ូម ឬការចាក់ថ្នាំ

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ជីរូបមន្តឱសថរបស់យើង ចូលទៅចំណងជើង "ឱសថវេជ្ជបញ្ជា បរិក្ខារផ្គត់ផ្គង់ និងថ្នាំបំប៉ន សម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យធានារ៉ាប់រងដោយ Kaiser Permanente" នៅផ្នែកក្រោយក្នុងជំពូកទី 4 នេះ។

ការថែទាំសម្ភពនិងទារកកើតថ្មី

ការអប់រំពីការបំបៅដោះ

យើងរ៉ាប់រងការគាំទ្រការបង្កើតទឹកដោះដែលទូលំទូលាយ។

ឧបករណ៍បូមទឹកដោះ និងសម្ភារៈផ្គត់ផ្គង់

យើងនឹងផ្តល់ឧបករណ៍បូមទឹកដោះមានគុណភាពល្អមួយសម្រាប់ការមានផ្ទៃពោះម្តង និងសម្ភារៈផ្គត់ផ្គង់មួយឈុតជាមួយឧបករណ៍បូមទឹកដោះនោះ។ ប្រសិនបើវាចាំបាច់ខាងវេជ្ជសាស្ត្រសម្រាប់អ្នកដើម្បីប្រើឧបករណ៍បូមទឹកដោះស្តង់ដារមន្ទីរពេទ្យ យើងនឹងរ៉ាប់រងលើការជួល ឬទិញវា។ ឧបករណ៍បូមទឹកដោះស្តង់ដារមន្ទីរពេទ្យគឺជាបរិក្ខារវេជ្ជសាស្ត្រប្រើបានយូរ (Durable Medical Equipment, "DME") ហើយត្រូវតែបានអនុញ្ញាតជាមុនសម្រាប់អ្នក។ យើងនឹងជ្រើសរើសឈ្មួញ ហើយអ្នកត្រូវតែបញ្ជូនត្រឡប់មកវិញនូវឧបករណ៍បូមទឹកដោះស្តង់ដារមន្ទីរពេទ្យនោះ ក្រោយពីអ្នកលែងត្រូវការវាទៀត។

ការថែទាំពេលសម្រាលនិងក្រោយពេលសម្រាលកូន

យើងរ៉ាប់រងសេវានៅក្នុងមន្ទីរពេទ្យនិងការថែទាំក្រោយពេលសម្រាលកូន។

ការថែទាំមុនសម្រាលកូន

យើងរ៉ាប់រងនូវសេវាកម្មនៃការពិនិត្យថែទាំមុនសម្រាលកូន។

សេវាមជ្ឈមណ្ឌលផ្តល់កំណើត

យើងរ៉ាប់រងសេវានៅមជ្ឈមណ្ឌលផ្តល់កំណើតដែលជាអ្នកផ្តល់សេវា Comprehensive Perinatal Services Program ("CPSP") ដែលត្រូវបានយល់ព្រមដោយ Medi-Cal។ សេវាមជ្ឈមណ្ឌលផ្តល់កំណើតគឺជាជម្រើសប្រភេទផ្សេងពីការថែទាំសម្ភពនៅមន្ទីរពេទ្យសម្រាប់ស្ត្រីដែលមានផ្ទៃពោះមានហានិភ័យទាប។ ប្រសិនបើអ្នកចង់បង្កើតកូនរបស់អ្នកនៅមជ្ឈមណ្ឌលមួយក្នុងចំណោមមជ្ឈមណ្ឌលទាំងនេះ និងដើម្បីចង់ដឹងថាតើអ្នកមានលក្ខណៈគ្រប់គ្រាន់ឬទេ ចូរសាកសួរវេជ្ជបណ្ឌិតរបស់អ្នក។

សេវាឆ្មបគិលានុបដ្ឋាយិកាមានវិញ្ញាបនប័ត្រ ("CNM")

យើងរ៉ាប់រងសេវាចាំបាច់ខាងវេជ្ជសាស្ត្រ ដែលផ្តល់ដោយឆ្មបគិលានុបដ្ឋាយិកាមានវិញ្ញាបនប័ត្រដែលធ្វើការស្របតាមវិសាលភាពនៃជំនាញរបស់ពួកគេ។

សេវាកម្មឆ្មបមានវិញ្ញាបនប័ត្រ ("LM")

យើងរ៉ាប់រងសេវាចាំបាច់ខាងវេជ្ជសាស្ត្រ ដែលផ្តល់ដោយឆ្មបគិលានុបដ្ឋាយិកាមានអាជ្ញាប័ណ្ណ ដែលធ្វើការស្របតាមវិសាលភាពនៃឯកទេសរបស់គេ។

ការធ្វើតេស្តនិងការប្រឹក្សាចំពោះជំងឺហ្សេន

យើងរ៉ាប់រងការធ្វើតេស្តនិងការប្រឹក្សារោគវិនិច្ឆ័យទាក់ទងនឹងទារកមានជម្ងឺហ្សេន។

ការថែទាំទារកទើបកើតថ្មី

ទារកទើបកើតថ្មីពីអាយុ 0 ទៅដល់ 2 ខែ។ ប្រសិនបើម្តាយជាសមាជិក Medi-Cal នៅពេលកើតនោះ យើងរ៉ាប់រងលើសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ក្រោមការធានារ៉ាប់រង Medi-Cal របស់ម្តាយសម្រាប់ទារកទើបនឹងកើត។ វាមានសារៈសំខាន់ណាស់ក្នុងការចុះឈ្មោះទារកទើបនឹងកើតរបស់អ្នកនៅក្នុង Medi-Cal ដើម្បីឲ្យទារកទើបនឹងកើតរបស់អ្នកអាចមានការធានារ៉ាប់រង Medi-Cal ផ្ទាល់ខ្លួនរបស់ពួកគេ។ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចុះឈ្មោះទារកថ្មីរបស់អ្នកក្នុងកម្មវិធី Medi-Cal សូមទូរស័ព្ទទៅការិយាល័យខោនធីរបស់អ្នក។

The Provisional Postpartum Care Extension Program

(មានប្រសិទ្ធិភាពរហូតដល់ថ្ងៃទី 1 ខែមេសា ឆ្នាំ 2022)

Provisional Postpartum Care Extension Program ("PPCE") ផ្តល់នូវការរ៉ាប់រងបន្ថែមសម្រាប់សមាជិក Medi-Cal ដែលមានស្ថានភាពសុខភាពផ្លូវចិត្តរបស់មាតាក្នុងកំឡុងពេលមានផ្ទៃពោះ ឬកំឡុងពេលក្រោយពីសម្រាលកូន។

យើងរ៉ាប់រងការថែរក្សាសុខភាពផ្លូវចិត្តរបស់មាតាសម្រាប់ស្ត្រី អំឡុងពេលមានផ្ទៃពោះ និងរហូតដល់ពីរខែបន្ទាប់ពីការបញ្ចប់នៃការមានផ្ទៃពោះ។ កម្មវិធី PPCE បន្ថែមការរ៉ាប់រងរហូតដល់ 12 ខែក្រោយពីការធ្វើរោគវិនិច្ឆ័យ ឬពីចុងបញ្ចប់នៃការមានផ្ទះពោះ ណាមួយដែលកើតឡើងក្រោយគេ។

ដើម្បីមានលក្ខណៈសម្បត្តិសម្រាប់កម្មវិធី PPCE វេជ្ជបណ្ឌិតរបស់អ្នកត្រូវតែបញ្ជាក់នូវរោគវិនិច្ឆ័យរបស់អ្នក នៃស្ថានភាពសុខភាពផ្លូវចិត្តមាតាក្នុងកំឡុង 150 ថ្ងៃក្រោយពីចុងបញ្ចប់ការមានផ្ទះពោះ។ សាកសួរវេជ្ជបណ្ឌិតរបស់អ្នកអំពីសេវាទាំងនេះ ប្រសិនបើអ្នកគិតថាអ្នកត្រូវការពួកវា។ ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកគិតថាអ្នកគួរតែមានសេវាពី PPCE វេជ្ជបណ្ឌិតរបស់អ្នកបំពេញនិងដាក់បញ្ជូនទម្រង់បែបបទសម្រាប់អ្នក។

ដើម្បីស្វែងយល់អំពីសេវាសុខភាពផ្លូវចិត្តដែលយើងរ៉ាប់រង សូមចូលទៅកាន់ចំណងជើង "សេវាសុខភាពផ្លូវចិត្ត" ក្នុងជំពូកទី 4 នេះ។

The Postpartum Care Extension Program

(មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2022)

Postpartum Care Extension Program ផ្តល់ការធានារ៉ាប់រងបន្ថែមសម្រាប់សមាជិក Medi-Cal ក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល។

Postpartum Care Extension Program ពង្រីកការធានារ៉ាប់រង Medi-Cal ដល់ទៅ 12 ខែបន្ទាប់ពីការបញ្ចប់នៃការមានផ្ទៃពោះ ដោយមិនគិតពីប្រាក់ចំណូល សញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍ ហើយមិនត្រូវការសកម្មភាពបន្ថែមទេ។

សេវា តេឡេសុខភាព

តេឡេសុខភាពគឺជាវិធីមួយនៃការទទួលបានសេវា ដោយមិនចាំបាច់នៅក្នុងទីកន្លែងជាមួយគ្នានឹងអ្នកផ្តល់សេវារបស់អ្នក។ តេឡេសុខភាពអាចពាក់ព័ន្ធជាមួយនឹងការសន្ទនាដោយផ្ទាល់ជាមួយអ្នកផ្តល់សេវារបស់អ្នក។ ឬតេឡេសុខភាពក៏អាចរួមមានការចែករំលែកព័ត៌មានជាមួយអ្នកផ្តល់សេវារបស់អ្នកដោយមិនចាំបាច់ មានការសន្ទនាដោយផ្ទាល់។ អ្នកអាចទទួលបានសេវាតាមរយៈតេឡេសុខភាព។ ប៉ុន្តែ តេឡេសុខភាពមិនអាចមានជូនសម្រាប់គ្រប់សេវាដែលធានារ៉ាប់រងទាំងអស់ឡើយ។ អ្នកអាចទាក់ទងអ្នកផ្តល់សេវារបស់អ្នកដើម្បីស្វែងយល់ថាតើប្រភេទសេវាណាមួយអាចរកបានតាមរយៈ តេឡេសុខភាព។ វាសំខាន់ណាស់ដែលអ្នកនិងអ្នកផ្តល់សេវារបស់អ្នកប្រើប្រាស់ទូរសុខភាព សម្រាប់សេវាជាក់ច្បាស់ណាមួយ ដែលសមរម្យសម្រាប់អ្នក។ អ្នកមានសិទ្ធិទទួលបានសេវាដោយផ្ទាល់ ហើយមិនតម្រូវឲ្យប្រើតេឡេសុខភាពទេ ទោះបីជាអ្នកផ្តល់សេវារបស់អ្នកយល់ព្រមថាវាសមរម្យសម្រាប់អ្នកក៏ដោយ។

សេវាសុខភាពផ្លូវចិត្ត

ការវាយតម្លៃសុខភាពផ្លូវចិត្ត

អ្នកមិនត្រូវការការបញ្ជូន ឬការយល់ព្រមជាមុន ដើម្បីទទួលបានការវាយតម្លៃសុខភាពផ្លូវចិត្តដំបូងពីអ្នកផ្តល់សេវាក្នុងបណ្តាញទេ។ អ្នកអាចទទួលបានការវាយតម្លៃសុខភាពផ្លូវចិត្តនៅពេលណាក៏បាន ពីអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណដែលជាអ្នកផ្តល់សេវាក្នុងបណ្តាញ។ អ្នកអាចមើលបញ្ជីឈ្មោះអ្នកផ្តល់សេវាអនឡាញរបស់យើងនៅ **kp.org/facilities** (ជាភាសាអង់គ្លេស) ដើម្បីស្វែងរកអ្នកផ្តល់សេវាម្នាក់ក្នុងបណ្តាញរបស់យើង ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ ប្រសិនបើអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តរបស់អ្នកកំណត់ថា អ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឯកទេស (Specialty Mental Health Services, "SMHS") គ្រូពេទ្យរបស់អ្នកនឹងបញ្ជូនអ្នកទៅផែនការសុខភាពផ្លូវចិត្តរបស់ខោនធីដើម្បីទទួលបានការវាយតម្លៃ។

យើងនឹងរ៉ាប់រងលើសេវាបង្ការ ពិនិត្យ វាយតម្លៃ និងសេវាព្យាបាលសម្រាប់ស្ថានភាពសុខភាពផ្លូវចិត្តកម្រិតស្រាលទៅមធ្យម ដែលអាចត្រូវបានផ្តល់ជូនអ្នក មុនពេលអ្នកទទួលការធ្វើរោគវិនិច្ឆ័យផ្លូវការទាក់ទងនឹងសុខភាពផ្លូវចិត្តរបស់អ្នក។

សេវាសុខភាពផ្លូវចិត្តមិនសម្រាកនៅមន្ទីរពេទ្យ សម្រាប់ស្ថានភាពស្រាលឬមធ្យម

ប្រសិនបើអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តរបស់អ្នកកំណត់ថា អ្នកមានស្ថានភាពសុខភាពផ្លូវចិត្តកម្រិតស្រាល ឬមធ្យម ឬមានភាពខ្វះខាតក្នុងមុខងារផ្លូវសតិ អារម្មណ៍ ឬអាកប្បកិរិយា យើងអាចរ៉ាប់រងសេវាសុខភាពផ្លូវចិត្តមិនស្នាក់ក្នុងមន្ទីរពេទ្យដូចខាងក្រោម៖

- ការវាយតម្លៃនិងព្យាបាលសុខភាពផ្លូវចិត្តជាលក្ខណៈបុគ្គលនិងក្រុម (ការព្យាបាលបែបចិត្តសាស្ត្រ)
- ការធ្វើតេស្តចិត្តសាស្ត្រនៅពេលដែលចាំបាច់ដើម្បីវាយតម្លៃលក្ខខណ្ឌសុខភាពផ្លូវចិត្ត

- ការអភិវឌ្ឍជំនាញការយល់ដឹងដើម្បីបង្កើនការផ្តង់ស្មារតី ការចងចាំ និងការដោះស្រាយបញ្ហា
- សេវាជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យសម្រាប់គោលបំណងពិនិត្យការព្យាបាលដោយឱសថ
- ការពិគ្រោះជំងឺវិកលចរិក
- សេវាឆ្លុះពិនិត្យនិងទីពិសោធន៍ដែលទាក់ទងទៅនឹងការព្យាបាលស្ថានភាពសុខភាពផ្លូវចិត្តរបស់អ្នក (សូមមើល "មន្ទីរពិសោធន៍និងសេវាវិទ្យុសកម្ម" នៅក្នុងជំពូកទី 4 នេះ)

ឱសថវេជ្ជបញ្ជាជំងឺមិនសម្រាកមន្ទីរពេទ្យ សម្ភារៈផ្គត់ផ្គង់ និងអាហារបំប៉នដែលទាក់ទងនឹងសេវាសុខភាពផ្លូវចិត្តត្រូវបានរាប់រងក្រោមកម្មវិធី Medi-Cal Rx។ សម្រាប់ព័ត៌មានបន្ថែមអំពី Medi-Cal Rx សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្នុងផ្នែក "កម្មវិធី និងសេវា Medi-Cal ផ្សេងទៀតដែលមិនត្រូវបានរាប់រងដោយ Kaiser Permanente" នៅក្នុងជំពូកទី 4 នេះ។

សម្រាប់ជំនួយស្វែងរកព័ត៌មានបន្ថែមអំពីសេវាសុខភាពផ្លូវចិត្តដែលផ្តល់ដោយ Kaiser Permanente អ្នកអាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

សេវាសង្គ្រោះបន្ទាន់

សេវាជំងឺសម្រាកមន្ទីរពេទ្យនិងមិនសម្រាកមន្ទីរពេទ្យដែលចាំបាច់ ដើម្បីព្យាបាលភាពបន្ទាន់ផ្នែកវេជ្ជសាស្ត្រ

យើងរាប់រងសេវាទាំងអស់ដែលចាំបាច់ដើម្បីព្យាបាលសង្គ្រោះបន្ទាន់ខាងវេជ្ជសាស្ត្រដែលកើតឡើង ក្នុងសហរដ្ឋអាមេរិក (រាប់បញ្ចូលទាំងទឹកដីដូចជា ព័រតូរីកូ កោះវឺជីនសហរដ្ឋអាមេរិក ។ល។) ឬតម្រូវអ្នកឲ្យអ្នកសម្រាកនៅមន្ទីពេទ្យក្នុងប្រទេសកាណាដា ឬមិកស៊ិកូ។ ភាពបន្ទាន់ផ្នែកវេជ្ជសាស្ត្រគឺជាស្ថានភាពវេជ្ជសាស្ត្រដែលមានការឈឺចាប់ខ្លាំង ឬរបួសធ្ងន់ធ្ងរ។ ស្ថានភាពគឺធ្ងន់ធ្ងរខ្លាំងដែលប្រសិនបើមិនទទួលការពិនិត្យព្យាបាលខាងវេជ្ជសាស្ត្រភ្លាមៗទេ សាមញ្ញជនដែលប្រយ័ត្នប្រយែង (សមហេតុផល) (មិនមែនជាអ្នកជំនាញផ្នែកថែទាំសុខភាព) ដែលមានចំណេះដឹងមធ្យមអំពីសុខភាពនិងឱសថអាចរំពឹងថាវានឹងមានលទ្ធផលដូចខាងក្រោម៖

- ហានិភ័យខ្ពស់ដល់សុខភាពរបស់អ្នក
- គ្រោះថ្នាក់ធ្ងន់ធ្ងរដល់មុខងាររាងកាយ
- ការខូចមុខងារសរីរាង្គកាយឬផ្នែកណាមួយធ្ងន់ធ្ងរ

- ក្នុងករណីស្ត្រីមានផ្ទៃពោះកំពុងឈឺពោះសម្រាលកូន ដែលមានន័យថាឈឺពោះនៅពេលដែល មួយក្នុងចំណោមខាងក្រោមអាចកើតឡើង៖
  - មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីបញ្ជូនអ្នកទៅមន្ទីរពេទ្យផ្សេងទៀតដោយសុវត្ថិភាពមុនពេលសម្រាល
  - ការផ្ទេរនេះអាចបង្កការគំរាមកំហែងដល់សុខភាព ឬសុវត្ថិភាពរបស់អ្នក ឬចំពោះកូនដែលមិនទាន់កើតរបស់អ្នក

សេវាថែទាំសង្គ្រោះបន្ទាន់ត្រូវបានរ៉ាប់រងរួមមានការផ្តល់ជូនបន្ទាន់ចំនួន 72-ម៉ោងនៃឱសថវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យ ប្រសិនបើឱសថការី ឬនាយកដ្ឋានសង្គ្រោះបន្ទាន់នៃមន្ទីពេទ្យផ្តល់ជូនអ្នកនូវឱសថ ដែលជាផ្នែកនៃការទៅទទួលការថែទាំសង្គ្រោះបន្ទាន់របស់អ្នក។

ប្រសិនបើអ្នកផ្តល់សេវាផ្នែកសង្គ្រោះបន្ទាន់របស់មន្ទីរពេទ្យផ្តល់ឲ្យអ្នកនូវវេជ្ជបញ្ជាដែលអ្នកត្រូវយកទៅឱសថស្ថានជំងឺមិនសម្រាកមន្ទីរពេទ្យដើម្បីបំពេញនោះ Medi-Cal Rx នឹងទទួលខុសត្រូវចំពោះការរ៉ាប់រងនៃវេជ្ជបញ្ជានោះ។ ប្រសិនបើឱសថការីនៅឱសថស្ថានជំងឺមិនសម្រាកមន្ទីរពេទ្យផ្តល់ឲ្យអ្នកនូវការផ្តត់ផ្តង់ថ្នាំសង្គ្រោះបន្ទាន់ នោះវេជ្ជបញ្ជានោះក៏នឹងត្រូវបានរ៉ាប់រងដោយ Medi-Cal Rx ផងដែរ ហើយមិនមែនដោយពួកយើងទេ។ ប្រសិនបើឱសថស្ថានត្រូវការជំនួយដើម្បីដំណើរការវេជ្ជបញ្ជារបស់អ្នក ពួកគេអាចទូរស័ព្ទទៅសេវាអតិថិជន Medi-Cal Rx នៅ **1-800-977-2273**, 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍។

សេវាដឹកជញ្ជូនសង្គ្រោះបន្ទាន់

យើងរ៉ាប់រងសេវាសង្គ្រោះបន្ទាន់ដើម្បីជួយអ្នកទៅដល់កន្លែងថែទាំដែលនៅជិតបំផុត ក្នុងស្ថានភាពអាសន្ន។ នេះមានន័យថាស្ថានភាពរបស់អ្នកធ្ងន់ធ្ងរដល់កម្រិតដែលមធ្យោបាយផ្សេងៗក្នុងការទៅដល់ កន្លែងថែទាំអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពឬជីវិតអ្នក។ គ្មានសេវាណាដែលត្រូវបានរ៉ាប់រងនៅក្រៅសហរដ្ឋអាមេរិកឡើយ លើកលែងតែសេវាសង្គ្រោះបន្ទាន់ ដែលតម្រូវឲ្យអ្នកសម្រាកនៅមន្ទីពេទ្យក្នុងប្រទេសកាណាដា ឬមីកស៊ីកូ។ ប្រសិនបើអ្នកទទួលបានសេវាថយន្តសង្គ្រោះបន្ទាន់នៅប្រទេសកាណាដា និងមីកស៊ិកូ ហើយអ្នកមិនត្រូវបានសម្រាកនៅមន្ទីរពេទ្យក្នុងអំឡុងពេលនៃការថែទាំនោះ យើងនឹងមិនរ៉ាប់រងសេវាថយន្តសង្គ្រោះរបស់អ្នកទេ។

ការអប់រំផ្នែកសុខភាព

យើងរ៉ាប់រងលើការប្រឹក្សាយោបល់ កម្មវិធី និងឯកសារអប់រំសុខភាពជាច្រើនប្រភេទដែល PCP របស់អ្នក ឬអ្នកផ្តល់សេវាផ្សេងទៀតផ្តល់អោយក្នុងកំឡុងពេលណាត់ជួប ឬការជួបពិនិត្យ។

យើងក៏រ៉ាប់រងផងដែរលើការប្រឹក្សាយោបល់ កម្មវិធី និងឯកសារអប់រំសុខភាពជាច្រើនប្រភេទ ដើម្បីជួយអ្នកអោយដើរតួនាទីដែលសកម្មក្នុងការការពារនិងកែលំអសុខភាពរបស់អ្នក ដែលរួមមានទាំងកម្មវិធីសំរាប់ការបញ្ឈប់ថ្នាំជក់ ការគ្រប់គ្រងភាពតានតឹង និងជំងឺរ៉ាំរ៉ៃ (ដូចជាទឹកនោមផ្អែមនិងជំងឺហឺត)។ កម្មវិធី និងឯកសារទាំងនេះមានជូនដោយមិនគិតថ្លៃពីអ្នក។

សម្រាប់ព័ត៌មានបន្ថែមអំពីការប្រឹក្សាយោបល់ កម្មវិធី និងឯកសារអប់រំសុខភាពរបស់យើង សូមទំនាក់ទំនងនាយកដ្ឋានអប់រំសុខភាពនៅឯទីតាំងផែនការក្នុងមូលដ្ឋានរបស់អ្នក។

អ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**) ឬចូលទៅគេហទំព័ររបស់យើងនៅ **kp.org** (ជាភាសាអង់គ្លេស)។

ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់

ការថែទាំជំងឺមុខនឹងស្លាប់

ការថែទាំជំងឺមុខនឹងស្លាប់ ផ្តល់អត្ថប្រយោជន៍ដល់សមាជិកដែលឈឺមុខនឹងស្លាប់។ វាគឺជាអន្តរាគមន៍ដែលផ្តោតដោយចម្បងទៅលើការគ្រប់គ្រងការឈឺចាប់និងរោគសញ្ញា ជាជាងការព្យាបាលដើម្បីពន្យាពេលជីវិត។

យើងរ៉ាប់រងការថែទាំជំងឺមុខនឹងស្លាប់តែក្នុងករណីដែលបំពេញបានរាល់លក្ខខណ្ឌតម្រូវខាងក្រោម៖

- វេជ្ជបណ្ឌិតក្នុងបណ្តាញបានធ្វើរោគវិនិច្ឆ័យអ្នកថាមានជម្ងឺមុខតែនឹងស្លាប់ហើយកំណត់ថា ជីវិតរបស់អ្នកនៅរស់បាន 6 ខែឬតិចជាងនេះ
- សេវាត្រូវបានផ្តល់នៅក្នុងតំបន់លំនៅដ្ឋានរបស់អ្នក
- សេវាត្រូវបានផ្តល់ជូនដោយទីភ្នាក់ងារជំងឺមុខនឹងស្លាប់មានអាជ្ញាប័ណ្ណ ដែលជាអ្នកផ្តល់សេវាក្នុងបណ្តាញ
- វេជ្ជបណ្ឌិតក្នុងបណ្តាញកំណត់ថា សេវាគឺចាំបាច់សម្រាប់ការបន្ថយការឈឺចាប់នៃជំងឺមុខនឹងស្លាប់និងលក្ខខណ្ឌពាក់ព័ន្ធរបស់អ្នក

ការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ

- មនុស្សពេញវ័យដែលមានអាយុ 21 ឆ្នាំឡើងទៅអាចទទួលបានការថែទាំដើម្បីសម្រាលការឈឺចាប់ និងរោគសញ្ញាផ្សេងៗទៀតនៃជំងឺមុខនឹងស្លាប់ ប៉ុន្តែមិនមែនព្យាបាលឲ្យជាសះស្បើយទេ។ មនុស្សពេញវ័យអាចមិនទទួលបានទាំងសេវាថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំសម្រាលការឈឺចាប់ ក្នុងពេលតែមួយបានទេ។
- កុមារក្រោមអាយុ 21 ឆ្នាំ ទទួលបានការថែទាំដើម្បីសម្រាលការឈឺចាប់និងរោគសញ្ញាផ្សេងៗ នៃជំងឺមុខនឹងស្លាប់របស់ពួកគេ ហើយអាចជ្រើសរើសបន្តការព្យាបាលជម្ងឺរបស់ពួកគេ

អ្នកអាចផ្លាស់ប្តូរជម្រើសរបស់អ្នកដើម្បីទទួលបានការថែទាំជំងឺមុខនឹងស្លាប់បានគ្រប់ពេល។ ជម្រើសរបស់អ្នកក្នុងការចាប់ផ្តើមឬបញ្ឈប់ការថែទាំជំងឺមុខនឹងស្លាប់ត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ និងគោរពតាមច្បាប់របស់ Medi-Cal។

ប្រសិនបើទាំងអស់នៃតម្រូវការខាងលើត្រូវបានឆ្លើយតប យើងរ៉ាប់រងសេវាថែទាំជំងឺមុខនឹងស្លាប់ ដូចខាងក្រោម៖

- សេវារបស់វេជ្ជបណ្ឌិតក្នុងបណ្តាញ
- ការថែទាំគិលានុបដ្ឋាយិកាជំនាញ រួមមានការវាយតម្លៃនិងគ្រប់គ្រងករណីនៃតម្រូវការផ្នែកគិលានុបដ្ឋាយិកា

ការព្យាបាលការឈឺចាប់និងការគ្រប់គ្រងរោគសញ្ញា
ជំនួយផ្នែកស្មារតីសម្រាប់អ្នកនិងគ្រួសារអ្នក និងការអប់រំដល់អ្នកថែទាំអ្នកជម្ងឺ

- ការព្យាបាលដោយចលនា ការធ្វើកិច្ចការងារ ឬការនិយាយសម្រាប់ការគ្រប់គ្រងរោគសញ្ញា ឬដើម្បីជួយរក្សាសកម្មភាពរស់នៅប្រចាំថ្ងៃ
- ការព្យាបាលប្រព័ន្ធដង្ហើម
- សេវាសង្គមរវេជ្ជសាស្ត្រ
- ជំនួយសុខភាពនៅផ្ទះ និងជំនួយដល់ការបរិភោគ ងូតទឹក និងស្លៀកពាក់
- ឱសថម្រាប់គ្រប់គ្រងការឈឺចាប់ និងដើម្បីជួយជាមួយរោគសញ្ញាដទៃទៀតនៃជម្ងឺមុខនឹងស្លាប់របស់អ្នក។
  - ♦ យើងរ៉ាប់រងឱសថដែលមានការត្រួតពិនិត្យដោយអនុលោមតាមគោលការណ៍រូបមន្តឱសថរបស់យើង
  - ♦ យើងរ៉ាប់រងឱសថសម្រាប់ជំងឺមិនសម្រាកក្នុងមន្ទីពេទ្យដែលជាប់ទាក់ទងដោយផ្តាល់ទៅនឹង សេវាជំងឺមុខនឹងស្លាប់ដែលត្រូវបានរ៉ាប់រង។ អ្នកត្រូវតែទទួលបានថ្នាំទាំងនេះពីឱសថស្ថាន Kaiser Permanente ក្នុងបណ្តាញ។ សំរាប់ឱសថមួយចំនួន យើងរ៉ាប់រងលើការផ្គត់ផ្គង់ 30 ថ្ងៃក្នុងកំឡុងពេល 30 ថ្ងៃណាមួយ
  - ♦ ឱសថរវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យដែលមិនមែនជាផ្នែកនៃការថែទាំជំងឺដំណាក់កាលចុងក្រោយរបស់អ្នកត្រូវបានរ៉ាប់រងដោយ Medi-Cal Rx ។ អ្នកអាចស្វែងយល់បន្ថែមអំពីកម្មវិធី Medi-Cal Rx ដោយចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្រោមផ្នែក "កម្មវិធីនិងអត្ថប្រយោជន៍ផ្សេងទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" នៅពេលក្រោយនៅក្នុងជំពូកទី 4 នេះ។
- បរិក្ខារវេជ្ជសាស្ត្រប្រើជាប់បានយូរ
- ការថែទាំបណ្តោះអាសន្នដើម្បីជួយសម្រាលដល់អ្នកថែទាំរបស់អ្នក។ ការថែទាំបណ្តោះអាសន្នគឺជាការថែទាំអ្នកជម្ងឺក្នុងមន្ទីរពេទ្យរយៈពេលខ្លីយូរៗម្តង ដែលត្រូវបានកំណត់មិនឲ្យលើសពីប្រាំថ្ងៃជាប់គ្នាក្នុងមួយដង។
- ការប្រឹក្សាយោបល់ដើម្បីជួយដល់ការជាត់បង់
- ការផ្តល់ដំបូន្មានអំពីរបបអាហារ

យើងក៏រ៉ាប់រងសេវាថែទាំជំងឺមុខនឹងស្លាប់ដូចខាងក្រោមផងដែរ តែក្នុងអំឡុងពេលមានវិបត្តិនៅពេលដែលវាមានភាពចាំបាច់ផ្នែករវេជ្ជសាស្ត្រ ដើម្បីសម្រេចបានការសម្រាលការឈឺចាប់ឬការគ្រប់គ្រងរោគសញ្ញារវេជ្ជសាស្ត្រធ្ងន់ធ្ងរខ្លាំងៗ៖

- ការមើលថែទាំលើមូលដ្ឋានបន្តរហូតដល់ 24 ម៉ោងក្នុងមួយថ្ងៃតាមការចាំបាច់ដើម្បីរក្សាអ្នកនៅផ្ទះ
- ការថែទាំអ្នកជម្ងឺក្នុងមន្ទីរពេទ្យដែលត្រូវបានតម្រូវក្នុងកម្រិតដែលមិនអាចត្រូវបានផ្តល់ជូននៅផ្ទះ

ការថែទាំបន្តយការឈឺចាប់

យើងរ៉ាប់រងលើការថែទាំព្យាបាលសម្រាលការឈឺចាប់សម្រាប់សមាជិកដែលបំពេញតាម លក្ខណៈវិនិច្ឆ័យសិទ្ធិទទួល Medi-Cal សម្រាប់សេវាទាំងនេះ។ ការថែទាំបំបាត់ការឈឺចាប់ កាត់បន្ថយភាពមិនស្រួលខាងរាងកាយ អារម្មណ៍ សង្គម និងខាងវិញ្ញាណសម្រាប់សមាជិកដែលមានជំងឺធ្ងន់ធ្ងរ។ ការថែទាំបំបាត់ការឈឺចាប់អាចត្រូវបានផ្តល់ជូនក្នុងពេលតែមួយជាមួយនឹងការថែទាំព្យាបាល។

ការថែទាំបំបាត់ការឈឺចាប់រួមមានដូចខាងក្រោម៖

- ការធ្វើផែនការការថែទាំជាមុន
- ការវាយតម្លៃការថែទាំបំបាត់ការឈឺចាប់ និងការពិគ្រោះយោបល់
- ផែនការថែទាំរួមមាន ប៉ុន្តែមិនមានកំណត់តែចំពោះកត្តាខាងក្រោម តាមការចាំបាច់៖
  - សេវាកម្មនៃវេជ្ជបណ្ឌិតផ្នែកវេជ្ជសាស្ត្រ ឬ ផ្នែកគក់ច្របាច់
  - សេវាអ្នកជំនួយការវេជ្ជបណ្ឌិត
  - សេវាគិលានុបដ្ឋាយិកាដែលមានអាជ្ញាប័ណ្ណ
  - សេវាគិលានុបដ្ឋាយិការិជ្ជាជីវៈដែលមានអាជ្ញាប័ណ្ណ ឬគិលានុបដ្ឋាយិកាឧត្តម
  - សេវាអ្នកធ្វើការខាងសង្គមកិច្ច
  - សេវារបស់បព្វជិត
  - ការសម្របសម្រួលការថែទាំ
  - ការគ្រប់គ្រងការឈឺចាប់និងរោគសញ្ញា
- សេវាសុខភាពផ្លូវចិត្ត និងសង្គមវេជ្ជសាស្ត្រ

មនុស្សពេញវ័យដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅមិនអាចទទួលបានទាំងការថែទាំបំបាត់ការឈឺចាប់ និងការថែទាំជំងឺមុខនឹងស្លាប់ក្នុងពេលតែមួយបានទេ។ ប្រសិនបើអ្នកកំពុងទទួលបានការថែទាំបំបាត់ការឈឺចាប់ ហើយបំពេញបានតាមលក្ខខ័ណ្ឌទទួលបាន ការថែទាំជំងឺមុខនឹងស្លាប់ អ្នកអាចស្នើសុំផ្លាស់ប្តូរទៅការថែទាំជំងឺមុខនឹងស្លាប់ នៅពេលណាក៏បាន។

ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ

សេវាអ្នកជំនាញខាងថ្នាំស្ពឹក

យើងរ៉ាប់រងលើសេវាអ្នកឯកទេសថ្នាំស្ពឹកដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ ក្នុងកំឡុងពេលស្នាក់នៅមន្ទីរពេទ្យដែលត្រូវបានរ៉ាប់រង។ អ្នកឯកទេសថ្នាំស្ពឹកគឺជាអ្នកផ្តល់សេវាដែលមានជំនាញក្នុងការផ្តល់ឲ្យអ្នកជំងឺនូវថ្នាំស្ពឹក។ ថ្នាំស្ពឹកគឺជាប្រភេទឱសថដែលប្រើក្នុងកំឡុងពេលដំណើរការវេជ្ជសាស្ត្រមួយចំនួន។

សេវាជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ

យើងរ៉ាប់រងការថែទាំជំងឺសម្រាកក្នុងមន្ទីពេទ្យដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ នៅពេលអ្នកត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យក្នុងបណ្តាញ។ សេវារួមមានបន្ទប់និងក្តារបរអាហារ ឱសថ គ្រឿងបរិក្ខារ សេវាថតឆ្លុះនិងទិពិសោធន៍ រួមទាំងសេវាផ្សេងៗទៀតដែលមន្ទីរពេទ្យផ្តល់ជូនជាធម្មតា។ ប្រសិនបើអ្នកត្រូវបានចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យក្រៅបណ្តាញ អ្នកត្រូវតែទទួលការយល់ព្រមពីយើង សម្រាប់ការថែទាំដែលអ្នកទទួល ក្រោយពីស្ថានភាពរបស់អ្នកមានស្ថេរភាព។ ប្រសិនបើអ្នកមិនទទួលបានការយល់ព្រមពីយើងទេ ការសម្រាកនៅមន្ទីពេទ្យរបស់អ្នក នឹងមិនត្រូវបានរ៉ាប់រងឡើយ។

សេវាវះកាត់

យើងរ៉ាប់រងលើការវះកាត់ចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលបានធ្វើឡើងនៅក្នុងមន្ទីរពេទ្យ។

លំដាប់បណ្តុំហ្សែនទាំងមូលឆាប់រហ័ស

លំដាប់បណ្តុំហ្សែនទាំងមូលឆាប់រហ័ស (Rapid Whole Genome Sequencing, "rWGS") ដែលរួមមានការចាត់ថ្នាក់បុគ្គល ការចាត់ថ្នាក់ទាំងបីសម្រាប់មាតាបិតា ឬមាតាបិតា និងទារករបស់ពួកគេ និងការចាត់ថ្នាក់រហ័សបំផុត គឺជាអត្ថប្រយោជន៍ដែលត្រូវបានរ៉ាប់រងសម្រាប់សមាជិក Medi-Cal ណាដែលមានអាយុមួយឆ្នាំ ឬក្មេងជាងនេះ និង កំពុងទទួលសេវាសម្រាកព្យាបាលក្នុងមន្ទីរពេទ្យនៅផ្នែកថែទាំកម្រិតធ្ងន់។ rWGS គឺជាវិធីសាស្ត្រដែលកំពុងលេចឡើងក្នុងការធ្វើរោគវិនិច្ឆ័យស្ថានភាពទាន់ពេលវេលា ដើម្បីមានឥទ្ធិពលដល់ការថែទាំ នៃកមើលថែទាំជិតដល់ (Intensive Care Unit, ICU) របស់កុមារដែលមានអាយុមួយឆ្នាំចុះក្រោម។ ប្រសិនបើកូនរបស់អ្នកមានសិទ្ធិទទួលបាន California Children's Services ("CCS") នោះ CCS អាចនឹងទទួលខុសត្រូវចំពោះការរ៉ាប់រងការស្នាក់នៅក្នុងមន្ទីរពេទ្យ និង rWGS។

សេវាអង្កេត

សេវាអង្កេតគឺជាសេវាឱសថ គ្រឿងបរិក្ខារ ដំណើរការ ឬសេវាវេជ្ជសាស្ត្រផ្សេងទៀតដែល កំពុងត្រូវបានសិក្សានៅលើមនុស្សដើម្បីកំណត់ថាតើពួកគេមានប្រសិទ្ធិភាពនិងសុវត្ថិភាពឬទេ។ យើងរ៉ាប់រងសេវាអង្កេតតែនៅពេលដែលលក្ខខ័ណ្ឌទាំងអស់ខាងក្រោមត្រូវបានឆ្លើយតបប៉ុណ្ណោះ៖

- ការព្យាបាលស្តង់ដារនឹងមិនព្យាបាលស្ថានភាពជំងឺបានគ្រប់គ្រាន់
- ការព្យាបាលស្តង់ដារនឹងមិនបង្ការពិការភាពដែលធ្ងន់ធ្ងរ ឬការស្លាប់មុនអាយុ
- អ្នកផ្តល់សេវានៃសេវានេះមានកំណត់ត្រាសុវត្ថិភាពនិងជោគជ័យដែលរឹងមាំ
- សេវានេះមិនមែនជាផ្នែកនៃពិធីការសិក្សាស្រាវជ្រាវ
- មានការរំពឹងទុកដោយសមហេតុផលថា សេវានឹងពន្យារអាយុជីវិតបានយូរ ឬនឹងរក្សា ឬស្តារឡើងវិញនូវសកម្មភាពនៃមុខងារការរស់នៅប្រចាំថ្ងៃ

រាល់សេវាអង្កេតទាំងអស់តម្រូវឲ្យមានការយល់ព្រមជាមុន។ សូមមើល "ការត្រួតពិនិត្យសើរើរវេជ្ជសាស្ត្រឯករាជ្យ" នៅក្នុងជំពូកទី 6 ("ការរាយការណ៍និង ការដោះស្រាយបញ្ហា") ដើម្បីស្វែងយល់អំពីការត្រួតពិនិត្យផ្សេងផ្ទាត់វេជ្ជសាស្ត្រឯករាជ្យទៅលើសំណើសម្រាប់សេវាអង្កេត។

ឱសថដែលត្រូវបានរ៉ាប់រងជាផ្នែកនៃសេវាស៊ើបអង្កេតត្រូវបានរ៉ាប់រងដោយ Kaiser Permanente និងមិនមែន Medi-Cal Rx ទេ។ អ្នកត្រូវតែទៅឱសថស្ថានបណ្តាញ Kaiser Permanente ដើម្បីបំពេញវេជ្ជបញ្ជាដែលទាក់ទងនឹងសេវាស៊ើបអង្កេតដើម្បីឲ្យថ្នាំទទួលបានការធានារ៉ាប់រង។

ឱសថ បរិក្ខារផ្គត់ផ្គង់ និងថ្នាំបំប៉នមានវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យដែលរ៉ាប់រងដោយ Kaiser Permanente

ឱសថវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកពេទ្យភាគច្រើនត្រូវបានរ៉ាប់រងដោយ Medi-Cal Rx ក្នុងភាពជាសេវាមួយតាមរយៈកម្មវិធី Medi-Cal បង់ថ្លៃ-ពេលប្រើ-សេវា ។ អ្នកអាចស្វែងយល់បន្ថែមអំពីកម្មវិធី Medi-Cal Rx ដោយចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្រោមផ្នែក "កម្មវិធី Medi-Cal និងសេវាផ្សេងៗទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" នៅពេលក្រោយ នៅក្នុងជំពូកទី 4 នេះ។

មានឱសថវេជ្ជបញ្ជា និងមុខទំនិញមួយចំនួនដែលនៅតែត្រូវបានរ៉ាប់រងដោយពួកយើង ដោយសារច្បាប់របស់រដ្ឋតម្រូវឲ្យយើងរ៉ាប់រងពួកគេ។ ផ្នែកនេះពិពណ៌នាអំពីឱសថវេជ្ជបញ្ជា និងមុខទំនិញដែលយើងនៅតែរ៉ាប់រងនៅក្រោមច្បាប់រដ្ឋ។

អាហាររូបត្ថម្ភតាមបំពង់អាហារនិងតាមសរសៃឈាម

វិធីសាស្ត្រទាំងនេះនៃការផ្តល់សារធាតុចិញ្ចឹមដល់រាងកាយត្រូវបានប្រើប្រាស់ នៅពេលដែលស្ថានភាពវេជ្ជសាស្ត្ររារាំងអ្នកពីការញ៉ាំអាហារតាមធម្មតា។ យើង រ៉ាប់រងផលិតផលអាហាររូបត្ថម្ភតាមបំពង់អាហារនិងតាមសរសៃឈាមនៅពេលដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

ថ្នាំនិងឧបករណ៍ពន្យារកំណើត

យើងរ៉ាប់រងថ្នាំ និងឧបករណ៍ពន្យារកំណើតនៅពេលចេញវេជ្ជបញ្ជាដោយអ្នកផ្តល់សេវាក្នុងបណ្តាញ។ ប្រសិនបើអ្នកទទួលបានថ្នាំ ឬឧបករណ៍ពន្យារកំណើត ពីអ្នកផ្តល់សេវាក្រៅបណ្តាញ អ្នកផ្តល់សេវានឹងស្នើសុំ Medi-Cal Rx ឲ្យបង់ប្រាក់សម្រាប់ទំនិញរបស់អ្នក។ អ្នកមិនចាំបាច់ត្រូវបង់ថ្លៃសេវាពន្យារកំណើតដែលត្រូវបានរ៉ាប់រងទេ។

គ្រឿងផ្គត់ផ្គង់តេស្តជម្ងឺទឹកនោមផ្អែម

ច្បាប់របស់រដ្ឋតម្រូវឲ្យយើងរ៉ាប់រងលើការផ្គត់ផ្គង់ការធ្វើតេស្តជំងឺទឹកនោមផ្អែម នៅពេលដែលបានចេញវេជ្ជបញ្ជាដោយអ្នកផ្តល់សេវាក្នុងបណ្តាញ។ ប្រសិនបើអ្នកទទួលបានការផ្គត់ផ្គង់ការធ្វើតេស្តជំងឺទឹកនោមផ្អែមរបស់អ្នកនៅឱសថស្ថាននៅខាងក្រៅបណ្តាញ Kaiser Permanente ឱសថស្ថានរបស់អ្នកនឹងស្នើសុំ Medi-Cal Rx ឲ្យបង់ប្រាក់សម្រាប់ការផ្គត់ផ្គង់របស់អ្នក។

ឱសថវេជ្ជបញ្ជាដទៃទៀតដែលយើងធានារ៉ាប់រង

យើងក៏រ៉ាប់រងលើមុខទំនិញដែលចេញវេជ្ជបញ្ជា ដោយអ្នកផ្តល់សេវាក្រៅបណ្តាញដូចខាងក្រោម៖

- វេជ្ជបណ្ឌិតក្រៅបណ្តាញ ប្រសិនបើ Southern California Permanente Medical Group អនុញ្ញាតការបញ្ជូនជាលាយលក្ខណ៍អក្សរទៅកាន់វេជ្ជបណ្ឌិតក្រៅបណ្តាញ ហើយទំនិញនោះត្រូវបានរ៉ាប់រងជាផ្នែកមួយនៃការបញ្ជូននោះ

- វេជ្ជបណ្ឌិតក្រៅបណ្តាញ ប្រសិនបើមុខទំនិញនោះត្រូវបានរ៉ាប់រងជាផ្នែកនៃការថែទាំសង្គ្រោះបន្ទាន់ដែលមានធានារ៉ាប់រង ឬការថែទាំបន្ទាន់ដែលត្រូវបានរ៉ាប់រង
  - ឱសថការីក្រៅបណ្តាញ ឬបន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យអាចផ្តល់ឲ្យអ្នកនូវការផ្គត់ផ្គង់បន្ទាន់ ដល់ទៅ 72 ម៉ោង

អ្នកអាចស្វែងយល់បន្ថែមអំពីកម្មវិធី Medi-Cal Rx សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្រោមផ្នែក "កម្មវិធី Medi-Cal និងសេវាផ្សេងទៀតដែលមិនត្រូវបានគ្របដណ្តប់ដោយ Kaiser Permanente" នៅពេលក្រោយ នៅក្នុងជំពូកទី 4 នេះ។

ចំនួនកំណត់ការផ្គត់ផ្គង់ពេលថ្ងៃ

មានការដាក់កម្រិតចំពោះបរិមាណឱសថឬទំនិញផ្សេងទៀត ដែលអាចត្រូវបានចែកជូនក្នុងមួយដង។

- ***ថ្នាំពន្យាកំណើតអ័រម៉ូន***

  វេជ្ជបណ្ឌិតដែលចេញវេជ្ជបញ្ជាកំណត់ថាតើឱសថ ឬទំនិញពន្យារកំណើតច្រើនប៉ុណ្ណាដែលត្រូវចេញវេជ្ជបញ្ជា។ សម្រាប់គោលបំណងនៃដែនកំណត់ធានារ៉ាប់រងសម្ភារៈផ្គត់ផ្គង់ពេលថ្ងៃ អ្នកផ្តល់សេវាក្នុងបណ្តាញកំណត់នូវអ្វីដែលជាការផ្គត់ផ្គង់ចាំបាច់ផ្នែកវេជ្ជសាស្ត្រដល់អ្នកសម្រាប់រយៈពេល 30 ថ្ងៃ ឬ 100 ថ្ងៃ ឬ 365 ថ្ងៃ។ ចំនួនច្រើនបំផុតដែលអ្នកអាចទទួលបានក្នុងមួយដង សម្រាប់ថ្នាំពន្យាកំណើតអ័រម៉ូនគឺជាការផ្គត់ផ្គង់ 365 ថ្ងៃ។

- ***មុខទំនិញផ្សេងៗទៀតទាំងអស់***

  វេជ្ជបណ្ឌិតដែលចេញវេជ្ជបញ្ជាឬទន្តពេទ្យកំណត់ថាតើឱសថ ការផ្គត់ផ្គង់ ឬថ្នាំបំប៉នច្រើនប៉ុណ្ណាត្រូវចេញវេជ្ជបញ្ជា។ វេជ្ជបណ្ឌិតក្នុងបណ្តាញសម្រេចចិត្តថាតើប៉ុន្មានជាការផ្គត់ផ្គង់ចាំបាច់ផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកសម្រាប់ 30 ថ្ងៃឬ 100 ថ្ងៃ

  ច្រើនបំផុតដែលអ្នកអាចទទួលបានក្នុងមួយដងនៃទំនិញដែលត្រូវបានរ៉ាប់រងគឺការផ្គត់ផ្គង់ 30 ថ្ងៃមួយ ក្នុងអំឡុងពេល 30 ថ្ងៃ ឬការផ្គត់ផ្គង់ 100 ថ្ងៃមួយក្នុងអំឡុងពេល 100 ថ្ងៃ។ បរិមាណឱសថឬទំនិញដែលលើសពីកម្រិតផ្គត់ផ្គង់ប្រចាំថ្ងៃមិនត្រូវបានរ៉ាប់រងឡើយ។

  ឱសថស្ថានប្រហែលជាកាត់បន្ថយការផ្គត់ផ្គង់ប្រចាំថ្ងៃដែលចែកជូនទៅជាការផ្គត់ផ្គង 30 ថ្ងៃ ក្នុងអំឡុងពេល 30 ថ្ងៃណាមួយ ប្រសិនបើឱសថស្ថានរកឃើញថា ទំនិញនោះនៅក្នុងការផ្គត់ផ្គង់ ដែលមានកំណត់នៅក្នុងទីផ្សារ ឬសម្រាប់ឱសថដាក់លាក់ (ឱសថស្ថានក្នុងបណ្តាញរបស់អ្នក អាចប្រាប់អ្នកថាតើថ្នាំដែលអ្នកលេបជាថ្នាំមួយក្នុងចំណោមថ្នាំទាំងនោះឬទេ)។

បញ្ជីរូបមន្តឱសថសម្រាប់ទំនិញមានវេជ្ជបញ្ជាដែលរ៉ាប់រងដោយ Kaiser Permanente

យើងរ៉ាប់រងទំនិញចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលតម្រូវឲ្យមានវេជ្ជបញ្ជា និងទំនិញជាក់លាក់ មួយចំនួនដែលអាចរកទិញបានដោយគ្មានវេជ្ជបញ្ជា (over the counter, "OTC")។ យើងរ៉ាប់រងលើមុខទំនិញទាំងនេះ នៅពេលអ្នកទទួលវាជាផ្នែកមួយនៃការស្នាក់ នៅក្នុងមន្ទីរពេទ្យដែលមានការធានារ៉ាប់រង ឬនៅពេលអ្នកទទួលវាជាផ្នែកមួយនៃការទៅជួបគ្រូពេទ្យ។ យើងក៏ធានារ៉ាប់រងលើមុខទំនិញមួយចំនួនដែលបានតម្រូវនៅក្រោមច្បាប់រដ្ឋ នៅពេលដែលទំនិញទាំងនោះត្រូវបានចែកចាយពីឱសថស្ថានជំងឺមិនសម្រាកមន្ទីរពេទ្យក្រៅបណ្តាញ។ យើងរ៉ាប់រងទំនិញដែលចេញវេជ្ជបញ្ជាដោយអ្នកផ្តល់សេវា ក្នុងបណ្តាញនៅក្នុងវិសាលភាព នៃអាជ្ញាប័ណ្ណនិងវិជ្ជាជីវៈរបស់ពួកគេ ស្របជាមួយនឹងសេចក្តីណែនាំបញ្ជីឱសថរបស់យើង។

បញ្ជីរូបមន្តឱសថរបស់យើងរួមមានបញ្ជីថ្នាំដែលគណៈកម្មាធិការឱសថស្ថាន និងការព្យាបាលរបស់យើងបានយល់ព្រមសម្រាប់សមាជិករបស់យើង។ គណកម្មាធិការឱសថស្ថាន និងការព្យាបាលរបស់យើង គឺជាក្រុមវេជ្ជបណ្ឌិតក្នុងបណ្តាញ និងឱសថការីដែលត្រួតពិនិត្យឱសថទៅលើភាពមានសុវត្ថិភាព និងប្រសិទ្ធភាព។ គណកម្មាធិការឱសថស្ថាន និងការព្យាបាល សម្រេចថាតើថ្នាំមួយណានឹងស្ថិតនៅក្នុងបញ្ជីរូបមន្តឱសថ Kaiser Permanente។ គណៈកម្មាធិការឱសថស្ថាន និងការព្យាបាលត្រូវជួបប្រជុំយ៉ាងហោចណាស់រៀងរាល់ត្រីមាស ដើម្បីពិចារណាលើការបន្ថែម និងការលុបដោយផ្អែកលើព័ត៌មានថ្មី ឬថ្នាំដែលអាចរកបាន។

ដើម្បីចង់ដឹងថាតើថ្នាំមាននៅលើបញ្ជីឱសថឬអត់ ឬដើម្បីទទួលបានមួយច្បាប់នៃបញ្ជីឱសថ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក **1-800-464-4000** (TTY **711**)។

ចំណាំ៖ ការពិតដែលថាឱសថមួយមាននៅក្នុងបញ្ជីមិនចាំបាច់មានន័យថាវេជ្ជបណ្ឌិតនឹងចេញវេជ្ជបញ្ជា ឲ្យប្រើវាសម្រាប់លក្ខខ័ណ្ឌវេជ្ជសាស្ត្រជាក់លាក់មួយនោះទេ។

បញ្ជីឱសថមានកិច្ចសន្យា សម្រាប់ឱសថព្យាបាលជំងឺមិនស្នាក់ក្នុងមន្ទីរពេទ្យដែលរ៉ាប់រងដោយ Medi-Cal Rx

អ្នកអាចបើស្វែងយល់បន្ថែមអំពីកម្មវិធី Medi-Cal Rx សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្រោមផ្នែក "កម្មវិធី Medi-Cal និងសេវាផ្សេងទៀតដែលមិនត្រូវបានគ្របដណ្តប់ដោយ Kaiser Permanente" នៅពេលក្រោយ នៅក្នុងជំពូកទី 4 នេះ។

ឱសថស្ថាន

អ្នកអាចទៅបើកថ្នាំវេជ្ជបញ្ជារបស់អ្នកនៅឱសថស្ថានបណ្តាញ Kaiser Permanente ឬអ្នកអាចទៅកាន់ឱសថស្ថាន Medi-Cal Rx សម្រាប់វេជ្ជបញ្ជា Medi-Cal ភាគច្រើនរបស់អ្នក។ ប្រសិនបើវេជ្ជបញ្ជារបស់អ្នកជាផ្នែកនៃការព្យាបាលស៊ើបអង្កេត ឬសេវាថែទាំជំងឺដំណាក់កាលចុងក្រោយដែលមានការធានារ៉ាប់រង អ្នកត្រូវតែទៅបើកឱសថវេជ្ជបញ្ជានៅឱសថស្ថានបណ្តាញ Kaiser Permanente។

- ***ទទួលបានវេជ្ជបញ្ជានៅឯឱសថស្ថាន Kaiser Permanente***

  អ្នកអាចស្វែងរកទីតាំងឱសថស្ថានរបស់យើងនៅលើគេហទំព័ររបស់យើងនៅ **kp.org/facilities** (ជាភាសាអង់គ្លេស) ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនង

សេវាសមាជិករបស់យើងតាមរយៈលេខ **1-800-464-4000** (TTY **711**) សម្រាប់ទីតាំងនិងម៉ោងនៃឱសថស្ថានក្នុងបណ្តាញនៅក្នុងមូលដ្ឋានរបស់អ្នក។

នៅពេលដែលអ្នកជ្រើសរើសឱសថស្ថានហើយ យកវេជ្ជបញ្ជារបស់អ្នកទៅឱសថស្ថាននោះ។ ផ្តល់ទៅឱសថស្ថាននូវវេជ្ជបញ្ជារបស់អ្នក រួមទាំងអត្តសញ្ញាណប័ណ្ណ Kaiser Permanente របស់អ្នក។ សូមប្រាកដថាឱសថស្ថានដឹងអំពីឱសថទាំងអស់ដែលអ្នកកំពុងប្រើនិងអាឡែកហ្ស៊ីណាមួយដែលអ្នកមាន។ ប្រសិនបើអ្នកមានសំណួរអំពីវេជ្ជបញ្ជារបស់អ្នក សូមប្រាកដថាអ្នកសួរឱសថការី។

នៅពេលដែលអ្នកត្រូវការទៅបើកថ្នាំជាថ្មី អ្នកអាចទូរស័ព្ទទៅជាមុន បញ្ជាទិញតាមប្រៃសណីយ៍ ឬបញ្ជាទិញតាមអនឡាញ។ ឱសថស្ថានមួយចំនួនមិនផ្តល់ជូនការបើកថ្នាំដែលត្រូវបានរ៉ាប់រងទេ ហើយមិនមែនរាល់ឱសថទាំងអស់ អាចត្រូវបានផ្ញើតាមរយៈសេវាបញ្ជាតាមប្រៃសណីយ៍របស់យើងដែរ។ សុំបសួរឱសថស្ថានរបស់អ្នក ប្រសិនបើអ្នកមានសំណួរថាតើឱសថវេជ្ជបញ្ជារបស់អ្នកអាចត្រូវបានផ្ញើតាមប្រៃសណីយ ឬទទួលបាននៅឱសថស្ថានក្នុងបណ្តាញឬទេ។ រាល់មុខទំនិញដែលមានតាមរយៈសេវាបញ្ជាទិញតាមប្រៃសណីយ៍របស់យើងអាចមានការផ្លាស់ប្តូរ គ្រប់ពេលដោយមិនមានការជូនដំណឹង។

- ***ទទួលបានវេជ្ជបញ្ជានៅឱសថស្ថាន Medi-Cal Rx***

  សូមចូលទៅកាន់ចំណងជើង "Medi-Cal Rx" នៅក្នុងផ្នែក "កម្មវិធី និងសេវាកម្ម Medi-Cal ផ្សេងទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" សម្រាប់ព័ត៌មានស្តីពីការស្វែងរកឱសថស្ថាន Medi-Cal Rx នៅខាងក្រៅបណ្តាញ Kaiser Permanente។

Medicare ផ្នែក D

ប្រសិនបើអ្នកត្រូវបានរ៉ាប់រងដោយ Medi-Cal និងមានសិទ្ធិទទួល ឬចុះឈ្មោះក្នុង Medicare ជាមួយការធានារ៉ាប់រងផ្នែក D Medicare ផ្នែក D នឹងបង់ប្រាក់មុន។ ជួនកាល ឱសថដែលរ៉ាប់រងដោយ Medi-Cal ប្រហែលជាមិនត្រូវបានរ៉ាប់រងដោយកម្មវិធី Medicare ផ្នែក D។ ប្រសិនបើ Medicare មិនរ៉ាប់រងលើឱសថដែលរ៉ាប់រងដោយ Medi-Cal វាអាចនៅតែត្រូវបានរ៉ាប់រងក្រោមធានារ៉ាប់រង Medi-Cal របស់អ្នក។ ប្រសិនបើអ្នកជាសមាជិកអត្ថប្រយោជន៍ជនចាស់ជរា Kaiser Permanente ហើយចង់ដឹងបន្ថែម អំពីការធានារ៉ាប់រងលើថ្លៃថ្នាំពេទ្យ Medicare ផ្នែក D របស់អ្នកសូមមើលភស្តុតាងនៃការធានារ៉ាប់រង (Evidence of Coverage) Senior Advantage។ អ្នកក៏អាចស្វែងយល់ពីរបៀបទទួលបានជំនួយបន្ថែមដើម្បីបង់ថ្លៃសម្រាប់ចំណាយចេញពីហោប៉ៅ របស់អ្នកផងដែរ។

ដើម្បីស្វែងយល់បន្ថែមអំពី Medicare ផ្នែក D (ដែលរួមបញ្ចូលការចុះឈ្មោះចូលជាសមាជិកផ្នែក D) សូមទូរស័ព្ទទៅសេវាបម្រើសមាជិកនៅ **1-800-443-0815** (TTY **711**)។ អ្នកក៏អាចទូរស័ព្ទទៅ Medicare ដោយឥតគិតថ្លៃលេខ (**1-800-633-4227**) (TTY **1-877-486-2048**) ឬចូលទៅគេហទំព័ររបស់ពួកគេ **www.medicare.gov** (ជាភាសាអង់គ្លេស)។

សេវានិងឧបករណ៍ ("ការព្យាបាល") ពង្រឹងនិងស្តារនីតិសម្បទា

យើងរ៉ាប់រងសេវាកម្មស្តារនីតិសម្បទានិងនិតិសម្បទាដែលបានពិពណ៌នានៅក្នុងផ្នែកនេះ ប្រសិនបើលក្ខខណ្ឌតម្រូវដូចខាងក្រោមត្រូវបានបំពេញ ៖

- សេវាកម្មនោះមានសារៈសំខាន់ខាងវេជ្ជសាស្ត្រ
- សេវាកម្មនោះគឺដើម្បីដោះស្រាយស្ថានភាពសុខភាព
- សេវានោះគឺដើម្បីជួយអ្នកអោយរក្សា ស្វែងយល់ និងកែលម្អជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ
- អ្នកទទួលសេវានោះនៅទីតាំងរបស់ផែនការលើកលែងតែវេជ្ជបណ្ឌិត ក្នុងបណ្តាញកំណត់ថា វាមានភាពចាំបាច់ខាងវេជ្ជសាស្ត្រក្នុងការដែលអ្នកទទួលបានសេវានោះនៅក្នុងទីតាំង មួយទៀត

វិធីព្យាបាលតាមម្ជុលវិទ្យាសាស្ត្រ

យើងរ៉ាប់រងសេវាចាក់ម្ជុលវិទ្យាសាស្ត្រដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រដើម្បីបង្ការ កែប្រែ ឬកាត់បន្ថយការទទួលរងភាពឈឺចាប់ការ៉ែធ្ងន់ធ្ងរមិនព្រមបាត់ ដែលបណ្តាលមកពីស្ថានភាពវេជ្ជសាស្ត្រជំងឺដែលត្រូវបានទទួលស្គាល់ជាទូទៅ។ សេវាចាក់ម្ជុលវិទ្យាសាស្ត្រមិនតម្រូវឲ្យមានការបញ្ជូន ឬការយល់ព្រមជាមុនទេ។

សេវាម្ជុលវិទ្យាសាស្ត្រគឺត្រូវបានរ៉ាប់រង នៅពេលទទួលបានតាមរយៈអ្នកផ្តល់សេវាក្នុងបណ្តាញ ឬអ្នកផ្តល់សេវាក្នុងបណ្តាញ American Specialty Health។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាម្ជុលវិទ្យាសាស្ត្រ សូមទាក់ទងផ្នែកសុខភាពឯកទេសអាមេរិក លេខ **1-800-678-9133** (TTY **711**)។

សរនវិជ្ជា (ការស្តាប់)

យើងរ៉ាប់រងសេវាព្យាបាលការស្តាប់ដែលចាំបាច់ខាងវេជ្ជសាស្ត្រ។

ការព្យាបាលសុខភាពអាកប្បកិរិយា

យើងរ៉ាប់រងលើសេវាព្យាបាលសុខភាពអាកប្បកិរិយា (Behavioral Health Treatment, "BHT") សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ អត្ថប្រយោជន៍នៃការពិនិត្យដំបូង និងតាមកាលកំណត់របស់សហព័ន្ធ ការពិនិត្យរោគវិនិច្ឆ័យ និងការព្យាបាល ("EPSDT") ។ BHT រួមបញ្ចូលសេវាកម្មនិងកម្មវិធីព្យាបាលដូចជា ការវិភាគអាកប្បកិរិយាអនុវត្តនិងកម្មវិធីអន្តរាគមន៍លើអាកប្បកិរិយាផ្នែកលើភស្តុតាងដែលអភិវឌ្ឍ ឬស្តារឡើងវិញ ដល់កម្រិតអតិបរមាដែលអាចអនុវត្តបានទូរមុខងារដំណើការរបស់បុគ្គលម្នាក់ មានអាយុក្រោម 21 ឆ្នាំ។

សេវា BHT បង្រៀនជំនាញដោយការប្រើការសង្កេតនិងការពង្រឹងអាកប្បកិរិយា ឬតាមរយៈការបំផុសគំនិតដើម្បីបង្រៀនជំហាននីមួយៗនៃអាកប្បកិរិយាគោលដៅ។ សេវា BHT ត្រូវបានផ្នែកលើភស្តុតាងដែលអាចទុកចិត្តបាននិងមិនមែនជាការពិសោធន៍។ ឧទាហរណ៍នៃសេវា BHT រួមមានអន្តរាគមន៍អាកប្បកិរិយា ឯកសារអន្តរាគមន៍អាកប្បកិរិយាការយល់ដឹង ការព្យាបាលអាកប្បកិរិយាដែលទូលំទូលាយ និងការវិភាគអាកប្បកិរិយាអនុវត្ត។

សេវា BHT ត្រូវតែជាការចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលត្រូវបានចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិតដែលមានអាជ្ញាប័ណ្ណ ឬចិត្តវិទូដែលត្រូវបានយល់ព្រមដោយ Southern California Permanente Medical Group ហើយត្រូវបានផ្តល់ជូនតាមវិធីដែលអនុវត្តតាមផែនការព្យាបាលដែលបានព្រមព្រៀង។

ផែនការព្យាបាល៖

- ត្រូវតែបានបង្កើតឡើងដោយអ្នកផ្តល់សេវាក្នុងបណ្តាញដែលជាអ្នកផ្តល់សេវាជម្ងឺអូធីសឹមដែល មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអាចត្រូវបានគ្រប់គ្រងដោយអ្នកផ្តល់សេវាជម្ងឺអូធីសឹមដែល មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬអ្នកមានវិជ្ជាជីវៈសេវាជម្ងឺអូធីសឹមដែលមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ ឬអ្នកមានវិជ្ជាជីវៈជំនួសផ្នែកសេវាអូធីសឹមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- មានគោលដៅផ្តល់ខ្លួនដែលអាចវាស់វែងបានសម្រាប់អំឡុងពេលជាក់លាក់មួយ ដែលត្រូវបានបង្កើតនិងយល់ព្រមដោយអ្នកផ្តល់សេវាជម្ងឺអូធីសឹមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់សមាជិកដែលកំពុងទទួលការព្យាបាល
- ត្រូវបានត្រួតពិនិត្យមិនតិចជាងមួយដង រៀងរាល់ប្រាំមួយខែដោយអ្នកផ្តល់សេវាជម្ងឺអូធីសឹមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងធ្វើការកែសម្រួលនៅពេលណាដែលសមរម្យ
- ធ្វើឲ្យប្រាកដថាអន្តរាគមន៍គឺស្របតាមវិធីបច្ចេកទេស BHT ដែលផ្អែកលើភស្តុតាង
- រួមមានការសម្របសម្រួលតំហែទាំពាក់ព័ន្ធទៅនឹងឪពុកម្តាយ ឬអ្នកផ្តល់ការថែទាំ សាលារៀន ឬកម្មវិធីពិការភាពរបស់រដ្ឋ និងផ្សេងទៀតតាមដែលអាចអនុវត្ត
- រួមមានការបណ្តុះបណ្តាល ការគាំទ្រ និងការចូលរួមរបស់ឪពុកម្តាយ/អ្នកផ្តល់ការថែទាំ
- ពិពណ៌នាចំណុចខ្វះខាតផ្នែកសុខភាពអាកប្បកិរិយារបស់សមាជិកដែលនឹងត្រូវបានព្យាបាល ព្រមទាំងលក្ខណៈវិនិច្ឆ័យវាយតម្លៃវាស់វែងលទ្ធផលដែលត្រូវបានប្រើដើម្បីវាស់ស្ទង់សមិទ្ធផលនៃគោលដៅអាកប្បកិរិយា
- រួមមានប្រភេទនៃសេវា ចំនួនម៉ោង និងការចូលរួមរបស់ឪពុកម្តាយដែលត្រូវការដើម្បីសម្រេចគោលដៅនិងគោលបំណងរបស់ផែនការ ហើយនិងភាពញឹកញាប់ដែលការរីកចំរើនរបស់សមាជិកត្រូវបានវាយតម្លៃ និងរាយការណ៍
- ប្រើប្រាស់ការអនុវត្តន៍ផ្អែកលើភស្តុតាង ជាមួយភាពសក្តិសិទ្ធនៃការព្យាបាលដែលត្រូវបានបង្ហាញ ក្នុងការព្យាបាលជម្ងឺអូធីសឹម ឬរិបត្តិនៃការរីកលូតលាស់ដែលរាលដាល

ការរាំប់រង Medi-Cal មិនរួមបញ្ចូល៖

- BHT ដែលត្រូវបានផ្តល់នៅពេលអត្ថប្រយោជន៍ការព្យាបាលបន្ត មិនត្រូវបានរំពឹងទុក
- សេវាដែលជាចំបងគឺបណ្តោះអាសន្ន ការថែទាំពេលថ្ងៃ ឬលក្ខណៈអប់រំ

- សំណងសម្រាប់ការចូលរួមនៃឪពុកម្តាយក្នុងកម្មវិធីព្យាបាល
- ការព្យាបាលនៅពេលដែលគោលបំណងមានលក្ខណៈវិជ្ជាជីវៈ ឬការកំសាន្ត
- ការថែទាំលាងសំអាត គឺត្រូវបានផ្តល់ជាចម្បង (i) ដើម្បីជួយនៅក្នុងសកម្មភាពការរស់នៅប្រចាំថ្ងៃ (ដូចជា ការងូតទឹក ការស្លៀកពាក់ ការញ៉ាំអាហារ និងការរក្សាអនាម័យផ្ទាល់ខ្លួន) (ii) ដើម្បីរក្សាសុវត្ថិភាពសមាជិក ឬអ្នកដទៃ និង (iii) អាចត្រូវបានផ្តល់ដោយអ្នកដែលគ្មានជំនាញ ឬការបណ្តុះបណ្តាល
- សេវា សម្ភារៈផ្គត់ផ្គង់ ឬដំណើរការដែលបានអនុវត្តឡើងនៅទីកន្លែងមិនធម្មតា រួមមាន ប៉ុន្តែកំណត់ចំពោះតែ តំបន់រមណីយដ្ឋាន ស្ប៉ា និងកន្លែងបោះតង់
- សេវាដែលបានផ្តល់ដោយឪពុកម្តាយ អាណាព្យាបាលស្របច្បាប់ ឬបុគ្គលទទួលខុសត្រូវស្របច្បាប់

ប្រសិនបើអ្នកមានសំណួរ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

ការស្តារដំណើរការបេះដូងឡើងវិញ

យើងរ៉ាប់រងសេវាស្តារដំណើរការបេះដូងសម្រាប់ជំងឺសម្រាកក្នុងមន្ទីរពេទ្យ និងមិនសម្រាកមន្ទីរពេទ្យ ដែលចាំបាច់ខាងវេជ្ជសាស្ត្រ។

បរិក្ខារវេជ្ជសាស្ត្រប្រើជាប់បានយូរ

ឧបករណ៍វេជ្ជសាស្ត្រប្រើប្រាស់បានយូរ ("DME") រួមបញ្ចូលមុខទំនិញដែលត្រូវនឹងលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម:

- មុខទំនិញនោះក្នុងគោលបំណងសម្រាប់ការប្រើប្រាស់ម្តងហើយម្តងទៀត
- មុខទំនិញនោះត្រូវបានប្រើប្រាស់ជាចម្បង និងជាទម្លាប់ដើម្បីបម្រើគោលបំណងវេជ្ជសាស្ត្រ
- មុខទំនិញនោះជាទូទៅមានប្រយោជន៍សម្រាប់តែអ្នកដែលមានជំងឺ ឬរបួសប៉ុណ្ណោះ
- មុខទំនិញនោះគឺសមរម្យសម្រាប់ប្រើប្រាស់ក្នុងផ្ទះ
- មុខទំនិញនោះចាំបាច់ដើម្បីជួយអ្នកក្នុងសកម្មភាពនៃការរស់នៅប្រចាំថ្ងៃ (activities of daily living, "ADL")

បរិក្ខាវេជ្ជសាស្ត្រជាប់បានយូរតម្រូវឲ្យមានការអនុញ្ញាតជាមុន។ យើងរ៉ាប់រងការទិញ ឬការជួលសម្ភារៈផ្គត់ផ្គង់វេជ្ជសាស្ត្រ បរិក្ខារ និងសេវាផ្សេងៗទៀតដោយមាន វេជ្ជបញ្ជាពីវេជ្ជបណ្ឌិត ប្រសិនបើទំនិញនោះមានភាពចាំបាច់ខាងវេជ្ជសាស្ត្រ ហើយត្រូវបានយល់ព្រមជាមុន សម្រាប់អ្នក។ ការផ្តល់ជូននេះត្រូវបានកំណត់ត្រឹមបរិក្ខាដែលមានតម្លៃទាបបំផុតដែលបំពេញតម្រូវការពេញលេញផ្នែកវេជ្ជសាស្ត្ររបស់អ្នក។ យើងជ្រើសរើសអ្នកលក់។ អ្នកត្រូវតែផ្ទេរក្រឿងបរិក្ខារនោះត្រឡប់មកឲ្យយើងវិញ ឬបង់ថ្លៃមកយើងតាមតម្លៃទីផ្សារ ដែលសមរម្យសម្រាប់បរិក្ខានោះ នៅពេលដែលយើងលែងរ៉ាប់រងវា។

ផែនការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលដូចខាងក្រោម៖

- គ្រឿងបរិក្ខារ ឬលក្ខណៈពិសេសសម្រាប់ជាសុកភាព ភាពងាយស្រួលឬ ប្រណិតលើកលែងតែ ម៉ាស៊ីនបូមទឹកដោះកម្រិតលក់រាយដូចដែលបានពិពណ៌នាក្រោម "ម៉ាស៊ីនបូមទឹកដោះនិងសម្ភារៈផ្គត់ផ្គង់" ក្រោមចំណងជើង "សម្ភពនិងការថែទាំទារកទើបនឹងកើត" ក្នុងជំពូកនេះ
- ទំនិញដែលមិនមានបំណងសម្រាប់ការរក្សាសកម្មភាពធម្មតានៃការរស់នៅប្រចាំថ្ងៃ ដូចជាគ្រឿងបរិក្ខាហាត់ប្រាណ (រួមមានឧបករណ៍ដែលមានបំណងផ្តល់ជំនួយបន្ថែមសម្រាប់ការកំសាន្ត ឬសកម្មភាពកីឡា)
- បរិក្ខាអនាម័យ លើកលែងតែចាំបាច់ខាងវេជ្ជសាស្ត្រ សម្រាប់សមាជិកក្រោមអាយុ 21 ឆ្នាំ
- ទំនិញមិនមែនវេជ្ជសាស្ត្រដូចជាការងូតទឹកសូណា ឬជណ្តើរយន្ត
- ការកែកុនផ្ទះ ឬរថយន្តរបស់អ្នក លើកលែងតែជណ្តើរយន្តដែលមិនត្រូវការការផ្លាស់ប្តូរជាអចិន្ត្រៃយ៍ចំពោះផ្ទះរបស់អ្នក។ សម្រាប់ព័ត៌មានស្តីពីការកែប្រែដែលអាចត្រូវបានធានារ៉ាប់រងក្រោមកម្មវិធី Community Supports សូមចូលទៅកាន់ចំណងជើងនោះនៅពេលក្រោយនៅក្នុងជំពូកទី 4 នេះ។
- ឧបករណ៍សម្រាប់ធ្វើតេស្តឈាម ឬសារធាតុរាងកាយផ្សេងទៀត លើកលែងតែសម្ភារៈផ្គត់ផ្គង់ការធ្វើតេស្តជំងឺទឹកនោមផ្អែម។ ឧបករណ៍ត្រួតពិនិត្យជាតិស្ករក្នុងឈាមបន្ទះតេស្ត និងម្ជុលត្រូវបានធានារ៉ាប់រង។ សូមមើលផ្នែក "ការផ្គត់ផ្គង់ការធ្វើតេស្តជំងឺទឹកនោមផ្អែម" មុនក្នុងជំពូកនេះ សម្រាប់ព័ត៌មានបន្ថែម។
- ឧបករណ៍អេឡិចត្រូនិចត្រួតពិនិត្យបេះដូងឬសួត លើកលែងតែឧបករណ៍ត្រួតពិនិត្យដង្ហើមទារក នៅ○ពេលគេង
- ការជួសជុល ឬការជំនួសបរិក្ខាដោយសារការបាត់បង់ ការលួច ឬការប្រើប្រាស់មិនត្រឹមត្រូវ លើកលែងតែនៅពេលវាចាំបាច់ខាងវេជ្ជសាស្ត្រ សម្រាប់សមាជិកក្រោមអាយុ 21 ឆ្នាំ។
- មុខទំនិញផ្សេងៗទៀតដែលជាទូទៅមិនត្រូវបានប្រើសម្រាប់គោលបំណងថែទាំសុខភាព

កំណត់ចំណាំ៖ សេវាដែលត្រូវការការអនុញ្ញាតជាមុន (ការយល់ព្រមជាមុន) អាចមានភាព ខុសគ្នានៅក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរអ្នកផ្តល់សេវាក្នុងបណ្តាញ សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ឧបករណ៍ជំនួយការស្តាប់

យើងធានារ៉ាប់រងឧបករណ៍ជំនួយការស្តាប់ដូចបានពណ៌នាក្នុងផ្នែកនេះ ប្រសិនបើ៖

- អ្នកត្រូវបានធ្វើតេស្តសម្រាប់ការបាត់បង់ការស្តាប់ឮ

- ឧបករណ៍ជំនួយការស្តាប់ដែលចាំបាច់ខាងវេជ្ជសាស្ត្រ
- អ្នកទទួលវេជ្ជបញ្ជាពីវេជ្ជបណ្ឌិតរបស់អ្នក។
- ការផ្តល់ជូននេះត្រូវបានកំណត់ត្រឹមឧបករណ៍ដែលមានតម្លៃទាបបំផុតដែលបំពេញតម្រូវការ ផ្នែកវេជ្ជសាស្ត្ររបស់អ្នក។ យើងនឹងជ្រើសរើសថាតើនរណានឹងផ្គត់ផ្គង់ជំនួយឧបករណ៍ស្តាប់នោះ។ យើងរ៉ាប់រងឧបករណ៍ជំនួយការស្តាប់ចំនួនមួយ លើកលែងតែជំនួយមួយម្ខាងសម្រាប់ត្រចៀកនីមួយៗគឺចាំបាច់ក្នុងការទទួលបានលទ្ធផលប្រសើរខ្លាំងជាងដែលអ្នកទទួលបានឧបករណ៍តែមួយ។

- ***ឧបករណ៍ជំនួយការស្តាប់សម្រាប់សមាជិកក្រោមអាយុ 21 ឆ្នាំ***
  ច្បាប់រដ្ឋតម្រូវឲ្យកុមារដែលត្រូវការឧបករណ៍ជំនួយការស្តាប់ត្រូវបានបញ្ជូនទៅ California Children's Services ("CCS") ដើម្បីសម្រេចថាតើកូនរបស់អ្នកមានសិទ្ធិទទួលបាន CCS ឬទេ។ ប្រសិនបើកុមារមានសិទ្ធិទទួល CCS, CCS នឹងរ៉ាប់រងថ្លៃចំណាយសម្រាប់ឧបករណ៍ជំនួយការស្តាប់ ដែលចាំបាច់ខាងវេជ្ជសាស្ត្រ។ ប្រសិនបើកុមារមិនមានសិទ្ធិទទួល CCS, CCS នឹងរ៉ាប់រងសម្រាប់ឧបករណ៍ជំនួយការស្តាប់ ដែលចាំបាច់ខាងវេជ្ជសាស្ត្រជាផ្នែកនៃការរ៉ាប់រងរបស់ Medi-cal។

- ***ឧបករណ៍ជំនួយការស្តាប់សម្រាប់សមាជិកអាយុ 21 ឆ្នាំឡើងទៅ***

  នៅក្រោម Medi-Cal យើងរ៉ាប់រងដូចខាងក្រោមសម្រាប់ឧបករណ៍ជំនួយការស្តាប់នីមួយៗ៖
  - ពុម្ពត្រចៀកចាំបាច់សម្រាប់ការកាត់តម្រូវ
  - កញ្ចប់ថ្មពិលស្តង់ដារមួយ
  - ការជួបពិនិត្យដើម្បីធ្វើឲ្យប្រាកដថាឧបករណ៍ជំនួយដំណើរការត្រឹមត្រូវ
  - ការជួបពិនិត្យសម្រាប់ការសំអាតនិងការកាត់តម្រូវឧបករណ៍ជំនួយការស្តាប់របស់អ្នក
  - ការជួសជុលឧបករណ៍ជំនួយការស្តាប់របស់អ្នក

  នៅក្រោម Medi-Cal យើងនឹងរ៉ាប់រងការផ្លាស់ប្តូរឧបករណ៍ជំនួយការស្តាប់ថ្មី ប្រសិនបើ៖
  - ការបាត់បង់សោតវិញ្ញាណរបស់អ្នកគឺដល់ថ្នាក់ដែលឧបករណ៍ជំនួយការស្តាប់បច្ចុប្បន្នរបស់អ្នកមិនអាចជួយវាបាន
  - ឧបករណ៍ជំនួយការស្តាប់របស់អ្នកបានបាត់ ត្រូវគេលួច ឬបែកបាក់ (ហើយមិនអាចជួសជុលបាន) ហើយវាមិនមែនជាកំហុសរបស់អ្នក។ អ្នកត្រូវតែប្រគល់ឲ្យយើងនូវកំណត់ត្រាមួយប្រាប់អំពីអ្វីដែលបានកើតឡើង

  សម្រាប់មនុស្សពេញវ័យអាយុ 21 ឡើងទៅ ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូល៖
  - ការផ្លាស់ប្តូរថ្មឧបករណ៍ជំនួយការស្តាប់

សេវាសុខភាពតាមគេហដ្ឋាន

យើងរ៉ាប់រងលើសេវាសុខភាពដែលចាំបាច់ខាងវេជ្ជសាស្ត្រដែលផ្តល់ជូននៅក្នុងផ្ទះរបស់អ្នក និងដែលបានចេញវេជ្ជបញ្ជាដោយគ្រូពេទ្យរបស់អ្នក ប្រសិនបើស្ថានភាពទាំងអស់ខាងក្រោមនេះពិត៖

- អ្នកចេញពីផ្ទះមិនរួចដោយសារជំងឺ (ជាប់នៅក្នុងផ្ទះរបស់អ្នក ឬរបស់មិត្តភក្តិអ្នក ឬរបស់សមាជិកគ្រួសារអ្នក)
- ស្ថានភាពរបស់អ្នកទាមទារសេវាគិលានុបដ្ឋាយិកា អ្នកព្យាបាលដោយចលនា អ្នកព្យាបាលឯកទេស ឬក៏អ្នកព្យាបាលដោយការនិយាយ។
- វេជ្ជបណ្ឌិតក្នុងបណ្តាញរកឃើញថា វាអាចធ្វើបានក្នុងការតាមដាននិងគ្រប់គ្រងការថែទាំអ្នកនៅក្នុងផ្ទះរបស់អ្នក
- វេជ្ជបណ្ឌិតក្នុងបណ្តាញរកឃើញថាសេវាអាចត្រូវបានផ្តល់ជូន ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធិភាពនៅក្នុងផ្ទះរបស់អ្នក
- អ្នកទទួលបានសេវាពីអ្នកផ្តល់សេវាក្នុងបណ្តាញ

សេវាសុខភាពតាមផ្ទះត្រូវបានកំណត់ទៅលើសេវាដែល Medi-Cal រ៉ាប់រងដូចជា៖

- ការថែទាំដោយគិលានុបដ្ឋាយិកាជំនាញក្រៅម៉ោង
- ជំនួយសុខភាពតាមផ្ទះក្រៅម៉ោង
- សេវាសង្គមវេជ្ជសាស្ត្រ
- សម្ភារៈផ្គត់ផ្គង់វេជ្ជសាស្ត្រ

សម្ភារៈផ្គត់ផ្គង់វេជ្ជសាស្ត្រ គ្រឿងបរិក្ខា និងឧបករណ៍ប្រើប្រាស់

យើងរ៉ាប់រងគ្រឿងបរិក្ខា ឧបករណ៍ប្រើប្រាស់ និង សម្ភារៈផ្គត់ផ្គង់វេជ្ជសាស្ត្រដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចេញវេជ្ជបញ្ជាដោយអ្នកផ្តល់សេវាក្នុងបណ្តាញ រួមទាំងឧបករណ៍ស្តាប់ដែលដាក់ចូលក្នុងរាងកាយ។ គ្រឿងផ្គត់ផ្គង់វេជ្ជសាស្ត្រខ្លះ ត្រូវបានគ្របដណ្តប់ដោយ Medi-Cal Rx ហើយមិនមែនដោយសារយើងឡើយ។ អ្នកអាចសុំរកឱសថស្ថានរបស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីគ្រឿងផ្គត់ផ្គង់ណាដែលត្រូវបានគ្របដណ្តប់ដោយ Medi-Cal Rx. ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធី Medi-Cal Rx សូមមើលក្រោមចំណងជើង "Medi-Cal Rx" នៅក្រោមផ្នែក "កម្មវិធីនិងសេវាកម្មផ្សេងៗទៀតដែលមិនត្រូវបានធានារ៉ាប់រងដោយ Kaiser Permanente" នៅពេលក្រោយ នៅក្នុងជំពូកទី 4 នេះ។

ការធានារ៉ាប់រង Medi-Cal មិនរួមបញ្ចូលដូចខាងក្រោម៖

- ទំនិញប្រើប្រាស់ក្នុងផ្ទះទូទៅ រួមមានប៉ុន្តែមិនកំណត់តែចំពោះ
  - ♦ បង់ស្អិត (គ្រប់ប្រភេទ)
  - ♦ អាល់កុលលាប
  - ♦ គ្រឿងសម្អាង

- ដុំសំឡីកប្បាសនិងតម្បាររន្ធច្រមុះ
- តម្បារត្រចៀក នឹងម្សៅហុយ
- ក្រណាត់ជូតសើម
- ថ្នាំរីចហេស្សួល

- ឱសថប្រើតាមផ្ទះទូទៅ រួមមានប៉ុន្តែមិនកំណត់តែចំពោះ ដូចខាងក្រោម៖
  - ដែលប្រែងកាតពណ៌ស
  - ប្រែងនិងឡេលាបសម្រាប់ស្បែកស្ងួត
  - ផលិតផលម្សៅហុយ និងផ្សំជាមួយម្សៅហុយ
  - ភ្នាក់ងារអុកស៊ីតកម្មដូចជាអ៊ីដ្រូសែនធីរ៉ែកសៃ
  - កាបាម៉ែធីរ៉ែកសៃ និងសូដៀមធីបូរេត
  - សាប៊ូកក់សក់ដែលមិនមែនវេជ្ជបញ្ជា
- ការរៀបចំប្រែងលាបដែលមានផ្ទុកក្រមួនអាស៊ីតបិនស្សូអ៊ិក និងសាលីស៊ីលិក ក្រែមអាស៊ីត សាលីស៊ីលិក ក្រមួនឬថ្នាំរ៉ាវនិងស័ង្កសីអុកស៊ីដ
- ទំនិញផ្សេងៗទៀតដែលជាទូទៅមិនត្រូវបានប្រើជាចម្បងសម្រាប់ការថែទាំសុខភាព និងដែលត្រូវបានប្រើជាប្រចាំនិងជាចម្បងដោយមនុស្សដែលមិនមានតម្រូវការវេជ្ជ សាស្ត្រជាក់លាក់ សម្រាប់ពួកគេ

ការព្យាបាលដោយកិច្ចការងារ

យើងរ៉ាប់រងសេវាការព្យាបាលដោយកិច្ចការងារដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ រួមមានការវាយតម្លៃការព្យាបាល ដោយកិច្ចការងារ ការធ្វើផែនការព្យាបាល ការព្យាបាល ការបង្រៀន និងសេវាប្រឹក្សាយោបល់។

កំណត់ចំណាំ៖ សេវាដែលត្រូវការការអនុញ្ញាតជាមុន (ការយល់ព្រមជាមុន) អាចមានភាពខុសគ្នានៅក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរអ្នកផ្តល់សេវាក្នុងបណ្តាញ សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ការតម្រង់ក្រោងឆ្អឹងជើង/អវៈយវៈសិប្បនិម្មិត

យើងរ៉ាប់រងឧបករណ៍សិប្បនិម្មិត និងឧបករណ៍តម្រង់ក្រោងឆ្អឹងជើង ប្រសិនបើល័ក្ខខ័ណ្ឌដូចខាងក្រោមត្រូវបានបំពេញ៖

- មុខទំនិញនោះគឺចាំបាច់ខាងវេជ្ជសាស្ត្រដើម្បីស្រោចស្រង់អំពីរបៀបដែលផ្នែកនៃរាងកាយមានដំណើរការ (សម្រាប់តែសិប្បនិម្មិតប៉ុណ្ណោះ)
- មុខទំនិញនោះត្រូវបានចេញវេជ្ជបញ្ជាសម្រាប់អ្នក

- ទំនិញនោះគឺចាំបាច់ខាងវេជ្ជសាស្ត្រដើម្បីគាំទ្រផ្នែកនៃរាងកាយ (សម្រាប់តែការតម្រង់ឆ្អឹងជើងប៉ុណ្ណោះ)
- ទំនិញនោះគឺជាចាំបាច់ខាងវេជ្ជសាស្ត្រសម្រាប់អ្នកដើម្បីធ្វើសកម្មភាពនៃការរស់នៅប្រចាំថ្ងៃ
- ទំនិញនោះសមហេតុផលសម្រាប់ស្ថានភាពវេជ្ជសាស្ត្រជារួមរបស់អ្នក

ទំនិញត្រូវតែបានការអនុញ្ញាតជាមុនសម្រាប់អ្នក។ នេះរួមបញ្ចូលទាំងឧបករណ៍ស្តាប់សម្លេងដែលត្រូវបានផ្សាំក្នុងសាច់ ប៉ុងពង្រីកសុដន់/ អាវទ្រនាប់សម្រាប់អ្នកកាត់ដោះចេញ បង់រុំណែនសម្រាប់ការឆេះរលាក និងអវៈយវៈសិប្បនិម្មិត ដើម្បីស្តារមុខងារឡើងវិញ ឬជំនួសផ្នែករាងកាយ ឬដើម្បីគាំទ្រផ្នែករាងកាយដែលចុះខ្សោយ ឬខូចទ្រង់ទ្រាយ។ ការផ្តល់ជូននេះត្រូវបានកំណត់ត្រឹមបរិក្ខាទំនិញដែលមានតម្លៃទាបបំផុតដែលបំពេញតម្រូវការ ពេញលេញផ្នែកវេជ្ជសាស្ត្ររបស់អ្នក។ យើងជ្រើសរើសអ្នកលក់។

កំណត់ចំណាំ៖ សេវាដែលត្រូវការការអនុញ្ញាតជាមុន (ការយល់ព្រមជាមុន) អាចមានភាពខុសគ្នានៅក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរអ្នកផ្តល់សេវាក្នុងបណ្តាញ សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

សម្ភារៈផ្គត់ផ្គង់ការរះរន្ធលាមក និងតម្រងនោម

សម្ភារៈផ្គត់ផ្គង់ការរះប្រហោងលាមកនិងតម្រងនោមត្រូវតែបានយល់ព្រមជាមុនសម្រាប់អ្នក។

យើងរ៉ាប់រងលើថង់ដាក់លាមក បំពង់ទឹកនោម ថង់បង្ហូរ សម្ភារៈផ្គត់ផ្គង់ប្រព័ន្ធបង្ហូរនិងការបិទ។ យើងមិនរ៉ាប់រងសម្ភារៈផ្គត់ផ្គង់ក្នុងគោលបំណងដើម្បីជាសុកភាព ឬភាពងាយស្រួលទេ។ យើងក៏មិនរ៉ាប់រងផងដែរលើគ្រឿងបរិក្ខាដែលប្រណិត ឬមានលក្ខណៈពិសេស។

កំណត់ចំណាំ៖ សេវាដែលត្រូវការការអនុញ្ញាតជាមុន (ការយល់ព្រមជាមុន) អាចមានភាពខុសគ្នានៅក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរអ្នកផ្តល់សេវាក្នុងបណ្តាញ សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

ការព្យាបាលដោយចលនារាងកាយ

យើងរ៉ាប់រងសេវាការព្យាបាលដោយចលនាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ដែលរួមបញ្ចូលការវាយតម្លៃការព្យាបាលដោយចលនា ការធ្វើផែនការព្យាបាល ការព្យាបាល ការបង្រៀន សេវាប្រឹក្សាយោបល់ និងការប្រើថ្នាំព្យាបាលពីក្រៅ។

ការស្តារដំណើរការសួតឡើងវិញ

យើងរ៉ាប់រងការស្តារដំណើរការសួតដែលចាំបាច់ខាងវេជ្ជសាស្ត្រ និងដែលត្រូវបានចេញវេជ្ជបញ្ជាដោយអ្នកផ្តល់សេវាក្នុងបណ្តាញ។

សេវាទីកន្លែងមើលថែទាំដែលមានជំនាញ

យើងរ៉ាប់រងសេវាទីកន្លែងមើលថែទាំដែលមានជំនាញជាការចាំបាច់ខាងវេជ្ជសាស្ត្រ ប្រសិនបើអ្នកពិការនិងត្រូវការការថែទាំកម្រិតខ្ពស់។ សេវាទាំងនេះរួមមានបន្ទប់និងមួបអាហារ នៅទីតាំងដែលទទួលបានអាជ្ញាប័ណ្ណ ដោយមានការថែទាំដែលមានជំនាញ 24 ម៉ោងក្នុងមួយថ្ងៃ។

ការព្យាបាលដោយការនិយាយ

យើងរ៉ាប់រងការព្យាបាលដោយការនិយាយដែលចាំបាច់ខាងវេជ្ជសាស្ត្រ។

សេវាការប្តូរភេទ

យើងរ៉ាប់រងសេវាប្តូរភេទ (សេវាបញ្ជាក់ភេទពិតប្រាកដ) នៅពេលដែលវាមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ឬនៅពេលដែលសេវានោះបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការរះកែលម្អ។

ការព្យាបាលសាកល្បង

យើងរ៉ាប់រងសេវាដែលអ្នកទទួលពាក់ព័ន្ធនឹងការសាកល្បងការព្យាបាល ប្រសិនបើលក្ខខណ្ឌទាំងអស់ក្រោមត្រូវបានបំពេញ៖

- យើងនឹងបានរ៉ាប់រងសេវានោះ ប្រសិនបើវាមិនបានពាក់ព័ន្ធនឹងការសាកល្បងការព្យាបាល
- អ្នកមានលក្ខណៈសម្បត្តិចូលរួមនៅក្នុងការសាកល្បងព្យាបាល យោងទៅលើពិធីការការសាកល្បងទាក់ទងនឹងការព្យាបាលជម្ងឺមហារីក ឬលក្ខខ័ណ្ឌគំរាមកំហែងអាយុជីវិតដទៃទៀត (ជាលក្ខខ័ណ្ឌដែលមរណភាពអាចនឹងកើតមានឡើងលើកលែងតែដំណើរការនៃស្ថានភាពនោះត្រូវបានទប់ស្កាត់) ដូចដែលបានកំណត់តាមមួយក្នុងចំណោមវិធីខាងក្រោម៖
  - អ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente ធ្វើការសម្រេចចិត្តនេះ
  - អ្នកផ្តល់ឲ្យយើងនូវព័ត៌មានវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ ដែលបង្កើតឲ្យមានការសម្រេចចិត្តនេះ
- ប្រសិនបើអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente ចូលរួមនៅក្នុងការសាកល្បងការព្យាបាល ហើយនឹងទទួលយកអ្នកជាអ្នកចូលរួមនៅក្នុងការសាកល្បងព្យាបាលនោះ អ្នកត្រូវតែចូលរួមនៅក្នុងការសាកល្បងការព្យាបាលតាមរយៈអ្នកផ្តល់សេវាក្នុងបណ្តាញ Kaiser Permanente លើកលែងតែការសាកល្បងព្យាបាលនោះស្ថិតនៅក្រៅរដ្ឋដែលអ្នករស់នៅ
- ការសាកល្បងព្យាបាល គឺជាការសាកល្បងការព្យាបាលដែលត្រូវបានយល់ព្រម

"ការសាកល្បងការព្យាបាលដែលត្រូវបានយល់ព្រម" មានន័យថាការសាកល្បងការព្យាបាលដំហានទី I, ដំហានទី II, ដំហានទី III, ឬ ដំហានទី IV ដែលពាក់ព័ន្ធទៅនឹងការទប់ស្កាត់ ការរកឃើញ ឬការព្យាបាល ឬលក្ខខ័ណ្ឌគំរាមកំហែងអាយុជីវិតដទៃទៀត។ ការសាកល្បងព្យាបាលត្រូវតែបំពេញតាមមួយក្នុងចំណោមតម្រូវការខាងក្រោម៖

- ការសិក្សា ឬការអង្កេតគឺត្រូវបានប្រតិបត្តិក្រោមការប្រើប្រាស់ឱសថថ្មីលក្ខណៈអង្កេតដែលត្រូវបានត្រួតពិនិត្យដោយរដ្ឋបាលចំណីអាហារ និងឱសថអាមេរិក។
- ការសិក្សាស្រាវជ្រាវ ឬការអង្កេតគឺជាការសាកល្បងឱសថដែលត្រូវបានលើកលែងពីការប្រើប្រាស់ឱសថថ្មីដែលស្ថិតក្រោមការអង្កេត
- ការសិក្សា ឬការអង្កេតគឺត្រូវបានយល់ព្រម ឬផ្តល់ផ្តងមូលនិធិដោយយ៉ាងហោចមួយក្នុងចំណោមខាងក្រោម៖
  - វិទ្យាស្ថានជាតិនៃសុខភាព
  - មជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងការទប់ស្កាត់ជំងឺ
  - ទីភ្នាក់ងារសម្រាប់ការស្រាវជ្រាវនិងគុណភាពការថែទាំសុខភាព
  - មជ្ឈមណ្ឌលសម្រាប់សេវា Medicare និង Medicaid
  - ក្រុមសហប្រតិបត្តិការ ឬមជ្ឈមណ្ឌលនៃអង្គភាពណាមួយក្នុងចំណោមទាំងអស់ខាងលើ ឬនៃនាយកដ្ឋានការពារប្រទេស ឬនាយកដ្ឋានកិច្ចការអតីតទាហាន
  - អង្គភាពស្រាវជ្រាវមិនមែនរដ្ឋាភិបាលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលត្រូវ បានបង្ហាញ នៅក្នុងសេចក្តីណែនាំចេញដោយវិទ្យាស្ថានជាតិសុខភាពសម្រាប់មូលនិធិគាំទ្រមជ្ឈមណ្ឌល
  - នាយកដ្ឋានកិច្ចការអតីតទាហាន ឬនាយកដ្ឋានការពារប្រទេស ឬនាយកដ្ឋានថាមពល ប៉ុន្តែលើកលែងតែការសិក្សាស្រាវជ្រាវឬការអង្កេតនោះ ត្រូវបានត្រួតពិនិត្យនិងអនុម័តតាមរយៈប្រព័ន្ធវាយតម្លៃក្នុងអង្គភាព ដែលលេខាធិការសេវាសុខភាពនិងមនុស្សជាតិអាមេរិកសម្រេចឆ្លើយតបទៅនឹងតម្រូវការទាំងអស់ដូចក្រោម៖ (1) វាអាចប្រៀបធៀបបានទៅនឹងប្រព័ន្ធវាយតម្លៃក្នុងអង្គភាពលើការសិក្សាស្រាវជ្រាវនិងអង្កេតរបស់វិទ្យាស្ថានជាតិសុខភាព (2) វាធានាអះអាងការត្រួតពិនិត្យវាយតម្លៃដែលមិនលំអៀង នៃបទដ្ឋានវិទ្យាសាស្ត្រខ្ពស់បំផុត ដោយអ្នកដែលមានលក្ខណៈសម្បត្តិដែលមិនមានចំណាប់អារម្មណ៍លើលទ្ធផលនៃការវាយតម្លៃ

យើងមិនរាប់រងសេវាដែលត្រូវបានផ្តល់ជូនសម្រាប់តែការប្រមូលទិន្នន័យនិងការវិភាគនោះទេ។

ប្រសិនបើសេវាដែលទាក់ទងនឹងការសាកល្បងព្យាបាលពាក់ព័ន្ធនឹងឱសថវេជ្ជបញ្ជា សម្ភារៈផ្គត់ផ្គង់ឬថ្នាំបំប៉នសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យដែលបើមិនដូច្នោះទេនឹងត្រូវបានរាប់រងដោយ Medi-Cal Rx យើងនឹងមិនរាប់រងវាទេ។ អ្នក ឬអ្នកផ្តល់សេវារបស់អ្នកនឹងត្រូវស្នើសុំការធានារ៉ាប់រងសម្រាប់រមុខទំនិញវេជ្ជបញ្ជាពីកម្មវិធី Medi-Cal Rx ។

សេវាមន្ទីរពិសោធន៍និងវិទ្យុសកម្ម

យើងរ៉ាប់រងសេវាទីពិសោធន៍ និងការស្កេនអិចសម្រាប់ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ និងជំងឺសម្រាកក្នុងមន្ទីពេទ្យ នៅពេលមានការចាំបាច់ខាងវេជ្ជសាស្ត្រ។ ដំណើការឆ្លុះពិនិត្យបែបទំនើបផ្សេងៗ ដូចជាការថត ការថតដោយកាំរស្មី (Computerized Tomography, CT), ការថតឆ្លុះដោយកំលាំងមេដែកនិងវិទ្យុសកម្ម (Magnetic Resonance Imaging, MRI) និងការថត

ការថតឆ្លុះដោយវិទ្យុសកម្មភាពកាំរស្មីអិច (Positron Emission Tomography, PET) ត្រូវបានរាប់រងផ្នែកលើភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

សេវាបង្ការនិងសុខុមាលភាព និងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ

សេវាបង្ការ

យើងរាប់រងសេវាបង្ការដូចខាងក្រោម៖

- ថ្នាំវ៉ាក់សាំងដែលត្រូវបានណែនាំដោយគណៈកម្មាធិការប្រឹក្សាសម្រាប់ការអនុវត្តការចាក់ថ្នាំបង្ការ
- សេវាការធ្វើផែនការគ្រួសារ
- អនុសាសន៍របស់ បណ្ឌិតសភាអាមេរិចផ្នែកជំងឺកុមារ Bright Futures
- សេវាបង្ការសម្រាប់ស្ត្រីដែលត្រូវបានណែនាំដោយ វិទ្យាស្ថានវេជ្ជសាស្ត្រ រដ្ឋបាលធនធានសេវាកម្មសុខភាព, និង មហាវិទ្យាល័យអាមេរិចផ្នែកសម្ភពនិងរោគស្ត្រី
- សេវាបញ្ឈប់ការជក់បារី
- សេវាបង្ការដែលត្រូវបានផ្តល់អនុសាសន៍ដោយក្រុមអ្នកជំនាញសេវាបង្ការរបស់អាមេរិក A និង B

សេវាធ្វើផែនការគ្រួសារត្រូវបានផ្តល់ជូនដល់សមាជិកស្ថិតក្នុងវ័យបង្កើតកូន ដើម្បីជួយពួកគេកំណត់ចំនួននិងគម្លាតកូន។ សេវាទាំងនេះរួមមានមធ្យោបាយទាំងអស់នៃការពន្យាកំណើតដែលអនុម័តដោយ រដ្ឋបាលឱសថនិងចំណីអាហារ (Food and Drug Administration, FDA)។ ក្នុងនាមជាសមាជិក អ្នកជ្រើសរើសយកវេជ្ជបណ្ឌិតដែលមានទីតាំងនៅជិតអ្នក ហើយនឹងផ្តល់ឲ្យអ្នកនូវសេវាដែលអ្នកត្រូវការ។

PCP និង អ្នកឯកទេសសម្ភពនិងរោគស្ត្រីរបស់ Kaiser Permanente អាចរកបានសម្រាប់សេវាធ្វើផែនការគ្រួសារ។ សំរាប់សេវាធ្វើផែនការគ្រួសារ អ្នកក៏អាចជ្រើសរើសវេជ្ជបណ្ឌិតឬគ្លីនិក Medi-Cal ដែលមិនមានទំនាក់ទំនងជាមួយ Kaiser Permanente ផងដែរដោយមិនចាំបាច់ទទួលការបញ្ជូន ឬការយល់ព្រមជាមុន។ យើងនឹងបង់ថ្លៃទៅគ្រូពេទ្យឬគ្រិលានុបង្ហាយិកា សម្រាប់សេវាផែនការគ្រួសារដែលអ្នកទទួលបាន។

កំណត់ចំណាំ៖ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាបង្ការសម្រាប់កុមារ សូមចូលទៅផ្នែក "សេវាជំងឺកុមារ" ក្នុងជំពូកទី 4 នេះ។

Diabetes Prevention Program (“DPP”)

Diabetes Prevention Program ("DPP") គឺជាកម្មវិធីផ្លាស់ប្តូរឥរិយាបថរបស់នៅផ្នែកលើភស្តុតាង ដែលត្រូវបានបង្កើតឡើងដើម្បីការពារ ឬពន្យារពេលការចាប់ផ្តើមនៃជំងឺទឹកនោមផ្អែមប្រភេទទី 2 ក្នុងចំណោមអ្នកដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជាតិស្ករក្នុងឈាមខ្ពស់។ កម្មវិធីមានសុពលភាពមួយឆ្នាំ។ វាមានសុពលភាពសម្រាប់ឆ្នាំទីពីរ សម្រាប់សមាជិកទាំងនោះដែលមានសិទ្ធិទទួល។

កម្មវិធីនេះប្រើប្រាស់ការគាំទ្រនិងបច្ចេកទេសរបៀបរបបរស់នៅដែលបានយល់ព្រម ដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់តែចំពោះចំណុចដូចខាងក្រោម៖

- ការផ្តល់ក្រូបង្វឹកដែលមានវ័យប្រហាក់ប្រហែល
- ការបង្រៀនអំពីការត្រួតពិនិត្យខ្លួនឯង និងការដោះស្រាយបញ្ហា
- ការផ្តល់នូវការលើកទឹកចិត្តនិងមតិកប
- ការផ្តល់ឯកសារព័ត៌មានដើម្បីគាំទ្រគោលដៅ
- ការតាមដានទំងន់ជាទៀងទាត់ដើម្បីជួយសំរេចគោលដៅ

សមាជិកដែលចាប់អារម្មណ៍លើ DPP ត្រូវតែបំពេញតាមលក្ខខ័ណ្ឌតម្រូវនៃកម្មវិធី។ ទាក់ទងមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង **1-800-464-4000** (TTY **711**) សំរាប់ព័ត៌មានបន្ថែមអំពីកម្មវិធី និងសិទ្ធិទទួលបាន។

ការរះកាត់កែលម្អ

យើងរ៉ាប់រង៖

- ការរះកាត់នៅពេលមានបញ្ហាលើផ្នែកនៃរាងកាយរបស់អ្នក។ បញ្ហានេះត្រូវអាចបានបណ្តាលមកពីបញ្ហាពីកំណើត ភាពមិនប្រក្រតីផ្នែកការលូតលាស់ ការប៉ះទង្គិច ការឆ្លងមេរោគ ដុំសាច់ ជម្ងឺ ឬ របួស។ យើងរ៉ាប់រងការរះកាត់ដើម្បីកែកុន ឬជួសជុលទម្រង់ខុសពីធម្មតានៃខ្លួនប្រាណ ដើម្បីបង្កើតរូបរាងធម្មតារហូតដល់កម្រិតដែលអាចធ្វើទៅបាន។
- បន្ទាប់ពីការយកចេញផ្នែកខ្លះ ឬទាំងអស់នៃសុដន់ម្ខាងដែលជាភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ យើងរ៉ាប់រងការរះកាត់កែលម្អសុដន់នោះ រួមទាំងការរះកាត់កែលម្អសុដន់ម្ខាងទៀត ឲ្យមើលទៅមានទ្រង់ទ្រាយប្រហាក់ប្រហែលគ្នា។ យើងរ៉ាប់រងសេវាសម្រាប់ការហើមក្រោយពេលដែលដុំពកត្រូវបានកាត់ចេញ

យើងមិនរ៉ាប់រងការរះកាត់ដែលនឹងផ្តល់លទ្ធផលត្រឹមតែការផ្លាស់ប្តូរអប្បបរមានៃរូបរាងរបស់អ្នកទេ។

សេវាពិនិត្យមើលវិបត្តិការប្រើប្រាស់គ្រឿងញៀន

យើងរ៉ាប់រងសេវាការពិនិត្យនិងប្រឹក្សាយោបល់សម្រាប់ការបំពានការប្រើប្រាស់គ្រឿងស្រវឹងនិងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ យើងមិនរ៉ាប់រងការព្យាបាលវិបត្តិការប្រើប្រាស់គ្រឿងញៀនទេ។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាព្យាបាលវិបត្តិការប្រើប្រាស់គ្រឿងញៀន សូមចូលទៅកាន់ចំណងជើង "សេវាព្យាបាលវិបត្តិការប្រើប្រាស់គ្រឿងញៀន" នៅក្រោមផ្នែក "អត្ថប្រយោជន៍និងកម្មវិធីផ្សេងៗទៀតដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente" នៅពេលក្រោយនៅក្នុងដំពូកនេះ។

សេវាផ្នែកចក្ខុ

ការពិនិត្យភ្នែកជាប្រចាំ

យើងរ៉ាប់រងលើការពិនិត្យភ្នែកជាប្រចាំចំនួនមួយដងរៀងរាល់ 24 ខែ។ ការពិនិត្យភ្នែកបន្ថែមត្រូវបានរ៉ាប់រងប្រសិនបើចាំបាច់ផ្នែកវេជ្ជសាស្ត្រ

វ៉ែនតា

យើងរ៉ាប់រងដូចខាងក្រោម៖

- ***វ៉ែនតាទាំងមូល (ស៊ុម និងកញ្ចក់)***

  យើងធានារ៉ាប់រងវ៉ែនតាមួយ រៀងរាល់ 24 ខែ នៅពេលដែលអ្នកមានវេជ្ជបញ្ជាយ៉ាងហោចណាស់ 0.75 ឌីអុបទ័រ។

- ***កញ្ចក់លែនស៍វ៉ែនតា***
  យើងនឹងបញ្ជាទិញវ៉ែនតាថ្មី ឬជំនួសសម្រាប់អ្នកពីឈ្មួញវ៉ែនតារបស់ នាយកដ្ឋានសេវាថែទាំសុខភាព (Department of Health Care Services, DHCS)។ ប្រសិនបើឈ្មួញរបស់ DHCS មិនអាចផ្តល់ដល់អ្នកនូវកញ្ចក់លែនស៍ដែលអ្នកត្រូវការ យើងនឹងរៀបចំឲ្យគេធ្វើលែនស៍របស់អ្នកនៅមន្ទីរពិសោធន៍ចក្ខុមួយទៀត។ អ្នកនឹងមិនចាំបាច់បង់ប្រាក់បន្ថែមទេប្រសិនបើយើងត្រូវធ្វើការរៀបចំ ដោយសារតែឈ្មួញរបស់ DHCS មិនអាចធ្វើលែនស៍វ៉ែនតារបស់អ្នកបាន។

  ប្រសិនបើអ្នកចង់បានលែនស៍វ៉ែនតា ឬលក្ខណៈពិសេសណាមួយដែលមិនត្រូវបានរ៉ាប់រងដោយ Medi-Cal នោះអ្នកអាចត្រូវបង់លុយបន្ថែមសម្រាប់ការបង្កើនគុណភាពទាំងនោះ។

- ***ស៊ុមវ៉ែនតា***
  យើងរ៉ាប់រងស៊ុមវ៉ែនតាថ្មី ឬផ្លាស់ប្តូរដែលមានតម្លៃ $80 ចុះក្រោម។ ប្រសិនបើអ្នកជ្រើសរើសយកស៊ុមដែលមានតម្លៃច្រើនជាង $80 អ្នកត្រូវចេញផ្លែខុសគ្នា រវាងតម្លៃស៊ុម និង $80 ។

- ***ការផ្លាស់ប្តូរវ៉ែនតាក្នុងអំឡុងពេល 24 ខែ៖***

  យើងរ៉ាប់រងការផ្លាស់ប្តូរវ៉ែនតា ប្រសិនបើអ្នកមានការប្តូរវេជ្ជបញ្ជាយ៉ាងហោចណាស់ 0.50 ឌីអុបទ័រ ឬវ៉ែនតារបស់អ្នកត្រូវបានបាត់ លួច ឬខូច (និងមិនអាចជួសជុលបាន) ហើយវាមិនមែនជាកំហុសរបស់អ្នក។ អ្នកត្រូវផ្តល់ឲ្យយើងនូវកំណត់ត្រាដែលប្រាប់យើងពីរបៀបដែលវ៉ែនតារបស់អ្នកបានបាត់ ត្រូវបានលួច ឬខូច។ ស៊ុមវ៉ែនតាផ្លាស់ប្តូរថ្មីនឹងមានរចនាបថដូចគ្នានឹងស៊ុមចាស់របស់អ្នក (រហូតដល់ $80) ប្រសិនបើតិចជាង 24 ខែបានកន្លងផុតទៅចាប់តាំងពីអ្នកបានទទួលវ៉ែនតារបស់អ្នក

ឧបករណ៍សម្រាប់ភ្នែកខ្សោយ

ឧបករណ៍សម្រាប់ភ្នែកខ្សោយគឺត្រូវបានរ៉ាប់រងដោយ Medi-Cal នៅពេលល័ក្ខខ័ណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ភាពមុតនៃភ្នែកដែលត្រូវបានកែល្អបំផុតគឺ 20/60 ឬ យ៉ាប់ជាងនេះនៅក្នុងភ្នែកល្អម្ខាងទៀត ឬមានកំណត់ទំហំទីដែលភ្នែកទាំងពីរអាចមើលឃើញ 10 ដឺក្រេ ឬតិចជាងនេះពីចំណុចកំណត់។
- ស្ថានភាពដែលបណ្តាលឲ្យមានការមើលឃើញតិចជាងធម្មតាគឺរ៉ាំរ៉ៃ ហើយមិនអាចសម្រាលបាន ដោយវិធីនៃការវះកាត់ ឬវេជ្ជសាស្ត្រ។
- ស្ថានភាពផ្លូវកាយនិងផ្លូវចិត្តរបស់អ្នកទទួលគឺមានការរំពឹងទុកសមហេតុផលថាជំនួយនឹងត្រូវបានប្រើដើម្បីបង្កើនមុខងារប្រចាំថ្ងៃរបស់អ្នកទទួល។

ការផ្តល់ជូននេះត្រូវបានកំណត់ត្រឹមឧបករណ៍ដែលមានតម្លៃទាបបំផុតដែលបំពេញតម្រូវការរបស់សមាជិក។ ការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលឧបករណ៍កញ្ចក់ពង្រីកអេឡិចត្រូនិចនិងឧបករណ៍ដែលមិនមានលែនស៍ សម្រាប់ការប្រើប្រាស់ជាមួយភ្នែកទេ។

លែនស៍ពាក់ក្នុងភ្នែកពិសេស

ប្រសិនបើអ្នកមានស្ថានភាពវេជ្ជសាស្ត្រដែលវេជ្ជបណ្ឌិតបណ្តាញ ឬវេជ្ជបណ្ឌិតភ្នែកសម្រេចថាវាចាំបាច់ខាងវេជ្ជសាស្ត្រសម្រាប់អ្នកក្នុងការពាក់កញ្ចក់លែនស៍ក្នុងភ្នែក យើងនឹងរ៉ាប់រងកញ្ចក់លែនស៍ទាំងនោះ។ ល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កញ្ចក់លែនស៍ពិសេស រួមមានប៉ុន្តែមិនកំណត់តែចំពោះ អានីរីឌៀ អាហ្វាគៀ គែរ៉ាតូកូណូស។

យើងនឹងផ្លាស់ប្តូរកញ្ចក់លែនស៍ដែលចាំបាច់ផ្នែកវេជ្ជសាស្ត្ររបស់អ្នក ប្រសិនបើកញ្ចក់លែនស៍របស់អ្នកបានបាត់ ឬត្រូវគេលួច។ អ្នកត្រូវតែផ្តល់ឲ្យយើងនូវកំណត់ត្រាដែលប្រាប់យើងពីរបៀបដែលកញ្ចក់លែនស៍របស់អ្នកត្រូវ បានបាត់ ឬលួច។

សម្គាល់៖ គោលការណ៍ការផ្លាស់ប្តូរលែនស៍អាចខុសគ្នាក្នុងចំណោមបណ្តាញអ្នកផ្តល់សេវារបស់ L.A. Care Health Plan។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបផ្លាស់ប្តូរអ្នកផ្តល់សេវាក្នុងបណ្តាញ សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍ រួមទាំងថ្ងៃឈប់សម្រាក។

សេវាការដឹកជញ្ជូនសម្រាប់ស្ថានភាពដែលមិនមែនសង្គ្រោះបន្ទាន់

សម្រាប់ព័ត៌មានអំពីសេវាដឹកជញ្ជូនសង្គ្រោះបន្ទាន់ សូមមើលចំណងជើង "សេវាសង្គ្រោះបន្ទាន់" នៅដើមជំពូកទី 4 នេះ។

ការដឹកជញ្ជូនខាងវេជ្ជសាស្ត្រសម្រាប់ស្ថានភាពដែលមិនមែនសង្គ្រោះបន្ទាន់

អ្នកមានសិទ្ធិទទួលបានការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រក្នុងស្ថានភាពមិនមែនសង្គ្រោះបន្ទាន់ ប្រសិនបើអ្នកមានតម្រូវការផ្នែកវេជ្ជសាស្ត្រដែលមិនអនុញ្ញាតឲ្យអ្នកប្រើប្រាស់រថយន្ត ឡានក្រុង រថភ្លើង ឬតាក់ស៊ី ដើម្បីទៅដល់ការណាត់ជួប Medi-Cal របស់អ្នក។ ការដឹកជញ្ជូនវេជ្ជសាស្ត្រអា

ចត្រូវបានផ្តល់ជូនសម្រាប់សេវា Medi-Cal ដូចជាការណាត់ជួបផ្នែកវេជ្ជសាស្ត្រ ធ្មេញ សុខភាពផ្លូវចិត្ត ការប្រើប្រាស់សារធាតុញៀន និងឱសថស្ថាន។ ក្រុមគ្រូពេទ្យរបស់អ្នកនឹងសម្រេចចិត្តអំពីប្រភេទនៃការដឹកជញ្ជូនត្រឹមត្រូវដែលអ្នកត្រូវការ។ ការដឹកជញ្ជូនវេជ្ជសាស្ត្រអាចជារថយន្តសង្គ្រោះបន្ទាន់ ឡានដឹកកាកសំណល់ ឡានដឹករទេះរុញ ឬការដឹកជញ្ជូនតាមផ្លូវអាកាស។

ការដឹកជញ្ជូនវេជ្ជសាស្ត្រត្រូវតែប្រើប្រាស់នៅពេលៈ

- អ្នកមិនអាចតាមផ្លូវកាយ ឬវេជ្ជសាស្ត្រក្នុងការប្រើប្រាស់ឡានក្រុង តាក់ស៊ី រថយន្ត ឬឡានដឹក ដើម្បីទៅដល់ការណាត់ជួបរបស់អ្នកបាន
- អ្នកត្រូវការជំនួយពីអ្នកបើកបរទៅនិងមកពីលំនៅដ្ឋាន យានយន្ត ឬទីកន្លែងព្យាបាលរបស់អ្នក ដោយសារអស្ថេរភាពផ្លូវកាយ ឬផ្លូវចិត្ត
- វាត្រូវបានស្នើសុំដោយវេជ្ជបណ្ឌិតក្នុងបណ្តាញនិងត្រូវបានអនុញ្ញាតជាមុន

ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកសម្រេចថាអ្នកត្រូវការការដឹកជញ្ជូនខាងវេជ្ជសាស្ត្រ ពួកគេនឹងចេញវេជ្ជបញ្ជាវាសម្រាប់អ្នក។ យើងនឹងទូរស័ព្ទទៅអ្នកដើម្បីរៀបចំកាលវិភាគការដឹកជញ្ជូនខាងវេជ្ជសាស្ត្ររបស់អ្នក។

ចំនួនកំណត់ការដឹកជញ្ជូនខាងវេជ្ជសាស្ត្រ

នៅក្នុងស្ថានភាពដែលមិនមានភាពអាសន្ន យើងរ៉ាប់រងលើថ្លៃដឹកជញ្ជូនវេជ្ជសាស្ត្រដែលមានតម្លៃទាបបំផុតសម្រាប់តម្រូវការវេជ្ជសាស្ត្ររបស់អ្នកទៅកាន់អ្នកផ្តល់សេវាដែលនៅជិតបំផុតដែលជាកន្លែងមានការណាត់ជួប។ នោះមានន័យថា ឧទាហរណ៍ ប្រសិនបើអ្នកមានលទ្ធភាពផ្នែករាងកាយ ឬវេជ្ជសាស្ត្រក្នុងការត្រូវបានដឹកជញ្ជូនដោយរថយន្តដាក់រទេះពិការបាន យើងនឹងមិនបង់ថ្លៃរថយន្តសង្គ្រោះបន្ទាន់ទេ។ អ្នកមានសិទ្ធិទទួលបានការដឹកជញ្ជូនតាមអាកាសប្រសិនបើស្ថានភាពវេជ្ជសាស្ត្ររបស់អ្នកធ្វើឲ្យការដឹកជញ្ជូនផ្លូវគោកមិនអាចទៅរួចប៉ុណ្ណោះ។

យើងនឹងមិនរៀបចំការដឹកជញ្ជូនវេជ្ជសាស្ត្រទេ ប្រសិនបើសេវានោះមិនត្រូវបានរ៉ាប់រងដោយ Medi-Cal។ ប្រសិនបើសេវានោះត្រូវបានរ៉ាប់រងដោយ Medi-Cal ប៉ុន្តែមិនមែនដោយពួកយើងទេ យើងនៅតែអាចជួយអ្នកក្នុងការរៀបចំការដឹកជញ្ជូនវេជ្ជសាស្ត្របាន។ ប្រសិនបើអ្នកត្រូវការការដឹកជញ្ជូនវេជ្ជសាស្ត្រនៅខាងក្រៅតំបន់ផ្ទះរបស់អ្នក ឬទៅកាន់អ្នកផ្តល់សេវាក្រៅបណ្តាញ យើងនឹងរ៉ាប់រងលើការដឹកជញ្ជូនវេជ្ជសាស្ត្រលុះត្រាតែយើងបានផ្តល់ការអនុញ្ញាតសម្រាប់អ្នក។

ថ្លៃចំណាយចំពោះសមាជិក សម្រាប់ការដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនសង្គ្រោះបន្ទាន់

មិនមានគិតថ្លៃពីអ្នកឡើយនៅពេលដែលការដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនសង្គ្រោះបន្ទាន់ត្រូវបានអនុញ្ញាតដោយយើង។

ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ

អត្ថប្រយោជន៍ Medi-Cal របស់អ្នក រួមមានការជិះទៅកាន់ការណាត់ជួបរបស់អ្នក ឬទៅកាន់ឱសថស្ថានសម្រាប់សេវាជានារ៉ាប់រងដោយ Medi-Cal ។ អ្នកអាចរកបានជំនិះ ដោយមិនគិតថ្លៃពីអ្នក នៅពេលអ្នកៈ

- ការធ្វើដំណើរទាំងទៅទាំងមកពីការណាត់ជួប សម្រាប់សេវារ៉ាប់រងដោយ Medi-Cal

- ការទៅយកឱសថមានវេជ្ជបញ្ជា និងសម្ភារៈវេជ្ជសាស្ត្រ

Kaiser Permanente អនុញ្ញាតឲ្យអ្នកប្រើរថយន្ត តាក់ស៊ី រថយន្តក្រុង ឬមធ្យោបាយសាធារណៈ/ឯកជនផ្សេងទៀត ដើម្បីទៅដល់ការណាត់ជួបវេជ្ជសាស្ត្ររបស់អ្នកសម្រាប់សេវាដែលរ៉ាប់រងដោយ Medi-Cal។ យើងអនុញ្ញាតឲ្យនូវប្រភេទ NMT តម្លៃទាបបំផុតដែលបំពេញតម្រូវការវេជ្ជសាស្ត្ររបស់អ្នក។ ជួនកាល យើងអាចបង់ប្រាក់សងអ្នកសម្រាប់ការធ្វើដំណើរតាមរថយន្តឯកជនដែលអ្នករៀបចំ។ នេះត្រូវតែបានយល់ព្រមដោយយើងមុននឹងអ្នកទទួលបានការជិះ។ អ្នកត្រូវតែប្រាប់យើង អំពីមូលហេតុដែលអ្នកមិនអាចរកបានយានជំនិះដូចជាឡានក្រុង។ យើងនឹងមិនផ្តល់សំណងដល់អ្នកសម្រាប់ការប្រើប្រាស់ឈ្នួញកណ្តាលខាងដឹកជញ្ជូន ប័ណ្ណជិះរថយន្តសាធារណៈ ប័ណ្ណជិះតាក់ស៊ី ឬ សំបុត្រជិះរថភ្លើងទេ។ ដើម្បីស្នើសុំការអនុញ្ញាតនិងលក្ខខ័ណ្ឌនិងថ្នាំយដែលបានប្រើដើម្បីធ្វើសេចក្តីសម្រេចអនុញ្ញាត សូមទូរស័ព្ទ អ្នកផ្តល់សេវាការដឹកជញ្ជូនរបស់យើងលេខ **1-844-299-6230** (TTY **711**)។ អ្នកតំណាងក៏អាចឆ្លើយសំនួរផ្សេងៗអំពីការទូទាត់សំណងចំនួនម៉ែលផងដែរ។

សូមទូរស័ព្ទទៅអ្នកផ្តល់សេវាដឹកជញ្ជូនរបស់ Kaiser Permanente លេខ **1-844-299-6230** (TTY **711**) យ៉ាងហោចណាស់បីថ្ងៃធ្វើការ (ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ) មុនការណាត់ជួបរបស់អ្នក ឬហៅទូរស័ព្ទឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេលអ្នកមានការណាត់ជួបដែលបន្ទាន់។ សូមត្រៀមអ្វីៗទាំងអស់ដូចខាងក្រោមនៅពេលដែលអ្នកទូរស័ព្ទទៅ៖

- ប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នក។
- កាលបរិច្ឆេទនិងពេលវេលានៃការណាត់ជួបវេជ្ជសាស្ត្ររបស់អ្នក
- អាសយដ្ឋានទីកន្លែងដែលអ្នកត្រូវការអោយគេមកដឹក និងអាសយដ្ឋាននៃទីកន្លែងដែលអ្នកនឹងធ្វើដំណើរទៅ
- ថាតើអ្នកនឹងត្រូវការការធ្វើដំណើរត្រឡប់មកវិញឬទេ
- ថាតើនរណាម្នាក់នឹងធ្វើដំណើរជាមួយអ្នកឬទេ (ឧទាហរណ៍ ឪពុកម្តាយឬអាណាព្យាបាលស្របច្បាប់ ឬអ្នកថែទាំ)

កំណត់ចំណាំ៖ ជនអាមេរិកស្បែកក្រហមអាចទំនាក់ទំនង មជ្ឈមណ្ឌលសុខភាពឥណ្ឌា (Indian Health Clinic, IHC) ក្នុងមូលដ្ឋានរបស់ពួកគេ ដើម្បីស្នើសុំសេវា NMT ។

ដែនកំណត់នៃ NMT

យើងរ៉ាប់រងថ្លៃចំណាយដែលទាបបំផុតលើការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ ដែលបំពេញតម្រូវការរបស់អ្នកទៅជួបអ្នកផ្តល់សេវាដែលនៅជិតបំផុតពីផ្ទះរបស់អ្នក ដែលជាកន្លែងដែលមានការណាត់ជួប។ សមាជិកមិនអាចបើកឡានខ្លួនឯងបាន ឬត្រូវបានទទួលថ្លៃសំណងដោយផ្ទាល់។

NMT មិនអនុវត្តទេប្រសិនបើ៖

- រថយន្តសង្គ្រោះបន្ទាន់ រថយន្តសង្គ្រោះធុនតូច រថយន្តសម្រាប់កៅអីកង់ ឬទម្រង់នៃ NEMT ផ្សេងទៀតគឺចាំបាច់ផ្នែកវេជ្ជសាស្ត្រដើម្បីទៅដល់សេវាដែលត្រូវបានរ៉ាប់រង

- អ្នកត្រូវការជំនួយពីអ្នកបើកបរទៅនិងមកពីលំនៅដ្ឋាន យានយន្ត ឬទីកន្លែងព្យាបាលរបស់អ្នក ដោយសារលក្ខខ័ណ្ឌផ្លូវកាយ ឬវេជ្ជសាស្ត្រ
- អ្នកប្រើកៅអីមានកង់ និងមិនអាចចូលនិងក្រោកចេញពីរថយន្តដោយគ្មានជំនួយពីអ្នកបើកឡាន
- សេវាមិនត្រូវបានរ៉ាប់រងដោយ Medi-cal។

ថ្លៃចំណាយពីសមាជិកសម្រាប់ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ
មិនមានការចំណាយទេនៅពេលដែលការដឹកជញ្ជូនត្រូវបានរៀបចំដោយយើងខ្ញុំ។

អត្ថប្រយោជន៍និងកម្មវិធីដទៃទៀតដែលរ៉ាប់រងដោយ Kaiser Permanente

សេវានិងជំនួយរយៈពេលវែងមានការគ្រប់គ្រង ("MLTSS")

យើងរ៉ាប់រងអត្ថប្រយោជន៍ MLTSS ខាងក្រោមសម្រាប់សមាជិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់៖

- ការថែទាំរយៈពេលវែងដោយទីកន្លែងថែទាំដែលមានជំនាញ កន្លែងថែទាំកម្រិតមធ្យម ឬកន្លែងថែទាំជិតដល់ សម្រាប់សម្រាប់ការស្នាក់នៅយូរជាងខែដែលចាបផ្តើមចូលព្យាបាល និងខែបន្ទាប់
- សេវាមនុស្សពេញវ័យតាមសហគមន៍ (Community-Based Adult Services, "CBAS")
- សេវាថែទាំផ្ទាល់ខ្លួន / ជំនួយនិងសេវានៅក្នុងផ្ទះ (In-home supports and services, "IHSS")
    - ♦ ប្រសិនបើអ្នកមានលក្ខណៈគ្រប់គ្រាន់សម្រាប់ IHSS អ្នកនឹងទទួលបានសេវាទាំងនេះពីខោនធី។

សម្រាប់ព័ត៌មានអំពីកម្មវិធីទាំងនេះ ហើយអ្នកមានសិទ្ធិទទួលបាន សូមនិយាយជាមួយ PCP ឬទូរស័ព្ទទៅផ្នែកគ្រប់គ្រងការថែទាំ Kaiser Permanent លេខ **1-866-551-9619** (TTY **711**) ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹកដល់ 6 ល្ងាច។

ការសម្របសម្រួលការថែទាំ

យើងផ្តល់សេវាដើម្បីជួយអ្នកក្នុងការសម្របសម្រួលតម្រូវការថែទាំសុខភាពរបស់អ្នក ដោយឥតគិតថ្លៃ។ យើងនឹងសម្របសម្រួលជាមួយកម្មវិធីផ្សេងទៀត ដើម្បីធានាថាអ្នកទទួលបានសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រទាំងអស់ដែលរ៉ាប់រងដោយ Medi-Cal ទោះបីជាសេវាទាំងនោះត្រូវបានរ៉ាប់រងដោយកម្មវិធីផ្សេងទៀត និងមិនមែនយើងក៏ដោយ។ ប្រសិនបើអ្នកមានសំណួរ ឬកង្វល់អំពីសុខភាពនៃកូនរបស់អ្នក សូមទូរស័ព្ទមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង លេខ **1-800-464-4000** (TTY **711**)។

ការផ្តួចផ្តើមការថែទាំដែលត្រូវបានសម្របសម្រួល ("CCI")

គំនិតផ្តួចផ្តើមថែទាំដែលត្រូវបានសម្របសម្រួលរដ្ឋកាលីហ្វ័រញ៉ា (Coordinated Care Initiative, "CCI") ធ្វើការដើម្បីកែលំអការសម្របសម្រួលផ្នែកថែទាំសម្រាប់អ្នកមានសិទ្ធិពីរ (អ្នកដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ទាំង Medicaid និង Medicare)។ វាមានផ្នែកចម្បងពីរ ៖ សេវា Cal MediConnect និងសេវានិងជំនួយរយៈពេលវែង មានការគ្រប់គ្រង។

Cal MediConnect

កម្មវិធី Cal MediConnect មានបំណងដើម្បីកែលម្អការសំរបសំរួលផ្នែកថែទាំសំរាប់អ្នកមានសិទ្ធិពីរ។ វាអនុញ្ញាតឲ្យពួកគេចុះឈ្មោះក្នុងផែនការមួយដើម្បីគ្រប់គ្រងផលប្រយោជន៍ទាំងអស់របស់ពួកគេ ជំនួសឲ្យការមានផែនការ Medi-Cal និង Medicare ដាច់ដោយឡែកពីគ្នា។ វាក៏មានគោលបំណងក្នុងការថែទាំដែលមានគុណភាពខ្ពស់ដែលជួយឲ្យប្រជាជនមានសុខភាពល្អ និងនៅក្នុងផ្ទះរបស់ពួកគេឲ្យបានយូរតាមដែលអាចទៅបាន។

ផែនការ Cal MediConnect រ៉ាប់រងដូចខាងក្រោម៖

- អ្នកផ្តល់សេវាក្នុងបណ្តាញដែលធ្វើការរួមគ្នាសម្រាប់អ្នក
- អ្នកសម្របសម្រួលផ្នែកថែទាំផ្ទាល់ខ្លួនដែលនឹងធ្វើឲ្យប្រាកដថាអ្នកទទួលបានការថែទាំ និងជំនួយដែលអ្នកត្រូវការ
- ការត្រួតពិនិត្យដែលត្រូវបានតម្រូវទៅតាមសេចក្តីត្រូវការសុខភាពនិងផែនការថែទាំរបស់អ្នក

សេវានិងជំនួយ Medi-Cal រយៈពេលវែងដែលត្រូវបានគ្រប់គ្រង ("MLTSS")

បុគ្គលដែលមានសិទ្ធិទទួលបាន Medicare និង Medi-Cal ឬមនុស្សចាស់ ឬជនពិការ (Seniors or Persons with Disabilities, SPD) ដែលបានចុះឈ្មោះក្នុង Medi-Cal ត្រូវតែចូលរួមជាមួយគម្រោងថែទាំសុខភាពដែលគ្រប់គ្រងដោយ Medi-Cal ដើម្បីទទួលបានអត្ថប្រយោជន៍ Medi-Cal របស់ពួកគេ រួមទាំងអត្ថប្រយោជន៍បំពេញបន្ថែម MLTSS និង Medicare ជ។

ដើម្បីស្វែងយល់បន្ថែមអំពី CCI សូមទូរស័ព្ទទៅលេខ **1-800-464-4000** (TTY **711**)។

ការគ្រប់គ្រងការថែទាំបានពង្រីក

យើងជានារ៉ាប់រងលើសេវាគ្រប់គ្រងការថែទាំដែលបានពង្រីក (Enhanced Care Management, "ECM") សម្រាប់សមាជិកដែលមានតម្រូវការស្មុគស្មាញខ្ពស់។ ECM គឺជាអត្ថប្រយោជន៍ដែលផ្តល់សេវាសម្របសម្រួលការថែទាំបន្ថែម ដើម្បីជួយអ្នកទទួលបានការថែទាំដែលអ្នកត្រូវការដើម្បីរក្សាសុខភាព។ វាសម្របសម្រួលការថែទាំដែលអ្នកទទួលបានពីវេជ្ជបណ្ឌិតផ្សេងៗគ្នា។ ECM ជួយសម្របសម្រួលការថែទាំបឋម ការថែទាំស្ត្រេចស្រាវ សុខភាពអាកប្បកិរិយា សេវាអភិវឌ្ឍន៍សុខភាពមាត់ធ្មេញ និងសេវានិងការគាំទ្ររយៈពេលវែងផ្នែកលើសហគមន៍ (long-term services and supports, "LTSS") និងការបញ្ជូនទៅកាន់ធនធានសហគមន៍ដែលមាន។

ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ ECM អ្នកអាចត្រូវបានគេទាក់ទងទៅអំពីសេវា ECM ដែលមានជូនសម្រាប់អ្នក។ អ្នកក៏អាចទូរស័ព្ទទៅយើង ឬពិគ្រោះជាមួយគ្រូពេទ្យ ឬបុគ្គលិកគ្លីនិករបស់អ្នក ដើម្បីដឹងថាតើអ្នកអាចទទួលសេវា ECM ឬទេ។

សេវា ECM ដែលត្រូវបានរ៉ាប់រង

ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ ECM អ្នកនឹងមានក្រុមថែទាំផ្ទាល់ខ្លួនរបស់អ្នករួមទាំងអ្នកសម្របសម្រួលផ្នែកថែទាំផងដែរ។ អ្នកសម្របសម្រួលការថែទាំរបស់អ្នកនឹងនិយាយជាមួយអ្នក និងវេជ្ជបណ្ឌិតរបស់អ្នក អ្នកឯកទេស ឱសថការី អ្នកគ្រប់គ្រងករណីអ្នកផ្តល់សេវាសង្គម និងអ្នកដទៃទៀត ដើម្បីប្រាកដថាអ្នកគ្រប់គ្នាធ្វើការជាមួយគ្នាដើម្បីទទួលបានការថែទាំដែលអ្នកត្រូវការ។ អ្នកសម្របសម្រួលការថែទាំរបស់អ្នកក៏នឹងអាចជួយអ្នកស្វែងរក និងដាក់ពាក្យស្នើសុំសេវាផ្សេងទៀតនៅក្នុងសហគមន៍របស់អ្នកផងដែរ។ ECM រួមមាន៖

- ការផ្សព្វផ្សាយនិងការចូលរួម
- ការវាយតម្លៃទូលំទូលាយ និងការគ្រប់គ្រងការថែទាំ
- ការសម្របសម្រួលការថែទាំដែលបានពង្រីក
- ការលើកកម្ពស់សុខភាព
- ការថែទាំកំឡុងពេលផ្លាស់ប្តូរដែលទូលំទូលាយ
- សេវាគាំទ្រសមាជិក និង គ្រួសារ
- ការសម្របសម្រួលនិងការបញ្ជូនទៅកាន់ជំនួយសហគមន៍ និងសង្គម

ដើម្បីចង់ដឹងថាតើ ECM ប្រហែលជាត្រឹមត្រូវសម្រាប់អ្នកឬទេ និយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នក។

ការចំណាយដោយសមាជិក

សេវា ECM គឺមិនគិតថ្លៃសម្រាប់អ្នកឡើយ។

Community Supports (“CS”)

Community Supports អាចមានសម្រាប់អ្នកនៅក្រោមផែនការថែទាំផ្ទាល់ខ្លួនរបស់អ្នក។ Community Supports គឺសមរម្យ និងជាសេវាកម្មឬទីកន្លែងជំនួសដែលផ្តល់ប្រសិទ្ធិភាពការចំណាយ ចំពោះអ្នកដែលត្រូវបានរ៉ាប់រងក្រោមផែនការរដ្ឋ Medi-Cal ។ Community Supports គឺស្រេចចិត្តសម្រាប់សមាជិក; អ្នកមិនចាំបាច់ទទួលយកពួកគេទេ។ ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ Community Supports អាចជួយអ្នករស់នៅដោយឯករាជ្យ។ Community Supports មិនជំនួសឲ្យអត្ថប្រយោជន៍ដែលអ្នកទទួលរួចហើយនៅក្រោម Medi-Cal នោះទេ។ ការគាំទ្រសហគមន៍មិនមានជូនសម្រាប់តំបន់ទាំងអស់នោះទេ។ មិនមែនសមាជិកគ្រប់រូបមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Community Supports ឡើយ។ ដើម្បីមានសិទ្ធិទទួលអ្នកត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់។

សម្រាប់ព័ត៌មានបន្ថែមអំពី Community Supports សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងភ្លាមៗតាមលេខ **1-800-464-4000** (TTY **711**)។

ការវះកាត់ប្តូរសរីរាង្គធំៗ

ការវះកាត់ប្តូរសរីរាង្គសម្រាប់កុមារក្រោមអាយុ 21 ឆ្នាំ

ច្បាប់រដ្ឋតម្រូវឲ្យកុមារដែលត្រូវការឧបករណ៍ការផ្សាំត្រូវបានបញ្ជូនទៅ California Children's Services ("CCS") ដើម្បីសម្រេចថាតើកូនរបស់អ្នកមានសិទ្ធិទទួលបាន CCS ឬទេ។ ប្រសិនបើកុមារមានសិទ្ធិទទួលបាន CCS នោះ CCS នឹងរ៉ាប់រងថ្លៃចំណាយសម្រាប់ការវះកាត់ប្តូរ និងសេវាពាក់ព័ន្ធ។ ប្រសិនបើកុមារមិនមានសិទ្ធិទទួលបាន CCS ទេនោះ យើងនឹងបញ្ជូនកុមារនោះទៅកាន់មជ្ឈមណ្ឌលប្តូរសរីរាង្គដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការវាយតម្លៃ។ ប្រសិនបើមជ្ឈមណ្ឌលប្តូរសរីរាង្គបញ្ជាក់ថាការវះកាត់ប្តូរគឺត្រូវការចាំបាច់ និងមានសុវត្ថិភាព យើងនឹងរ៉ាប់រងការប្តូរសរីរាង្គ និងសេវាពាក់ព័ន្ធ។

ការវះកាត់ប្តូរសរីរាង្គសម្រាប់មនុស្សពេញវ័យអាយុ 21 ឆ្នាំឡើងទៅ

ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកសម្រេចចិត្តថា អ្នកប្រហែលជាត្រូវការការប្តូរសរីរាង្គដ៏សំខាន់ យើងនឹងបញ្ជូនអ្នកទៅកាន់មជ្ឈមណ្ឌលប្តូរសរីរាង្គដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការវាយតម្លៃមួយ។ ប្រសិនបើមជ្ឈមណ្ឌលប្តូរសរីរាង្គបញ្ជាក់ថាការប្តូរគឺជាការចាំបាច់ និងមានសុវត្ថិភាពសម្រាប់ស្ថានភាពសុខភាពរបស់អ្នក យើងនឹងរ៉ាប់រងការប្តូរសរីរាង្គ និងសេវាពាក់ព័ន្ធផ្សេងទៀត។

ការប្តូរសរីរាង្គសំខាន់ៗដែលរ៉ាប់រងដោយពួកយើងរួមមាន ប៉ុន្តែមិនកំណត់តែចំពោះ៖

- ខួរឆ្អឹង
- បេះដូង
- បេះដូង/សួត
- តម្រងនោម
- តម្រងនោម/លំពែង
- ថ្លើម
- ថ្លើម/ពោះវៀនតូច
- សួត
- ពោះវៀនតូច

កម្មវិធីនិងសេវា Medi-Cal ដទៃទៀតដែលមិនធានារ៉ាប់រងដោយ Kaiser Permanente

ជួនកាល Kaiser Permanente មិនរ៉ាប់រងលើសេវាទេ ប៉ុន្តែអ្នកនៅតែអាចទទួលបានវាតាមរយៈបង់ថ្លៃពេលប្រើសេវា (Fee-For-Service, FFS) Medi-Cal ឬកម្មវិធី Medical ផ្សេងទៀត។ ផ្នែកនេះចុះបញ្ជីខ្លះនៃសេវាកម្មទាំងនេះ។ ដើម្បីស្វែងយល់បន្ថែម សូមទូរស័ព្ទទៅកាន់អ្នកធ្វើការផ្នែកសិទ្ធិទទួលបានរបស់ខោនធី ឬ Medi-Cal ដោយឥតគិតថ្លៃលេខ **1-800-541-5555** (អង់គ្លេស និងអេស្ប៉ាញ) យើងនឹងសម្របសម្រួលជាមួយកម្មវិធីផ្សេងទៀត ដើម្បីធានាថាអ្នក

ទទួលបានសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រទាំងអស់ដែលរ៉ាប់រងដោយ Medi-Cal នោះបើជាសេវាទាំងនោះមិនត្រូវបានរ៉ាប់រងដោយយើងក៏ដោយ។

ការថែទាំគ្រប់គ្រងផ្នែកទន្តសាស្ត្រ

អ្នកទទួលអត្ថប្រយោជន៍ L.A. Care Health Plan ដែលមានសិទ្ធិទទួលសេវាមាត់ធ្មេញត្រូវតែជ្រើសរើសមួយក្នុងចំណោមផែនការថែទាំគ្រប់គ្រងទន្តសាស្ត្រដែលមានសំរាប់ការថែទាំមាត់ធ្មេញរបស់ពួកគេ។ សំរាប់ព័ត៌មានបន្ថែមអំពីជំរើសនៃផែនការថែទាំគ្រប់គ្រងទន្តសាស្ត្រ សូមទូរស័ព្ទទៅកាន់ Health Care Options លេខ 1-800-430-4263។

កំណត់ចំណាំ៖ សេវាថ្នាំស្ពឹកសម្រាប់នីតិវិធីទន្តសាស្ត្រជាក់លាក់មួយចំនួន ត្រូវបានរ៉ាប់រងក្រោមលក្ខខណ្ឌក្នុងសៀវភៅណែនាំសមាជិកនេះ។ សូមមើលចំណងជើង "សេវាអ្នកជំនាញថ្នាំស្ពឹក" ដែលនៅក្រោម "ការថែទាំជំងឺមិនសម្រាកនៅមន្ទីរពេទ្យ" នៅក្នុងជំពូកទី 4 នេះ ("អត្ថប្រយោជន៍និងសេវាកម្ម") សម្រាប់ព័ត៌មានបន្ថែម។

Medi-Cal Rx

ឱសថវេជ្ជបញ្ជាសម្រាប់ជំងឺមិនសម្រាកមន្ទីរពេទ្យភាគច្រើនត្រូវបានរ៉ាប់រងដោយ Medi-Cal Rx ជាសេវាមួយតាមរយៈថ្លៃសេវា FFS Medi-Cal ។ ដើម្បីទទួលបានជានារ៉ាប់រងដោយ Medi-Cal Rx មុខទំនិញនោះត្រូវតែមាននៅក្នុងបញ្ជីថ្នាំកិច្ចសន្យា (Contract Drug List, "CDL") Medi-Cal ឬត្រូវតែត្រូវបានអនុម័តជាមុនសម្រាប់អ្នកដោយ Medi-Cal Rx។ អ្នកផ្តល់សេវារបស់អ្នកអាចប្រាប់អ្នកថាតើឱសថ មាននៅក្នុង Medi-Cal Rx CDL ឬអត់។

បញ្ជីឱសថក្នុងកិច្ចសន្យា ("CDL") Medi-Cal Rx

បញ្ជីឱសថកិច្ចសន្យា Medi-Cal គឺជាបញ្ជីឱសថដែលមិនត្រូវការការយល់ព្រមជាមុនពី Medi-Cal Rx។ អ្នកផ្តល់សេវារបស់អ្នកអាចប្រាប់អ្នកថាតើឱសថមាននៅក្នុង Medi-Cal Rx បញ្ជីថ្នាំក្នុងកិច្ចសន្យា ឬអត់។

ជួនកាលអ្នកអាចត្រូវការមុខទំនិញណាមួយ ដែលមិននៅក្នុងបញ្ជីឱសថមានកិច្ចសន្យា។ ក្នុងករណីបែបនេះ Medi-Cal Rx នឹងត្រូវយល់ព្រមលើមុខទំនិញទាំងនេះជាមុនសិន មុនពេលដែលឱសថស្ថានអាចផ្តល់ឲ្យអ្នកបាន។ Medi-Cal Rx នឹងត្រួតពិនិត្យសំណើពីអ្នកផ្តល់សេវារបស់អ្នក ហើយធ្វើការសម្រេចចិត្តក្នុងអំឡុងពេល 24 ម៉ោង។

- ឱសថការីនៅឱសថស្ថានជំងឺមិនសម្រាកមន្ទីរពេទ្យរបស់អ្នក ឬបន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យអាចផ្តល់ឲ្យអ្នកនូវការផ្គត់ផ្គង់សង្គ្រោះបន្ទាន់រយៈពេល 72 ម៉ោង ប្រសិនបើពួកគេគិតថាអ្នកត្រូវការវា។ Medi-Cal Rx នឹងចេញថ្លៃសម្រាប់ការផ្គត់ផ្គង់ថ្នាំសង្គ្រោះបន្ទាន់ដែលផ្តល់ដោយឱសថស្ថានជំងឺមិនសម្រាកមន្ទីរពេទ្យ។
- Medi-Cal Rx អាចឆ្លើយថាទេចំពោះសំណើដែលមិនមែនបន្ទាន់។ ប្រសិនបើគេថាឆ្លើយថាទេ ពួកគេនឹងផ្ញើរលិខិតមួយច្បាប់មកប្រាប់អ្នក។ ពួកគេនឹងប្រាប់អ្នកថាតើអ្នកមានជម្រើសណាខ្លះ។ សូមមើលផ្នែក "ពាក្យបណ្តឹងតវ៉ា" នៅក្នុងជំពូកទី 6 ("ការរាយការណ៍ និងការដោះស្រាយបញ្ហា") សម្រាប់ព័ត៌មានបន្ថែម។

ដើម្បីចង់ដឹងថាតើថ្នាំមាននៅលើបញ្ជីឱសថកិច្ចសន្យា ឬដើម្បីទទួលបានច្បាប់ចម្លងនៃបញ្ជីឱសថកិច្ចសន្យា សូមទូរស័ព្ទទៅផ្នែកសេវាអតិថិជន Medi-Cal Rx តាមរយៈលេខ **1-800-977-2273** 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **711** ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច។ អ្នកក៏អាចចូលទៅកាន់គេហទំព័រ Medi-Cal Rx សម្រាប់ព័ត៌មាននៅ **https://www.Medi-CalRx.dhcs.ca.gov/home/** (ជាភាសាអង់គ្លេស)។

ឱសថស្ថាន Medi-Cal Rx

ប្រសិនបើអ្នកនឹងបើក ឬបើកឡើងវិញនូវឱសថវេជ្ជបញ្ជា អ្នកត្រូវតែទទួលយកឱសថវេជ្ជបញ្ជារបស់អ្នកពីឱសថស្ថានដែលធ្វើការជាមួយ Medi-Cal Rx។ ឱសថស្ថានអ្នកជំងឺមិនសម្រាកមន្ទីរពេទ្យ Kaiser Permanente ទាំងអស់នៅក្នុងតំបន់ផ្ទះរបស់អ្នក ធ្វើការជាមួយ Medi-Cal Rx។ អ្នកអាចស្វែងរកបញ្ជីឱសថស្ថានដែលធ្វើការជាមួយ Medi-Cal Rx នៅក្នុងសៀវភៅព័ត៌មានឱសថស្ថាន Medi-Cal Rx នៅ **https://www.Medi-CalRx.dhcs.ca.gov/home/** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចទូរស័ព្ទទៅសេវាបម្រើអតិថិជន Medi-Cal Rx តាមរយៈលេខ **1-800-977-2273** បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ **711** ចន្ទដល់សុក្រពីម៉ោង 8 ព្រឹកដល់ 5 ល្ងាច។

នៅពេលដែលអ្នកជ្រើសរើសឱសថស្ថានហើយ យកវេជ្ជបញ្ជារបស់អ្នកទៅឱសថស្ថាននោះ។ អ្នកផ្តល់សេវាក៏អាចបញ្ជូនវាទៅឱសថស្ថានសម្រាប់អ្នកផងដែរ។ ផ្តល់ទៅឱសថស្ថាននូវវេជ្ជបញ្ជារបស់អ្នក រួមទាំងប័ណ្ណសម្គាល់អត្ថប្រយោជន៍ (Benefits Identification Card, "BIC") Medi-Cal និងប័ណ្ណអត្តសញ្ញាណ Kaiser Permanente របស់អ្នក។ សូមប្រាកដថាឱសថស្ថានដឹងអំពីឱសថទាំងអស់ដែលអ្នកកំពុងប្រើនិងអាឡែកហ្ស៊ីណាមួយដែលអ្នកមាន។ ប្រសិនបើអ្នកមានសំណួរអំពីវេជ្ជបញ្ជារបស់អ្នក សូមប្រាកដថាអ្នកសួរឱសថការី។

អ្នកអាចទទួលបានជំនួយផ្នែកដឹកជញ្ជូនពីពួកយើងដើម្បីទៅកាន់ឱសថស្ថាន ដើម្បីទទួលយកឱសថវេជ្ជបញ្ជារបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ចំណងជើង "សេវាដឹកជញ្ជូនសម្រាប់ស្ថានភាពដែលមិនមែនសង្គ្រោះបន្ទាន់" នៅដើមដំពូកទី 4 នេះ។

សេវាសុខភាពផ្លូវចិត្តឯកទេស

ផែនការសុខភាពផ្លូវចិត្តរបស់ខោនធីផ្តល់សេវាសុខភាពផ្លូវចិត្តឯកទេសដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ ("SMHS") ដល់សមាជិក Medi-Cal ។ សេវាសុខភាពផ្លូវចិត្តឯកទេស រួមមានផ្នែកដូចខាងក្រោម៖

សេវាជំងឺមិនសម្រាកនៅមន្ទីរពេទ្យ៖

- សេវាសុខភាពផ្លូវចិត្ត (ការវាយតម្លៃ ការបង្កើតផែនការ ការព្យាបាល ការស្តារឡើងវិញ និងការដាក់ជានា)
- សេវាជំនួយផ្នែកឱសថ
- សេវាដិតដល់ព្យាបាលនៅពេលថ្ងៃ
- សេវាស្តារពង្រឹងនីតិសម្បទានៅពេលថ្ងៃ

- សេវាអន្តរាគមន៍ពេលមានវិបត្តិ
- សេវាធ្វើឲ្យមានស្ថេរភាពពេលមានវិបត្តិ
- សេវាគ្រប់គ្រងករណីតាមគោលដៅ
- សេវាអាកប្បកិរិយាព្យាបាល
- ការសម្របសម្រួលការថែទាំដិតដល់ (Intensive care coordination, "ICC") (សម្រាប់អ្នកទទួលអត្ថប្រយោជន៍រហូតដល់អាយុ 21 ឆ្នាំ)
- សេវាកម្មតាមផ្ទះដិតដល់ (Intensive home-based services, "IHBS") (សម្រាប់អ្នកទទួលអត្ថប្រយោជន៍រហូតដល់អាយុ 21 ឆ្នាំ)
- ការថែទាំចិញ្ចឹមបីបាច់លក្ខណៈព្យាបាល (Intensive home-based services, "TFC") (សម្រាប់អ្នកទទួលអត្ថប្រយោជន៍រហូតដល់អាយុ 21 ឆ្នាំ)

សេវាតាមលំនៅដ្ឋាន:

- សេវាព្យាបាលក្នុងលំនៅដ្ឋានមនុស្សពេញវ័យ
- សេវាព្យាបាលក្នុងលំនៅដ្ឋានពេលមានវិបត្តិ

សេវាកម្មជំងឺសម្រាកក្នុងមន្ទីរពេទ្យ:

- សេវាមន្ទីពេទ្យសម្រាប់ជំងឺសម្រាកព្យាបាលផ្នែកវិកលចរិកធ្ងន់ធ្ងរ
- សេវាជំនាញមន្ទីរពេទ្យសម្រាប់ជំងឺសម្រាកព្យាបាលផ្នែកវិកលចរិក
- សេវាទីកន្លែងសុខភាពផ្នែកវិកលចរិក

ដើម្បីស្វែងយល់បន្ថែមអំពីសេវាសុខភាពផ្លូវចិត្តឯកទេស ផ្តល់ដោយផែនការសុខភាពផ្លូវចិត្តរបស់ខោនធី អ្នកអាចទូរស័ព្ទទៅខោនធី។ ដើម្បីស្វែងរកលេខទូរស័ព្ទរបស់ខោនធីទាំងអស់ដោយឥតគិតថ្លៃតាមអនឡាញ សូមចូលទៅកាន់ **http://www.dhcs.ca.gov/individuals/Pages/MHPContactList.aspx** (ជាភាសាអង់គ្លេស)។

California Children's Services ("CCS")

CCS គឺជាកម្មវិធី Medi-Cal ដែលព្យាបាលកុមារអាយុក្រោម 21 ឆ្នាំដែលមានលក្ខខ័ណ្ឌសុខភាពជាក់លាក់ ជំងឺ ឬបញ្ហាសុខភាពរ៉ាំរ៉ៃ និងដែលបំពេញតាមគោលការណ៍ កម្មវិធី CCS។ ប្រសិនបើ Kaiser Permanente ឬ PCP របស់អ្នកជឿថាកូនរបស់អ្នកមានលក្ខខណ្ឌដែលមានសិទ្ធិ CCS នោះកូនរបស់អ្នកនឹងត្រូវបានបញ្ជូនទៅកម្មវិធី CCS county ដើម្បីធ្វើការវាយតម្លៃសម្រាប់សិទ្ធិទទួលបាន។

បុគ្គលិកកម្មវិធី CCS ខោនធីនឹងសំរេចថាតើកូនរបស់អ្នកមានលក្ខណៈសម្បត្តិសម្រាប់សេវា CCS ឬទេ។ យើងមិនធ្វើការសម្រេចសិទ្ធិទទួល CCS ឡើយ។ ប្រសិនបើកូនរបស់អ្នកមានសិទ្ធិទទួលបានការថែទាំប្រភេទនេះ អ្នកផ្តល់សេវា CCS នឹង ព្យាបាលកូនរបស់អ្នកសម្រាប់លក្ខខ័ណ្ឌ

CCS។ Kaiser Permanente នឹងបន្តរ៉ាប់រងប្រភេទនៃសេវាដែលមិនទាក់ទងនឹងលក្ខខ័ណ្ឌ CCS ដូចជាការពនិត្យរាងកាយ ការចាក់វ៉ាក់សាំង និងការពិនិត្យសុខភាពកុមារ ។

Kaiser Permanente មិនរ៉ាប់រងសេវាដែលផ្តល់ដោយកម្មវិធី CCS ទេ។ ដើម្បីឲ្យ CCS រ៉ាប់រងលើសេវាទាំងនេះ CCS ត្រូវតែព្រមព្រៀងលើអ្នកផ្តល់សេវា សេវា និងសម្ភារៈបរិក្ខារ។

CCS មិនរ៉ាប់រងគ្រប់លក្ខខ័ណ្ឌសុខភាពទាំងអស់ទេ។ CCS រ៉ាប់រងលើលក្ខខ័ណ្ឌសុខភាពភាគច្រើនដែលធ្វើឲ្យពិការខាងរាងកាយ ឬត្រូវការការព្យាបាលដោយប្រើឱសថ ការវះកាត់ ឬការស្តារឡើងវិញ។ CCS រ៉ាប់រងកុមារដែលមានបញ្ហាសុខភាពដូចជាៈ

- ជំងឺបេះដូងពីកំណើត
- ជំងឺមហារីក
- ការដុះសាច់
- ជំងឺឈាមមិនងាយកក
- ជំងឺខ្វះឈាមក្រហម
- បញ្ហាក្រពេញទីរ៉ូអុីដ
- ជំងឺទឹកនោមផ្អែម
- បញ្ហាតម្រងនោមរ៉ាំរ៉ៃធ្ងន់ធ្ងរ
- ជម្ងឺផ្តើម
- ជម្ងឺពោះវៀនតូច
- បបូរមាត់/ មាត់ឆែប
- ឆ្អឹងខ្នងប៉ោង
- ការបាត់បង់ការស្តាប់
- ជំងឺភ្នែកឡើងបាយ
- ជំងឺខ្វិន
- ជំងឺប្រកាច់ក្នុងកាលៈទេសៈជាក់លាក់
- ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ
- ជំងឺខ្សោយសាច់ដុំ
- ជំងឺអេដស៍
- របួសក្បាល ខួរក្បាល ឬឆ្អឹងខ្នងធ្ងន់ធ្ងរ
- ការរលាកខ្លាំង
- ធ្មេញជំពើសខ្លាំង

បុគ្គលិកកម្មវិធី CCS ខោនធីនឹងសំរេចថាតើកូនរបស់អ្នកមានលក្ខណៈសម្បត្តិសម្រាប់សេវា CCS ឬទេ។ ប្រសិនបើកូនរបស់អ្នកមានសិទ្ធដើម្បីទទួលបានការថែទាំប្រភេទនេះ អ្នកផ្តល់សេវា CCS នឹងព្យាបាលគាត់សម្រាប់លក្ខខ័ណ្ឌ CCS។ DHCS នឹងបង់ថ្លៃសម្រាប់សេវា CCS ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ប្រសិនបើកូនរបស់អ្នកមិនមានសិទ្ធិសម្រាប់សេវា CCS ទេ ពួកគេនឹងបន្តទទួលការថែទាំដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រពី Kaiser Permanente។ ដើម្បីស្វែងយល់បន្ថែមអំពី CCS អ្នកអាចចូលមើលគេហទំព័ររបស់ CCS នៅ **www.dhcs.ca.gov/services/ccs** (ជាភាសាអង់គ្លេស) ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងតាមលេខ **1-800-464-4000** (TTY **711**)។

សេវាព្យាបាលវិបត្តិការប្រើប្រាស់គ្រឿងញៀន

ខោនធីផ្តល់សេវាកម្មវិបត្តិនៃការប្រើប្រាស់សារធាតុញៀនដល់សមាជិក Medi-Cal ដែលបំពេញតាមវិធានចាំបាច់ផ្នែកវេជ្ជសាស្ត្រ។ សមាជិកដែលត្រូវបានកំណត់អត្តសញ្ញាណសម្រាប់សេវាព្យាបា

លបញ្ហាការប្រើប្រាស់សារធាតុញៀន ត្រូវបានបញ្ជូនទៅនាយកដ្ឋានក្នុងខោនធីរបស់ពួកគេដើម្បីធ្វើការព្យាបាល។ ដើម្បីស្វែងរកលេខទូរស័ព្ទរបស់ខោនធីទាំងអស់លៃតាមអនឡាញ សូមចូលទៅកាន់ **http://www.dhcs.ca.gov/individuals/Pages/MHPContactList.aspx** (ជាភាសាអង់គ្លេស)។

ការព្យាបាលដោយការឧទ្ទិស ឬសាសនា

សេវាព្យាបាលដោយការឧទ្ទិស ឬសាសនាដូចដែលបានបញ្ជាក់ក្នុងចំណងជើង 22 ក្រមច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា (California Code of Regulations, CCR) ផ្នែក 51312 គឺមានជូនតាមរយៈ FFS Medi-Cal។ សូមទំនាក់ទំនងខោនធីរបស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចូលប្រើសេវាទាំងនេះ។

សេវារាយតម្លៃនៃទីភ្នាក់ងារការអប់រំតាមមូលដ្ឋាន ("LEA")

ផែនការសុខភាពមិនទទួលខុសត្រូវចំពោះការធានារ៉ាប់រងសម្រាប់សេវារាយតម្លៃ ភ្នាក់ងារការអប់រំតាមមូលដ្ឋាន (Local Education Agency, LEA) ទេ ដូចដែលបានបញ្ជាក់នៅក្នុងចំណងជើង 22 CCR ផ្នែកទី 51360 (ខ) នៅពេលផ្តល់ជូនដល់ សមាជិកដែលមានសិទ្ធិទទួលសេវា LEA ដោយផ្អែកលើចំណងជើង 22 CCR ផ្នែក 51190.1។

សេវា LEA ដូចបានបញ្ជាក់ក្នុងចំណងជើង 22 CCR ផ្នែក 51360

ផែនការសុខភាពមិនទទួលខុសត្រូវចំពោះការរ៉ាប់រងសេវា LEA ដែលត្រូវបានផ្តល់ជូនស្របតាមផែនការអប់រំលក្ខណៈបុគ្គល (Individuaized Education Plan, IEP) ដូចមានចែងក្នុង ក្រមអប់រំ ផ្នែក 56340 និងបន្តបន្ទាប់ ឬផែនការសេវាគ្រួសារលក្ខណៈបុគ្គល (Individualized Family Service Plan, IFSP) ដូចមានចែងក្នុងក្រមផ្នែក 95020 របស់រដ្ឋាភិបាល ឬសេវា LEA ដែលផ្តល់ជូនក្រោមផែនការសុខភាពនិងជំនួយលក្ខណៈបុគ្គល (Individualized Health and Support Plan, IHSP) ដូចដែលបានពិពណ៌នាក្នុងចំណងជើង 22 CCR ផ្នែក 51360 ។

សេវាមន្ទីពិសោធន៍ដែលបានផ្តល់នៅក្រោមកម្មវិធីធ្វើតេស្តអាល់ហ្វា - ហ្វីតូប្រូតេទីនរបស់រដ្ឋ

ការរ៉ាប់រងសម្រាប់សេវានៅក្រោមកម្មវិធីតេស្តអាល់ហ្វា - ហ្វីតូប្រូតេទីនរបស់រដ្ឋ គឺតាមរយៈ FFS Medi-Cal។

ការថែទាំសុខភាពពេលថ្ងៃសម្រាប់កុមារ

ការរ៉ាប់រងសម្រាប់សេវាថែទាំសុខភាពពេលថ្ងៃរបស់កុមារ គឺតាមរយៈ FFS Medi-Cal។ សូមទំនាក់ទំនងខោនធីរបស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចូលប្រើសេវាទាំងនេះ។

សេវាគ្រប់គ្រងករណីតាមគោលដៅដូចដែលបានបញ្ជាក់ក្នុងចំណងជើង 22 CCR ផ្នែក 51185 និង 51351

សេវាគ្រប់គ្រងករណីតាមគោលដៅដូចដែលបានបញ្ជាក់ក្នុងចំណងជើង 22 CCR ផ្នែក 51185 និង 51351 គឺតាមរយៈ FFS Medi-Cal។ សូមទំនាក់ទំនងខោនធីរបស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបប្រើប្រាស់សេវាទាំងនេះ ។

សេវាដែលអ្នកមិនអាចទទួលបានតាមរយៈ Kaiser Permanente ឬ Medi-Cal

ផ្នែកនេះពណ៌នាអំពីសេវាដែលយើងឬ Medi-Cal នឹងមិនធានារ៉ាប់រង។ អានផ្នែកនិមួយៗដូចខាងក្រោមដើម្បីស្វែងយល់បន្ថែម ឬហៅទូរស័ព្ទទៅ 1-800-464-4000 (TTY 711)។

ការពិនិត្យជំងឺ និងសេវាជាក់លាក់មួយចំនួន

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលការពិនិត្យជំងឺ និងសេវាដែលត្រូវការ៖

- ដើម្បីទទួលបាន ឬរក្សាការងារ
- ដើម្បីទទួលបានធានារ៉ាប់រង
- ដើម្បីទទួលបានអាជ្ញាប័ណ្ណប្រភេទណាមួយ
- ដោយដីកាពីតុលាការ ឬប្រសិនបើ ដើម្បីការដោះលែង ឬការដោះលែងមានលក្ខខ័ណ្ឌ

ការដកចេញនេះមិនត្រូវបានអនុវត្តទេ ប្រសិនបើវេជ្ជបណ្ឌិតក្នុងបណ្តាញរកឃើញថាសេវាទាំងនេះចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

ទំនិញសម្រាប់ផាសុកភាព ឬភាពងាយស្រួល

ការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលបរិក្ខារឬមុខងារពិសេសដើម្បីភាពផាសុកភាព ភាពងាយស្រួល ឬភាពប្រណិតឡើយ។ ទាំងនេះរួមមានទំនិញដែលសម្រាប់តែផាសុកភាព ឬភាពងាយស្រួលនៃសមាជិក គ្រួសាររបស់សមាជិក ឬអ្នកផ្តល់សេវាថែទាំសុខភាពរបស់សមាជិក។ ការមិនរាប់បញ្ចូលនេះមិនអនុវត្តទៅឧបករណ៍បូមទឹកដោះកម្រិតលក់រាយ ដែលត្រូវបានផ្តល់ដល់ស្ត្រីក្រោយពីការមានផ្ទៃពោះឡើយ។
ការបដិសេធនេះក៏មិនអនុវត្តចំពោះមុខទំនិញដែលត្រូវបានអនុញ្ញាតសម្រាប់អ្នកនៅក្រោមកម្មវិធី Community Supports ទេ។ សម្រាប់ព័ត៌មានអំពី Community Supports ចូលទៅចំណងជើងនោះនៅដើមជំពូក 4 នេះ។

សេវាសំអិតសំអាងខ្លួន

ការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលសេវាដើម្បីផ្លាស់ប្តូររូបរាងដែលអ្នកមើលឃើញ (រួមមានការរះកាត់លើផ្នែកធម្មតានៃរាងកាយរបស់អ្នកដើម្បីផ្លាស់ប្តូររូបរាង)។
ការដកចេញនេះមិនអនុវត្តចំពោះឧបករណ៍សិប្បនិម្មិតដែលត្រូវបានរ៉ាប់រងទេដូចជា៖

- ពងស្វាសសិប្បនិម្មិតដែលត្រូវបានដាំបង្កប់ជាផ្នែកមួយនៃការរះកាត់កែលម្អដែលត្រូវបានរ៉ាប់រង
- សុដន់សិប្បនិម្មិតដែលត្រូវការបន្ទាប់ពីរះកាត់សុដន់ និងការកាត់ដុំសាច់ចេញ
- គ្រឿងសិប្បនិម្មិតដើម្បីជំនួសទាំងអស់ ឬមួយផ្នែកនៃផ្នែកខាងក្រៅរបស់ផ្ទៃមុខ

សម្ភារៈដែលប្រើហើយបោះចោល

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលសម្ភារៈដែលប្រើហើយបោះចោលសម្រាប់ការប្រើប្រាស់នៅផ្ទះដូចជា៖ បង់រុំរបួស ស្បៃ បង់ស្អិត អាល់កុលសម្លាប់មេរោគ ក្រណាត់រុំ និងបង់រុំរបួសប្រភេទ Ace។ ការដកចេញនេះមិនអនុវត្តចំពោះសម្ភារៈផ្គត់ផ្គង់ប្រើហើយបោះចោលដែលត្រូវបានផ្តល់ជាផ្នែកមួយនៃអត្ថប្រយោជន៍ខាងក្រោម ដែលត្រូវបានពិពណ៌នានៅក្នុងជំពូកទី 4 ("អត្ថប្រយោជន៍និងសេវា") នៃសៀវភៅសមាជិកនេះទេ៖

- ការព្យាបាលដោយការលាងឈាម/ការលាងក្រលៀន
- បរិក្ខារវេជ្ជសាស្ត្រប្រើជាប់បានយូរ
- ការថែទាំសុខភាពនៅផ្ទះ
- ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់
- សម្ភារៈផ្គត់ផ្គង់វេជ្ជសាស្ត្រ គ្រឿងបរិក្ខារ និងឧបករណ៍ប្រើប្រាស់
- ឱសថវេជ្ជបញ្ជា

សេវាពិសោធន៍

សេវាពិសោធន៍គឺជាឱសថ គ្រឿងបរិក្ខារ ដំណើការ ឬសេវាដែលកំពុងត្រូវបានធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍ ឬទៅលើសត្វ ប៉ុន្តែពួកគេមិនទាន់រួចរាល់ដើម្បីធ្វើតេស្តទៅលើមនុស្សទេ។ ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលសេវាកម្មពិសោធន៍ទេ។

សេវាការបន្តពូជ

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលសេវាដើម្បីជួយនរណាម្នាក់ឲ្យមានផ្ទៃពោះ រួមមានសេវាសម្រាប់ភាពមិនអាចបន្តកំណើត ការចាក់បញ្ចូលមេជីវិត និងសេវាបច្ចេកវិទ្យាបន្តពូជមានជំនួយ។ សេវារក្សាការមានកូន មិនត្រូវបានរ៉ាប់រងដោយ Medi-Cal ទេ។

ការព្យាបាលការជ្រុះ ឬបណ្តុះសក់

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលទំនិញនិងសេវាសម្រាប់ការលើកកម្ពស់ ការការពារ ឬការព្យាបាលនៃការជ្រុះសក់ ឬការបណ្តុះសក់ឡើយ។

ទំនិញនិងសេវាដែលពុំមែនជាទំនិញនិងសេវាថែទាំសុខភាព

ការជានារ៉ាប់រងរបស់ Medi-Cal មិនរួមបញ្ចូលមុខទំនិញដែលមិនមែនជាទំនិញ ឬសេវាថែទាំសុខភាពទេ លុះត្រាតែពួកគេត្រូវបានយល់ព្រមសម្រាប់អ្នកនៅក្រោមកម្មវិធី Community Supports ឬយល់ព្រមសម្រាប់អ្នកនៅក្រោមឧបករណ៍វេជ្ជសាស្ត្រប្រើជាប់បានយូរ។ ឧទាហរណ៍យើងមិនរ៉ាប់រង៖

- ការបង្រៀនពីឥរិយាបថ និងសុជីវធម៌
- សេវាការបង្រៀននិងជំនួយដើម្បីអភិវឌ្ឍជំនាញរៀបចំផែនការ ដូចជាការធ្វើផែនការសកម្មភាពប្រចាំថ្ងៃ និងការធ្វើផែនការគម្រោងឬកិច្ចការ
- ទំនិញនិងសេវាសម្រាប់គោលបំណងនៃការបង្កើនចំណេះដឹងនិងជំនាញ

- សេវាការបង្រៀននិងជំនួយដើម្បីបង្កើនភាពឆ្លាតវៃ
- ការបង្ហាត់ ឬបង្រៀនផ្នែកការសិក្សាសម្រាប់ជំនាញដូចជាវេយ្យាករណ៍ គណិតវិទ្យា និងការគ្រប់គ្រងពេលវេលា
- បង្រៀនពីរបៀបអាន មិនថាអ្នកមានជំងឺខ្សោយខាងការអានឬអត់
- ការធ្វើតេស្តការអប់រំ
- ការបង្រៀនសិល្បៈ: ការរាំ ការដិះសេះ តន្ត្រី ល្ខោន ឬការហែលទឹក លើកលែងតែថាការដកចេញនេះសម្រាប់ "ការលេងលក្ខណៈជាការបង្រៀន" មិនអនុវត្តទៅលើសេវានានាដែលជាផ្នែកនៃផែនការការព្យាបាលសុខភាពឥរិយាបទ និងត្រូវបានរ៉ាប់រងក្រោម "ការព្យាបាលសុខភាពអាកប្បកិរិយា" ក្នុងជំពូកទី 4 ("អត្ថប្រយោជន៍និងសេវាកម្ម")
- ការបង្រៀនជំនាញសម្រាប់គោលបំណងការងារ ឬវិជ្ជាជីវៈ:
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ: ឬការបង្រៀនជំនាញវិជ្ជាជីវៈ:
- វគ្គបណ្តុះបណ្តាលការរីកលូតលាស់វិជ្ជាជីវៈ:
- ការបណ្តុះបណ្តាលសម្រាប់ការងារជាក់លាក់មួយ ឬការប្រឹក្សាការងារ
- ការកែកុនផ្ទះ ឬរថយន្តរបស់អ្នក លុះត្រាតែពួកគេគឺជាការផ្លាស់ប្តូរបណ្តោះអាសន្នដែលត្រូវបានកំណត់ថាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ឬត្រូវបានយល់ព្រមសម្រាប់អ្នកនៅក្រោម Community Supports
- ការព្យាបាលដោយទឹក និងវិធីព្យាបាលដោយទឹកផ្សេងទៀត។ ការដកចេញសម្រាប់ការព្យាបាលដោយទឹក និងវិធីព្យាបាលដោយទឹកផ្សេងទៀតនេះ មិនអនុវត្តទៅលើសេវាព្យាបាលដែលជាផ្នែកនៃផែនការព្យាបាលដោយចលនាទេ ហើយត្រូវបានរ៉ាប់រងជាផ្នែកមួយនៃអត្ថប្រយោជន៍ដូចខាងក្រោមនៅក្នុងជំពូកទី 4 ("អត្ថប្រយោជន៍និងសេវាកម្ម")៖
  - ♦ ការថែទាំសុខភាពនៅផ្ទះ
  - ♦ ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់
  - ♦ សេវាព្យាបាល និងជំនួយពង្រឹងនីតិសម្បទា
  - ♦ សេវាទីកន្លែងមើលថែទាំដែលមានជំនាញ

ការព្យាបាលដោយការគក់ច្រចាច់

ការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលការព្យាបាលគក់ច្រចាច់ទេ។ ការដកចេញនេះមិនអនុវត្តទៅលើសេវាព្យាបាលដែលជាផ្នែកនៃផែនការព្យាបាល ដោយចលនាទេ ហើយត្រូវបានរ៉ាប់រងជាផ្នែកមួយនៃអត្ថប្រយោជន៍ដូច នៅក្នុងជំពូកទី 4 ("អត្ថប្រយោជន៍និងសេវាកម្ម") នៃសៀវភៅណែនាំសមាជិកនេះ៖

- ការថែទាំសុខភាពនៅផ្ទះ
- ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់

- សេវាព្យាបាល និងជំនួយពង្រឹងនីតិសម្បទា
- សេវាទីកន្លែងមើលថែទាំដែលមានជំនាញ

សេវាថែទាំផ្ទាល់ខ្លួន

ការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលសេវាដែលមិនមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ដូចជាការជួយក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ (ឧទាហរណ៍ ការដើរ ការចូលនិងក្រោកពីគេង ការងូតទឹក ការស្លៀកពាក់ ការហូបចុក ការប្រើបន្ទប់ទឹក និងការលេបថ្នាំ)។ ការដកចេញនេះមិនអនុវត្តចំពោះជំនួយលើសកម្មភាពរស់នៅប្រចាំថ្ងៃ ដែលត្រូវបានផ្តល់ជា ផ្នែកនៃជានារ៉ាប់រងដែលត្រូវបានពិពណ៌នាក្រោមផ្នែកនៅខាងក្រោមនេះ៖

- ការថែទាំជំងឺមុខនឹងស្លាប់ និងការថែទាំព្យាបាលសម្រាលការឈឺចាប់
- សេវានិងជំនួយរយៈពេលវែងមានការគ្រប់គ្រង ("MLTSS")
- ការថែទាំនៅទីកន្លែងគិលានុបដ្ឋាយិកាជំនាញ/កម្រិតមធ្យម/ជិតដល់
- Community Supports Program

ការស្រាយចំណងស្បូន

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលសេវាដើម្បីបញ្ច្រាសការពន្យាកំណើតតាមការវះកាត់ដែលស្ម័គ្រចិត្តទេ។

ទំនិញនិងសេវាថែទាំប្រអប់ជើងជាប្រចាំ

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលសេវានិងទំនិញថែទាំជើងដែលមិនចាំបាច់ខាងវេជ្ជសាស្ត្រទេ។

សេវាកម្មដែលមិនត្រូវបានអនុម័តដោយរដ្ឋបាលចំណីអាហារ និងឱសថរបស់សហព័ន្ធ។

ការរ៉ាប់រង Medi-Cal មិនរាប់បញ្ចូលសេវាឱសថ អាហារប៉ិន ការធ្វើតេស្ត ការចាក់ថ្នាំបង្ការ ឧបករណ៍ សារធាតុវិទ្យុសកម្ម និងសេវាផ្សេងទៀតដែលច្បាប់តម្រូវឲ្យមានការឯកភាពរបស់រដ្ឋបាលចំណីអាហារ និងឱសថ ("FDA") ដើម្បីយកមកលក់នៅក្នុងសហរដ្ឋអាមេរិក ប៉ុន្តែមិនត្រូវបានឯកភាពដោយ FDA។ ការលើកលែងនេះមិនអនុវត្តទៅលើស្ថានភាពដូចក្រោម៖

- សេវាសង្គ្រោះបន្ទាន់មានជានារ៉ាប់រងដែលបានទទួលក្នុងប្រទេសកាណាដា ឬ មីចសុិកូ
- សេវាត្រូវបានរ៉ាប់រងនៅក្រោម "ការសាកល្បងការព្យាបាលជម្ងឺមហារីក" ក្នុងជំពូកទី 4 នៃសៀវភៅណែនាំសមាជិកនេះ
- សេវាត្រូវបានផ្តល់ជាផ្នែកនៃសេវាអង្គេតមានជានារ៉ាប់រង ដូចបានពណ៌នាក្នុងជំពូកទី 4 នៃសៀវភៅណែនាំសមាជិកនេះ

សេវាបានអនុវត្តដោយអ្នកដែលគ្មានអាជ្ញាប័ណ្ណ

ការរ៉ាប់រង Medi-Cal មិនរួមបញ្ចូលសេវាដែលត្រូវបានអនុវត្តយ៉ាងមានសុវត្ថិភាព និងប្រសិទ្ធភាព ដោយអ្នកដែលមិនតម្រូវឲ្យមានអាជ្ញាប័ណ្ណ ឬលិខិបញ្ជាក់ដោយរដ្ឋដើម្បីផ្តល់សេវាថែទាំសុខភាពនិងនៅពេលដែលស្ថានភាពរបស់សមាជិកនោះ មិនតម្រូវឲ្យអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ ផ្តល់សេវានោះទេ

ការមិនរាប់បញ្ចូលនេះមិនអនុវត្តចំពោះសេវាដែលរ៉ាប់រងនៅក្រោម "ការព្យាបាលសុខភាពផ្លូវចិត្ត" នៅក្រោម "សេវាស្តារនិងពង្រឹងនីតិសម្បទា" នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំសមាជិកនេះ។ ការបដិសេធនេះក៏មិនអនុវត្តចំពោះ Community Supports ដែលត្រូវបានយល់ព្រមសម្រាប់អ្នកដែរ។

សេវាទាក់ទងនឹងសេវាមិនមានធានារ៉ាប់រង

នៅពេលសេវាមួយមិនត្រូវបានរ៉ាប់រង រាល់សេវាទាំងអស់ដែលពាក់ព័ន្ធទៅនឹងសេវា ដែលមិនមានធានារ៉ាប់រងនោះត្រូវបានដកចេញ។ ការមិនរាប់បញ្ចូលនេះមិនអនុវត្តទៅលើការព្យាបាលនៃការផលវិបាក ដែលជាលទ្ធផលមកពី សេវាមិនត្រូវបានរ៉ាប់រងទេ ប្រសិនបើផលវិបាកទាំងនោះ នឹងត្រូវបានរ៉ាប់រងដោយ Medi-Cal។ ឧទាហរណ៍ ប្រសិនបើអ្នកមានការរះកាត់កែសម្រស់ដែលមិនត្រូវបានរ៉ាប់រង យើងនឹងមិនរ៉ាប់រងចំពោះសេវាដែលអ្នកទទួល ដើម្បីរៀបចំសម្រាប់ការរះកាត់ ឬសម្រាប់ការថែទាំតាមដានបន្តឡើយ។ ប្រសិនបើអ្នករងនូវផលវិបាកដែលគំរាមកំហែងដល់អាយុជីវិត ដូចជាការឆ្លងមេរោគធ្ងន់ធ្ងរ ការដកចេញនេះនឹងមិនអនុវត្តទេ ហើយយើងនឹងរ៉ាប់រងសេវាដែលត្រូវការដើម្បីព្យាបាល ផលវិបាកនោះ ដរាបណាសេវាត្រូវបានរ៉ាប់រងដោយ Medi-Cal។

ការគ្រប់គ្រងករណីពុលជាតិសំណក្នុងកុមារភាពផ្តល់ដោយមន្ទីរសុខាភិបាលខោនធី

សូមទំនាក់ទំនងខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែមអំពីសេវាគ្រប់គ្រងករណីពុលជាតិសំណ ។

ការវាយតម្លៃនៃបច្ចេកវិទ្យាថ្មីនិងដែលមានស្រាប់

Kaiser Permanente មានដំណើរការដែលហ្មត់ចត់សម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃ ភស្តុតាងការព្យាបាលសម្រាប់បច្ចេកវិទ្យាវេជ្ជសាស្ត្រថ្មីដែលជាការព្យាបាលនិងការធ្វើតេស្ត។ វេជ្ជបណ្ឌិតក្នុងបណ្តាញសំរេចចិត្តថាតើបច្ចេកវិទ្យាវេជ្ជសាស្ត្រថ្មីដែលត្រូវបានបង្ហាញថាមាន សុវត្ថិភាពនិងមានប្រសិទ្ធភាពនៅក្នុងការសិក្សាស្រាវជ្រាវការព្យាបាលដែលត្រូវបានវាយតម្លៃ និងបោះពុម្ពផ្សាយ មានលក្ខណៈត្រឹមត្រូវផ្តែកវេជ្ជសាស្ត្រសម្រាប់អ្នកជំងឺរបស់ពួកគេដែរឬទេ។

5. ការថែទាំសុខភាពកុមារនិងយុវជន

សមាជិកដែលជាកុមារ និងយុវជនដែលមានអាយុក្រោម 21 ឆ្នាំអាចទទួលបានសេវាសុខភាពពិសេសភ្លាមនៅពេលដែលពួកគេត្រូវបានចាត់តាំងទៅ Kaiser Permanente។ នេះធ្វើឲ្យប្រាកដថាពួកគេទទួលបានសេវាកម្មបង្ការ ធ្មេញ សុខភាពផ្លូវចិត្ត និងអភិវឌ្ឍន៍ និងឯកទេសដែលត្រឹមត្រូវ។ ជំពូកនេះពន្យល់អំពីសេវាកម្មទាំងនេះ។

សេវាជំងឺកុមារ (កុមារក្រោមអាយុ 21)

សមាជិកក្រោមអាយុ 21 ឆ្នាំត្រូវបានធានារ៉ាប់រងសម្រាប់ការថែទាំចាំបាច់។ បញ្ជីខាងក្រោមរួមមានសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រដើម្បីព្យាបាល ឬកែលម្អគុណវិបត្តិ និងការធ្វើរោគវិនិច្ឆ័យរាងកាយ ឬផ្លូវចិត្ត។ សេវាដែលបានរ៉ាប់រងរួមមាន ប៉ុន្តែមិនកំណត់តែចំពោះ ស្ថានភាពដូចខាងក្រោម៖

- ការទៅពិនិត្យសុខភាពទូទៅកុមារ និងការពិនិត្យក្មេងជំទង់ (ការជួបពិនិត្យសំខាន់ៗដែលកុមារត្រូវការ)
- ការចាក់ថ្នាំបង្ការ
- សេវាសុខភាពខាងផ្លូវចិត្តសម្រាប់ស្ថានភាពស្រាល ឬមធ្យម (សេវាសុខភាពផ្លូវចិត្តឯកទេសត្រូវបានរ៉ាប់រងដោយខោនធី)
- សេវាស្តាប់ (រ៉ាប់រងដោយ California Children's Services ["CCS"] សម្រាប់កុមារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ យើងនឹងរ៉ាប់រងលើសេវាការស្តាប់ចាំបាច់ផ្នែកវេជ្ជសាស្ត្រដែល CCS មិនរ៉ាប់រង)
- តេស្តនៅទីពិសោធន៍ រួមទាំងការធ្វើតេស្តរកជាតិពុលសំណក្តងឈាម
- ការអប់រំសុខភាពនិងការការពារ
- សេវាផ្នែកចក្ខុ
- សេវាទន្តសាស្ត្រ (រ៉ាប់រងដោយ បង់ថ្លៃពេលប្រើសេវា [Fee-For-Service, FFS] Medi-Cal Dental)
- សេវាទន្តសាស្ត្រ (រ៉ាប់រងដោយ Dental Managed Care)

សេវាទាំងនេះត្រូវបានគេហៅថា សេវាពិនិត្យ និងព្យាបាលជាមុន និងតាមកាលកំណត់ (Early and Periodic Screening, Diagnostic and Treatment, EPSDT)។ សេវា EPSDT ដែលត្រូវបានផ្តល់អនុសាសន៍ ដោយសេចក្តីណែនាំរបស់ក្រូពេទ្យកុមារដើម្បីជួយអ្នក ឬកូនរបស់អ្នកឲ្យមានសុខភាពល្អ។

ការពិនិត្យសុខភាព និងការថែទាំបង្ការសុខភាពកុមារ

ការថែទាំបង្ការរួមមានការពិនិត្យសុខភាព និងការពិនិត្យសុខភាពជាប្រចាំ ដើម្បីជួយក្រូពេទ្យរបស់អ្នកស្វែងរកបញ្ហាបានទាន់ពេល និងសេវាប្រឹក្សាដើម្បីរកមើលជំងឺ មេរោគ ឬលក្ខខណ្ឌវេជ្ជសាស្ត្រ មុនពេលពួកគេបង្កបញ្ហា។ ការពិនិត្យសុខភាពទៀងទាត់ជួយអ្នក និងកូនរបស់អ្នកស្វែងរកបញ្ហាណាមួយ។ បញ្ហាអាចរួមមានផ្នែកវេជ្ជសាស្ត្រ ធ្មេញ ចក្ខុ ការស្តាប់ សុខភាពផ្លូវចិត្ត និងបញ្ហាការប្រើប្រាស់សារធាតុញៀន (គ្រឿងញៀន)។ យើងរ៉ាប់រងលើការពិនិត្យដើម្បីពិនិត្យរកមើលបញ្ហា (រួមទាំងការវាយតម្លៃកម្រិតជាតិសំណ) នៅពេលណាដែលមានតម្រូវការសម្រាប់ពួកគេ ទោះបីជាវាមិនមែនជាអំឡុងពេលពិនិត្យសុខភាពទៀងទាត់របស់អ្នក ឬកូនរបស់អ្នកក៏ដោយ។

ការថែទាំបង្ការក៏រួមមានការចាក់ថ្នាំបង្ការដែលអ្នក ឬកូនរបស់អ្នកត្រូវការ។ យើងត្រូវតែធ្វើឲ្យប្រាកដថាកុមារដែលបានចុះឈ្មោះទាំងអស់ ទទួលការចាក់ថ្នាំបង្ការដែលចាំបាច់ នៅពេលនៃការពិនិត្យសុខភាព។ សេវាថែទាំបង្ការ និងការឆ្លុះពិនិត្យគឺមានជូនដោយមិនយកប្រាក់ និងដោយមិនត្រូវការការយល់ព្រមមុន (ការអនុញ្ញាតជាមុន)

កូនរបស់អ្នកត្រូវទទួលការពិនិត្យសុខភាពនៅក្នុងអាយុទាំងនេះ៖

- 2-4 ថ្ងៃក្រោយពីកំណើត
- 1 ខែ
- 2 ខែ
- 4 ខែ
- 6 ខែ
- 9 ខែ
- 12 ខែ
- 15 ខែ
- 18 ខែ
- 24 ខែ
- 30 ខែ
- ម្តងមួយឆ្នាំពីអាយុ 3 ឆ្នាំរហូតដល់ 20 ឆ្នាំ

ការពិនិត្យសុខភាពកូនរួមមាន៖

- ប្រវត្តិពេញលេញ និងការពិនិត្យរាងកាយពីក្បាលដល់ចុងជើង
- ការចាក់ថ្នាំបង្ការរោគតាមអាយុ (កាលីហ្វ័រញ៉ាធ្វើតាមកាលវិភាគបណ្ឌិតសភាអាមេរិចផ្នែកជំងឺកុមារ Bright Futures ភាពតាមកំណត់ពេល)
- តេស្តនៅទីពិសោធន៍ រួមទាំងការធ្វើតេស្តរកជាតិពុលឡិដ ក្នុងឈាម
- ការអប់រំសុខភាព

- ការតេស្តមើលភ្នែក និងការស្តាប់
- ការពិនិត្យសុខភាពមាត់ធ្មេញ
- ការវាយតម្លៃសុខភាពអាកប្បកិរិយា

នៅពេលដែលមានបញ្ហាសុខភាពផ្លូវកាយឬផ្លូវចិត្តត្រូវបានរកឃើញ ក្នុងកំឡុងពេលពិនិត្យឬឆ្លុះពិនិត្យសុខភាព អាចមានការមើលថែទាំដែលអាចដោះស្រាយបញ្ហាឬជួយបញ្ហានោះបាន។ ប្រសិនបើការថែទាំគឺជាការចាំបាច់ខាងវេជ្ជសាស្ត្រ ហើយយើងទទួលខុសត្រូវក្នុងការចំណាយលើការថែទាំ យើងនឹងរ៉ាប់រងការថែទាំនោះដោយមិនគិតថ្លៃដល់អ្នក។ សេវាទាំងនេះរួមមាន៖

- វេជ្ជបណ្ឌិត គិលានុបដ្ឋាយិនាញ និង ការថែទាំមន្ទីរពេទ្យ
- ការចាក់ថ្នាំបង្ការដើម្បីជួយអ្នកឲ្យមានសុខភាពល្អ
- ការព្យាបាលដោយចលនា ការនិយាយ/ភាសា និងដោយវិជ្ជាជីវៈ
- សេវាសុខភាពតាមផ្ទះដែលអាចជាបរិក្ខាវេជ្ជសាស្ត្រ គ្រឿងផ្គត់ផ្គង់ និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ
- ការព្យាបាលបញ្ហាភ្នែក រួមទាំងវែនតា
- ការព្យាបាលបញ្ហានៃការស្តាប់ រួមទាំងឧបករណ៍ជំនួយការស្តាប់ នៅពេលដែលវាមិនត្រូវបានរ៉ាប់រងដោយ CCS
- ការព្យាបាលសុខភាពអាកប្បកិរិយាចំពោះរបិត្តិអូធីសឹម និងពិការភាពផ្នែកការលូតលាស់ផ្សេងៗទៀត
- ការគ្រប់គ្រងករណី និងការអប់រំសុខភាព
- ការវះកាត់កែលម្អដែលជាការវះកាត់ដើម្បីកែ ឬជួសជុលរចនាសម្ព័ន្ធមិនធម្មតានៃរាងកាយ ដែលបណ្តាលមកពីភាពពិការពីកំណើត ភាពខុសប្រក្រតីផ្នែកការលូតលាស់ ការប៉ះទង្គិច ការឆ្លងមេរោគ ដុំសាច់ ឬជំងឺ ដើម្បីធ្វើឲ្យមុខងារប្រសើរឡើង ឬបង្កើតឲ្យមានរូបរាងធម្មតា

ការតេស្តជាតិពុលសំណក្នុងឈាម

កុមារទាំងអស់ដែលត្រូវបានចាត់តាំងឲ្យទៅ Kaiser Permanente គួរតែទទួលបានការធ្វើតេស្តជាតិពុលសំណក្នុងឈាមនៅអាយុ 12 ទៅ 24 ខែ ឬចន្លោះអាយុពី 36 ទៅ 72 ខែ ប្រសិនបើពួកគេមិនទាន់ត្រូវបានធ្វើតេស្តពីមុន។

ជំនួយដើម្បីទទួលបានសេវាថែទាំសុខភាពកុមារ និងយុវជន

យើងនឹងជួយសមាជិកក្រោមអាយុ 21 ឆ្នាំហើយនិងគ្រួសាររបស់ពួកគេទទួលសេវាដែលពួកគេត្រូវការ។ អ្នកសម្របសម្រួលថែទាំ Kaiser Permanente អាច៖

- ប្រាប់អ្នកអំពីសេវាដែលមានជូន៖
- ជួយស្វែងរកអ្នកផ្តល់បណ្តាញ ឬអ្នកផ្តល់សេវាក្រៅបណ្តាញ នៅពេលចាំបាច់
- ជួយដាក់ការណាត់ជួប
- រៀបចំការដឹកជញ្ជូនវេជ្ជសាស្ត្រ និងការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ ដូច្នេះកុមារអាចទៅដល់ការណាត់ជួបរបស់ពួកគេ។
- ជួយសម្របសម្រួលការថែទាំសម្រាប់សេវានានា តាមរយៈ FFS Medi-Cal ដូចជា ប៉ុន្តែមិនកំណត់តែចំពោះ៖
  - ♦ សេវាព្យាបាលនិងស្ថានីតិសម្បទាសម្រាប់សុខភាពផ្លូវចិត្ត និងរបត្តិប្រើប្រាស់គ្រឿងញៀន
  - ♦ ការព្យាបាលបញ្ហាធ្មេញ រួមជាមួយការតម្រង់ធ្មេញ

សេវាដែលអ្នកអាចទទួលបានតាមរយៈថ្លៃឈួល-សម្រាប់-សេវា ("FFS") Medi-Cal ឬកម្មវិធីផ្សេងៗទៀត

ការពិនិត្យធ្មេញ

រក្សាអញ្ចាញ្ចកូនរបស់អ្នកឲ្យស្អាត ដោយការដុះជួមៗ ជាមួយក្រណាត់លាងសំអាតរៀងរាល់ថ្ងៃ។ នៅប្រហែលបួនទៅប្រាំមួយ ខែ "ការដុះឡើងនូវធ្មេញដំបូង" នឹងចាប់ផ្តើមនៅពេលដែលធ្មេញទារកចាប់ផ្តើមចូលមក។ អ្នកគួរតែធ្វើការណាត់ជួបសម្រាប់ការពិនិត្យធ្មេញលើកដំបូងរបស់កូនអ្នកភ្លាមៗ នៅពេលដែលធ្មេញដំបូងរបស់ពួកគេដុះចេញមក ឬនៅខួបកំណើតដំបូងរបស់ពួកគេ មួយណាដែលដល់មុនគេ។

សេវាធ្មេញ Medi-Cal ខាងក្រោមគឺជាសេវាឥតគិតថ្លៃ ឬតម្លៃទាបសម្រាប់៖

ទារកអាយុ 1 ទៅ 4

- ការទៅជួបពេទ្យធ្មេញដំបូងរបស់ទារក
- ការពិនិត្យមើលធ្មេញដំបូងរបស់ទារក
- ការពិនិត្យមើលធ្មេញ (រៀងរាល់ 6 ខែ; រៀងរាល់ 3 ខែពីកំណើតរហូតដល់ 3 ឆ្នាំ)
- ការស្ទីអ៊ិច
- ការសំអាតធ្មេញ (រៀងរាល់ 6 ខែ)
- លាបវ៉ានីស ផ្លូអរ៉ាយ (រៀងរាល់ 6 ខែ)
- ការបំពេញប្រហោងធ្មេញ
- ការដកធ្មេញ

- សេវាសង្គ្រោះបន្ទាន់
- សេវាជំងឺមិនសម្រាកមន្ទីរពេទ្យ
- ការប្រើថ្នាំស្ពឹក (ប្រសិនបើចាំបាច់ខាងវេជ្ជសាស្ត្រ)

កុមារអាយុ 5-12

- ការពិនិត្យធ្មេញ (រៀងរាល់ 6 ខែ)
- ការាំស្ពីអ៊ុច
- ការលាបថ្នាំ ផ្លូអរ៉ាយកម្រិតខ្លាំង (រៀងរាល់ 6 ខែ)
- ការសំអាតធ្មេញ (រៀងរាល់ 6 ខែ)
- ការស្រោបថ្នាំលើថ្គាមធ្មេញ
- ការបំពេញប្រហោងធ្មេញ
- ការជួសជុលឬសធ្មេញ
- សេវាសង្គ្រោះបន្ទាន់
- សេវាជំងឺមិនសម្រាកមន្ទីរពេទ្យ
- ការប្រើថ្នាំស្ពឹក (ប្រសិនបើចាំបាច់ខាងវេជ្ជសាស្ត្រ)

កុមារអាយុ 13-17

- ការពិនិត្យមើលធ្មេញ (រៀងរាល់ 6 ខែ)
- ការាំស្ពីអ៊ុច
- លាបថ្នាំ ផ្លូអរ៉ាយកម្រិតខ្លាំង (រៀងរាល់ 6 ខែ)
- ការសំអាតធ្មេញ (រៀងរាល់ 6 ខែ)
- ធ្មេញ (រណប) សម្រាប់អ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- ការបំពេញប្រហោងធ្មេញ
- ស្រោបធ្មេញ
- សរសៃធ្មេញ
- ការដកធ្មេញ
- សេវាសង្គ្រោះបន្ទាន់
- សេវាជំងឺមិនសម្រាកមន្ទីរពេទ្យ
- ការប្រើថ្នាំស្ពឹក (ប្រសិនបើចាំបាច់ខាងវេជ្ជសាស្ត្រ)

ប្រសិនបើអ្នកមានសំណួរ ឬចង់ស្វែងយល់បន្ថែមអំពីសេវាធ្មេញ សូមទូរស័ព្ទទៅ Medi-Cal Denti-Cal **1-800-322-6384** (TTY/TDD **1-800-735-2922** ឬ **711**)។ អ្នកក៏អាចចូលទៅគេហទំព័រ Medi-Cal Dental Program នៅ **https://smilecalifornia.org/** (ជាភាសាអង់គ្លេស)។

សេវាបញ្ជូនការអប់រំបង្ការបន្ថែម

ប្រសិនបើអ្នកព្រួយបារម្ភថាកូនរបស់អ្នកមានការពិបាកក្នុងការចូលរួម និងរៀនសូត្រនៅសាលា សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតថែទាំបឋមរបស់កូនអ្នក គ្រូ ឬបុគ្គលិកគ្រប់គ្រងនៅសាលា។ បន្ថែមពីលើអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្ររបស់អ្នកដែលរ៉ាប់រងដោយពួកយើង មានសេវាដែលសាលាត្រូវតែផ្តល់ដើម្បីជួយកូនរបស់អ្នករៀន និងមិនតាមមិនទាន់គេ។

គំរូនៃសេវាដែលនឹងត្រូវបានផ្តល់ដើម្បីជួយកូនរបស់អ្នកឲ្យរៀន រួមមាន៖

- សេវានិយាយ និងភាសា
- សេវាផ្លូវចិត្ត
- ការព្យាបាលដោយចលនារាងកាយ
- ការព្យាបាលដោយកិច្ចការងារ
- បច្ចេកវិទ្យាជំនួយ
- សេវាការសង្គមកិច្ច
- សេវាប្រឹក្សា
- សេវាគិលានុបដ្ឋាយិកាសាលា
- ការដឹកជញ្ជូនទៅនិងមកពីសាលា

សេវាទាំងនេះត្រូវបានផ្តល់ដោយ និងបង់ថ្លៃដោយនាយកដ្ឋានអប់រំរដ្ឋកាលីហ្វ័រញ៉ា។ រួមគ្នាជាមួយវេជ្ជបណ្ឌិត និងគ្រូរបស់កូនអ្នក អ្នកអាចបង្កើតផែនការផ្ទាល់ខ្លួនដែលនឹងជួយកូនរបស់អ្នកបានល្អបំផុត។

6. ការរាយការណ៍និងការដោះស្រាយបញ្ហា

មានបញ្ហាពីរប្រភេទដែលអ្នកអាចមានជាមួយ Kaiser Permanente៖

- **ពាក្យបណ្តឹងភ្លាញ់ភ្នែរ** (ឬ **សារទុក្ខ**) គឺនៅពេលអ្នកមានបញ្ហាជាមួយ Kaiser Permanente ឬអ្នកផ្តល់សេវា ឬជាមួយការថែទាំសុខភាព ឬការព្យាបាលដែលអ្នកទទួលបានពីអ្នកផ្តល់សេវា
- បណ្តឹង **ឧទ្ធរណ៍** គឺនៅពេលដែលអ្នកមិនយល់ព្រមជាមួយនឹងការសម្រេចចិត្តរបស់យើងក្នុងការមិនរ៉ាប់រង ឬផ្លាស់ប្តូរសេវារបស់អ្នក

អ្នកអាចប្រើប្រាស់ដំណើរការបណ្តឹងសារទុក្ខ និងបណ្តឹងឧទ្ធរណ៍បស់ Kaiser Permanente ដើម្បីប្រាប់ឲ្យយើងដឹងអំពីបញ្ហារបស់អ្នក។ អ្នកក៏អាចទំនាក់ទំនង L.A. Care Health Plan ជំនួសឲ្យ Kaiser Permanente បានដែរ។ សូមទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃបុណ្យដើម្បី ប្រាប់ពួកគេបញ្ហារបស់អ្នក។ ការប្រើប្រាស់ទាំងដំណើរការបណ្តឹងសារទុក្ខរបស់ Kaiser Permanente ឬ L.A. Care Health Plan នឹងមិនដកហូតសិទ្ធិស្របច្បាប់ណាមួយរបស់អ្នកឡើយ។ ទាំង Kaiser Permanente និង L.A. Care Health Plan នឹងមិនរើសអើងឬសងសឹកប្រឆាំងនឹងអ្នក ដោយសារការភ្លាញ់ភ្នែរប្រាប់យើងឡើយ។ ការអនុញ្ញាតឲ្យយើងដឹងអំពីបញ្ហារបស់អ្នកនឹងជួយយើងកែលម្អការថែទាំសម្រាប់ សមាជិកទាំងអស់។

ប្រសិនបើបណ្តឹងសារទុក្ខ ឬបណ្តឹងតឧទ្ធរណ៍របស់អ្នកនៅតែមិនត្រូវបានដោះស្រាយបន្ទាប់ពី 30 ថ្ងៃ ឬអ្នកមិនសប្បាយចិត្តនឹងលទ្ធផល អ្នកអាចស្នើសុំឲ្យ នាយកដ្ឋានការថែទាំសុខភាពមានការគ្រប់គ្រង (Department of Managed Health Care, DMHC) ពិនិត្យមើលការតវ៉ារបស់អ្នក ឬធ្វើការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រឯករាជ្យ (Independent Medical Review, "IMR")។ អ្នកអាចទូរស័ព្ទទៅនាយកដ្ឋានការថែទាំសុខភាពមានការគ្រប់គ្រងរដ្ឋកាលីហ្វ័រញ៉ា ("DMHC") លេខ **1-888-466-2219** (TTY **1-877-688-9891** ឬ **711**) ឬ ចូលទៅគេហទំព័រ DMHC **www.dmhc.ca.gov** (ជាភាសាអង់គ្លេស)។

មន្ត្រីស៊ើបអង្កេតការថែទាំគ្រប់គ្រង Medi-Cal នៃនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋ កាលីហ្វ័រញ៉ា (Department of Health Care Services, "DHCS") ក៏អាចជួយបានផងដែរ។ ពួកគេអាចជួយបាន ប្រសិនបើអ្នកមានបញ្ហាក្នុងការចូលរួម ផ្លាស់ប្តូរ ឬចាកចេញពីផែនការសុខភាព។ ពួកគេក៏អាចជួយបានដែរ ប្រសិនបើអ្នកផ្លាស់ប្តូរទីលំនៅនិងមានការលំបាកក្នុងការទទួលបាន Medi-Cal របស់អ្នកដែលបានផ្ទេរទៅខោនធីថ្មីរបស់អ្នក។ អ្នកអាចទូរស័ព្ទទៅមន្ត្រីអង្កេតការណ៍លេខ1-888-452-8609 ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹកដល់ម៉ោង 5 ល្ងាច។

អ្នកក៏អាចដាក់ពាក្យបណ្តឹងជាមួយនឹងការិយាល័យផ្នែកសិទ្ធិទទួលបានក្នុងខោនធីអ្នក អំពីសិទ្ធិទទួលបាន Medi-Cal របស់អ្នក។ ប្រសិនបើអ្នកមិនច្បាស់ថាអ្នកណាដែលអ្នកអាចដាក់ពាក្យសារទុក្ខរបស់អ្នកជាមួយ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

ដើម្បីរាយការណ៍ពីព័ត៌មានខុសទាក់ទងនឹងការធានារ៉ាប់រងសុខភាពបន្ថែមរបស់អ្នក សូមទូរស័ព្ទទៅ Medi-Cal លេខ **1-800-541-5555** ថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ រវាងម៉ោង 8 ព្រឹកនិងម៉ោង 5 ល្ងាច។

ពាក្យបណ្តឹងភ្លាញស្អែរ

ពាក្យបណ្តឹងភ្លាញស្អែរ (ឬសារទុក្ខ) គឺនៅពេលដែលអ្នកមានបញ្ហាឬមិនសប្បាយចិត្ត ជាមួយសេវាដែលអ្នកកំពុងទទួលបានពី Kaiser Permanente ឬអ្នកផ្តល់សេវា។ មិនមានពេលវេលាកំណត់ក្នុងការដាក់ពាក្យបណ្តឹងទេ។

ប្រសិនបើអ្នកមានពាក្យបណ្តឹងអំពីថ្នាំតាមវេជ្ជបញ្ជារបស់អ្នកជំងឺក្រៅដែលអ្នកបានទទួលតាមរយៈ Medi-Cal Rx សូមដាក់ពាក្យបណ្តឹងរបស់អ្នកទៅកាន់ Medi-Cal Rx។ អ្នកអាចដាក់បណ្តឹងតវ៉ា ឬក្នុងលាយលក្ខណ៍អក្សរ ឬតាមរយៈទូរស័ព្ទដោយចូលទៅ **www.Medi-CalRx.dhcs.ca.gov** (ជាភាសាអង់គ្លេស) ឬទូរស័ព្ទទៅសេវា Medi-Cal Rx សេវាកម្មអតិថិជន លេខ **1-800-977-2273** 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយសប្តាហ៍។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅលេខ 711 ច័ន្ទដល់សុក្រពីម៉ោង 8 ព្រឹកដល់ 5 ល្ងាច។

បណ្តឹងតវ៉ាទាក់ទងនឹងអត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx មិនស្ថិតក្រោមដំណើរការសារទុក្ខរបស់យើងទេ ហើយមិនមានសិទ្ធិទទួលបានការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រឯករាជ្យទេ។ សមាជិកអាចដាក់បណ្តឹងតវ៉ាអំពីអត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx ដោយទូរស័ព្ទទៅលេខ **1-800-977-2273** (TTY **800-977-2273** និងចុចលេខ 5 ឬ **711**) ឬចូលទៅ **www.Medi-CalRx.dhcs.ca.gov** (ជាភាសាអង់គ្លេស)។ ប្រសិនបើគ្រូពេទ្យរបស់អ្នកបដិសេធមិនចេញវេជ្ជបញ្ជាថ្នាំដែលអ្នកគិតថាអ្នកត្រូវការ អ្នកអាចស្នើសុំការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រឯករាជ្យលើការសម្រេចចិត្តរបស់វេជ្ជបណ្ឌិតរបស់អ្នក។ លេខទូរស័ព្ទឥតគិតថ្លៃរបស់ DMHC គឺ **1-888-466-2219** ហើយនិងបណ្តាញ TTY គឺ **1-877-688-9891**។ អ្នកអាចស្វែងរកការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យ/ទម្រង់បណ្តឹងភ្លាញស្អែរ និងសេចក្តីណែនាំតាមអនឡាញ នៅគេហទំព័ររបស់ DMHC៖ **www.dmhc.ca.gov** (ជាភាសាអង់គ្លេស)។

សម្រាប់បញ្ហាដទៃទៀតទាំងអស់ អ្នកអាចដាក់ពាក្យបណ្តឹងតាមរយៈ Kaiser Permanente ឬ L.A. Care Health Plan គ្រប់ពេលតាមទូរស័ព្ទ ដោយសរសេរ ឬតាមអនឡាញ។

- **តាមទូរស័ព្ទ៖**
  - សូមទូរស័ព្ទទៅសេវាសមាជិក Kaiser Permanente លេខ **1-800-464-4000** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងតែថ្ងៃឈ

ប់សម្រាកដែលបិទ) ។ ផ្តល់ឲ្យយើងនូវលេខកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក ឈ្មោះរបស់អ្នក និងហេតុផលសម្រាប់បណ្តឹងភ្ជាប់ផ្សែរបស់អ្នក

- ទូរស័ព្ទទៅផ្នែកសេវាសមាជិក LA Care Health Plan តាមលេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃបុណ្យ សូមផ្តល់លេខសម្គាល់ផែនការសុខភាព LA Care របស់អ្នក ឈ្មោះរបស់អ្នក និងហេតុផលសម្រាប់ពាក្យបណ្តឹងរបស់អ្នក

- **តាមប្រៃសណីយ៍៖**
  - សូមទូរស័ព្ទទៅសេវាសមាជិក Kaiser Permanente លេខ **1-800-464-4000** (TTY **711**) និងស្នើសុំឲ្យគេផ្ញើរទម្រង់បែបបទទៅអ្នក ។ លើសពីនេះ ការិយាល័យវេជ្ជបណ្ឌិតរបស់អ្នកក៏នឹងមានទម្រង់បែបបទពាក្យបណ្តឹងផងដែរ។ នៅពេលអ្នកទទួលបានទម្រង់បែបបទ សូមបំពេញវា។ ត្រូវប្រាកដថារួមបញ្ចូលឈ្មោះរបស់អ្នក លេខកំណត់ត្រាវេជ្ជសាស្ត្រ និងមូលហេតុសម្រាប់បណ្តឹងរបស់អ្នក។ ប្រាប់យើងពីអ្វីដែលបានកើតឡើងនិងរបៀបដែលយើងអាចជួយអ្នកបាន។ ផ្ញើទម្រង់បែបបទទៅការិយាល័យសេវាសមាជិកនៅទីតាំងក្នុងបណ្តាញ Kaiser Permanente (សូមមើលសៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា **kp.org/facilities** [ជាភាសាអង់គ្លេស] ដើម្បីរកទីតាំង)
  - សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) ហើយស្នើសុំឲ្យមានទម្រង់បែបបទផ្ញើទៅអ្នក ។ នៅពេលអ្នកទទួលបានទម្រង់បែបបទ សូមបំពេញវា។ ត្រូវប្រាកដថារួមបញ្ចូលឈ្មោះរបស់អ្នក លេខអត្តសញ្ញាណផែនការសុខភាព និងមូលហេតុសម្រាប់បណ្តឹងរបស់អ្នក។ ប្រាប់ពួកគេនូវអ្វីដែលបានកើតឡើង និងរបៀបដែលពួកគេអាចជួយអ្នក។ ផ្ញើរទម្រង់បែបទទៅ៖

    L.A. Care Health Plan
    1055 W. 7th St., 10th Floor
    Los Angeles, CA 90017

- **ដោយជួបផ្ទាល់៖**
  - បំពេញសំណុំបែបបទបណ្តឹងភ្ជាប់ផ្សែរ ឬបណ្តឹងទាមទារសំណង/ស្នើសុំអត្ថប្រយោជន៍ នៅការិយាល័យសេវាសមាជិកដែលស្ថិតនៅទីតាំងផែនការ

- **តាមអនឡាញ៖**
  - ប្រើទម្រង់បែបបទអនឡាញនៅលើគេហទំព័ររបស់យើងតាមរយៈ **kp.org** (ជាភាសាអង់គ្លេស)
  - សូមចូលទៅគេហទំព័រ L.A. Care Health Plan **www.lacare.org** (ជាភាសាអង់គ្លេស)

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យបណ្តឹងរបស់អ្នក យើងអាចជួយអ្នកបាន។ យើងអាចផ្តល់ឲ្យអ្នកនូវសេវាភាសាឥតគិតថ្លៃ។ ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ

1-800-464-4000 (TTY **711**)។ អ្នកក៏អាចទទួលជំនួយពី L.A. Care Health Plan ផងដែរ។ ពួកគេក៏អាចផ្តល់ឲ្យអ្នកនូវសេវាភាសាឥតគិតថ្លៃផងដែរ។

ប្រសិនបើអ្នកបានដាក់ពាក្យបណ្តឹងរបស់អ្នកជាមួយ L.A. Care Health Plan ពួកគេនឹងធ្វើការជាមួយអ្នកនិង Kaiser Permanente ដើម្បីដោះស្រាយបញ្ហា។ ដើម្បីស្វែងយល់បន្ថែមអំពីដំណើរការបណ្តឹងសារទុក្ខ L.A. Care Health Plan សូមទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**)។

ក្នុងរយៈពេល 5 ថ្ងៃបន្ទាប់ពីទទួលបានពាក្យបណ្តឹង យើងនឹងផ្ញើលិខិតមួយជូនដំណឹងអ្នកថាយើងបានទទួលវា។ ក្នុងរយៈពេល 30 ថ្ងៃ យើងនឹងផ្ញើលិខិតមួយទៀតប្រាប់អ្នកអំពីរបៀបដែលយើងបាន ដោះស្រាយបញ្ហារបស់អ្នក។ ប្រសិនបើអ្នកបានដាក់ពាក្យបណ្តឹងសារទុក្ខរបស់អ្នកជាមួយ L.A. Care Health Plan ពួកគេនឹងឆ្លើយតបក្នុងកំឡុងពេលដូចគ្នា។ ប្រសិនបើអ្នកទូរស័ព្ទមកយើងអំពីសារទុក្ខដែលមិនមែនទាក់ទងនឹងការរ៉ាប់រងថែទាំសុខភាព ឬភាពចាំបាច់ខាងវេជ្ជសាស្ត្រ ការព្យាបាលស្រាវជ្រាវឬអង្គេត ហើយសារទុក្ខរបស់អ្នកត្រូវបានដោះស្រាយនៅពេលចុងបញ្ចប់នៃថ្ងៃធ្វើការបន្ទាប់ អ្នកអាចមិនទទួលបានលិខិតឡើយ ។

ប្រសិនបើអ្នកចង់ ឬក្រូពេទ្យរបស់អ្នកចង់អោយ Kaiser Permanente ឬ L.A. Care Health Plan ធ្វើការសំរេចចិត្តអោយបានលឿន ពីព្រោះពេលវេលាដែលត្រូវការដើម្បីដោះស្រាយបណ្តឹងតវ៉ារបស់អ្នកនឹងធ្វើអោយអាយុជីវិត សុខភាព ឬសមត្ថភាពរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់ អ្នកអាចស្នើសុំការត្រួតពិនិត្យបន្ទាន់ (លឿន)។ ដើម្បីស្នើសុំការត្រួតពិនិត្យបន្ទាន់ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក លេខ **1-800-464-4000** (TTY **711**) ឬ L.A. Care Health Plan **1-888-839-9909** (TTY **711**)។ ក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីការទទួលពាក្យបណ្តឹងរបស់អ្នក យើង ឬ L.A. Care Health Plan នឹងធ្វើការសម្រេចចិត្តអំពីរបៀបដែលយើងនឹងដោះស្រាយបណ្តឹងរបស់អ្នក និងថាតើយើងនឹងពន្លឿនការតវ៉ារបស់អ្នកដែរឬទេ។ ប្រសិនបើយើង ឬ L.A. Care Health Plan កំណត់ថាយើងនឹងមិនពន្លឿនការតវ៉ារបស់អ្នកទេ យើងនឹងប្រាប់អ្នកថាយើងនឹងដោះស្រាយការតវ៉ារបស់អ្នកក្នុងរយៈពេល 30 ថ្ងៃ។

បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍គឺខុសពីបណ្តឹងភ្លាមៗ។ បណ្តឹងឧទ្ធរណ៍គឺជាសំណើរសុំឲ្យ Kaiser Permanente ឬ L.A. Care Health Plan ត្រួតពិនិត្យនិងផ្លាស់ប្តូរការសម្រេចចិត្ត ដែលយើងបានធ្វើអំពីការធានារ៉ាប់រងសម្រាប់សេវាដែលត្រូវបានស្នើសុំ។ ប្រសិនបើយើងផ្ញើលិខិតជូនដំណឹងអំពីការអនុវត្តវិធានការណ៍ (Notice of Action, "NOA") ដែលប្រាប់អ្នកថាយើងកំពុងបដិសេធ ពន្យាពេល ផ្លាស់ប្តូរ ឬបញ្ចប់សេវា ហើយអ្នកមិនយល់ស្របជាមួយការសម្រេចចិត្តរបស់យើង អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ អ្នកផ្តល់សេវាថែទាំបឋម (Primary Care Provider, PCP) របស់អ្នកក៏អាចដាក់បណ្តឹងឧទ្ធរណ៍សម្រាប់អ្នកដោយការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក។

អ្នកត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល 60 ថ្ងៃប្រតិទិនចាប់ពីកាលបរិច្ឆេទ NOA ដែលអ្នកបានទទួល។ ប្រសិនបើយើងសម្រេចចិត្តកាត់បន្ថយ ផ្អាក ឬបញ្ឈប់សេវាដែលអ្នកកំពុ

ឯទទួលបានឥឡូវនេះ អ្នកអាចបន្តទទួលបានសេវានោះ ខណៈពេលដែលអ្នករង់ចាំការសម្រេចលើពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នក។ នេះត្រូវបានគេហៅថា ជំនួយបានទូទាត់ដែលកំពុងរង់ចាំ ដើម្បីទទួលបានជំនួយបានទូទាត់ដែលកំពុងរង់ចាំ អ្នកត្រូវតែស្នើសុំឲ្យយើងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល 10 ថ្ងៃចាប់ពីកាលបរិច្ឆេទនៅលើ NOA ឬមុនកាលបរិច្ឆេទដែលយើងបាននិយាយថាសេវារបស់អ្នកនឹងឈប់ មួយណាដែលមកដល់ក្រោយគេ។ នៅពេលអ្នកស្នើសុំបណ្តឹងឧទ្ធរណ៍ នៅក្រោមកាលៈទេសៈទាំងនេះ សេវាកម្មនឹងបន្ត។ យើងអាចតម្រូវឲ្យអ្នកបង់ប្រាក់សម្រាប់តម្លៃសេវា ប្រសិនបើការសម្រេចចិត្តចុងក្រោយនោះ បដិសេធ ឬផ្លាស់ប្តូរសេវាមួយ។

ប្រសិនបើអ្នកចង់ដាក់បណ្តឹងឧទ្ធរណ៍ចំពោះការសម្រេចចិត្តដែលបានធ្វើឡើងដោយ Medi-Cal Rx អ្នកអាចស្នើសុំសវនាការរដ្ឋមួយ។ នាយកដ្ឋានសេវាសង្គមរដ្ឋកាលីហ្វ័រញ៉ាមានដំណើរការសវនាការរដ្ឋ ប្រសិនបើអ្នកចង់ដាក់បណ្តឹងឧទ្ធរណ៍ការសម្រេចចិត្តរបស់ Medi-Cal Rx។ ដំណើរការនេះគឺខុសគ្នាពីដំណើរការបណ្តឹងឧទ្ធរណ៍ដែលអ្នកប្រើប្រាស់សម្រាប់អត្ថប្រយោជន៍ឯទៀតរបស់អ្នក។ ក្នុងសវនាការរដ្ឋ ចៅក្រមម្នាក់ពិនិត្យមើលសំណើរបស់អ្នកជាមួយនឹងព័ត៌មានគ្លីនិកពីឱសថការី DHCS ដើម្បីធ្វើឲ្យប្រាកដថាការសម្រេចចិត្តស្របនឹងគោលការណ៍ឱសថស្ថានរបស់ Medi-Cal។

សម្រាប់បញ្ហាដទៃទាំងអស់ទៀត អ្នកអាចដាក់បណ្តឹងឧទ្ធរណ៍តាមរយៈ Kaiser Permanente ឬ L.A. Care Health Plan ក្រៅពេលតាមទូរស័ព្ទ ដោយសរសេរ ដោយផ្ទាល់ ឬតាមអនឡាញ។

- **តាមទូរស័ព្ទ៖**
  - សូមទូរស័ព្ទទៅសេវាសមាជិក Kaiser Permanente លេខ **1-800-464-4000** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងតែថ្ងៃឈប់សម្រាកដែលបិទ) ។ ផ្តល់ឲ្យយើងនូវលេខកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកឈ្មោះរបស់អ្នក និងសេវាដែលអ្នកកំពុងដាក់បណ្តឹងឧទ្ធរណ៍
  - ទូរស័ព្ទទៅផ្នែកសេវាសមាជិក LA Care Health Plan តាមរយៈលេខ **1-888-839-9909** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃបុណ្យ សូមផ្តល់លេខសម្គាល់ផែនការសុខភាព LA Care របស់អ្នកឈ្មោះរបស់អ្នក និងសេវាដែលអ្នកកំពុងដាក់បណ្តឹងឧទ្ធរណ៍។ ពួកគេអាចផ្ញើរទម្រង់បែបបទដល់អ្នកដើម្បីបំពេញ ដើម្បីបញ្ជាក់ថាអ្នកបានស្នើសុំបណ្តឹងឧទ្ធរណ៍មួយ។
- **តាមប្រៃសណីយ៍៖**
  - សូមទូរស័ព្ទទៅសេវាសមាជិក Kaiser Permanente លេខ **1-800-464-4000** (TTY **711**) និងស្នើសុំឲ្យគេផ្ញើរទម្រង់បែបបទទៅអ្នក ។ លើសពីនេះ ការិយាល័យវេជ្ជបណ្ឌិតរបស់អ្នកក៏នឹងមានទម្រង់បែបបទបណ្តឹងឧទ្ធរណ៍ផងដែរ។ នៅពេលអ្នកទទួលបានទម្រង់បែបបទ សូមបំពេញវា។ សូមប្រាកដថារួមបញ្ចូលឈ្មោះរបស់អ្នក លេខកំណត់ត្រាវេជ្ជសាស្ត្រ និងសេវាដែលអ្នកកំពុងដាក់បណ្តឹងឧទ្ធរណ៍។ ផ្ញើទម្រង់បែបបទទៅការិយាល័យសេវាសមាជិកនៅទីតាំងក្នុងបណ្តាញផែនការ Kaiser Permanente (សូមមើល **kp.org/facilities** [ជាភាសាអង់គ្លេស] ដើម្បីរកទីតាំង)

- សូមទូរស័ព្ទទៅសេវាសមាជិក L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**) ហើយស្នើសុំឲ្យមានទម្រង់បែបបទផ្ញើរទៅអ្នក ។ នៅពេលអ្នកទទួលបានទម្រង់បែបបទ សូមបំពេញវា។ ត្រូវប្រាកដថារួមបញ្ចូលឈ្មោះរបស់អ្នក លេខអត្តសញ្ញាណ L.A. Care Health Plan និងសេវាដែលអ្នកកំពុងធ្វើឧទ្ធរណ៍។ ផ្ញើរទម្រង់ទៅ៖

  L.A. Care Health Plan
  1055 W. 7th St., 10th Floor
  Los Angeles, CA 90017

- **ទំនាក់ទំនងដោយផ្ទាល់**
  - បំពេញទម្រង់បណ្តឹងឧទ្ធរណ៍នៅឯការិយាល័យសេវាសមាជិក ដែលមានទីតាំងនៅស្ថាប័នរបស់ផែនការ
- **តាមអនឡាញ៖**
  - ប្រើទម្រង់បែបបទអនឡាញនៅលើគេហទំព័ររបស់យើងតាមរយៈ **kp.org** (ជាភាសាអង់គ្លេស)
  - សូមចូលទៅគេហទំព័រ L.A. Care Health Plan **www.lacare.org** (ជាភាសាអង់គ្លេស)

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬជាមួយ ជំនួយបានទូទាត់កំពុងរង់ចាំ យើងអាចជួយអ្នកបាន។ យើងអាចផ្តល់ឲ្យអ្នកនូវសេវាភាសាឥតគិតថ្លៃ។ ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ អ្នកក៏អាចទទួលបានជំនួយពី L.A. Care Health Plan ដោយទូរស័ព្ទទៅលេខ **1-888-839-9909** (TTY **711**)។ ពួកគេក៏អាចផ្តល់ឲ្យអ្នកនូវសេវាភាសាឥតគិតថ្លៃផងដែរ។

ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នកជាមួយ L.A. Care Health Plan ពួកគេនឹងធ្វើការជាមួយអ្នកនិង Kaiser Permanente លើបណ្តឹងឧទ្ធរណ៍របស់អ្នក។ ដើម្បីស្វែងយល់បន្ថែមអំពីដំណើរការបណ្តឹងឧទ្ធរណ៍ L.A. Care Health Plan សូមទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**)។

ក្នុងរយៈពេល 5 ថ្ងៃបន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ យើងនឹងផ្ញើលិខិតមួយជូនដំណឹងអ្នកថាយើងបានទទួលវា។ ក្នុងរយៈពេល 30 ថ្ងៃ យើងនឹងប្រាប់អ្នកពីការសម្រេចចិត្តលើបណ្តឹងឧទ្ធរណ៍របស់យើង ហើយផ្ញើលិខិតជូនដំណឹងអំពីការដោះស្រាយបណ្តឹងឧទ្ធរណ៍ (Notice of Appeal Resolution, "NAR") ដល់អ្នក។ ប្រសិនបើអ្នកបានដាក់បណ្តឹងឧទ្ធរណ៍ជាមួយ L.A. Care Health Plan ពួកគេនឹងឆ្លើយតបក្នុងកំឡុងពេលរវេលាប្រហែលគ្នានេះ។ ប្រសិនបើយើងមិនប្រាប់អ្នកអំពីការសម្រេចចិត្តបណ្តឹងឧទ្ធរណ៍របស់យើងក្នុងកំឡុងពេល 30 ថ្ងៃ អ្នកអាចស្នើសុំសវនាការរដ្ឋ និងការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យមួយ។ ប៉ុន្តែប្រសិនបើអ្នកស្នើសុំសវនាការរដ្ឋមុនហើយសវនាការបានកើតឡើងហើយ អ្នកមិនអាចស្នើសុំ IMR បានទេ។ ក្នុងករណីនេះសវនាការរដ្ឋជាអ្នកវិនិច្ឆ័យសម្រេចចុងក្រោយ។

ប្រសិនបើអ្នកចង់ ឬវេជ្ជបណ្ឌិតអ្នកចង់ឲ្យ Kaiser Permanente ឬ L.A. Care Health Plan ធ្វើការសម្រេចចិត្តរហ័ស ពីព្រោះពេលវេលាដែលវាត្រូវការដើម្បីដោះស្រាយបណ្តឹងឧទ្ធរណ៍របស់អ្នក នឹងធ្វើឲ្យជីវិត សុខភាព ឬសមត្ថភាពក្នុងការបំពេញមុខងាររបស់អ្នកមានគ្រោះថ្នាក់ អ្នកអាចស្នើសុំការត្រួតពិនិត្យបន្ទាន់ (លឿន)។ ដើម្បីស្នើសុំការត្រួតពិនិត្យបន្ទាន់ សូមទូរស័ព្ទមកពួកយើងតាមលេខ **1-800-464-4000** (TTY **711**) ឬ L.A. Care Health Plan **1-888-839-9909** (TTY **711**) ។ ពួកយើង ឬ L.A. Care Health Plan នឹងធ្វើការសម្រេចចិត្តក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់អ្នក អំពីថាតើយើងនឹងពន្លឿនបណ្តឹងឧទ្ធរណ៍របស់អ្នក ឬអត់។

អ្វីដែលត្រូវធ្វើប្រសិនបើអ្នកមិនយល់ស្របជាមួយសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍

ប្រសិនបើអ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ហើយបានលិខិតពីយើង ឬ L.A. Care Health Plan ដែលប្រាប់អ្នកថាយើងមិនបានផ្លាស់ប្តូរការសម្រេចចិត្តរបស់យើង ឬអ្នកមិនបានទទួលលិខិតប្រាប់អ្នកអំពីការសម្រេចចិត្តរបស់យើង ហើយវាមានរយៈពេលលើស 30 ថ្ងៃហើយនោះ អ្នកអាចៈ

- ស្នើសុំ ***សវនាការរដ្ឋ*** ពីនាយកដ្ឋានសេវាសង្គមរដ្ឋកាលីហ្វ័រញ៉ា (California Department of Social Services, "CDSS") ហើយចៅក្រមម្នាក់នឹងត្រួតពិនិត្យករណីរបស់អ្នក
- ដាក់ទម្រង់ត្រួតពិនិត្យវេជ្ជសាស្ត្រ/បណ្តឹងភ្ជាប់ពាក្យជាមួយក្រសួងការថែទាំសុខភាពមានការគ្រប់គ្រង (DMHC) ដើម្បីឲ្យការសម្រេចចិត្តរបស់យើងត្រូវបានត្រួតពិនិត្យ ឬស្នើសុំ **ការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យ** ("IMR") ពី DMHC។ ក្នុងកំឡុង IMR របស់ DMHC, វេជ្ជបណ្ឌិតខាងក្រៅ ដែលមិនមែនជាផ្នែកនៃ Kaiser Permanente ឬ L.A. Care Health Plan នឹងត្រួតពិនិត្យករណីរបស់អ្នក។ លេខទូរស័ព្ទឥតគិតថ្លៃលេខរបស់ DMHC គឺ (**1-888-466-2219**) និងបណ្តាញ TTY សម្រាប់សវនាការនិងអ្នកពិការខាងការនិយាយស្តី (**1-877-688-9891**)។ អ្នកអាចស្វែងរកការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យ/ទម្រង់បណ្តឹងភ្ជាប់ពាក្យ និងសេចក្តីណែនាំតាមអនឡាញនៅគេហទំព័ររបស់ DMHC៖ **www.dmhc.ca.gov** (ជាភាសាអង់គ្លេស)។

អ្នកនឹងមិនចាំបាច់ត្រូវបង់ថ្លៃសវនាការរដ្ឋឬ IMR ទេ។

អ្នកមានសិទ្ធិទាំងចំពោះទាំងសវនាការរដ្ឋ និង IMR ។ ប៉ុន្តែប្រសិនបើអ្នកស្នើសុំសវនាការរដ្ឋមុនហើយសវនាការបានកើតឡើងហើយ អ្នកមិនអាចស្នើសុំ IMR បានទេ។ ក្នុងសំណុំរឿងនេះសវនាការរដ្ឋមានសេចក្តីសម្រេចចុងក្រោយ។ អត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx គឺមិនស្ថិតនៅក្រោមដំណើរការ IMR ទេ។

ផ្នែកខាងក្រោមនឹងផ្តល់ឲ្យអ្នកនូវព័ត៌មានបន្ថែម អំពីរបៀបស្នើសុំសវនាការរដ្ឋ ឬ IMR ។

បណ្តឹងភ្ជាប់ពាក្យ និងបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងអត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx គឺមិនត្រូវបានចាត់ចែងដោយ Kaiser Permanente ទេ។ អ្នកអាចដាក់បណ្តឹងភ្ជាប់ពាក្យ

និងបណ្តឹងឧទ្ធរណ៍អំពីអត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx ដោយទូរស័ព្ទទៅលេខ **800-977-2273** (TTY **800-977-2273** ហើយចុចលេខ 5 ឬ **711**)។ ប៉ុន្តែបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងអត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យមួយ។ ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងការសម្រេចចិត្តទាក់ទងនឹងអត្ថប្រយោជន៍ឱសថស្ថាន Medi-Cal Rx របស់អ្នកទេ អ្នកអាចស្នើសុំសវនាការរដ្ឋ។

កំណត់ចំណាំ៖ មុខទំនិញនិងសេវាអ្នកទទួលនៅក្រោមកម្មវិធី Community Supports មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ IMR ទេ។

ពាក្យបណ្តឹងភ្លុញភ្លែរនិងការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យ ("IMR") ជាមួយនាយកដ្ឋានថែទាំសុខភាពមានការគ្រប់គ្រង

IMR គឺនៅពេលដែលអ្នកត្រួតពិនិត្យខាងក្រៅដែលមិនទាក់ទងទៅនឹងផែនការសុខភាពត្រួតពិនិត្យករណីរបស់អ្នក។ ប្រសិនបើអ្នកចង់បាន IMR ដំបូងអ្នកត្រូវតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយ ពួកយើង ឬ L.A. Care Health Plan ជាមុន។ ប្រសិនបើអ្នកមិនឮពីយើងក្នុងរយៈពេល 30 ថ្ងៃប្រតិទិន ឬប្រសិនបើអ្នកមិនសប្បាយចិត្តនឹង សេចក្តីសម្រេចចិត្តរបស់យើងនោះ អ្នកអាចស្នើសុំ IMR។ អ្នកត្រូវស្នើសុំ IMR ក្នុងរយៈពេល 6 ខែចាប់ពីកាលបរិច្ឆេទលើសេចក្តីជូនដំណឹងដែលប្រាប់អ្នក អំពីសេចក្តីសម្រេចរបស់បណ្តឹងឧទ្ធរណ៍។ អ្នកមានតែ 120 ថ្ងៃប៉ុណ្ណោះដើម្បីស្នើសុំសវនាការរដ្ឋ ដូច្នេះប្រសិនបើអ្នកចង់បាន IMR និងសវនាការរដ្ឋ សូមដាក់បណ្តឹងតវ៉ារបស់អ្នក កាន់តែឆាប់កាន់តែល្អ។ សូមចាំថា ប្រសិនបើអ្នកស្នើសុំសវនាការរដ្ឋមុន ហើយសវនាការបានកើតឡើងហើយ អ្នកមិនអាចស្នើសុំ IMR បានទេ។ ក្នុងករណីនេះសវនាការរដ្ឋជាអ្នកវិនិច្ឆ័យសម្រេចចុងក្រោយ។

អ្នកប្រហែលជាអាចទទួលបាន IMR ភ្លាមៗ ដោយមិនចាំបាច់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមុន។ នេះគឺនៅក្នុងករណីដែលបញ្ហាសុខភាពរបស់អ្នកគឺបន្ទាន់ ឬការស្នើសុំត្រូវបានបដិសេធ ដោយសារការព្យាបាលត្រូវបានចាត់ទុកថាជាការពិសោធន៍ ឬការអង្កេត។

ប្រសិនបើបណ្តឹងភ្លុញភ្លែររបស់អ្នកចំពោះ DMHC មិនមានលក្ខណៈសម្បត្តិទទួលបាន IMR, DMHC នឹងនៅតែត្រួតពិនិត្យពាក្យបណ្តឹងរបស់អ្នក ដើម្បីបញ្ជាក់ថាយើងបានធ្វើការសម្រេចចិត្តត្រូវ នៅពេលអ្នកដាក់បណ្តឹងឧទ្ធរណ៍ចំពោះការបដិសេធនៃសេវា។ យើងត្រូវតែអនុលោមតាមការសម្រេចចិត្ត IMR និងការត្រួតពិនិត្យរបស់ DMHC ។

កថាខណ្ឌខាងក្រោមនឹងផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីរបៀបស្នើរសុំ IMR។ សូមកត់ចំណាំថាពាក្យ "សារទុក្ខ" គឺនិយាយអំពីទាំង "បណ្តឹងភ្លុញភ្លែរ" និង "បណ្តឹងឧទ្ធរណ៍"។

នាយកដ្ឋានការថែទាំសុខភាពមានការគ្រប់គ្រងរដ្ឋកាលីហ្វ័រញ៉ាទទួលខុសត្រូវចំពោះការដាក់កម្រិត លើផែនការសេវាថែទាំសុខភាព។ ប្រសិនបើអ្នកមានសារទុក្ខប្រឆាំងនឹងផែនការសុខភា

ពរបស់អ្នក ដំបូងអ្នកគួរតែទូរស័ព្ទទៅផែនការសុខភាពតាមលេខ **1-800-464-4000** (TTY **711**) ហើយប្រើដំណើរការបណ្តឹងសារទុក្ខរបស់ផែនការសុខភាពអ្នក មុននឹងទំនាក់ទំនងទៅនាយកដ្ឋាន។ ការប្រើប្រាស់នីតិវិធីសារទុក្ខនេះមិនហាមឃាត់សិទ្ធិ ឬដំណោះស្រាយស្របច្បាប់ដែលមានសក្តានុពល ណាមួយដែលអាចមានសម្រាប់អ្នកទេ។ ប្រសិនបើអ្នកត្រូវការជំនួយជាមួយនឹងសារទុក្ខដែលពាក់ព័ន្ធនឹងការសង្គ្រោះបន្ទាន់ សារទុក្ខដែលមិនត្រូវបាន ដោះស្រាយឲ្យបានពេញចិត្តដោយផែនការសុខភាពរបស់អ្នក ឬសារទុក្ខដែលនៅតែមិនទាន់ដោះស្រាយ បានអស់រយៈពេលលើសពី 30 ថ្ងៃ អ្នកអាចទូរស័ព្ទទៅនាយកដ្ឋានដើម្បីរកជំនួយ។ អ្នកក៏អាចមានសិទ្ធិទទួលបានការត្រួតពិនិត្យវេជ្ជសាស្ត្រឯករាជ្យ ("IMR") ផងដែរ។ ប្រសិនបើអ្នកមានសិទ្ធិទទួលបាន IMR ដំណើរការ IMR នឹងផ្តល់ការត្រួតពិនិត្យឡើងវិញដែលមិនលំអៀង លើការសម្រេចចិត្តវេជ្ជសាស្ត្រដែលបានធ្វើឡើងដោយផែនការសុខភាពដែលទាក់ទងនឹង ភាពចាំបាច់វេជ្ជសាស្ត្រនៃសេវា ឬការព្យាបាលដែលបានស្នើ សេចក្តីសំរេចលើការធានារ៉ាប់រង សម្រាប់ការព្យាបាលដែលមានលក្ខណៈពិសោធន៍ ឬអង្កេត និងវិវាទនៃការទូទាត់ប្រាក់ សម្រាប់សេវាវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ឬបន្ទាន់។ នាយកដ្ឋានក៏មានលេខទូរស័ព្ទឥតគិតថ្លៃលេខ (**1-888-466-2219**) និងបណ្តាញ TDD (**1-877-688-9891**) សំរាប់អ្នកមានបញ្ហាការស្តាប់និងនិយាយ។ គេហទំព័ររបស់នាយកដ្ឋាន **http://www.dmhc.ca.gov** (ជាភាសាអង់គ្លេស) មានទម្រង់បែបបទពាក្យបណ្តឹងតួញតែរ ទម្រង់បែបបទពាក្យសុំ IMR និងសេចក្តីណែនាំអនឡាញ។

សវនាការរដ្ឋ

សវនាការរដ្ឋគឺជាការជួបជាមួយនឹងមន្ត្រីមកពីនាយកដ្ឋានសេវាសង្គមរដ្ឋកាលីហ្វ័រញ៉ា ("CDSS")។ ចៅក្រមនឹងជួយដោះស្រាយបញ្ហារបស់អ្នក។ អ្នកមានសិទ្ធិស្នើសុំសវនាការរដ្ឋបានលុះត្រាតែអ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍រួចហើយ ជាមួយទាំង Kaiser Permanente ឬ L.A. Care Health Plan ហើយអ្នកនៅតែមិនពេញចិត្ត នឹងការសម្រេចចិត្តនេះ ឬប្រសិនបើអ្នកមិនបានទទួលសេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ របស់អ្នកបន្ទាប់ពី 30 ថ្ងៃ។

អ្នកត្រូវតែស្នើសុំសវនាការរដ្ឋក្នុងរយៈពេល 120 ថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទលើសេចក្តីជូនដំណឹងដែលប្រាប់អ្នកអំពីការសម្រេចចិត្តឧទ្ធរណ៍។ PCP របស់អ្នកអាចស្នើសុំសវនាការរដ្ឋសម្រាប់អ្នក ដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើយើងផ្តល់ឲ្យអ្នកនូវជំនួយបានទូទាត់ដែលកំពុងរង់ចាំក្នុងអំឡុងពេលបណ្តឹងឧទ្ធរណ៍របស់អ្នក ហើយអ្នកចង់ឲ្យវាបន្តរហូតដល់មានការសម្រេចចិត្តលើសវនាការរដ្ឋរបស់អ្នក អ្នកត្រូវតែស្នើសុំសវនាការរដ្ឋក្នុងរយៈពេល 10 ថ្ងៃក្រោយបានទទួលលិខិតជូនដំណឹងអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់យើង ("NAR") ឬមុនកាលបរិច្ឆេទដែលយើងបាននិយាយថាសេវារបស់អ្នកនឹងឈប់មួយណាដែលដល់ក្រោយគេ។ ប្រសិនបើអ្នកត្រូវការជំនួយធ្វើឲ្យប្រាកដថា ប្រាក់ជំនួយបានបង់ន នឹងបន្តរហូតដល់មានការសម្រេចចិត្តចុងក្រោយលើសវនាការរដ្ឋរបស់អ្នក សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងនៅ **1-800-464-4000** (TTY **711**)។ PCP របស់អ្នកអាចស្នើសុំសវនាការរដ្ឋសម្រាប់អ្នក ដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក។

ជួនកាលអ្នកអាចស្នើសុំសវនាការរដ្ឋ ដោយមិនបំពេញដំណើរការបណ្តឹងឧទ្ធរណ៍របស់យើង។ ឧទាហរណ៍ អ្នកអាចស្នើសុំសវនាការរដ្ឋដោយមិនចាំបាច់បំពេញដំណើរការបណ្តឹងឧទ្ធរណ៍របស់យើង

ប្រសិនបើយើងមិនបានជូនដំណឹងដល់អ្នកឲ្យបានត្រឹមត្រូវ ឬទាន់ពេលវេលាអំពីសេវារបស់អ្នក។ នេះត្រូវបានគេហៅថា អស់ពីលទ្ធភាពដែលបានពិចារណា។ ទាំងនេះគឺជាឧទាហរណ៍មួយចំនួននៃការអស់ពីលទ្ធភាពដែលបានពិចារណា៖

- យើងមិនបានធ្វើលិខិតជូនដំណឹងអំពីសកម្មភាព ("NOA") ឲ្យមានសម្រាប់អ្នកជាភាសាដែលអ្នកចង់បាន។
- យើងបានធ្វើឲ្យមានកំហុសដែលប៉ះពាល់ដល់សិទ្ធិណាមួយរបស់អ្នក។
- យើងមិនបានផ្តល់លិខិត NOA ដល់អ្នក។
- យើងបានមានកំហុសនៅក្នុងលិខិត NAR របស់យើង។
- យើងមិនបានធ្វើសេចក្តីសម្រេចចំពោះបណ្តឹងឧទ្ធរណ៍របស់អ្នកក្នុងអំឡុងពេល 30 ថ្ងៃ។
- យើងបានសម្រេចចិត្តថាករណីរបស់អ្នកចាំបាច់បន្ទាន់ ប៉ុន្តែមិនបានឆ្លើយតបចំពោះបណ្តឹងឧទ្ធរណ៍របស់អ្នកក្នុងអំឡុងពេល 72 ម៉ោង។

អ្នកអាចស្នើសុំសវនាការរដ្ឋតាមរយៈទូរស័ព្ទ ឬផ្ញើសំបុត្រ។

- **តាមទូរស័ព្ទ៖** សូមទូរស័ព្ទទៅផ្នែកឆ្លើយតបសាធារណៈ CDSS លេខ **1-800-952-5253** (TTY **1-800-952-8349**)។
- **តាមប្រៃសណីយ៍៖** បំពេញសំណុំបែបបទដែលបានផ្តល់ជូនជាមួយនឹងសេចក្តីជូនដំណឹងអំពីដំណោះស្រាយបណ្តឹងឧទ្ធរណ៍របស់អ្នក។ ផ្ញើរវាទៅអាសយដ្ឋានខាងក្រោម៖

  California Department of Social Services
  State Hearings Division
  P.O. Box 944243, MS 09-17-37
  Sacramento, CA 94244-2430

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្នើសុំសវនាការរដ្ឋ យើងអាចជួយអ្នកបាន។ យើងអាចផ្តល់ឲ្យអ្នកនូវសេវាភាសាឥតគិតថ្លៃ។ ទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY 711)។

នៅក្នុងសវនាការ អ្នកនឹងផ្តល់ភាគីរបស់អ្នក។ យើងនឹងផ្តល់ភាគីរបស់យើង។ វាអាចចំណាយពេលរហូតដល់ 90 ថ្ងៃដើម្បីឲ្យចៅក្រមចេញសេចក្តីសម្រេចលើសំណុំរឿងរបស់អ្នក។ យើងត្រូវតែធ្វើតាមអ្វីដែលចៅក្រមសម្រេច។

ប្រសិនបើអ្នកចង់ឲ្យ CDSS ធ្វើការសម្រេចចិត្តឆាប់រហ័ស ពីព្រោះពេលវេលាដែលត្រូវការក្នុងការមាន សវនាការរដ្ឋនឹងធ្វើឲ្យជីវិត សុខភាព ឬសមត្ថភាពរបស់អ្នកក្នុងការបំពេញមុខងារបានពេញលេញ មានគ្រោះថ្នាក់, អ្នក ឬ PCP របស់អ្នកអាចទំនាក់ទំនង CDSS និងស្នើសុំសវនាការរដ្ឋបន្ទាន់ (លឿន)។ CDSS ត្រូវធ្វើសេចក្តីសម្រេចមិនអោយលើសពី 3 ថ្ងៃធ្វើការក្រោយពីទទួលបានឯកសារសំណុំរឿង ពេញលេញរបស់អ្នកពី Kaiser Permanente និង L.A. Care Health Plan។

ការក្លែងបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពាន

ប្រសិនបើអ្នកសង្ស័យថាអ្នកផ្តល់សេវា ឬអ្នកដែលទទួល Medi-Cal បានប្រព្រឹត្តការក្លែងបន្លំ ខ្ជះខ្ជាយ ឬការរំលោភបំពាន វាជាសិទ្ធិរបស់អ្នកក្នុងការរាយការណ៍វា ដោយទូរស័ព្ទទៅលេខឥតគិតថ្លៃ **1-800-822-6222** ឬដាក់ពាក្យបណ្តឹងតាមអ៊ីនធឺណិតនៅ **https://www.dhcs.ca.gov** (ជាភាសាអង់គ្លេស)។
ការលួចបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពានពីអ្នកផ្តល់សេវារួមមាន៖

- ការក្លែងបន្លំឯកសារវេជ្ជសាស្ត្រ
- ការចេញវេជ្ជបញ្ជាច្រើនជាងអ្វីដែលចាំបាច់ខាងវេជ្ជសាស្ត្រ
- ការផ្តល់សេវាថែទាំសុខភាពច្រើនជាងអ្វីដែលចាំបាច់ខាងវេជ្ជសាស្ត្រ
- ការចេញវិក័យប័ត្រសម្រាប់សេវាដែលមិនត្រូវបានផ្តល់
- ការចេញវិក័យប័ត្រសម្រាប់សេវាវិជ្ជាជីវៈនៅពេលដែលអ្នកជំនាញវិជ្ជាជីវៈនោះមិនបានអនុវត្តសេវា
- ផ្តល់ជូននូវទំនិញនិងសេវាដោយឥតគិតថ្លៃ ឬបញ្ចុះតម្លៃដល់សមាជិកជាការប៉ុនប៉ងជះឥទ្ធិពល ថាអ្នកផ្តល់សេវាណាមួយដែលគួរត្រូវបានជ្រើសរើសដោយសមាជិក
- ការផ្លាស់ប្តូរវេជ្ជបញ្ជិតថែទាំចម្បងរបស់សមាជិកដោយគ្មានការដឹងឮរបស់សមាជិក

ការបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពានដោយអ្នកដែលទទួលអត្ថប្រយោជន៍រួមមាន ប៉ុន្តែមិនកំណត់តែចំពោះ៖

- ការផ្តល់ប្រាក់កម្ចី ការលក់ ឬការផ្តល់អត្តសញ្ញាណប័ណ្ណផែនការសុខភាព ឬប័ណ្ណសម្គាល់អត្ថប្រយោជន៍ (Benefits Identification Card, BIC) Medi-Cal ទៅនរណាម្នាក់ផ្សេងទៀត
- ការទទួលការព្យាបាលស្រដៀងគ្នាឬដូចគ្នា ឬឱសថពីអ្នកផ្តល់សេវាលើសពីមួយ
- ការទៅបន្ទប់សង្គ្រោះបន្ទាន់នៅពេលវាមិនមែនជាករណីអាសន្ន
- ការប្រើលេខសន្តិសុខសង្គម ឬលេខអត្តសញ្ញាណផែនការសុខភាពរបស់អ្នកដទៃ
- ការជិះមធ្យោបាយធ្វើដំណើរវេជ្ជសាស្ត្រ និងការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រសម្រាប់សេវាដែលមិនទាក់ទងនឹងការថែទាំសុខភាព ឬសម្រាប់សេវាដែលមិនត្រូវបានរ៉ាប់រងដោយ Medi-Cal ឬនៅពេលដែលអ្នកមិនមានការណាត់ជួបពេទ្យ ឬវេជ្ជបញ្ជាដើម្បីទៅយក។

ដើម្បីរាយការណ៍ការក្លែងបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពាន ចូរសរសេរឈ្មោះអាសយដ្ឋាន និងលេខអត្តសញ្ញាណរបស់បុគ្គលដែលបានប្រព្រឹត្តការលួចបន្លំ ការខ្ជះខ្ជាយ ឬការរំលោភបំពាននោះ។ ផ្តល់ព័ត៌មានច្រើនតាមដែលអ្នកអាចធ្វើបានអំពីជននោះដូចជាលេខទូរស័ព្ទ ឬជំនាញឯកទេស ប្រសិនបើជាអ្នកផ្តល់សេវា។ ផ្តល់កាលបរិច្ឆេទនៃព្រឹត្តិការណ៍និងសេចក្តីសង្ខេបអំពីអ្វីដែលបានកើតឡើង។

ប្រសិនបើអ្នកកត់សម្គាល់ឃើញសញ្ញានៃការប្រព្រឹត្តពុំត្រឹមត្រូវដែលមានសក្តានុពល សូមទំនាក់ទំនងមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក លេខ **1-800-464-4000** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (បិទថ្ងៃបុណ្យជាតិ) ។

មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់

មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ គឺជាវិធីមួយដើម្បីដោះស្រាយបញ្ហាដោយការប្រើភាគីអព្យាក្រឹតទីបី។ ភាគីទីបីនេះស្តាប់ភាគីទាំងសងខាងនៃបញ្ហា ហើយធ្វើសេចក្តីសម្រេចចិត្តដែលភាគីទាំងពីរត្រូវតែទទួលយក។ ភាគីទាំងពីរបោះបង់សិទ្ធិឲ្យទៅក្រុមប្រឹក្សាតុលាការ ឬការកាត់ក្តីតុលាការ។ យើងនឹងប្រើប្រាស់មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ដើម្បីដោះស្រាយការទាមទារសំណងដែលយើងបានដាក់ មុនកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃសៀវភៅណែនាំសមាជិកនេះ។ ការប្រើមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់សម្រាប់ពាក្យបណ្តឹងកន្លងមកទាំងនេះ គឺចងភ្ជាប់កាតព្វកិច្ច តែមកលើយើងប៉ុណ្ណោះ។

វិសាលភាពនៃមជ្ឈត្តវិនិច្ឆ័យ

អ្នកត្រូវតែប្រើប្រាស់មជ្ឈត្តវិនិច្ឆ័យ ប្រសិនបើការទាមទារសំណងមានការពាក់ព័ន្ធនឹង សៀវភៅណែនាំសមាជិកនេះ ឬសមាជិកភាពរបស់អ្នកជាមួយយើង ប្រសិនបើសេចក្តីតម្រូវខាងក្រោមទាំងអស់ត្រូវបានបំពេញ៖

- បណ្តឹងទាមទារនេះសម្រាប់៖
  - ការអនុវត្តខុស (ការតវ៉ាទាមទារថាសេវាឬទំនិញវេជ្ជសាស្ត្រ មិនមានភាពចាំបាច់ ឬមិនត្រូវបានអនុញ្ញាត ឬត្រូវបានផ្តល់ជូនដោយមិនត្រឹមត្រូវ ធ្វេសប្រហែស ឬមិនមានសមត្ថភាព) ឬ
  - ការផ្តល់ជូននៃសេវា ឬទំនិញ ឬ
  - ការទទួលខុសត្រូវលើទីតាំង
- បណ្តឹងទាមទារត្រូវបានធ្វើឡើងដោយ៖
  - អ្នកប្រឆាំងនឹងយើង; ឬ
  - យើងប្រឆាំងនឹងអ្នក
- ច្បាប់គ្រប់គ្រងមិនទប់ស្កាត់ការប្រើមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ដើម្បីដោះស្រាយបណ្តឹងទាមទារទេ
- បណ្តឹងទាមទារមិនអាចត្រូវបានដោះស្រាយតាមរយៈតុលាការបណ្តឹងទាមទារតូចទេ

សូមចាំថា៖

- អ្នកមិនចាំបាច់ប្រើមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់សម្រាប់ពាក្យបណ្តឹងដែលអាចត្រូវបានដោះស្រាយ តាមរយៈសវនាការរដ្ឋនោះទេ
- អ្នកមិនអាចប្រើមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់បានទេ ប្រសិនបើអ្នកបានទទួលសេចក្តីសំរេច លើបណ្តឹងទាមទារតាមរយៈសវនាការរដ្ឋ

នៅក្នុងផ្នែក "មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់" នេះតែប៉ុណ្ណោះ "អ្នក" មានន័យថាភាគីដែលស្នើសុំមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់៖

- អ្នក (សមាជិក)
- អ្នកស្នងមរតករបស់អ្នក សាច់ញាតិ ឬនរណាម្នាក់ដែលអ្នកដាក់ឈ្មោះធ្វើជាតំណាងសម្រាប់អ្នក
- នរណាម្នាក់ដែលអះអាងថាតួនាទីសម្រាប់ពួកគេមានដោយសារតែទំនាក់ទំនងរបស់អ្នកជាមួយយើង

នៅក្នុងផ្នែក "មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់" នេះតែប៉ុណ្ណោះ "យើង" មានន័យថា ភាគីដែលមានបណ្តឹងទាមទារ ដែលត្រូវបានដាក់ប្រឆាំងនឹងពួកគេ៖

- Kaiser Foundation Health Plan, Inc ("KFHP")
- Kaiser Foundation Hospitals ("KFH")
- Southern California Permanente Medical Group ("SCPMG")
- Permanente Medical Group, Inc. ("TPMG")
- Permanente Federation, LLC
- Permanente Company, LLC
- វេជ្ជបណ្ឌិតនៃ SCPMG ឬ TPMG ណាមួយ
- បុគ្គល ឬអង្គការដែលមានកិច្ចសន្យាជាមួយភាគីណាមួយក្នុងចំណោមទាំងនេះ ដែលតម្រូវឲ្យមានការប្រើប្រាស់មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់
- និយោជិក ឬភ្នាក់ងារនៃភាគីមួយក្នុងចំណោមទាំងនេះ

វិធាននៃនីតិវិធី

មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ ត្រូវបានប្រតិបត្តិដោយការប្រើប្រាស់វិធាននៃនីតិវិធី៖

- វិធាននៃនីតិវិធី ត្រូវបានបង្កើតឡើងដោយការិយាល័យរដ្ឋបាលឯករាជ្យដោយមានការចូលរួមមតិយោបល់ពី Kaiser Permanente និងពីគណៈកម្មាធិការប្រឹក្សាមជ្ឈត្តវិនិច្ឆ័យ
- អ្នកអាចទទួលបានសំណៅចម្លងនៃនីតិវិធីពីមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង លេខ **1-800-464-4000** (TTY **711**)

របៀបស្នើសុំមជ្ឈត្តវិនិច្ឆ័យ

ដើម្បីស្នើសុំមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ អ្នកត្រូវតែធ្វើសំណើផ្លូវការមួយ (តម្រូវការមជ្ឈត្តវិនិច្ឆ័យ) ដែលរួមមាន៖

- ការពិពណ៌នារបស់អ្នកលើបណ្តឹងទាមទារប្រឆាំងនឹងយើង
- ទំហំនៃការខូចខាតដែលអ្នកកំពុងស្នើសុំ

- ឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទរបស់ភាគីទាំងអស់ដែលកំពុងធ្វើការទាមទារសំណង។ ប្រសិនបើភាគីណាមួយក្នុងចំណោមភាគីទាំងនេះមានមេធាវី សូមរួមបញ្ចូលឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់មេធាវី
- ឈ្មោះភាគីដែលអ្នកកំពុងដាក់ពាក្យបណ្តឹងទាមទារប្រឆាំង

បណ្តឹងទាមទារទាំងអស់ដែលជាលទ្ធផលចេញពីឧបត្តិហេតុដូចគ្នា គួរតែត្រូវបានដាក់បញ្ចូលក្នុងសំណើតែមួយ។

ការបំពេញតាមការទាមទារសម្រាប់មជ្ឈត្តវិនិច្ឆ័យ

ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងទាមទារប្រឆាំងនឹង KFHP, KFH, SCPMG, TPMG, The Permanente Federation, LLC ឬ The Permanente Company, LLC, សូមផ្ញើតម្រូវការមជ្ឈត្តវិនិច្ឆ័យទៅកាន់៖

Kaiser Permanente
Legal Department
1950 Franklin St., 17th Floor
Oakland, CA 94612

ប្រសិនបើអ្នកកំពុងដាក់បណ្តឹងទាមទារប្រឆាំងនឹងភាគីណាផ្សេងទៀត អ្នកត្រូវតែផ្តល់ជូនពួកគេ នូវសេចក្តីជូនដំណឹងដូចដែលបានតម្រូវដោយក្រមនីតិវិធីបណ្តឹងរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រញ៉ា សម្រាប់វិធានការរដ្ឋប្បវេណី។

យើងត្រូវបានបំពេញករណីយកិច្ច នៅពេលយើងទទួលបានការទាមទារមជ្ឈត្តវិនិច្ឆ័យ៖

ថ្លៃឈ្នួលសម្រាប់ការរៀបចំពាក្យបណ្តឹង

ការចំណាយលើមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ រួមមានថ្លៃឈ្នួលដាក់ពាក្យប្តឹង $150 ដែលនឹងត្រូវលើកលែង ប្រសិនបើ អ្នកមិនអាចបង់ចំណែកនៃថ្លៃចំណាយរបស់អ្នកបាន។

ថ្លៃសេវាដាក់ពាក្យសុំត្រូវបង់ទៅ "គណនីមជ្ឈត្តវិនិច្ឆ័យ" និងជាចំនួនទឹកប្រាក់ដដែល មិនថាមានពាក្យបណ្តឹងប៉ុន្មាន នៅក្នុងសំណើរបស់អ្នក ឬចំនួនភាគីប៉ុន្មានដែលមានឈ្មោះនោះទេ។ ថ្លៃសេវាដាក់ពាក្យសុំនឹងមិនអាចដកវិញទេ។

ប្រសិនបើអ្នកមិនអាចបង់ចំណែករបស់អ្នកនៃថ្លៃចំណាយលើមជ្ឈត្តវិនិច្ឆ័យ អ្នកអាចស្នើការិយាល័យរដ្ឋបាលឯករាជ្យឲ្យលើកលែងថ្លៃចំណាយនោះ។ ដើម្បីធ្វើដូចនេះ អ្នកត្រូវតែបំពេញ និងផ្ញើទម្រង់បែបបទលើកលែងថ្លៃឈ្នួលទៅ៖

- ការិយាល័យរដ្ឋបាលឯករាជ្យ ហើយនិង
- ភាគីដែលអ្នកកំពុងដាក់ពាក្យបណ្តឹងទាមទារប្រឆាំង

ទម្រង់បែបបទការលើកលែងថ្លៃឈ្នួល៖

- ប្រាប់អ្នកអំពីរបៀបដែលរដ្ឋបាលឯការាជ្យសម្រេចចិត្តថាតើត្រូវលើកលែងថ្លៃឈ្នួលឬទេ។
- ប្រាប់អ្នកថាថ្លៃឈ្នួលនោះអាចត្រូវបានលើកលែង

អ្នកអាចទទួលបានមួយច្បាប់នៃទម្រង់បែបបទលើកលែងថ្លៃឈ្នួល ពីមជ្ឈមណ្ឌលទំនាក់ទំនងសេវា សមាជិករបស់យើងលេខ **1-800-464-4000** (TTY **711**)។

ចំនួននៃមជ្ឈត្តវិនិច្ឆ័យ

ករណីខ្លះត្រូវបានសម្រេចសវនាការដោយមជ្ឈត្តការម្នាក់ដែលភាគីទាំងពីរយល់ព្រម (មជ្ឈត្តការអព្យាក្រឹត)។ ក្នុងករណីផ្សេងទៀត អាចមានមជ្ឈត្តការច្រើនជាងម្នាក់។ ចំនួននៃមជ្ឈត្តការអាចជះឥទ្ធិពលថាតើយើងចេញថ្លៃចំណាយលើមជ្ឈត្តការអព្យាក្រឹតឬទេ។។

ករណីដែលស្នើសុំសំណងរហូតដល់ចំនួន $200,000 នៅក្នុងការខូចខាតនឹងត្រូវបានកាត់ក្តីចំពោះមុខមជ្ឈត្តការម្នាក់។ មជ្ឈត្តការត្រូវតែក្សាភាពអព្យាក្រឹត។ ភាគីទាំងសងខាងអាចយល់ស្របក្នុងការឲ្យមានមជ្ឈត្តការចំនួន 3 រូបដើម្បីសំរេចរឿងក្តី។ កិច្ចព្រមព្រៀងឲ្យមានមជ្ឈត្តការច្រើនជាងម្នាក់ ត្រូវតែធ្វើឡើងបន្ទាប់ពីពាក្យសុំការទាមទារមជ្ឈត្តការ ត្រូវបានដាក់។ នៅពេលមានមជ្ឈត្តការចំនួនបីនាក់ ម្នាក់តំណាងឲ្យភាគីនិមួយៗ ហើយអ្នកទីបីគឺអព្យាក្រឹត។ មជ្ឈត្តការមិនអាចផ្តល់សំណងលើសពី $200,000 ទេ។

ករណីដែលស្នើសុំច្រើនជាងចំនួន $200,000 នៅក្នុងការខូចខាតនឹងត្រូវកាត់ក្តីនៅចំពោះមុខមជ្ឈត្តការបីរូប។ នៅពេលដែលមានមជ្ឈត្តការបីរូប មានម្នាក់តំណាងឲ្យភាគីនីមួយៗនៅក្នុងជម្លោះ និងមជ្ឈត្តការអព្យាក្រឹតទីបី។ ទាំងសងខាងអាចលះបង់សិទ្ធិរបស់ពួកគេ ដើម្បីឲ្យមានមជ្ឈត្តការតំណាងឲ្យពួកគេ។ ភាគីទាំងសងខាងក្នុងជម្លោះអាចយល់ស្របនឹងគ្នា ឲ្យមានសវនាការលើរឿងក្តីនេះដោយ មជ្ឈត្តការអព្យាក្រឹតតែម្នាក់។ កិច្ចព្រមព្រៀងសម្រាប់អាជ្ញាកណ្តាលអព្យាក្រឹតតែម្នាក់ ត្រូវតែធ្វើឡើងបន្ទាប់ពីពាក្យសុំ ការទាមទារមជ្ឈត្តការត្រូវបានដាក់។

ថ្លៃឈ្នួលនិងការចំណាយរបស់មជ្ឈត្តការ

យើងនឹងបង់ថ្លៃឈ្នួលមជ្ឈត្តការអព្យាក្រឹតនៅក្នុងករណីខ្លះ។ ដើម្បីដឹងថាតើពេលណាយើងនឹងបង់ថ្លៃឈ្នួល សូមមើលនៅក្នុងវិធានននីតិវិធី។ អ្នកអាចទទួលបានសំណៅចម្លងនៃវិធាននីតិវិធីពីមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើង លេខ **1-800-464-4000** (TTY **711**)។ នៅក្នុងគ្រប់ករណីផ្សេងទៀត ការចំណាយនេះត្រូវបានចែករំលែកស្មើភាពគ្នាដោយភាគីទាំងពីរ។ ប្រសិនបើភាគីជ្រើសរើសអាជ្ញាកណ្តាលសម្រាប់ភាគី ភាគីនីមួយៗបង់ថ្លៃឈ្នួលសម្រាប់អាជ្ញាកណ្តាលភាគីរបស់ពួកគេ។

ថ្លៃចំណាយ

លើកលែងដូចបានកំណត់ពីខាងលើ និងដូចត្រូវបានអនុញ្ញាតដោយច្បាប់ ភាគីនីមួយៗត្រូវបង់ថ្លៃចំណាយផ្ទាល់ខ្លួនពួកគេលើមជ្ឈត្តវិនិច្ឆ័យចងក្រាប់ ទោះជាលទ្ធផលយ៉ាងណាក៏ដោយ ដូចជាថ្លៃឈ្នួលមេធាវី ថ្លៃឈ្នួលសាក្សី និងការចំណាយផ្សេងៗទៀត។

ការផ្តល់ជូនទូទៅ

អ្នកមិនអាចស្នើសុំមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់បានទេ ប្រសិនបើបណ្តឹងទាមទារមិនបំពេញតាមលក្ខន្តិក:កំណត់សម្រាប់ការទាមទារនោះនៅក្នុងបណ្តឹងរដ្ឋប្បវេណី។

បណ្តឹងទាមទាររបស់អ្នកនឹងត្រូវច្រានចោលប្រសិនបើណាមួយដូចខាងក្រោមបានកើតឡើង៖

- អ្នកមិនបានធ្វើវាដោយការព្យាយាមសមហេតុសមផលស្របទៅតាមវិធាននៃនីតិវិធី
- សវនាការមិនទាន់បានកើតឡើងហើយច្រើនជាង 5 ឆ្នាំបានកន្លងផុតទៅបន្ទាប់ពី៖
  - កាលបរិច្ឆេទដែលអ្នកបានបំពេញការទាមទារមជ្ឈត្តករ ឬ
  - កាលបរិច្ឆេទដែលអ្នកបានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីផ្អែកលើហេតុការណ៍ដូចគ្នា

បណ្តឹងទាមទារប្រហែលជាត្រូវបានច្រានចោលក្នុងមូលហេតុផ្សេងដោយមជ្ឈត្តកររអព្យាក្រឹត។ ហេតុផលដែលល្អត្រូវតែបានបង្ហាញដើម្បីមានករណីនេះកើតឡើង។

ប្រសិនបើម្ខាងនៃភាគីទាំងនេះមិនបានចូលរួមក្នុងសវនាការ មជ្ឈត្តកររអព្យាក្រឹតប្រហែលជាធ្វើសេចក្តីសម្រេចលើសំណុំរឿងដោយអវត្តមានរបស់ភាគីនោះ។

វិធានការណ៍កំណែទម្រង់សំណងជម្ងឺចិត្តការរបួសវេជ្ជសាស្ត្រនៃរដ្ឋកាលីហ្វ័រញ៉ា (California Medical Injury Compensation Reform Act) (និងវិសោធនកម្មនានា) អនុវត្តទៅលើបណ្តឹងទាមទារដែលអនុញ្ញាតដោយច្បាប់ ដូចជា៖

- សិទ្ធិក្នុងការណែនាំភស្តុតាងនៃការបង់ថ្លៃអត្ថប្រយោជន៍ជានាវ៉ាប់រង ឬពិការភាពទៅអ្នក
- ការកំណត់លើចំនួនទឹកប្រាក់ដែលអ្នកអាចស្រោចស្រង់មកវិញសម្រាប់ការបាត់បង់មិនមែនសេដ្ឋកិច្ច
- សិទ្ធិក្នុងការទទួលបានរង្វាន់សម្រាប់ការខូចខាតនៅពេលអនាគតដែលធ្វើឡើងជាការបង់ប្រាក់ជូនយូរៗម្តង

មជ្ឈត្តវិនិច្ឆ័យត្រូវបានគ្រប់គ្រងដោយផ្នែក "មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់" នេះ។ បទដ្ឋានទាំងនេះក៏អនុវត្តបានដែរដរាបណាវាមិនមានជម្លោះជាមួយផ្នែកនេះ៖

- ផ្នែកទី 2 នៃវិធានការណ៍មជ្ឈត្តវិនិច្ឆ័យសហព័ន្ធ
- ក្រមនៃនីតិវិធីរដ្ឋប្បវេណីរដ្ឋកាលីហ្វញ៉ា
- វិធាននៃនីតិវិធី

7. សិទ្ធិ និងទំនួលខុសត្រូវ

ក្នុងនាមជាសមាជិករបស់ Kaiser Permanente អ្នកមានសិទ្ធិនិងទំនួលខុសត្រូវ។ ជំពូកនេះពន្យល់អំពីសិទ្ធិនិងទំនួលខុសត្រូវទាំងនេះ។ ជំពូកនេះក៏រួមបញ្ចូលការជូនដំណឹងផ្លូវច្បាប់ថាអ្នកមានសិទ្ធិក្នុងនាមជាសមាជិក Kaiser Permanente ។

សិទ្ធិរបស់អ្នក

ទាំងនេះគឺជាសិទ្ធិរបស់អ្នក ក្នុងនាមជាសមាជិករបស់ Kaiser Permanente ៖

- ត្រូវបានប្រព្រឹត្តដោយការគោរព និងសុចរិតភាព ការផ្តល់នូវការពិចារណាលើសិទ្ធិឯកជនភាព និងតម្រូវការរក្សាការសម្ងាត់នៃព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក
- ត្រូវបានផ្តល់ព័ត៌មានអំពីផែនការនិងសេវារបស់ខ្លួន រួមទាំងសេវាដែលត្រូវបានរ៉ាប់រង អ្នកផ្តល់សេវាក្នុង និងសិទ្ធិនិងទំនួលខុសត្រូវរបស់សមាជិក
- ដើម្បីផ្តល់អនុសាសន៍អំពីគោលការណ៍សិទ្ធិ និងទំនួលខុសត្រូវរបស់សមាជិករបស់យើង
- អាចជ្រើសរើសអ្នកផ្តល់សេវាថែទាំចម្បងនៅក្នុងបណ្តាញរបស់យើង
- មានសិទ្ធិចូលទៅប្រើប្រាស់អ្នកផ្តល់សេវាក្នុងបណ្តាញ
- ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការថែទាំសុខភាពផ្ទាល់ខ្លួនរបស់អ្នក រួមទាំងសិទ្ធិក្នុងការបដិសេធការព្យាបាល
- ស្គាល់ឈ្មោះរបស់អ្នកដែលផ្តល់ការថែទាំរបស់អ្នក និងប្រភេទនៃការបណ្តុះបណ្តាលដែលពួកគេមាន
- ទទួលបានការថែទាំនៅទីកន្លែងដែលមានសុវត្ថិភាព សន្តិសុខ ស្អាត និងអាចចូលប្រើប្រាស់បាន
- ទទួលបានមតិទីពីរពីវេជ្ជបណ្ឌិតក្នុងបណ្តាញបានគ្រប់ពេល
- បញ្ចេញមតិអំពីសេចក្តីទុកព្រួយ ដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ អំពីស្ថាប័នឬការថែទាំដែលអ្នកបានទទួល
- ទទួលបានការសម្របសម្រួលថែទាំ
- ស្នើសុំបណ្តឹងឧទ្ធរណ៍លើការសម្រេចចិត្តបដិសេធ ពន្យារ ឬដាក់កំណត់សេវាឬអត្ថប្រយោជន៍
- ដើម្បីទទួលបានសេវាអ្នកបកប្រែដោយមិនគិតថ្លៃជាភាសារបស់អ្នក

- ទទួលបានជំនួយផ្នែកច្បាប់ឥតគិតថ្លៃនៅការិយាល័យជំនួយផ្នែកច្បាប់ក្នុងតំបន់របស់អ្នក ឬក្រុមផ្សេងទៀត
- រៀបចំសេចក្តីណែនាំជាមុន
- ស្នើសុំសវនាការរដ្ឋ ប្រសិនបើសេវាឬអត្ថប្រយោជន៍ត្រូវបានបដិសេធ។ អ្នកអាចស្នើសុំសវនាការរដ្ឋ ប្រសិនបើអ្នកបានដាក់បណ្តឹងឧទ្ធរណ៍ជាមួយយើង ហើយអ្នកមិនរីករាយជាមួយការសម្រេចចិត្តនោះ។ អ្នកក៏អាចស្នើសុំសវនាការរដ្ឋ ប្រសិនបើអ្នកមិនបានទទួលបានការសម្រេចចិត្ត ក្នុងកំឡុង 30 ថ្ងៃ ចំពោះបណ្តឹងឧទ្ធរណ៍ ដែលអ្នកបានដាក់ជាមួយយើង។ នេះរួមទាំងព័ត៌មានស្តីពីកាល:ទេស:ដែលសវនាការបន្ទាន់អាចធ្វើទៅបាន
- មានសិទ្ធិ និងពេលដែលត្រឹមត្រូវតាមច្បាប់ ទទួលបានច្បាប់ចម្លង កែប្រែ ឬកែតម្រូវកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក
- ដកឈ្មោះពី L.A. Care Health Plan និងផ្លាស់ប្តូរទៅផែនការថែទាំគ្រប់គ្រងមួយទៀត ក្នុងខោនធីដែលអ្នករស់នៅ។
- ទទួលបានសេវាត្រូវបានយល់ព្រមសម្រាប់អនីតិជន
- ដើម្បីទទួលបានព័ត៌មានសមាជិកជាលាយលក្ខណ៍អក្សរដោយមិនគិតថ្លៃក្នុងទម្រង់ផ្សេងទៀត ដូចជាអក្សរសម្រាប់អ្នកពិការភ្នែក ការបោះពុម្ពអក្សរធំៗ ជាសម្លេង និងទម្រង់អេឡិចត្រូនិកដែលអាចចូលប្រើបាន តាមការស្នើសុំ និងតាមពេលវេលាសមស្របតាមទម្រង់ដែលត្រូវបានស្នើសុំ និងអនុលោមតាមក្រមសុខុមាលភាព និងស្ថាប័ន ផ្នែក 14182 (b) (12)
- រួចផុតពីទម្រង់នៃការទប់ស្កាត់ឬការបង្ខាំងដែលត្រូវបានប្រើជាមធ្យោបាយនៃការបង្ខិតបង្ខំ ដាក់វិន័យ ភាពងាយស្រួល ឬការសងសឹក
- ដើម្បីពិភាក្សាដោយពិតត្រង់ អំពីព័ត៌មានដំរើសនៃការព្យាបាលដែលអាចរកបាន និងជម្រើសនានា ដែលត្រូវបានបង្ហាញក្នុងលក្ខណៈដែលសមស្របទៅនឹងលក្ខខ័ណ្ឌនិងសមត្ថភាពក្នុងការយល់ដឹងរបស់អ្នក ដោយមិនគិតពីតម្លៃនិងការរាំបរង។
- ទទួលបានច្បាប់ចម្លងនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក ហើយស្នើសុំឲ្យពួកគេកែប្រែ ឬកែតម្រូវដូចដែលបានបញ្ជាក់នៅក្នុង 45 ក្រមច្បាប់សហព័ន្ធ (Code of Federal Regulations, CFR) §164.524 និង 164.526
- សេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដោយមិនប៉ះពាល់ជាអវិជ្ជមានដល់របៀបដែលអ្នកត្រូវបាន ប្រព្រឹត្តចំពោះដោយ Kaiser Permanente អ្នកផ្តល់សេវា ឬរដ្ឋ
- ដើម្បីមានសិទ្ធិចូលប្រើសេវាកម្មរៀបចំផែនការគ្រួសារ មជ្ឈមណ្ឌលផ្តល់កំណើតឯករាជ្យ មណ្ឌលសុខភាពមានសិទ្ធិសហព័ន្ធ អ្នកផ្តល់សេវាថែទាំសុខភាពអាមេរិកស្បែកក្រហម សេវាឆ្លង មណ្ឌលសុខភាពជនបទ សេវាឆ្លងជំងឺកាមរោគ និងសេវាសង្គ្រោះបន្ទាន់នៅខាងក្រៅបណ្តាញរបស់យើង ស្របតាមច្បាប់សហព័ន្ធ

ទំនួលខុសត្រូវរបស់អ្នក

សមាជិក Kaiser Permanente មានទំនួលខុសត្រូវទាំងនេះ៖

- ការអានសៀវភៅណែនាំសមាជិកនេះដើម្បីស្វែងយល់ពីធានារ៉ាប់រងអ្វីដែលអ្នកមាន និងរបៀបទទួលបានសេវា
- ការប្រើប្រាស់ប័ណ្ណសម្គាល់ខ្លួនរបស់អ្នកឲ្យបានត្រឹមត្រូវ។ នាំយកប័ណ្ណសម្គាល់ Kaiser Permanente ប័ណ្ណសម្គាល់ខ្លួនដែលមានរូបថត និងប័ណ្ណសម្គាល់សមាជិក Medi-Cal របស់អ្នកមកជាមួយអ្នក នៅពេលអ្នកមកទទួលការថែទាំ
- ការរក្សាការណាត់ជួប
- ការប្រាប់ អ្នកផ្តល់សេវាថែទាំបឋម (Primary Care Provider, PCP) របស់អ្នកអំពីសុខភាព និងប្រវត្តិសុខភាពរបស់អ្នក
- ការអនុវត្តតាមគម្រោងថែទាំដែលអ្នក និង PCP របស់អ្នកព្រមព្រៀង
- ការទទួលស្គាល់នូវឥទ្ធិពលនៃរបៀបរស់នៅរបស់អ្នកលើសុខភាពអ្នក
- ការចេះគិតគូរដល់វេជ្ជបណ្ឌិតនៃបណ្តាញ បុគ្គលិកថែទាំសុខភាពផ្សេងទៀត និងសមាជិក
- ការបង់ថ្លៃសេវាដែលមិនត្រូវបានរ៉ាប់រងដោយ Medi-cal
- ការដោះស្រាយបញ្ហាដោយប្រើប្រាស់វិធីដូចបានពណ៌នាក្នុងសៀវភៅណែនាំសមាជិកនេះ
- ការប្រាប់យើងប្រសិនបើអ្នកត្រូវបានចូលសម្រាកក្នុងមន្ទីរពេទ្យដែលនៅក្រៅបណ្តាញ

សេចក្តីជូនដំណឹងពីការមិនរើសអើង

ការរើសអើងគឺប្រឆាំងនឹងច្បាប់។ Kaiser Permanente គោរពតាមច្បាប់សិទ្ធិរដ្ឋប្បវេណីថ្នាក់រដ្ឋ និងសហព័ន្ធ។

Kaiser Permanente មិនរើសអើងប្រឆាំងនឹងច្បាប់ បដិសេធមនុស្ស ឬប្រព្រឹត្តទៅលើពួកគេខុសៗគ្នាដោយសារអាយុ ជាតិសាសន៍ អត្តសញ្ញាណក្រុមពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម សាវតារវប្បធម៌ ពូជពង្ស សាសនា ជេនឌ័រ អត្តសញ្ញាណជេនឌ័រ ការបញ្ជាក់ពីជេនឌ័រ ទំនោរផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ពិការភាពរាងកាយ ឬផ្លូវចិត្ត ប្រភពនៃការទូទាត់ប្រាក់ ព័ត៌មានហ៊ឺរ៉ូន សញ្ជាតិ ភាសាចម្បង ឬស្ថានភាពអន្តោប្រវេសន៍ឡើយ។

Kaiser Permanente ផ្តល់សេវាដូចខាងក្រោម៖

- ផ្តល់ជំនួយនិងសេវាដោយឥតគិតថ្លៃដល់អ្នកមានពិការភាពដើម្បីជួយពួកគេធ្វើការប្រាស្រ័យទាក់ទងជាមួយយើងឲ្យមានប្រសិទ្ធិភាព ដូចជា៖
  - អ្នកបកប្រែភាសាសញ្ញាដែលមានសមត្ថភាព
  - ព័ត៌មានជាលាយលក្ខណ៍អក្សរក្នុងទម្រង់ផ្សេងៗទៀត (អក្សរសម្រាប់ជនពិការអក្សរធំ សំឡេង ទម្រង់អេឡិចត្រូនិចដែលអាចចូលប្រើប្រាស់បាន និងទម្រង់ផ្សេងៗទៀត)
- សេវាផ្នែកភាសាដែលឥតគិតថ្លៃដល់អ្នកដែលភាសាកំណើតរបស់គេមិនមែនជាភាសាអង់គ្លេស ដូចជា៖
  - អ្នកបកប្រែដែលមានសមត្ថភាព
  - ព័ត៌មានសរសេរជាភាសាផ្សេងៗទៀត

ប្រសិនបើអ្នកត្រូវការសេវាទាំងនេះ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងថ្ងៃឈប់សម្រាកដែលបិទ)។ ប្រសិនបើអ្នកមិនអាចស្តាប់ឮឬនិយាយបានល្អ សូមទូរស័ព្ទទៅ 711 ។

តាមការស្នើសុំ ឯកសារនេះអាចត្រូវបានផ្តល់ជូនអ្នកក្នុងទម្រង់ជាអក្សរសម្រាប់អ្នកពិការភ្នែក អក្សរធំ ខ្សែអាត់សម្លេង ឬទម្រង់អេឡិចត្រូនិក។ ដើម្បីទទួលបានច្បាប់ចម្លងនៅក្នុងទម្រង់ជំនួសមួយក្នុងចំណោមទម្រង់ទាំងនេះ ឬទម្រង់ផ្សេងទៀត សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិករបស់យើងហើយសួររកទម្រង់ដែលអ្នកត្រូវការ។

របៀបដាក់ពាក្យបណ្តឹងសារទុក្ខជាមួយ Kaiser Permanente

អ្នកអាចដាក់ពាក្យបណ្តឹងតវ៉ាអំពីការរើសអើងជាមួយ Kaiser Permanente ប្រសិនបើអ្នកជឿថាយើងបរាជ័យក្នុងការផ្តល់សេវាទាំងនេះ ឬមានការរើសអើងដោយខុសច្បាប់តាមវិធីផ្សេង។ សូមយោងទៅលើ ភស្តុតាងនៃការធានារ៉ាប់រង (Evidence of Coverage) ឬ វិញ្ញាបនប័ត្រនៃការធានារ៉ាប់រង (Certificate of Insurance) របស់អ្នកសម្រាប់ព័ត៌មានលម្អិត។ អ្នកក៏អាចនិយាយជាមួយអ្នកតំណាងសេវាសមាជិកអំពីជម្រើសនានាដែលអនុវត្តចំពោះអ្នក។ សូមទូរស័ព្ទមកសេវាសមាជិកប្រសិនបើអ្នកត្រូវការជំនួយដាក់ពាក្យបណ្តឹងសារទុក្ខ។

លោកអ្នកអាចដាក់បណ្តឹងសារទុក្ខតាមវិធីដូចខាងក្រោម៖

- **តាមទូរស័ព្ទ៖** ទូរស័ព្ទទៅសេវាសមាជិកលេខ **1-800-464-4000** (TTY **711**) 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងថ្ងៃឈប់សម្រាកដែលបិទ)។
- **តាមសំបុត្រ៖** ហៅមកយើងខ្ញុំតាមរយៈលេខ **1-800-464-4000** (TTY **711**) ហើយស្នើសុំឲ្យផ្ញើទម្រង់បែបបទទៅអ្នក
- **ដោយផ្ទាល់:** បំពេញទម្រង់បែបបទបណ្តឹងតវ៉ា ឬទាមទារសំណង/សំណើសុំអត្ថប្រយោជន៍នៅការិយាល័យសេវាសមាជិកដែលមានទីតាំងនៅអគារផែនការណាមួយ

(ចូលទៅកាន់បញ្ជីរាយនាមអ្នកផ្តល់សេវារបស់អ្នកនៅ **kp.org/facilities** [ជាភាសាអង់គ្លេស] សម្រាប់អាសយដ្ឋាន)

- **អនឡាញ៖** ប្រើទម្រង់អនឡាញលើគេហទំព័ររបស់យើង នៅ **kp.org** (ជាភាសាអង់គ្លេស)

អ្នកក៏អាចទំនាក់ទំនងមកអ្នកសម្របសម្រួលផ្នែកសិទ្ធិពលរដ្ឋរបស់ Kaiser Permanente ដោយផ្ញើលតាមអាសយដ្ឋានខាងក្រោម៖

ជូនចំពោះ៖ Kaiser Permanente Civil Rights Coordinator
Member Relations Grievance Operations
P.O. Box 939001
San Diego CA 92193

របៀបដាក់ពាក្យបណ្តឹងសារទុក្ខទៅការិយាល័យសិទ្ធិពលរដ្ឋនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ូ *(សម្រាប់តែអ្នកទទួលផលពី Medi-Cal ប៉ុណ្ណោះ)*

អ្នកក៏អាចដាក់ពាក្យបណ្តឹងសិទ្ធិពលរដ្ឋជាមួយការិយាល័យសិទ្ធិពលរដ្ឋនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ូ ដោយសរសេរតាមទូរស័ព្ទឬតាមអ៊ីមែល៖

- **តាមរយៈទូរស័ព្ទ៖** ទូរស័ព្ទទៅ ក្រសួងសេវាកម្មថែទាំសុខភាពការិយាល័យសិទ្ធិពលរដ្ឋតាមលេខ **916-440-7370** (TTY **711**)
- **តាមសំបុត្រ៖** បំពេញបែបបទពាក្យបណ្តឹងឬផ្ញើសំបុត្រទៅ:

  Deputy Director, Office of Civil Rights
  Department of Health Care Services
  Office of Civil Rights
  P.O. Box 997413, MS 0009
  Sacramento, CA 95899-7413

  ទម្រង់បែបបទពាក្យបណ្តឹងអាចរកបាននៅ៖
  http://www.dhcs.ca.gov/Pages/Language_Access.aspx (ជាភាសាអង់គ្លេស)
- **អនឡាញ**: ផ្ញើអ៊ីមែលទៅកាន់ CivilRights@dhcs.ca.gov

របៀបដាក់បណ្តឹងសារទុក្ខទៅកាន់ការិយាល័យសិទ្ធិពលរដ្ឋនាយកដ្ឋានសេវាសុខភាព និងមនុស្សជាតិអាមេរិក

អ្នកអាចដាក់បណ្តឹងតវ៉ាអំពីការរើសអើង ទៅកាន់ការិយាល័យសិទ្ធិពលរដ្ឋនាយកដ្ឋានសេវាសុខភាពនិងមនុស្សជាតិអាមេរិក។ អ្នកអាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ តាមទូរស័ព្ទឬតាមអនឡាញ៖

- **តាមទូរស័ព្ទ:** ទូរស័ព្ទទៅលេខ **1-800-368-1019** (TTY **711** ឬ **1-800-537-7697**)
- **តាមសំបុត្រ:** បំពេញបែបបទពាក្យបណ្តឹងឬផ្ញើសំបុត្រទៅ:

U.S. Department of Health and Human Services
200 Independence Avenue, SW
Room 509F, HHH Building
Washington, D.C. 20201

ទម្រង់បែបបទបណ្តឹងតវ៉ាមានជូននៅ៖
http:www.hhs.gov/ocr/office/file/index.html (ជាភាសាអង់គ្លេស)

- **អនឡាញ៖** ចូលទៅកាន់ទំព័រការិយាល័យបណ្តឹងសិទ្ធិពលរដ្ឋនៅ៖
  https://ocrportal.hhs.gov/ocr/cp (ជាភាសាអង់គ្លេស)

វិធីនានាដើម្បីចូលរួមក្នុងនាមជាសមាជិក

L.A. Care Health Plan ចង់ដឹងឮពីអ្នក។ ពួកគេមានកិច្ចប្រជុំដើម្បីនិយាយអំពីអ្វីដែលកំពុងដំណើរការល្អ និងរបៀបដែលពួកគេអាចកែលម្អ។ សមាជិកត្រូវបានអញ្ជើញឲ្យចូលរួម។ សូមមកចូលរួមការប្រជុំ!

គណៈកម្មាធិការប្រឹក្សាសាធារណៈ L.A. Care

L.A. Care មានក្រុមមួយដែលឈ្មោះថា គណៈកម្មាធិការប្រឹក្សាសាធារណៈ L.A. Care។ ក្រុមនេះត្រូវបានបង្កើតឡើងដោយបុគ្គលិក L.A. Care និងសមាជិកដូចជាអ្នក។ ក្រុមនេះនិយាយអំពីរបៀបកែលម្អគោលការណ៍ L.A Care និងទទួលខុសត្រូវក្នុងការពិភាក្សាបញ្ហាសមាជិកនិងផែនការសុខភាព។ ប្រសិនបើអ្នកចង់រួមចំណែកជាមួយក្រុមនេះ សូមទូរស័ព្ទមកលេខ **1-888-839-9909** (TTY **711**)។

គណៈកម្មាធិការប្រឹក្សាសហគមន៍ក្នុងតំបន់ L.A. Care ("RCAC")

មានគណៈកម្មការប្រឹក្សាសហគមន៍ក្នុងតំបន់ L.A. Care ("RCAC") ចំនួនដប់មួយនៅក្នុងខោនធី Los Angeles (RCAC ត្រូវបានប្រកបថា "រ៉ែក")។ គោលបំណងរបស់ពួកគេគឺដើម្បីអនុញ្ញាតឲ្យសមាជិកផ្តល់មតិយោបល់ដល់គណៈអភិបាល L.A. Care ដែលអាចមានឥទ្ធិពលលើគោលនយោបាយ នីតិវិធី កម្មវិធី និងការអនុវត្ត។

សមាជិក RCAC៖

- និយាយពីបញ្ហាសេវាថែទាំសុខភាពនិងសុខភាពដែលប៉ះពាល់ដល់សមាជិក L.A. Care
- ផ្តល់ឱវាទដល់គណៈអភិបាល L.A. Care
- អប់រំនិងផ្តល់សិទ្ធិអំណាចដល់សហគមន៍លើបញ្ហាថែទាំសុខភាព

RCAC ជួបប្រជុំរៀងរាល់ពីរខែម្តង។ RCAC រួមបញ្ចូលសមាជិក L.A Care អង្គការសហគមន៍ដែលធ្វើការជាមួយសមាជិក L.A. Care និងអ្នកផ្តល់សេវាថែទាំសុខភាព។ ដើម្បីស្វែងយល់ប

ន្ថែមអំពី RCAC សូមទូរស័ព្ទមកនាយកដ្ឋានផ្សព្វផ្សាយ និងទំនាក់ទំនងសហគមន៍ L.A. Care ដោយឥតគិតថ្លៃតាមលេខ **1-888-LA-CARE2** (**1-888-522-2732**)។

កិច្ចប្រជុំគណៈអភិបាល

គណៈអភិបាលធ្វើការសំរេចលើគោលការណ៍សម្រាប់ L.A. Care។ អ្នកគ្រប់គ្នាអាចចូលរួមក្នុងកិច្ចប្រជុំទាំងនេះ។ គណៈអភិបាលជួបប្រជុំនៅថ្ងៃព្រហស្បតិ៍ទីមួយនៃខែនីមួយៗចាប់ពីម៉ោង 2 រសៀល។ ដើម្បីស្វែងយល់បន្ថែមសូមទូរស័ព្ទមក L.A. Care លេខ **1-213-694-1250**។

សេចក្តីជូនដំណឹងការអនុវត្តន៍ឯកជនភាព

សេចក្តីថ្លែងការណ៍ដែលពាណ៌នាពីគោលការណ៍និងនីតិវិធីរបស់ KAISER PERMANENTE សម្រាប់ការថែរក្សាភាពសម្ងាត់នៃកំណត់ត្រាវេជ្ជសាស្ត្រគឺអាចរកបាន ហើយនឹងត្រូវបានផ្តល់ជូនដល់អ្នកទៅតាមការស្នើសុំ។

Kaiser Permanente នឹងការពារឯកជនភាពនៃព័ត៌មានសុខភាពដែលបានការពារបស់អ្នក (protected health information, "PHI")។ យើងក៏តម្រូវឲ្យអ្នកផ្តល់សេវាដែលចុះកិច្ចសន្យាទាំងអស់ការពារការសម្ងាត់ PHI របស់អ្នកផងដែរ។ PHI របស់អ្នកគឺជាព័ត៌មានដែលអាចកំណត់អត្តសញ្ញាណជាលក្ខណៈបុគ្គល (ផ្តល់មាត់ សរសេរ ឬអេឡិចត្រូនិក) អំពីសុខភាពរបស់អ្នក សេវាថែទាំសុខភាពដែលអ្នកបានទទួល ឬការទូទាត់ប្រាក់សម្រាប់ការថែទាំសុខភាពអ្នក។

ជាទូទៅអ្នកអាចមើល និងទទួលបានច្បាប់ចម្លងនៃ PHI របស់អ្នក កែកំហុស ឬធ្វើបច្ចុប្បន្នភាព PHI របស់អ្នក និងស្នើសុំពួកយើងរកបញ្ជីនៃការបង្ហាញជាក់លាក់នានានៃ PHI របស់អ្នក។ អ្នកអាចស្នើសុំការបញ្ជូនការទំនាក់ទំនងដែលសម្ងាត់ទៅទីតាំងមួយផ្សេងក្រៅពីអាសយដ្ឋាន ធម្មតារបស់អ្នក ឬដោយមធ្យោបាយដឹកជញ្ជូនក្រៅពីមធ្យោបាយធម្មតា។

យើងប្រហែលជាប្រើប្រាស់ ឬអនុញ្ញាតឲ្យអ្នកដទៃមើល PHI របស់អ្នកសម្រាប់ការថែទាំការស្រាវជ្រាវសុខភាព ការបង់ប្រាក់ ឬប្រតិបត្តិការថែទាំសុខភាព ដូចជាសម្រាប់ការស្រាវជ្រាវ ឬវាស់ស្ទង់គុណភាពនៃការថែទាំនិងសេវា។ លើសពីនេះ តាមច្បាប់យើងអាចផ្តល់ PHI របស់អ្នកទៅរដ្ឋាភិបាល ឬផ្តល់វាជាសកម្មភាពតាមច្បាប់។

យើងនឹងមិនប្រើឬបង្ហាញ PHI របស់អ្នក សម្រាប់គោលបំណងផ្សេងដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នក (ឬនរណាម្នាក់ដែលអ្នកឲ្យធ្វើជាតំណាងសម្រាប់អ្នក)លើកលែងតែដូចអ្វីដែលបានពាណ៌នានៅក្នុងសេចក្តីជូនដំណឹងការអនុវត្តឯកជនភាពរបស់យើង (មើលខាងក្រោម) និងច្បាប់ឯកជនភាព Medi-Cal។ អ្នកមិនចាំបាច់អនុញ្ញាតិការប្រើប្រាស់ផ្សេងនេះនៃ PHI របស់អ្នកទេ។

ប្រសិនបើអ្នកឃើញនរណាម្នាក់កំពុងប្រើប្រាស់ព័ត៌មានរបស់អ្នកដោយមិនត្រឹមត្រូវ សូមទាក់ទងមជ្ឈមណ្ឌលសេវាទំនាក់ទំនងសមាជិកលេខ **1-800-464-4000** (TTY **711**) ឬនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វញ៉ា មន្ត្រីផ្នែកឯកជនភាព លេខ **1-866-866-0602**

ជម្រើសទី 1 (**1-877-735-2929**)។ អ្នកក៏អាចអ៊ីមែលទៅនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ានៅ **privacyofficer@dhcs.ca.gov**។

នេះគ្រាន់តែជាសេចក្តីសង្ខេបខ្លីមួយចំនួននៃការអនុវត្តឯកជនភាពសំខាន់ៗរបស់យើងប៉ុណ្ណោះ។ សេចក្តីជូនដំណឹងការអនុវត្តន៍ឯកជនភាពរបស់យើង ដែលផ្តល់នូវព័ត៌មានបន្ថែមអំពីការអនុវត្តន៍ ឯកជនភាពរបស់យើង និងសិទ្ធិរបស់អ្នកទាក់ទងនឹង PHI របស់អ្នកគឺអាចរកបានហើយនឹងត្រូវបានផ្តល់ជូនអ្នកទៅតាមការស្នើសុំ។ ដើម្បីទទួលបានមួយច្បាប់ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ អ្នកក៏អាចរកមើលសេចក្តីជូនដំណឹងនេះនៅតាមទីតាំង Kaiser Permanente ឬតាមអនឡាញនៅ **kp.org** (ជាភាសាអង់គ្លេស)។

សេចក្តីជូនដំណឹងអំពីច្បាប់

ច្បាប់ជាច្រើនអនុវត្តទៅលើសៀវភៅណែនាំសមាជិកនេះ។ ច្បាប់ទាំងនេះអាចប៉ះពាល់ដល់សិទ្ធិនិងទំនួលខុសត្រូវរបស់អ្នក ទោះបីជាច្បាប់មិនត្រូវបានរួមបញ្ចូល ឬពន្យល់នៅក្នុងសៀវភៅសមាជិកនេះក៏ដោយ។ ច្បាប់សំខាន់ៗដែលអនុវត្តចំពោះសៀវភៅណែនាំសមាជិកនេះ គឺច្បាប់រដ្ឋនិងសហព័ន្ធអំពីកម្មវិធី Medi-Cal។ ច្បាប់រដ្ឋនិងសហព័ន្ធផ្សេងទៀតអាចអនុវត្តផងដែរ។

សេចក្តីជូនដំណឹងអំពី Medi-Cal ក្នុងនាមជាអ្នកបង់ប្រាក់ជម្រើសចុងក្រោយ ការធានារ៉ាប់រងសុខភាពដទៃទៀត និងការទទួលខុសត្រូវចំពោះការខូចខាត

ជួនកាលអ្នកណាម្នាក់ទៀតត្រូវបង់ប្រាក់មុនសម្រាប់សេវាដែល Kaiser Permanente ផ្តល់ឲ្យឬរៀបចំឲ្យអ្នក។ ឧទាហរណ៍ ប្រសិនបើអ្នកស្ថិតក្នុងគ្រោះថ្នាក់ចរាចរណ៍ ឬប្រសិនបើអ្នករងរបួសនៅកន្លែងធ្វើការ អ្នកធានារ៉ាប់រង ឬសំណងកម្មករត្រូវបង់ប្រាក់ជាមុនសិន។

នាយកដ្ឋានថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ាមានសិទ្ធិនិងទំនួលខុសត្រូវក្នុងការប្រមូលសម្រាប់សេវា Medi-Cal ដែលត្រូវបានរ៉ាប់រងដែល Medi-Cal មិនមែនជាអ្នកបង់ប្រាក់ទីមួយ។

កម្មវិធី Medi-Cal អនុវត្តតាមច្បាប់និងបទបញ្ជារបស់រដ្ឋនិងសហព័ន្ធទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកច្បាប់របស់ភាគីទីបី សម្រាប់សេវាថែទាំសុខភាពដល់អ្នកទទួលផល។ Kaiser Permanente នឹងចាត់វិធានការសមស្របទាំងអស់ដើម្បីធានាថាកម្មវិធី Medi-Cal គឺជាអ្នកទូទាត់ជម្រើសចុងក្រោយ។

ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន Medicare អ្នកត្រូវតែអោយយើងដឹង។ កម្មវិធី Medicare អាចនឹងត្រូវចំណាយលើសេវាមួយចំនួនដែលអ្នកទទួលបានពីយើង។ Medi-Cal តែងតែបង់ប្រាក់ចុងក្រោយគេ។

សមាជិក Medi-Cal ក៏អាចមានការរ៉ាប់រងសុខភាពឯទៀត (other health coverage, "OHC") ដែលបានផ្តល់ដល់ពួកគេ ដោយឥតគិតប្រាក់។ តាមច្បាប់ សមាជិកត្រូវបានតម្រូវឲ្យប្រើប្រាស់សេវាអោយអស់ពីលទ្ធភាពដែលផ្តល់ដោយ OHC មុននឹងការប្រើប្រាស់សេវាតាមរយៈ Medi-Cal។ ប្រសិនបើអ្នកមិនបានដាក់ពាក្យសុំ ឬក្សាទុក OHC ដែលឥតគិតថ្លៃ ឬ OHC ចេញថ្លៃដោយរដ្ឋនោះទេ អត្ថប្រយោជន៍ និង/ឬសិទ្ធិ Medi-Cal របស់អ្នកនឹងត្រូវបានបដិសេធ ឬបញ្ឈប់។ ច្បាប់សហព័ន្ធនិងរដ្ឋតម្រូវឲ្យសមាជិក Medi-Cal រាយការណ៍អំពីការធានារ៉ាប់រងសុខភាពឯកជន។ ដើម្បីរាយការណ៍ ឬផ្លាស់ប្តូរការធានារ៉ាប់រងសុខភាពឯកជន សូមចូលទៅ **http://dhcs.ca.gov/mymedi-cal** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចទូរស័ព្ទទៅ L.A. Care Health Plan លេខ **1-888-839-9909** (TTY **711**)។ ឬទូរស័ព្ទទៅ DHCS លេខ **1-800-541-5555** (TTY **1-800-430-7077** ឬ **711**)។ នៅក្រៅរដ្ឋកាលីហ្វ័រញ៉ា សូមទូរស័ព្ទ **1-916-636-1980**។ ប្រសិនបើអ្នកមិនរាយការណ៍ពីការផ្លាស់ប្តូរទៅ OHC របស់អ្នកទាន់ពេលវេលា និងដោយមូលហេតុនេះ ហើយទទួលបានអត្ថប្រយោជន៍ Medi-Cal ដែលអ្នកមិនមានសិទ្ធិ អ្នកអាចត្រូវបង់ប្រាក់សង DHCS វិញ។

ប្រសិនបើអ្នកមានគ្រោះថ្នាក់ ហើយភាគីមួយផ្សេងទៀតទទួលខុសត្រូវចំពោះការរងរបួស របស់អ្នក អ្នកនិងអ្នកតំណាងផ្លូវច្បាប់របស់អ្នក ត្រូវតែជូនដំណឹងដល់ DHCS ក្នុងកំឡុង 30 ថ្ងៃបន្ទាប់ពីការចាត់វិធានការតាមច្បាប់ ឬការទាមទារសំណង ។ បញ្ជូនការជូនដំណឹងរបស់អ្នកតាមអនឡាញ:

- កម្មវិធីគ្រោះថ្នាក់ផ្ទាល់ខ្លួននៅ **http://dhcs.ca.gov/PI** (ជាភាសាអង់គ្លេស)
- កម្មវិធីស្រោចស្រង់សំណងបុគ្គលិកនៅ **http://dhcs.ca.gov/WC** (ជាភាសាអង់គ្លេស)

ដើម្បីស្វែងយល់បន្ថែម សូមទូរស័ព្ទទៅលេខ **1-916-445-9891**។

សេចក្តីជូនដំណឹងការស្រោចស្រង់ទ្រព្យសម្បត្តិ

កម្មវិធី Medi-Cal ត្រូវតែស្វែងរកការបង់ប្រាក់សងសម្រាប់ទ្រព្យសម្បត្តិនៃសមាជិក Medi-Cal ដែលបានទទួលមរណភាពមួយចំនួនសម្រាប់ការទូទាត់ដែលបានធ្វើ រួមទាំងប្រាក់បុព្វលាភថែទាំ មានការគ្រប់គ្រងសម្រាប់សេវាមណ្ឌលថែទាំ សេវាថែទាំសុខភាពនៅតាមផ្ទះ និងសហគមន៍ និងសេវាមន្ទីរពេទ្យដែលពាក់ព័ន្ធរួមទាំងឱសថវេជ្ជបញ្ជាដែលត្រូវបាន ផ្តល់ជូនដល់សមាជិក Medi-Cal ដែលបានទទួលមរណភាពនៅ ឬក្រោយថ្ងៃកំណើតទី 55 របស់សមាជិក។ ប្រសិនបើសមាជិកដែលបានទទួលមរណភាពមិនបានបន្សល់ទុកទ្រព្យសម្បត្តិ ឬគ្មានកម្មសិទ្ធិអ្វីៗទាំងអស់នៅពេលពួកគេទទួលមរណភាព នឹងគ្មានជាប់ជំពាក់អ្វីឡើយ។

ដើម្បីស្វែងយល់បន្ថែមទៀតអំពីការស្រោចស្រង់ទ្រព្យសម្បត្តិ សូមទូរស័ព្ទលេខ **(916) 650-0590** ឬចូលទៅអនឡាញនៅ **http://dhcs.ca.gov/er** (ជាភាសាអង់គ្លេស)។ អ្នកក៏អាចទទួលបានការទូទ្រានផ្លូវច្បាប់ផងដែរ។

សេចក្តីជូនដំណឹងអំពីសកម្មភាព

Kaiser Permanente នឹងផ្ញើលិខិតជូនដំណឹងអំពី (Notice of Action, NOA) ដល់អ្នក នៅពេលណាដែលយើងបដិសេធ ពន្យាពេល បញ្ចប់ ឬកែប្រែសំណើសុំសេវាថែទាំសុខភាព។ ប្រសិនបើអ្នកមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់យើង អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន។ សូមមើលផ្នែកបណ្តឹងឧទ្ធរណ៍ក្នុងជំពូកទី 6 សម្រាប់ព័ត៌មានសំខាន់ ចំពោះការដាក់បណ្តឹងឧទ្ធរណ៍របស់អ្នក។ នៅពេលយើងផ្ញើ NOA ទៅអ្នក វានឹងប្រាប់អ្នកអំពីសិទ្ធិទាំងអស់របស់អ្នកដែលអ្នកមាន ប្រសិនបើអ្នកមិនយល់ស្របជាមួយការសម្រេចចិត្តដែលយើងបានធ្វើ។

សេចក្តីជូនដំណឹងអំពីកាល:ទេស:ខុសពីធម្មតា

ប្រសិនបើមានអ្វីមួយកើតឡើងដែលដាក់កម្រិតសមត្ថភាពរបស់យើងក្នុងការផ្តល់និងរៀបចំការថែទាំដូចជាគ្រោះមហន្តរាយធំ យើងនឹងខិតខំប្រឹងប្រែងដោយស្មោះត្រង់ដើម្បីផ្តល់ឲ្យអ្នកនូវការថែទាំដែលអ្នកត្រូវការជាមួយអ្នកផ្តល់សេវាក្នុងបណ្តាញ និងទីកន្លែងក្នុងបណ្តាញដែលមាន។ ប្រសិនបើអ្នកមានល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ សូមទៅមន្ទីរពេទ្យដែលនៅជិតបំផុត។ អ្នកមានធានារ៉ាប់រងលើសេវាសង្គ្រោះបន្ទាន់ ដូចដែលបានពិពណ៌នានៅក្នុងផ្នែក "សេវាសង្គ្រោះបន្ទាន់"។

សេចក្តីជូនដំណឹងអំពីការគ្រប់គ្រងនៃអត្ថប្រយោជន៍របស់អ្នក

អ្នកត្រូវតែបំពេញសំណុំបែបបទណាដែលយើងស្នើសុំក្នុងដំណើរការអាជីវកម្មធម្មតារបស់យើង។ លើសពីនេះ យើងអាចបង្កើតស្តង់ដារ (គោលការណ៍និងនីតិវិធី) ដើម្បីផ្តល់សេវារបស់អ្នកឲ្យកាន់តែប្រសើរ ។

ប្រសិនបើយើងខ្ចីធ្វើការលើកលែងក្នុងល័ក្ខខ័ណ្ឌនៃសៀវភៅណែនាំសមាជិកនេះ សម្រាប់អ្នក ឬអ្នកផ្សេង យើងមិនចាំបាច់ធ្វើដូចគ្នាចំពោះអ្នក ឬអ្នកផ្សេងនោះទេនាពេលអនាគតទេ។ ប្រសិនបើយើងមិនប្រតិបត្តិតាមផ្នែកនៃសៀវភៅណែនាំសមាជិកនេះ នេះមិនមែនមានន័យថាយើងលើកលែងល័ក្ខខ័ណ្ឌនៃសៀវភៅសមាជិកនេះទេ។ យើងមានសិទ្ធិបង្ខាប់ឲ្យប្រតិបត្តិតាមល័ក្ខខ័ណ្ឌនៃសៀវភៅណែនាំសមាជិកនេះនៅពេលណាក៏បាន។

សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរទៅលើសៀវភៅណែនាំសមាជិកនេះ

យើង ដោយមានការយល់ព្រម ពី L.A. Care Health Plan អាចធ្វើការផ្លាស់ប្តូរទៅលើសៀវភៅសមាជិកនេះនៅពេលណាក៏បាន។ យើងនឹងឲ្យអ្នកដឹងជាលាយលក្ខណ៍អក្សរអំពីការផ្លាស់ប្តូរណាមួយនៅ 30 ថ្ងៃ មុនពេលដែលវាកើតឡើង។

សេចក្តីជូនដំណឹងស្តីពីថ្លៃឈ្នួលនិងការចំណាយលើមេធាវីនិងអ្នកគាំពារ

នៅក្នុងជម្លោះណាមួយរវាងអ្នកនិងពួកយើង Southern California Permanente Medical Group ឬ Kaiser Foundation Hospitals ភាគីនីមួយៗនឹងទូទាត់ថ្លៃឈ្នួលនិងចំណាយផ្សេងៗ របស់ពួកគេដោយខ្លួនឯង។ ទាំងនេះរួមមានថ្លៃឈ្នួលរបស់មេធាវីនិងថ្លៃឈ្នួលរបស់អ្នកគាំពារ។

សេចក្តីជូនដំណឹងថាសៀវភៅណែនាំសមាជិកនេះនឹងចងភ្ជាប់កាតព្វកិច្ចលើសមាជិក

ល័ក្ខខ័ណ្ឌនៃសៀវភៅណែនាំសមាជិកនេះនឹងចងភ្ជាប់កាតព្វកិច្ចលើអ្នកនៅពេលដែលអ្នកជ្រើសរើសការចាត់តាំងនៅក្នុង Kaiser Permanente តាមរយៈ L.A. Care Health Plan ។

សេចក្តីជូនដំណឹងថា L.A. Care Health Plan មិនមែនជាភ្នាក់ងាររបស់យើងទេ

L.A. Care Health Plan គឺពុំមែនជាភ្នាក់ងារ ឬ តំណាងរបស់ Kaiser Foundation Health Plan, Inc. ទេ

សេចក្តីជូនដំណឹងអំពីជានារ៉ាប់រងរបស់អ្នក

យើងអាចផ្តើឲ្យអ្នកនូវបច្ចុប្បន្នភាពអំពីជានារ៉ាប់រងការថែទាំសុខភាពរបស់អ្នក។ យើងនឹងផ្តើវាទៅអាសយដ្ឋានថ្មីបំផុតដែលយើងមានសម្រាប់អ្នក។ បើអ្នកផ្លាស់ទីលំនៅ ឬមានអាសយដ្ឋានថ្មី សូមឲ្យយើងដឹងពីអាសយដ្ឋានថ្មីរបស់អ្នកឲ្យ បានឆាប់តាមដែលអ្នកអាច ដោយទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។ លើសពីនេះ អនុញ្ញាតឲ្យបុគ្គលិកផ្នែកសិទ្ធិទទួលបានក្នុងខោនធីរបស់អ្នក និង L.A. Care Health Plan ស្គាល់អាសយដ្ឋានថ្មីរបស់អ្នកផងដែរ។

8. លេខនិងពាក្យសំខាន់ៗដែលត្រូវដឹង

លេខទូរស័ព្ទសំខាន់ៗ

- ផ្នែកសេវាសមាជិក Kaiser Permanente៖
  - ភាសាអង់គ្លេស (និងច្រើនជាង 150 ភាសាដែលប្រើសេវាអ្នកបកប្រែ) **1-800-464-4000**
  - ភាសាអេស្ប៉ាញ **1-800-788-0616**
  - ក្រាមភាសាចិន **1-800-757-7585**
  - TTY **711**
- ការអនុញ្ញាតសម្រាប់ការថែទាំក្រោយមានស្ថេរភាព **1-800-225-8883** (TTY **711**)
- ការណាត់ជួបនិងដំបូន្មាន Kaiser Permanente 1-833-574-2273 (TTY **711**)
- L.A. Care Health Plan **1-888-839-9909** (TTY 711)
- Health Care Options **1-800-430-4263** (TTY **1-800-430-7077**)
- Medi-Cal Rx **1-800-977-2273** (TTY **711**)

ពាក្យដែលត្រូវដឹង

ការឈឺពោះសម្រាលកូន៖ អំឡុងពេលដែលស្ត្រីស្ថិតក្នុងដំណាក់កាលទីបីនៃការបង្កើតកូន ហើយមិនអាចត្រូវបានបញ្ឈប់ដោយសុវត្ថិភាពទាន់ពេលវេលាទៅមន្ទីរពេទ្យផ្សេងទៀតមុនពេលសម្រាល ឬការផ្ទេរទៅអាចធ្វើឲ្យគ្រោះថ្នាក់ដល់សុខភាពនិងសុវត្ថិភាពរបស់ស្ត្រី ឬកូនដែលមិនទាន់កើត។

ធ្ងន់ធ្ងរ៖ ស្ថានភាពវេជ្ជសាស្ត្រដែលភ្លាមៗ តម្រូវឲ្យមានការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រដែលលឿន និងមិនមានរយៈពេលយូរ។

អាមេរិកាំងស្បែកក្រហម៖ គឺជាបុគ្គល ដែលបានកំណត់នៅក្រោមចំណងជើង 25 នៃក្រមច្បាប់សហរដ្ឋអាមេរិច (United States Code, U.S.C) ផ្នែក 1603(c), 1603(f). 1679(b) ដែលត្រូវបានកំណត់ថាមានសិទ្ធិ ក្នុងនាមជាជនជាតិអាមេរិចស្បែកក្រហម ដោយអនុលោមតាម 42 ក្រមច្បាប់សហព័ន្ធ (Code of Federal Regulations, C.F.R.) 136.12 ឬចំណងជើង V នៃច្បាប់កែលម្អការថែទាំសុខភាពជនជាតិអាមេរិចស្បែកក្រហម ដើម្បីទទួលបានសេវាថែទាំសុខភាព ពីអ្នកផ្តល់សេវាថែទាំសុខភាពជនជាតិអាមេរិចស្បែកក្រហម (កុលសម្ព័ន្ធឥណ្ឌា អង្គការកុលសម្ព័ន្ធ ឬអង្គការឥណ្ឌានៅទីក្រុង – [Indian Tribe, Tribal Organization, or Urban Indian Organization, I/T/U]) ឬតាមរយៈការបញ្ជូនក្រោមសេវាសុខភាពមានកិច្ចសន្យា។

បណ្តឹងឧទ្ធរណ៍៖ បណ្តឹងឧទ្ធរណ៍គឺជាសំណើរសុំ Kaiser Permanente ឲ្យត្រួតពិនិត្យឡើងវិញនិងផ្លាស់ប្តូរ ការសម្រេចចិត្តដែលបានធ្វើអំពីការធានារ៉ាប់រងលើសេវាដែលបានស្នើសុំ។

អត្ថប្រយោជន៍៖ សេវាថែទាំសុខភាពនិងឱសថដែលត្រូវបានរ៉ាប់រងនៅក្រោមផែនការសុខភាពនេះ។

មជ្ឈត្តវិនិច្ឆ័យចងភ្ជាប់៖ គឺជាវិធីមួយដើម្បីដោះស្រាយបញ្ហាដោយការប្រើភាគីទីបីដែលអព្យាក្រឹត។ សម្រាប់បញ្ហាដែលត្រូវបានដោះស្រាយតាមរយៈការសម្រេចនៃមជ្ឈត្តវិនិច្ឆ័យចងភ្ជាប់ ភាគីទីបី ស្តាប់ភាគីទាំងសងខាងនៃបញ្ហា ហើយធ្វើសេចក្តីសម្រេចចិត្តដែលភាគីទាំងពីរត្រូវតែទទួលយក។ ភាគីទាំងពីរបោះបង់សិទ្ធិឲ្យទៅក្រុមប្រឹក្សាតុលាការ ឬការកាត់ក្តីតុលាការ។

California Children's Services ("CCS")៖ កម្មវិធី Medi-Cal មួយដែលផ្តល់សេវាសម្រាប់កុមារអាយុរហូតដល់ 21 ឆ្នាំ ដែលមានជម្ងឺនិងបញ្ហាសុខភាពជាក់លាក់។

ការបង្ការភាពពិការនិងសុខភាពរដ្ឋកាលីហ្វ័រញ៉ា (California Health and Disability Prevention, "CHDP")៖ កម្មវិធីសុខភាពសាធារណៈ ដែលផ្តល់ប្រាក់សំណងដល់អ្នកផ្តល់សេវាថែទាំសុខភាពសាធារណៈនិងឯកជនសម្រាប់ការវាយតម្លៃ សុខភាពដំណាក់កាលដំបូងដើម្បីរកមើល ឬការពារជំងឺ និងពិការភាពលើកុមារនិងយុវជន។ កម្មវិធីនេះជួយកុមារនិងយុវជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឲ្យទទួលបានការថែទាំសុខភាពជាទៀងទាត់។ PCP របស់អ្នកអាចផ្តល់ជូនសេវា CHDP។

អ្នកគ្រប់គ្រងករណី៖ គិលានុបដ្ឋាយិកាដែលបានចុះឈ្មោះ គិលានុបដ្ឋាយិការឺជ្ញាជីវៈដែលមានអាជ្ញាប័ណ្ណ បុគ្គលិកសង្គមកិច្ច ឬបុគ្គលិកដែលត្រូវបានចាត់តាំងផ្សេងទៀត ដែលអាចជួយអ្នកឲ្យយល់ពីបញ្ហាសុខភាពសំខាន់ៗ និងរៀបចំការថែទាំជាមួយអ្នកផ្តល់សេវារបស់អ្នក។

ឆ្មបដែលជាគិលានុបដ្ឋាយិកាមានវិញ្ញាបនប័ត្រ (Certified Nurse Midwife, "CNM")៖ បុគ្គលដែលមានអាជ្ញាប័ណ្ណជា គិលានុបដ្ឋាយិកាដែលបានចុះបញ្ជីនិងមានវិញ្ញាបនប័ត្រធ្វើជាឆ្មបគិលានុបដ្ឋាយិកា ដោយគណៈកម្មការគិលានុបដ្ឋាករដ្ឋកាលីហ្វ័រញ៉ា។ ឆ្មបដែលជាគិលានុបដ្ឋាយិកាមានវិញ្ញាបនប័ត្រ ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងករណីនៃការឆ្លងទន្លេធម្មតា។

វេជ្ជបណ្ឌិតចាប់សរសៃនិងសន្លាក់: អ្នកផ្តល់សេវាដែលព្យាបាលឆ្អឹងខ្នងដោយវិធីសាស្ត្រ នៃការចាប់សរសៃ

ស្ថានភាពរ៉ាំរ៉ៃ: ជំងឺឬបញ្ហាវេជ្ជសាស្ត្រផ្សេងទៀតដែលមិនអាចព្យាបាលបានទាំងស្រុង ឬយូរទៅកាន់តែយ៉ាប់យឺនទៅៗ ឬត្រូវតែបានព្យាបាលដូច្នេះអ្នកមិនទៅជាធ្ងន់ធ្ងរជាងមុន។

ក្លីនិក: ក្លីនិកគឺជាកន្លែងដែលសមាជិកអាចជ្រើសរើសធ្វើជាអ្នកផ្តល់សេវាថែទាំចម្បង (PCP)។ វាអាចជាមជ្ឈមណ្ឌលសុខភាពស្របតាមលក្ខខ័ណ្ឌសហព័ន្ធ (FQHC), ក្លីនិកក្នុងសហគមន៍ ក្លីនិកសុខភាពជនបទ (RHC) ក្លីនិកសុខភាពជនជាតិអាមេរិចស្បែកក្រហម ឬទីកន្លែងថែទាំចម្បងផ្សេងទៀត។

សេវាសម្រាប់មនុស្សពេញវ័យតាមសហគមន៍ (Community-based adult services, "CBAS"): សេវាតាមមូលដ្ឋានសម្រាប់ ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់ការមើលថែទាំមានជំនាញ សេវាសង្គម ការព្យាបាល ការថែទាំផ្ទាល់ខ្លួន ការបណ្តុះបណ្តាលនិងជំនួយសម្រាប់ត្រួសារនិងអ្នកផ្តល់ការថែទាំ សេវាអាហារូបត្ថម្ភ ការដឹកជញ្ជូន និងសេវាផ្សេងៗទៀតសម្រាប់សមាជិកដែលមានលក្ខណៈសម្បត្តិត្រប់ត្រាន់។

បណ្តឹងត្អូញត្អែរ: ការបញ្ចេញដោយពាក្យសម្តី ឬជាលាយលក្ខណ៍អក្សររបស់សមាជិកអំពី ការមិនពេញចិត្តលើ Kaiser Permanente អ្នកផ្តល់សេវា គុណភាពនៃការថែទាំ ឬសេវាដែលត្រូវបានផ្តល់ជូន។ បណ្តឹងត្អូញត្អែរគឺដូចគ្នាទៅនឹងសារទុក្ខ។

ការបន្តការថែទាំ: លទ្ធភាពរបស់សមាជិកផែនការដើម្បីបន្តទទួលបានសេវា Medi-Cal ពីអ្នកផ្តល់សេវាដែលមានស្រាប់របស់ពួកគេរហូតដល់ 12 ខែដោយគ្មានការផ្អាកសេវា ប្រសិនបើអ្នកផ្តល់សេវានិង Kaiser Permanente យល់ព្រម។

បញ្ជីឱសថកិច្ចសន្យា (Contract Drugs List, "CDL"): បញ្ជីថ្នាំដែលត្រូវបានអនុម័តសម្រាប់ Medi-Cal Rx ដែលត្រូពេទ្យរបស់អ្នកអាចបញ្ជាទិញថ្នាំដែលមានការរ៉ាប់រងដែលអ្នកត្រូវការ។

ការសម្របសម្រួលអត្ថប្រយោជន៍ (Coordination of Benefits, "COB"): ដំណើរការនៃការកំណត់ថា តើមួយណានៃ ការធានារ៉ាប់រង (Medi-Cal, Medicare, ក្រុមហ៊ុនធានារ៉ាប់រង ឬផ្សេងទៀត) មានទំនួលខុសត្រូវចម្បងលើការព្យាបាលនិងបង់ថ្លៃសម្រាប់សមាជិកដែលមានធានារ៉ាប់រងសុខភាពច្រើនជាងមួយប្រភេទ។

ការសហការបង់ប្រាក់: ការទូទាត់ប្រាក់ដែលអ្នកធ្វើ ជាទូទៅនៅពេលប្រើសេវា ដែលជាការបន្ថែមទៅលើការទូទាត់របស់ក្រុមហ៊ុនធានារ៉ាប់រង។

សេវាត្រូវបានរ៉ាប់រង: សេវាថែទាំសុខភាពដែលត្រូវបានផ្តល់ជូនដល់សមាជិក Kaiser Permanente ត្រូវគោរពតាមលក្ខខ័ណ្ឌ ស្ថានភាព ការដាក់កម្រិត និងការដកចេញនានានៃកិច្ចសន្យា Medi-Cal និងដូចដែលបានចុះនៅក្នុងសៀវភៅសមាជិក នេះនិងវិសោធនកម្មណាមួយ។

នាយកដ្ឋានសេវាកម្មថែទាំសុខភាព (Department of Health Care Services, DHCS)៖ នាយកដ្ឋានសេវាថែទាំសុខភាពមានការគ្រប់គ្រងរដ្ឋកាលីហ្វ័រញ៉ា។ នេះគឺជាការិយាល័យរដ្ឋដែលត្រួតពិនិត្យកម្មវិធី Medi-Cal ។

លុបឈ្មោះចេញ៖ ដើម្បីបញ្ឈប់ការប្រើ L.A. Care Health Plan ធ្វើជាផែនការថែទាំគ្រប់គ្រង Medi-Cal របស់អ្នក ពីព្រោះអ្នកលែងមានសិទ្ធិ ឬផ្លាស់ប្តូរទៅផែនការសុខភាពថ្មី។ អ្នកត្រូវតែចុះហត្ថលេខាលើទំរង់បែបបទមួយដែលនិយាយថា អ្នកលែងចង់ប្រើ L.A.Care Health Plan ឬទូរស័ព្ទទៅ Health Care Options ហើយលុបឈ្មោះចេញតាមរយៈទូរស័ព្ទ។

នាយកដ្ឋានការថែទាំសុខភាពមានការគ្រប់គ្រង (Department of Managed Health Care, "DMHC")៖ នាយកដ្ឋានថែទាំសុខភាពមានការគ្រប់គ្រងរដ្ឋកាលីហ្វ័រញ៉ា នេះគឺជាការិយាល័យរដ្ឋដែលត្រួតពិនិត្យផែនការថែទាំសុខភាពមានការគ្រប់គ្រង។

បរិក្ខារវេជ្ជសាស្ត្រជាប់បានយូរ (Durable medical equipment, "DME")៖ គ្រឿងបរិក្ខារដែលចាំបាច់ខាងវេជ្ជសាស្ត្រ និងត្រូវបានបញ្ជាទិញដោយវេជ្ជបណ្ឌិតអ្នក ឬអ្នកផ្តល់សេវាផ្សេងទៀត។ យើងសម្រេចចិត្តថាតើត្រូវជួល ឬទិញ DME។ តម្លៃជួលមិនត្រូវលើសពីតម្លៃទិញ។ ការជួសជុលគ្រឿងបរិក្ខារវេជ្ជសាស្ត្រត្រូវបានរ៉ាប់រង។

ការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលមុន និងតាមកាលកំណត់ (Early and periodic screening, diagnostic and treatment, "EPSDT")៖ សេវា EPSDT គឺជាអត្ថប្រយោជន៍សម្រាប់សមាជិក Medi-Cal ដែលមានអាយុក្រោម 21 ឆ្នាំ ដើម្បីជួយឲ្យពួកគេមានសុខភាពល្អ។ សមាជិកត្រូវតែទទួលបានការពិនិត្យសុខភាពត្រឹមត្រូវសម្រាប់អាយុរបស់ពួកគេ និងការពិនិត្យសមស្រប ដើម្បីស្វែងរកបញ្ហាសុខភាព និងព្យាបាលជំងឺឲ្យបានឆាប់ ព្រមទាំងការព្យាបាលណាមួយដើម្បីថែទាំ ឬជួយលក្ខខណ្ឌដែលអាចត្រូវបានរកឃើញនៅក្នុងការពិនិត្យ។

ស្ថានភាពវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់៖ ស្ថានភាពវេជ្ជសាស្ត្រ ឬ ផ្លូវចិត្តដែលមានរោគសញ្ញាធ្ងន់ធ្ងរដូចជា ការឈឺពោះសម្រាលកូន (សូមចូលទៅនិយមន័យខាងលើ) ឬការឈឺចាប់ធ្ងន់ធ្ងរដែលបុគ្គលដែលមានចំណេះដឹងផ្នែកសុខភាពនិងឱសថរកម្រិតធម្មតាដែលប្រកបដោយភាពប្រុងប្រយ័ត្ន អាចជឿជាក់យ៉ាងសមហេតុផលថាការមិនទទួលការថែទាំវេជ្ជសាស្ត្រភ្លាមៗអាច៖

- ធ្វើឲ្យសុខភាពរបស់អ្នក ឬសុខភាពទារកមិនទាន់កើតរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់ធ្ងន់ធ្ងរ
- បណ្តាលឲ្យមានការខូចខាតដល់មុខងាររាងកាយ
- បណ្តាលឲ្យផ្នែកមួយនៃរាងកាយ ឬសរីរាង្គមិនដំណើរការត្រឹមត្រូវ

ការថែទាំសង្គ្រោះបន្ទាន់៖ ការពិនិត្យដែលធ្វើឡើងដោយវេជ្ជបណ្ឌិត (ឬបុគ្គលិកដែលស្ថិតនៅក្រោមការដឹកនាំរបស់វេជ្ជបណ្ឌិតដែលត្រូវបានអនុញ្ញាតដោយច្បាប់) ដើម្បីដឹងថាតើស្ថានភាពវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់កើតមានឬទេ។ សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលចាំបាច់ដើម្បីឲ្យអ្នកមានស្ថេរភាពខាងការព្យាបាលនៅក្នុងកម្រិតសមត្ថភាពរបស់ទីតាំង។

ការដឹកជញ្ជូនវេជ្ជសាស្ត្របន្ទាន់៖ ដឹកជញ្ជូនតាមរថយន្តសង្គ្រោះបន្ទាន់ ឬយានជំនិះសង្គ្រោះបន្ទាន់ ទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ ដើម្បីទទួលការថែទាំសុខភាពគ្រាអាសន្ន។

អ្នកចុះឈ្មោះ៖ បុគ្គលដែលជាសមាជិកនៃផែនការសុខភាពហើយទទួលបានសេវាតាមរយៈផែនការនេះ។

អ្នកជម្ងឺចាស់៖ អ្នកជំងឺដែលមានទំនាក់ទំនងដែលមានស្រាប់ជាមួយអ្នកផ្តល់សេវា ហើយបានឃើញអ្នកផ្តល់សេវានោះក្នុងរយៈពេលជាក់លាក់មួយដែលបានបង្កើតឡើងដោយផែនការ។

សេវាដែលត្រូវបានដកចេញ៖ សេវាដែលមិនត្រូវបានរ៉ាប់រងដោយ Kaiser Permanente ដោយកម្មវិធី Medi-Cal California; សេវាដែលមិនមានការធានារ៉ាប់រង

ការព្យាបាលពិសោធន៍៖ ឱសថ ឧបករណ៍ នីតិវិធី ឬសេវាដែលស្ថិតក្នុងដំណាក់កាលសាកល្បងជាមួយមន្ទីរពិសោធន៍ និង/ឬការសិក្សាសត្វ មុនពេលធ្វើតេស្តលើមនុស្ស។ សេវាពិសោធន៍មិនស្ថិតនៅក្រោមការស៊ើបអង្កេតគ្លីនិកទេ។

សេវាធ្វើផែនការគ្រួសារ៖ គឺជាសេវាការពារឬពន្យាពេលមានផ្ទៃពោះ។

មជ្ឈមណ្ឌលសុខភាពស្របតាមលក្ខខ័ណ្ឌសហព័ន្ធ (Federally Qualified Health Center, "FQHC")៖ មណ្ឌលសុខភាពនៅក្នុងតំបន់ដែលមិនសូវមានអ្នកផ្តល់សេវាថែទាំសុខភាពច្រើន។ អ្នកអាចទទួលបានការថែទាំចម្បងនិងបង្ការនៅ FQHC។

បង់ថ្លៃពេលប្រើសេវា (Fee-For-Service, FFS)៖ ពេលខ្លះគម្រោង Medi-Cal របស់អ្នកមិនរ៉ាប់រងលើសេវាទេ ប៉ុន្តែអ្នកនៅតែអាចទទួលបានវាតាមរយៈ Medi-Cal FFS ដូចជាសេវាឱសថស្ថានជាដើមតាមរយៈ FFS Medi-Cal Rx។

ការថែទាំតាមដាន៖ ការថែទាំដោយវេជ្ជបណ្ឌិតជាទៀងទាត់ដើម្បីពិនិត្យមើលការវិវឌ្ឍរបស់អ្នកជំងឺ បន្ទាប់ពីចូលសម្រាកមន្ទីរពេទ្យ ឬអំឡុងពេលនៃដំណើរការព្យាបាល។

បញ្ជីឱសថ៖ បញ្ជីថ្នាំពេទ្យ និងមុខទំនិញដែលបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ និងត្រូវបានអនុម័តសម្រាប់សមាជិក។

ការក្លែងបន្លំ៖ សកម្មភាពដោយចេតនាដើម្បីបញ្ឆោតឬនិយាយខុសពីការពិតដោយបុគ្គលម្នាក់ដែលដឹងថាការបោកបញ្ឆោតអាចផ្តល់លទ្ធផលជាផលប្រយោជន៍ដែលមិនត្រូវបានអនុញ្ញាតចំពោះបុគ្គលនោះឬអ្នកណាម្នាក់ទៀត។

មជ្ឈមណ្ឌលផ្តល់កំណើតឯករាជ្យ (Freestanding Birth Centers, "FBC")៖ មណ្ឌលសុខភាពដែលការសម្រាលកូនត្រូវបានគ្រោងទុក ថានឹងកើតឡើងនៅឆ្ងាយពីគេហដ្ឋានរបស់ស្ត្រីមានផ្ទៃពោះដែលជាមណ្ឌលមានអាជ្ញាប័ណ្ណ ឬយល់ព្រមដោយរដ្ឋក្នុងការផ្តល់ការថែទាំមុនសម្រាល ពេលសម្រាលកូន ឬក្រោយពេលសម្រាលកូន និងសេវារថយន្តសង្គ្រោះបន្ទាន់ផ្សេងទៀតដែលត្រូវបានបញ្ចូលក្នុងផែនការ។ ស្ថាប័នទាំងនេះមិនមែនជាមន្ទីរពេទ្យទេ។

សារទុក្ខ៖ ការបញ្ចេញដោយពាក្យសម្តី ឬជាលាយលក្ខណ៍អក្សររបស់សមាជិកអំពីការមិនពេញចិត្តលើ Kaiser Permanente អ្នកផ្តល់សេវា គុណភាពនៃការថែទាំ ឬសេវាដែលត្រូវបានផ្តល់ជូន។ បណ្តឹងភ្លាញ្ជែរ គឺជាឧទាហរណ៍នៃសារទុក្ខមួយ ។

សេវានិងឧបករណ៍ស្តារពង្រឹងនីតិសម្បទា៖ សេវាថែទាំសុខភាពដែលជួយអ្នករក្សា យល់ដឹង ឬកែលម្អជំនាញ និងការបំពេញមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ។

Health Care Options ("HCO")៖ កម្មវិធីដែលអាចចុះឈ្មោះ ឬដកឈ្មោះអ្នកចេញពីផែនការសុខភាព។

អ្នកផ្តល់សេវាថែទាំសុខភាព៖ វេជ្ជបណ្ឌិតនិងគ្រូពេទ្យឯកទេសដូចជាគ្រូពេទ្យរះកាត់ វេជ្ជបណ្ឌិតដែលព្យាបាលជំងឺមហារីក ឬគ្រូពេទ្យដែលព្យាបាលផ្នែកពិសេសនៃរាងកាយ និងដែលធ្វើការជាមួយ Kaiser Permanente ឬនៅក្នុងបណ្តាញរបស់យើង។ អ្នកផ្តល់សេវាក្នុងបណ្តាញរបស់យើងត្រូវតែមានអាជ្ញាប័ណ្ណដើម្បីអនុវត្តនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា និងផ្តល់ឲ្យអ្នកនូវសេវាដែលយើងរ៉ាប់រង។

ជាធម្មតាអ្នកត្រូវការការបញ្ជូនពី PCP របស់អ្នកដើម្បីជួបជាមួយអ្នកឯកទេស។ សម្រាប់សេវាមួយចំនួន អ្នកត្រូវការការអនុម័តជាមុន (ការអនុញ្ញាតជាមុន) ។

អ្នក**មិន**ត្រូវការការបញ្ជូនពី PCP របស់អ្នកសម្រាប់ប្រភេទសេវាមួយចំនួនដូចជា ការធ្វើផែនការពន្យាគ្រួសារ ការថែទាំសង្គ្រោះបន្ទាន់ ការថែទាំរោគស្ត្រី ឬសេវាសម្ងាត់ទេ។

ធានារ៉ាប់រងសុខភាព៖ ការធានារ៉ាប់រងដែលចេញថ្លៃសម្រាប់ការចំណាយផ្នែកវេជ្ជសាស្ត្រ និងការរះកាត់ដោយការសងប្រាក់ដល់អ្នកមានធានារ៉ាប់រងចំពោះការចំណាយមកពីជំងឺឬរបួស ឬការបង់ប្រាក់ឲ្យអ្នកផ្តល់សេវាថែទាំដោយផ្ទាល់។

អ្នកផ្តល់សេវាថែទាំសុខភាពតាមផ្ទះ៖ ការមើលថែទាំដែលមានជំនាញនិងសេវាផ្សេងៗដែលត្រូវបានផ្តល់នៅផ្ទះ។

អ្នកផ្តល់សេវាថែទាំសុខភាពតាមផ្ទះ៖ អ្នកផ្តល់សេវាដែលផ្តល់ឲ្យអ្នកនូវការមើលថែទាំដែលមានជំនាញនិងសេវាផ្សេងៗនៅផ្ទះ។

តំបន់ល់នៅដ្ឋាន៖ Southern California Kaiser Foundation Health Plan, Inc. តំបន់។

ការថែទាំជំងឺមុខនឹងស្លាប់៖ ការថែទាំដើម្បីកាត់បន្ថយភាពមិនស្រួលខាងផ្លូវកាយ ផ្លូវចិត្តសង្គម និងខាងអារម្មណ៍ចំពោះសមាជិកដែលមានជម្ងឺមុខនឹងស្លាប់ (មិនត្រូវគេរំពឹងថារស់នៅបានលើសពី 6 ខែ)។

មន្ទីរពេទ្យ៖ កន្លែងដែលអ្នកទទួលការថែទាំសម្រាកក្នុងមន្ទីរពេទ្យនិងមិនសម្រាកមន្ទីរពេទ្យពីវេជ្ជបណ្ឌិតនិងគិលានុបដ្ឋាយិកា។

ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ៖ ការអនុញ្ញាតអោយចូលមន្ទីរពេទ្យដើម្បីទទួលបានការព្យាបាលជាអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ។

ការថែទាំជំងឺមិនសម្រាកមន្ទីរពេទ្យ៖ ការថែទាំផ្នែកវេជ្ជសាស្ត្រឬវះកាត់ដែលធ្វើឡើងនៅមន្ទីរពេទ្យ ដោយមិនមានការចូលសម្រាកក្នុងមន្ទីរពេទ្យ។

ក្លីនិកសុខភាពជនជាតិអាមេរិចស្បែកក្រហម (Indian Health Clinic, "IHC")៖ ក្លីនិកសុខភាពដែលត្រូវបានដំណើរការ ដោយសេវាសុខភាពជនជាតិអាមេរិចស្បែកក្រហម (Indian Health Service, IHS) ឬកុលសម្ព័ន្ធជនជាតិស្បែកក្រហម អង្គការកុលសម្ព័ន្ធ ឬ អង្គការជនជាតិស្បែកក្រហមនៅទីក្រុង ។

សេវាសុខភាពជនជាតិអាមេរិចស្បែកក្រហម៖ ទីភ្នាក់ងារសហព័ន្ធមួយនៅក្នុង នាយកដ្ឋានសេវាសុខភាពនិងមនុស្សជាតិអាមេរិកដែលទទួលខុសត្រូវក្នុងការផ្តល់សេវាសុខភាព ដល់ជនជាតិដើមអាមេរិកស្បែកក្រហមនិងអាឡាស្កា។

ការថែទាំជំងឺមិនសម្រាកមន្ទីរពេទ្យ៖ នៅពេលដែលអ្នកមិនចាំបាច់ត្រូវស្នាក់នៅមួយយប់ក្នុងមន្ទីរពេទ្យឬកន្លែងផ្សេងទៀតសម្រាប់ការថែទាំដែលអ្នកត្រូវការ។

ការព្យាបាលស៊ើបអង្កេត៖ ថ្នាំព្យាបាល ផលិតផលជីវសាស្ត្រ ឬឧបករណ៍ដែលបានបញ្ចប់ដោយជោគជ័យដំណាក់កាលទី 1 នៃការស៊ើបអង្កេតក្លីនិកដែលត្រូវបានអនុម័តដោយ រដ្ឋបាលឱសថនិងចំណីអាហារ (Food and Drug Administration, FDA) ប៉ុន្តែវាមិនត្រូវបានអនុម័តសម្រាប់ការប្រើប្រាស់ទូទៅដោយ FDA និងនៅតែស្ថិតក្រោមការស៊ើបអង្កេតនៅក្នុងការស៊ើបអង្កេតក្លីនិកដែលត្រូវបានអនុម័តដោយ FDA។

Kaiser Foundation Health Plan, Inc.៖ សាជីវកម្មមិនរកប្រាក់ចំណេញរដ្ឋកាលីហ្វ័រញ៉ា។ នៅក្នុងសៀវភៅណែនាំសមាជិកនេះ "យើង" ឬ "យើង" មានន័យថា Kaiser Foundation Health Plan, Inc.

KaiserPermanente៖ សំដៅលើ Kaiser Foundation Plan, Inc. Kaiser Foundation Hospitals (សាជីវកម្មមិនរកប្រាក់ចំណេញរដ្ឋកាលីហ្វ័រញ៉ា) និង Southern California Permanente Medical Group។

L.A. Care Health Plan៖ ផែនការថែទាំសុខភាពមានការគ្រប់គ្រង Medi-Cal របស់អ្នក។ Kaiser Permanente គឺជាបណ្តាញអ្នកផ្តល់សេវារបស់អ្នកតាមរយៈ L.A. Care Health Plan។

- តំបន់សេវា L.A. Care Health Plan៖ ខោនធី Los Angeles ¡។

ការថែទាំរយៈពេលវែង៖ ការថែទាំនៅក្នុងកន្លែងស្នាក់នៅយូរជាងខែនៃការចូលព្យាបាល បូកនឹងខែបន្ទាប់។

ផែនការថែទាំមានការគ្រប់គ្រង: ផែនការ Medi-Cal ដែលប្រើតែវេជ្ជបណ្ឌិត អ្នកឯកទេស ក្លីនិក ឱសថស្ថាន និងមន្ទីរពេទ្យជាក់លាក់មួយចំនួនសម្រាប់អ្នកទទួលបាន Medi-Cal ដែលបានចុះឈ្មោះក្នុងផែនការនោះ។ Kaiser Permanente គឺជាផែនការថែទាំដែលត្រូវបានគ្រប់គ្រង។

Medi-Cal Rx: សេវាអត្ថប្រយោជន៍ឱសថស្ថាន FFS Medi-Cal ដែលគេស្គាល់ថាជា "Medi-Cal Rx" ដែលផ្តល់អត្ថប្រយោជន៍ និងសេវាឱសថស្ថាន រួមទាំងថ្នាំតាមវេជ្ជបញ្ជា និងការផ្គត់ផ្គង់វេជ្ជសាស្ត្រមួយចំនួនដល់អ្នកទទួលអត្ថប្រយោជន៍ Medi-Cal ទាំងអស់។

ក្រុមវេជ្ជសាស្ត្រ: Southern California Permanente Medical Group ជាដៃគូវិជ្ជាជីវៈដែលរកប្រាក់ចំណេញ។

ផ្ទះវេជ្ជសាស្ត្រ: គំរូនៃការថែទាំដែលនឹងផ្តល់នូវគុណភាពថែទាំសុខភាពដែលប្រសើរជាងមុន តែលម្អការគ្រប់គ្រងខ្លួនឯងដោយសមាជិកទៅលើការថែទាំផ្តល់ខ្លួនរបស់ពួកគេ និងកាត់បន្ថយការចំណាយដែលអាចចៀសវាងបានក្នុងរយៈពេលវែង។

ដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ (ឬភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ): ការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រគឺជាសេវាពិពណ៌នា ដែលសមហេតុផលនិងការពារជីវិត។ ការថែទាំនេះជួយរក្សាអ្នកជំងឺពីការធ្លាក់ខ្លួនឈឺធ្ងន់ ឬពិការ។ ការថែទាំនេះជួយកាត់បន្ថយការឈឺចាប់ធ្ងន់ធ្ងរដោយការព្យាបាលរោគ ជំងឺ ឬរបួស។ សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ សេវា Medi-Cal រួមមានការថែទាំដែលចាំបាច់ខាងវេជ្ជសាស្ត្រ ដើម្បីព្យាបាល ឬជួយជម្ងឺផ្លូវកាយ ឬផ្លូវចិត្ត រួមទាំងវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន ដែលមានចែងក្នុងផ្នែក 1396d (r) នៃចំណងជើង 42 នៃក្រមសហរដ្ឋអាមេរិក ។

ការដឹកជញ្ជូនវេជ្ជសាស្ត្រ: ការដឹកជញ្ជូននៅពេលដែលអ្នកមិនអាចទៅដល់ការណាត់ជួបផ្នែកវេជ្ជសាស្ត្រដែលត្រូវបានរ៉ាប់រងដោយរថយន្ត ឡានក្រុង រថភ្លើង ឬតាក់ស៊ីបាន។ យើងបង់ថ្លៃមធ្យោបាយធ្វើដំណើរដែលមានតម្លៃទាបបំផុតសម្រាប់តម្រូវការវេជ្ជសាស្ត្ររបស់អ្នក នៅពេលដែលអ្នកត្រូវការជិះទៅការណាត់ជួបរបស់អ្នក។ ការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រត្រូវតែត្រូវបានចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិត ពេទ្យឆ្មេញ ពេទ្យក្រចកឆ្លោះ សុខភាពផ្លូវចិត្ត ឬអ្នកផ្តល់សេវាវិបត្តិការប្រើប្រាស់សារធាតុញៀនដែលមានអាជ្ញាប័ណ្ណ។

Medicare: កម្មវិធីជាន៉ាប់រងសុខភាពសហព័ន្ធសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ មនុស្សវ័យក្មេងជាក់លាក់មួយចំនួនដែលមានពិការភាព និងអ្នកដែលមានជំងឺតម្រងនោមដំណាក់កាលចុងក្រោយ (ការខូចក្រលៀនជាអចិន្ត្រៃយ៍ដែលតម្រូវឲ្យមានការលាងឈាម ឬការប្តូរសរីរាង្គ ជួនកាលហៅថា ជំងឺក្រលៀនដំណាក់កាលចុងក្រោយ [End-stage renal disease, ESRD])។

សមាជិក: អ្នកទទួលអត្ថប្រយោជន៍ Medi-Cal ដែលមានសិទ្ធិដែលត្រូវបានចាត់ឲ្យទៅ Kaiser Permanente តាមរយៈ L.A. Care Health Plan ដែលមានសិទ្ធិទទួលសេវាមានការជាន៉ាប់រង។ នៅក្នុងសៀវភៅណែនាំសមាជិកនេះ "អ្នក" មានន័យថាសមាជិក។

អ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត៖ បុគ្គលមានអាជ្ញាប័ណ្ណដែលផ្តល់សេវាសុខភាពផ្លូវចិត្ត និងសុខភាពអាកប្បកិរិយាដល់អ្នកជំងឺ។

សេវាឆ្លុះ៖ ការថែទាំមុនសម្រាលកូន អំឡុងពេលសម្រាល និងក្រោយពេលសម្រាលកូន រួមទាំងការថែទាំរៀបចំផែនការគ្រួសារសម្រាប់ម្តាយនិងការថែទាំបន្ទាន់សម្រាប់ទារកទើបនឹងកើត ផ្តល់ដោយឆ្លុះគិលានុបដ្ឋាយិកាមានវិញ្ញាបនប័ត្រ (certified nurse midwives, CNM) និងឆ្លុះមានអាជ្ញាប័ណ្ណ (licensed midwives, LM)។

បណ្តាញ៖ ក្រុមវេជ្ជបណ្ឌិត គ្លីនិក មន្ទីរពេទ្យ និងអ្នកផ្តល់សេវាផ្សេងទៀតបានចុះកិច្ចសន្យាជាមួយ Kaiser Permanente ក្នុងការផ្តល់សេវាត្រូវបានរ៉ាប់រង។

អ្នកផ្តល់សេវាបណ្តាញ (ឬអ្នកផ្តល់សេវាក្នុងបណ្តាញ)៖ សូមមើល "អ្នកផ្តល់សេវាដែលចូលរួម" ខាងក្រោម។

សេវាដែលមិនត្រូវបានរ៉ាប់រង៖ សេវាដែល Kaiser Permanente មិនរ៉ាប់រង។

ឱសថមិននៅក្នុងបញ្ជីរូបមន្ត៖ ថ្នាំពេទ្យដែលមិនមានក្នុងបញ្ជីឱសថ។

ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ៖ ការដឹកជញ្ជូននៅពេលធ្វើដំណើរទៅនិងមកពីការណាត់ជួបសម្រាប់សេវាដែលត្រូវបានរ៉ាប់រង Medi-Cal ដែលបានអនុញ្ញាតដោយអ្នកផ្តល់សេវារបស់អ្នកនៅពេលទៅយកឱសថមានវេជ្ជបញ្ជា និងសម្ភារៈវេជ្ជសាស្ត្រ។

អ្នកផ្តល់សេវាដែលមិនចូលរួម អ្នកផ្តល់សេវាដែលមិននៅក្នុងបណ្តាញ Kaiser Permanente។

ការរ៉ាប់រងសុខភាពឯទៀត (Other health coverage, "OHC")៖ ការធានារ៉ាប់រងសុខភាពឯកជន និងអ្នកបង់ថ្លៃសេវាក្រៅពី Medi-Cal។ សេវាអាចរួមមានផែនការបំពេញបន្ថែមផ្នែកវេជ្ជសាស្ត្រ ធ្មេញ ភ្នែក ឱសថស្ថាន និង/ឬផែនការ Medicare (ផ្នែក C និង D)។

ឧបករណ៍រណបៈ ឧបករណ៍ដែលត្រូវបានប្រើសម្រាប់ទប់ ឬផ្គុំបន្តាប់ពីខាងក្រៅ ទៅនឹងរាងកាយដើម្បីទ្រទ្រង់ ឬកែតម្រូវផ្នែករាងកាយដែលរងរបួស ឬមានជម្ងឺធ្ងន់ និងដែលចាំបាច់ខាងវេជ្ជសាស្ត្រសម្រាប់ការជាសះស្បើយផ្នែកវេជ្ជសាស្ត្ររបស់សមាជិក។

សេវាក្រៅតំបន់៖ សេវាខណៈពេលដែលសមាជិកនៅកន្លែងណាមួយខាងក្រៅតំបន់ដែល Kaiser Permanente មានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការ។ ដើម្បីទទួលបានព័ត៌មានបន្ថែមទៀតអំពីកន្លែងដែល Kaiser Permanente មានអាជ្ញាប័ណ្ណក្នុងការប្រតិបត្តិការ សូមហៅទៅសេវាសមាជិកលេខ **1-800-464-4000** (TTY **711**)។

អ្នកផ្តល់សេវាក្រៅបណ្តាញ៖ អ្នកផ្តល់សេវាដែលមិនមែនជាផ្នែកនៃបណ្តាញ Kaiser Permanente។

ការថែទាំជំងឺមិនសម្រាកមន្ទីរពេទ្យ៖ នៅពេលដែលអ្នកមិនចាំបាច់ត្រូវស្នាក់នៅមួយយប់ក្នុងមន្ទីរពេទ្យ ឬកន្លែងផ្សេងទៀតសម្រាប់ការថែទាំដែលអ្នកត្រូវការ។

សេវាសុខភាពផ្លូវចិត្តមិនសម្រាកមន្ទីរពេទ្យ៖ សេវាជម្ងឺមិនសម្រាកនៅមន្ទីរពេទ្យសំរាប់ សមាជិកដែលមានបញ្ហាសុខភាពផ្លូវចិត្តកម្រិតស្រាលទៅមធ្យមរួមមាន៖

- ការវាយតម្លៃនិងព្យាបាលសុខភាពផ្លូវចិត្តជាលក្ខណៈបុគ្គលនិងក្រុម (ការព្យាបាលបែបចិត្តសាស្ត្រ)
- ការធ្វើតេស្តចិត្តសាស្ត្រនៅពេលដែលត្រូវបានចង្អុលបង្ហាញផ្នែកព្យាបាលឲ្យវាយតម្លៃលក្ខខ័ណ្ឌ សុខភាពផ្លូវចិត្ត
- សេវាជម្ងឺមិនសម្រាកមន្ទីរពេទ្យក្នុងគោលបំណងពិនិត្យតាមដានការព្យាបាលដោយថ្នាំពេទ្យ
- ការពិគ្រោះជំងឺវិកលចរិក
- ទីពិសោធន៍ សម្ភារៈផ្គត់ផ្គង់ និងថ្នាំបំប៉នសម្រាប់ជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ

ការថែទាំសម្រាលការឈឺចាប់៖ ការថែទាំដើម្បីកាត់បន្ថយភាពមិនស្រួលខាងរាងកាយ ផ្លូវចិត្ត សង្គម និងអារម្មណ៍របស់សមាជិកដែលមានជំងឺធ្ងន់ធ្ងរ។ ការថែទាំសម្រាលការឈឺចាប់មិនតម្រូវឲ្យសមាជិកមានជីវិតសង្ឃឹមរស់ 6 ខែ ឬតិចជាងនេះទេ។

មន្ទីរពេទ្យដែលចូលរួម៖ មន្ទីរពេទ្យមានអាជ្ញាប័ណ្ណដែលមានកិច្ចសន្យាជាមួយ Kaiser Permanente ដើម្បីផ្តល់សេវាដល់សមាជិកនៅពេលដែលសមាជិកទទួលបានការថែទាំ។ សេវាត្រូវបានរ៉ាប់រងដែលមន្ទីរពេទ្យចូលរួមខ្លះអាចផ្តល់ជូនដល់សមាជិកត្រូវបានកំណត់ ដោយការត្រួតពិនិត្យការប្រើប្រាស់និងគោលការណ៍ធានាគុណភាព
ឬកិច្ចសន្យារបស់យើងជាមួយមន្ទីរពេទ្យ។

អ្នកផ្តល់សេវាដែលចូលរួម (ឬវេជ្ជបណ្ឌិតដែលចូលរួម)៖ វេជ្ជបណ្ឌិត មន្ទីពេទ្យ ឬអ្នកជំនាញថែទាំសុខភាពមានអាជ្ញាប័ណ្ណផ្សេងទៀត ឬទីតាំងសុខភាពមានអាជ្ញាប័ណ្ណ រួមទាំងទីកន្លែងថែទាំជំងឺធ្ងន់ដែលមានកិច្ចសន្យាជាមួយ Kaiser Permanente ក្នុងការផ្តល់សេវាដែលត្រូវបានរ៉ាប់រងដល់សមាជិកនៅពេលដែលសមាជិកទទួលបានការថែទាំ។

សេវាវេជ្ជបណ្ឌិត៖ សេវាដែលផ្តល់ដោយបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណក្រោមច្បាប់រដ្ឋ ដើម្បីអនុវត្តវិជ្ជាពេទ្យ ឬការព្យាបាលដោយគក់ច្របាច់ មិនរួមបញ្ចូលសេវាដែលផ្តល់ដោយវេជ្ជបណ្ឌិតខណៈពេលដែលអ្នកត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដែលត្រូវបានគិតប្រាក់នៅក្នុងវិក័យប័ត្រមន្ទីរពេទ្យទេ។

ផែនការ៖ ចូលទៅនិយមន័យសម្រាប់ "ផែនការថែទាំមានការគ្រប់គ្រង"។

មន្ទីរស្ថាប័នក្នុងផែនការ៖ មន្ទីរស្ថាប័នណាមួយដែលមានឈ្មោះនៅក្នុងគេហទំព័ររបស់យើង **kp.org/facilities** (ជាភាសាអង់គ្លេស) គឺជាផ្នែកនៃបណ្តាញរបស់យើង។ មន្ទីរស្ថាប័នក្នុងផែនការអាចមានការផ្លាស់ប្តូរដោយគ្មានការផ្តល់ដំណឹងជាមុន។ សម្រាប់ទីតាំងបច្ចុប្បន្ននៃមន្ទីរស្ថាប័នក្នុងផែនការ សូមទូរស័ព្ទទៅផ្នែកមជ្ឈមណ្ឌលទំនាក់ទំនង សេវាសមាជិក។

មន្ទីរពេទ្យក្នុងផែនការ៖ មន្ទីរពេទ្យដែលមានឈ្មោះនៅក្នុងគេហទំព័ររបស់យើង **kp.org/facilities** (ជាភាសាអង់គ្លេស) គឺជាផ្នែកនៃបណ្ដាញរបស់យើង។ មន្ទីរពេទ្យក្នុងផែនការអាចមានការផ្លាស់ប្ដូរដោយគ្មានការផ្ដល់ដំណឹងជាមុន។ សម្រាប់ទីតាំងបច្ចុប្បន្ននៃមន្ទីរពេទ្យក្នុងផែនការ សូមទូរស័ព្ទទៅផ្នែកមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក។

វេជ្ជបណ្ឌិតក្នុងផែនការ៖ ក្រូពេទ្យមានអាជ្ញាប័ណ្ណដែលជានិយោជិករបស់ Southern California Permanente Medical Group ឬក្រូពេទ្យដែលមានអាជ្ញាប័ណ្ណ ដែលបានចុះកិច្ចសន្យាផ្ដល់សេវាដែលត្រូវបានរ៉ាប់រងដល់សមាជិក។ ក្រូពេទ្យដែលចុះកិច្ចសន្យាជាមួយយើងគ្រាន់តែដើម្បីផ្ដល់សេវាដែលអ្នកត្រូវបានបញ្ជូនទៅ មិនត្រូវបានចាត់ទុកថាវេជ្ជបណ្ឌិតក្នុងផែនការទេ។

អ្នកផ្ដល់សេវារបស់ផែនការ៖ មន្ទីរពេទ្យផែនការ ក្រូពេទ្យផែនការ Southern California Permanente Medical Group ឱសថស្ថានផែនការ ឬអ្នកផ្ដល់សេវាផ្សេងទៀតដែលផែនការសុខភាពកំណត់ថាជាអ្នកផ្ដល់សេវារបស់ផែនការ។

សេវាក្រោយពេលមានស្ថេរភាព៖ សេវាដែលអ្នកទទួលបានបន្ទាប់ពីស្ថានភាពវេជ្ជសាស្ត្របន្ទាន់ត្រូវបានធ្វើឲ្យមានស្ថេរភាព។

ការយល់ព្រមជាមុន (ឬការអនុញ្ញាតជាមុន)៖ PCP របស់អ្នកត្រូវទទួលការព្រមព្រៀងពី Southern California Permanente Medical Group មុនពេលអ្នកទទួលបានសេវាមួយចំនួន។ Southern California Permanente Medical Group នឹងយល់ព្រមតែលើសេវាដែលអ្នកត្រូវការប៉ុណ្ណោះ។ ពួកគេនឹងមិនយល់ព្រមលើសេវាដោយអ្នកផ្ដល់សេវាដែលមិនចូលរួមទេប្រសិនបើពួកគេជឿជាក់ថា អ្នកអាចទទួលបានសេវាដែលស្រដៀងគ្នា ឬប្រសើរជាងតាមរយៈអ្នកផ្ដល់សេវារបស់ Kaiser Permanente។ ការបញ្ជូនមិនមែនជាការយល់ព្រមទេ។ អ្នកត្រូវតែទទួលបានការយល់ព្រមពី Southern California Permanente Medical Group ។

ធានារ៉ាប់រងលើឱសថមានវេជ្ជបញ្ជា៖ ការធានារ៉ាប់រងលើថ្នាំពេទ្យដែលបានចេញវេជ្ជបញ្ជា ដោយអ្នកផ្ដល់សេវា។

ឱសថមានវេជ្ជបញ្ជា៖ ឱសថដែលតម្រូវឲ្យមានដោយស្របច្បាប់នូវការបញ្ជាទិញពីអ្នកផ្ដល់សេវាដែលមានអាជ្ញាប័ណ្ណដើម្បីផ្ដល់ជូន ខុសពីឱសថទិញបានតាមហាងទូទៅ (over-the-counter, "OTC") ដែលមិនតម្រូវឲ្យមានវេជ្ជបញ្ជាទេ។

ការថែទាំចម្បង៖ ចូលទៅនិយមន័យនៃ "ការថែទាំជាប្រចាំ"។

អ្នកផ្ដល់សេវាថែទាំចម្បង (Primary care provider, "PCP")៖ អ្នកផ្ដល់សេវាមានអាជ្ញាប័ណ្ណដែលអ្នកមានសម្រាប់ការ ថែទាំសុខភាពភាគច្រើនរបស់អ្នក។ PCP របស់អ្នកជួយអ្នកទទួលបានការថែទាំដែលអ្នកត្រូវការ។ ការថែទាំមួយចំនួនត្រូវតែទទួលបានការយល់ព្រមជាមុន លើកលែងតែ៖

- អ្នកមានការអាសន្ន
- អ្នកត្រូវការការថែទាំផ្នែកសម្ភព/រោគស្ត្រី

- អ្នកត្រូវការការថែទាំសម្ងាត់
- អ្នកត្រូវការសេវាការធ្វើផែនការគ្រួសារ

PCP របស់អ្នកអាចជា៖

- អ្នកជំនាញទូទៅ
- វេជ្ជបណ្ឌិតព្យាបាលសរីរាង្គខាងក្នុង
- វេជ្ជបណ្ឌិតជំងឺកុមារ
- វេជ្ជបណ្ឌិតគ្រួសារ
- ពេទ្យឆ្មប/រោគស្ត្រី
- អ្នកផ្តល់សេវាថែទាំសុខភាពសម្រាប់អាមេរិកាំងស្បែកក្រហម (Indian Health Care Provider, "IHCP")
- កម្មវិធី មជ្ឈមណ្ឌលសុខភាពមានសិទ្ធិសហព័ន្ធ ("FQHC")
- គ្លីនិកសុខភាពជនបទ ("RHC")
- អ្នកជំនាញគិលានុបដ្ឋាយិកា
- ជំនួយការវេជ្ជបណ្ឌិត
- គ្លីនិក

ឧបករណ៍សិប្បនិម្មិត៖ ឧបករណ៍សិប្បនិម្មិតដែលភ្ជាប់ទៅនឹងរាងកាយដើម្បីជំនួសផ្នែករាងកាយដែលបាត់បង់។

សៀវភៅបញ្ជីឈ្មោះនិងព័ត៌មានអ្នកផ្តល់សេវា (Provider Directory)៖ បញ្ជីអ្នកផ្តល់សេវានៅក្នុងបណ្តាញ Kaiser Permanente។

ស្ថានភាពវេជ្ជសាស្ត្របន្ទាន់ជម្ងឺវិកលចរិក៖ វិបត្តិផ្លូវចិត្តដែលរោគសញ្ញាមានលក្ខណៈធ្ងន់ធ្ងរ ឬដុនដាបក្នុងកម្រិតអាចបង្កឲ្យមានគ្រោះថ្នាក់ភ្លាមៗ ចំពោះខ្លួនអ្នកឬអ្នកដទៃ ឬអ្នកមិនអាចផ្តល់ឬប្រើអាហារ កន្លែងស្នាក់នៅ ឬសម្លៀកបំពាក់បានភ្លាមៗដោយសារជំងឺផ្លូវចិត្ត។ សេវាសង្គ្រោះបន្ទាន់ផ្នែកសតិអាចរួមមានការផ្លាស់ប្តូរសមាជិកទៅអង្គភាពជំងឺវិកលចរិត នៅក្នុងមន្ទីរពេទ្យទូទៅ ឬមន្ទីរពេទ្យវិកលចរិកធ្ងន់ធ្ងរ។ ការផ្លាស់ប្តូរនេះត្រូវបានធ្វើដើម្បីជៀសវាង ឬបន្ថូរបន្ថយស្ថានភាពវេជ្ជសាស្ត្របន្ទាន់នៃជម្ងឺវិកលចរិក។ លើសពីនេះទៅទៀត អ្នកផ្តល់សេវាការព្យាបាលជឿជាក់ថាការផ្លាស់ប្តូរនេះនឹងមិនធ្វើឲ្យស្ថានភាព របស់សមាជិកកាន់តែយ៉ាប់យឺនទេ។

សេវាសុខភាពសាធារណៈ៖ សេវាសុខភាពដែលផ្តោតលើប្រជាជនទាំងមូល។ ទាំងនេះរួមមានក្នុងចំណោមផ្សេងៗទៀតដូចជា ការវិភាគស្ថានភាពសុខភាព ការពិនិត្យថែទាំសុខភាព ការលើកកម្ពស់សុខភាព សេវាទប់ស្កាត់ ការគ្រប់គ្រងជំងឺឆ្លង ការការពារបរិស្ថាននិងអនាម័យ ការត្រៀមលក្ខណៈនិងការឆ្លើយតបសម្រាប់គ្រោះមហន្តរាយ និងសុខភាពវិជ្ជាជីវៈ។

អ្នកផ្តល់សេវាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់៖
វេជ្ជបណ្ឌិតដែលមានសមត្ថភាពក្នុងការអនុវត្ត ត្រឹមត្រូវដើម្បីព្យាបាលជំងឺរបស់អ្នក។

ការវះកាត់កែលម្អ៖ ការវះកាត់ដើម្បីកែកុន ឬជួសជុលទម្រង់ខុសពីធម្មតានៃខ្លួនប្រាណ ដើម្បីកែលម្អតួនាទី ឬបង្កើតជារូបរាងធម្មតាអោយអស់ពីសមត្ថភាពដែលអាចធ្វើទៅបាន។ ទម្រង់ខុសពីធម្មតានៃខ្លួនប្រាណ គឺជាទម្រង់ទាំងឡាយដែលបណ្តាលមកពី ពិការភាពពីកំណើត, ភាពមិនប្រក្រតីនៃការរីឌ្ឍន៍, ការប៉ះទង្គិច, ការឆ្លងមេរោគ, ដុំសាច់ ឬជំងឺ។

ការបញ្ជូន៖ នៅពេល PCP របស់អ្នកនិយាយថាអ្នកអាចទទួលការថែទាំពីអ្នកផ្តល់សេវាផ្សេងទៀត។ ការថែទាំនិងសេវាដែលត្រូវបានរ៉ាប់រងមួយចំនួនតម្រូវឲ្យមានការបញ្ជូននិងការយល់ព្រមជាមុន។ សូមមើលជំពូកទី 3 ("របៀបទទួលបានការថែទាំ") ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីសេវាដែលត្រូវការការបញ្ជូន ឬការព្រមព្រៀងជាមុន។

តំបន់៖ អង្គការ Kaiser Foundation Health Plan ឬផែនការណបមួយដែលអនុវត្តកម្មវិធីសេវាថែទាំសុខភាពដោយផ្ទាល់។ តំបន់ អាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករារៀងរាល់ឆ្នាំ ដែលសព្វថ្ងៃនេះគឺជា ស្រុកកូឡំប៊ី និងផ្នែកនៃរដ្ឋ Northern California, Southern California, Colorado, Georgia, Hawaii, Idaho, Maryland, Oregon, Virginia, និង Washington។ សម្រាប់បញ្ជីបច្ចុប្បន្ននៃទីតាំងតំបន់ សូមចូលទៅគេហទំព័រ kp.org (ជាភាសាអង់គ្លេស) ឬទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាសមាជិក។

សេវានិង ឧបករណ៍ព្យាបាលការស្តារនិងពង្រឹងនីតិសម្បទា សេវានិងឧបករណ៍ ដើម្បីជួយមនុស្សជាមួយ ការរបួស ពិការភាព និងស្ថានភាពជំងឺរ៉ាំរ៉ៃ ដើម្បីទទួលបាន ឬស្រោចស្រង់ជំនាញផ្លូវចិត្ត និងរាងកាយ ។

ការថែទាំជាប្រចាំ៖ សេវានិងការថែទាំបង្ការចាំបាច់ផ្នែកវេជ្ជសាស្ត្រ ការទៅពិនិត្យសុខភាពកុមារ ឬការថែទាំដូចជាការថែទាំតាមដានជាប្រចាំ។ គោលដៅនៃការថែទាំជាប្រចាំគឺដើម្បីទប់ស្កាត់បញ្ហាសុខភាពនានា។

គ្លីនិកសុខភាពជនបទ (Rural Health Clinic, "RHC")៖ មណ្ឌលសុខភាពនៅក្នុងតំបន់ដែលមិនមានអ្នកផ្តល់សេវាថែទាំសុខភាពច្រើន។ អ្នកអាចទទួលបានការថែទាំចម្បងនិងបង្ការនៅ RHC។

ការថែទាំសម្ងាត់៖ គឺជាសេវាដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រសម្រាប់ការពន្យាកំណើតគ្រួសារ ជម្ងឺកាមរោគ (ជម្ងឺឆ្លងតាមរយៈការរួមភេទ) ជំងឺហ៊ីវ/ជម្ងឺអេដស៍ ការបំពានផ្លូវភេទ និងការរំលូតកូន។

ជំងឺធ្ងន់ធ្ងរ៖ ជំងឺឬលក្ខខ័ណ្ឌដែលត្រូវតែព្យាបាលហើយអាចផ្តល់លទ្ធផលជាការស្លាប់។

ការមើលថែទាំដែលមានជំនាញ៖ សេវាត្រូវបានរ៉ាប់រងដែលផ្តល់ដោយគិលានុបដ្ឋាយិកា អ្នកបច្ចេកទេស និង/ឬអ្នកព្យាបាលដែលមានអាជ្ញាប័ណ្ណក្នុងកំឡុងពេលស្នាក់នៅក្នុងទីកន្លែងថែទាំមានជំនាញ ឬនៅផ្ទះរបស់សមាជិក។

ទីកន្លែងមើលថែទាំដែលមានជំនាញ: ទីកន្លែងដែលផ្តល់ការថែទាំ 24 ម៉ោងក្នុងមួយថ្ងៃ ដែលមានតែអ្នកជំនាញសុខភាពទទួលការបណ្តុះបណ្តាលប៉ុណ្ណោះអាចផ្តល់ជូន។

អ្នកឯកទេស (ឬវេជ្ជបណ្ឌិតឯកទេស): វេជ្ជបណ្ឌិតដែលព្យាបាលបញ្ហាសុខភាពជាក់លាក់មួយចំនួន។ ឧទាហរណ៍ ក្រូពេទ្យរះកាត់ឆ្អឹងព្យាបាលឆ្អឹងបាក់; អ្នកជំនាញអាឡែកហ្សីព្យាបាលជំងឺអាឡែកហ្សី និងក្រូពេទ្យឯកទេសជំងឺបេះដូងព្យាបាលបញ្ហាបេះដូង។ ក្នុងករណីភាគច្រើន អ្នកត្រូវការការបញ្ជូនពី PCP របស់អ្នកដើម្បីជួបអ្នកជំនាញឯកទេស។

សេវាសុខភាពផ្លូវចិត្តឯកទេស: សេវាសម្រាប់សមាជិកដែលមានតម្រូវការសេវាសុខភាពផ្លូវចិត្តដែលមានកម្រិតកាន់តែខ្ពស់នៃពិការភាព ជាជាងកម្រិតស្រាលទៅដល់មធ្យម ។

ការជួបពានិត្យតាម Telehealth: ការជួបពិនិត្យតាមវីដេអូអន្តរកម្ម និងការជួបពិនិត្យតាមទូរស័ព្ទដែលត្រូវបានកំណត់ពេល និងអ្នកផ្តល់សេវារបស់អ្នក។

ជម្ងឺមុខនឹងស្លាប់: ស្ថានភាពសុខភាពដែលមិនអាចត្រូវបានផ្លាស់ប្តូរហើយអាចនឹងបណ្តាលឲ្យស្លាប់ ក្នុងរយៈពេលមួយឆ្នាំឬតិចជាងនេះបើជំងឺនេះកើតឡើងតាមធម្មជាតិរបស់វា។

ការចាត់ថ្នាក់ភាពបន្ទាន់នៃជម្ងឺ (ឬការពិនិត្យជម្ងឺ): ការវាយតម្លៃសុខភាពរបស់អ្នកដោយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាដែលត្រូវបានបណ្តុះបណ្តាលដើម្បីពិនិត្យមើលក្នុងគោលបំណងធ្វើការកំណត់ លើភាពបន្ទាន់នៃតម្រូវការរបស់អ្នកសម្រាប់ការថែទាំ។

ការថែទាំបន្ទាន់ (ឬសេវាថាំបាច់បន្ទាន់): សេវាដែលត្រូវបានផ្តល់ជូនដើម្បីព្យាបាលជំងឺមិនមែនសង្គ្រោះបន្ទាន់ របួសស្នាម ឬស្ថានភាពដែលតម្រូវឲ្យមានការថែទាំវេជ្ជសាស្ត្រ។ អ្នកអាចទទួលបានការថែទាំបន្ទាន់ពីអ្នកផ្តល់សេវាក្រៅបណ្តាញ ប្រសិនបើអ្នកផ្តល់សេវាក្នុងបណ្តាញមិនមាន ឬមិនអាចប្រើប្រាស់បានជាបណ្តោះអាសន្ន។

Kaiser Foundation Health Plan, Inc.
393 E.Walnut St.
Pasadena, CA 91188

824915515LaKh (01/2022)